រម្យ ។ លុះសួរេចពិធីទឹកសម្បថ ចក្រព័តិក៍ទ្រង់គង់ប្រជុំ គូវើរណើររុស៊ីដងត៍កំពង់ធំ គាល់ប្រជុំជំនំតាមកិច្ចា ។ ទ្រង់ ឲ្យហ្លួតនាទីអាជ្ញាហ្លួង តាយក្រសួងត៍ក្តែ៍ ៣ រាជអាជ្ញា ទាំង លោកធំកម្មសែរជាតស្បូរា ឲ្យផ្លាស់វិលភារាភ្នំពេញហោង ។ យកលោកធំរុស៊ីដងត៍កំពង់ស្វាយ ឡើងជានាយកម្មសែរព្រះ ដំបង មួយរាជកាសុខទុក្ខអស់រាស្ត្រផង ចៅហ្វាយខែត្រព្រះ ដំបងជាតស្បូរា ។ លុះប្រជុំរួបស្រេចស្តេចវត្តី អញ្ជុលីលា រូបព្រះសាស្តា ទ្រង់យាងបាទចេញតាមទ្វារបច្ចិមា ព្រមព្រះ វង្សពង្សាហែចេញឋ្កាន ។ ពួកអ្នកបិតបាំបិតព្រះរូបទ្រង់ ឲ្យ ជាប់ជុំទាំងវង្សព្រះប្រាង្គណ៍ស្ថាន ខុំឃើញគេពេញកោតគេបំ- ណាន បិតយកបានព្រះឆាយកាយភូធរ ។ លុះយាងដល់ រានហាលមុខព្រះលាន ពួកទាហានបារុធសៈលុតឈរ ស្តេច ឡើងគង់ព្រះសៈលៀងរាជបរិ ពួកអ្នកសែងហែចរចូលវាំងថ្មី ។ លុះដល់ត្រេចស្តេចចូលព្រះរោងធំ ថ្វាយបង្គំព្រះសង្ឃទាំង ចាស់ទ្វី អង្គាសភត្តភេសជចាយបំណើ ក្រុមសង្ឃការីចាត់ការ

បង្ហាន់សង្ឃ ។ ព្រះសង្ឃសូត្រទទួលរាជភត្ត តាមកំណត់ពេលនោះថ្ងៃទៀបត្រង់ សូរេបកិច្ចសង្ឃហៅព្រះបក្រពង្ស ស្ដេចក៏ទ្រង់ចូលកាន់ព្រះពន្លា ។ លុះដល់ពេលសូរិយេជ្រិស្រទន់ឲ្យនិមន្តព្រះសង្ឃសង្គាយនា បំនួនអង្គ ១០០ ដោយគណនាលោកទេសនាត្រៃ ៣ តាមព្រេងព្រិល ។ ទីឧបាលីវិន័យធរវត្តតាមិម អានន្ទគឺអាចារ្យគិមវត្តពិភិត ទីកស្សបព្រះគ្រូវត្តបូរ-ពិត ចៅគណៈសង្ឃស្ថិតស្រុកសៀមរាប ។ សង្គាយនាបឋមតាមវេណី ក្នុងគម្ពីរបិដកតាមសភាព លុះបប់បុះពេលថ្ងៃស្រ-ទន់ទាប សង្ឃបានលាភក៏វិលវត្តអាត្មា ។ ពេលយប់នោះមានការលេងអាប៉េ ក្បួនយីកេរាំឡកបកភាសា ពួកអ្នកស្រុកក៏មកមើលត្រៀបត្រា សែនមហាសប្បាយលោះលាយក្រៃ ។ លុះដល់ថ្ងៃ ១ វេជរូបពិធី ឲ្យបាត់ហែព្រះគម្ពីរបិដកថ្លៃ ប្អូលដឹកល់តាំងទុកនៅហោត្រៃ សម្រាប់នៃកុលបុត្រអ្នកសិក្សា ។ ថ្ងៃ ២ វេជពុទ្ធចាប់ក្រពង្ស ក្រសាលស្រះស្រង់ទិសបច្ចិមា ឯខ្ញុំបានក៏នាំភ្ញៀវយាត្រា ទៅមើលក្រុងភាពនគរធំ ។ លុះដើរ

ដល់ទ្វារគុមភ្នំបាខែង ព្រៃត្រសុមបាំងសែងសែនភិរម្យ ជើង
គិរីមានសឹង្ហទាំង ២ មុម ឈរបំអែបែបំទិសបូព៌ា ។ សឹង្ហបា-
សានបូរាណលោកសំអាង មើលដូចយ៉ាងសឹង្ហសត្វរាជសីហា
ជាត់ក្រអួនខ្លួនក្រអាញក្រាញដូចខ្លា បំអែងស្មាឈរអើតបំ-
ទើតជើង ។ ខ្ញុំយល់សឹង្ហឈរនឹងពុំកម្រើក បង់តែលើកយក
មកទុកស្រុកយើង តែធំហួសផុតការលើកមិនឡើង នឹងប-
ចើងលើកយកពុំរួចឡើយ ។ អនិច្ចាសឹង្ហអើយសឹង្ហបាសាន
ខ្ញុំយកទៅពុំបានណាសឹង្ហអើយ ឯងនៅចុះឲ្យសុខកុំទុក្ខឡើយ
កម្មសឹង្ហហើយមកនៅក្នុងព្រៃស្ងាត់ ។ បើសឹង្ហឯងរស់ពិតជីវិត
មាន គួរជានៅសមសាន្តសន្តានសត្វ ស្វែងអាហារលៀង
ជីព្វពុំស្ងួវខាត់ នេះមកបាត់វិញ្ញាណមានតែប្រាណ ។ នឹង
ដើរទៅទីណាក៏ពុំកើត នៅតែឈរបំអើតប្រចាំដាន ស្តាយ
អើយស្តាយរូបសឹង្ហលោកបូរាណ បោលក្នុងស្ថានស្មសាន
អាតាឋា ។ ខ្ញុំសម្តេទរូបសឹង្ហប្រឹងឡើងភ្នំ ឬត្វបធំជិតជុំជាន់
រអា ខ្ពស់ត្រឈឹងខំប្រឹងឡើងប្រវ៉ា លុះដល់នាកំពូលគីរី

ស្ថាន ។ លើបាខែងលោកតែងជាសថូប មានរូតរូប៥ជាន់ ជាជានៗ ខាងបូព៌ាមានប្រាង្គណ៍ទាំង៤ស្ថាន វិចិត្រដោយបាសានឥដ្ឋសិលា ។ ខាងមុខប្រាង្គណ៍មានល៉ាយព្រះបាទព្រះភិលស្រទ្បះពុំមានគ្រិះលេខា ជាប់ទំលុះធ្លុះបុះក្នុងសិលា ខាងលើលោកតាំងជាវិហារបាំង ។ តែវិហារនោះឯងលោកតែងថ្មី ធ្វើដោយឈើដោយឬស្សីប្រកស្បូវភ្លាំង ទីបូរាណមានតែរណ្តៅតាំង ថ្មរឹងតាំងនៅបណ្តោលគោលសីលា ។ ពុទ្ធបាទខ្នាតជ្រៅជុំវៀបាទ ប្លាយហាត់ខ្នាតបណ្តោយ៤ហត្ថា ទទឹងសោតពីរហត្ថជាមាត្រា ក្នុងបាទាលាយលក្ខណ៍កងច័ក្រជុំ ។ លោកវិចិត្របិទមាសវិលាសលឿង មើលរុងរឿងគួរយើងទ្បើងបង្គំ សព្វថ្ងៃមានលោកយួនគេជាធំ នៅថែទាំពិភក្តិ៍រក្សាស្ថាន ។ ខ្ញុំយល់ព្រះពុទ្ធបាទអាណាចបិត្រ គិតដល់អង្គអគ្គ-និដ្ឋព្រះទ្រង់ញាណ កាលព្រះអង្គស្តេចនឹងចូលនិព្វាន ព្រះ-ទ័យមានមេត្តាដល់នរៈជាតិ ។ សត្វឯក្រោយពុំបានឃល់សា-ស្តា បានទាន់តែសាស្នាបរមនាថ ទើបប្រតិស្ឋានព្រះពុទ្ធបាទ

នឹងឱវាទឲ្យប្រោសអស់សត្វផង ។ ឱព្រះគុណបានបុណ្យលន់វិសេស ទ្រង់កំចាត់កិលេសជាគ្រឿងហ្មង បាននិព្វាននៅមានព្រះទ័យបង ដំកល់បាទតាំងស្នងព្រះពុទ្ធអង្គ ។ ទុកឲ្យសត្វឯក្រោយបានបូជា ជាផ្លូវទៅសួគ៌ាឋានទេពទ្រង់ សាងកុសលទាល់បានកាត់ភាគបង់ មិនយូរលង់គង់បានស្ថានសុខា ។ វេលានេះខ្ញុំមកដោយការខាត់ ពុំមានអ្វីប្រតិបត្តិបាត់បូជា មានតែដៃទាំង ១០ ខ្ញុំវន្ទា ចិត្តវាចាបូជាក្នុងគ្រានេះ ។ ឱព្រះបាទនេះជាព្រះជាន់ឬ ឬមួយគឺគេសាកទុកទេអែះ ក្នុងជម្រាពុំមានតាំងភ្នំនេះ បើតាមរិះយ៉ាងសំណាកគេសាកថ្មី ។ បញ្ចូបាទទាំង ៥ សឹងមានជាន់ ឈ្មោះគេមានគ្រប់ស្ថានទាំង ៥ ទី ភ្នំបាខែងពុំមានក្នុងព្រះគម្ពីរ ជាក់ជាទីកើតក្រោយដោយនិយម ។ ខ្ញុំវន្ទាព្រះបាទស្រែបលាបុះ ជម្រង់ឆ្ពោះកាត់ទៅមើលនគរធំ ផ្លូវធ្លាឬល់សឹងឈើម្ទុបត្រសុម គេរំលំកាត់ត្រង់នគរា ។ លុះដើរដល់ខ្លោងទ្វារនគរធំ សុទ្ធសឹងដុំថ្មជិតប្រកិតគ្នា កំពូលខ្ពស់សិនសេសដោយគណនា បំលាក់ជារូបទេពប្រណម្យដៃ ។

កំពូលលើឈើដុះទំលុះបាក់ ថ្មរូសជ្រុះធ្លាក់ខ្ទាយរាយដោយព្រៃ នៅតែរាងដូចយ៉ាងព្រះប្រាង្គណ៍ជ័យ ចូលអាស្រ័យបុះមនុស្សជាងរយនាក់ ។ ផ្ទៃកំពែងតែងដោយថ្មក្រៀមក្រាសបូកដីដាសពាសប៉ះឡើងថ្នាក់ៗ កម្រាស់ក្រាស់ប្រម៉ាណ ៣ ព្យាមជាក់ ធំអាណាក់វែងអនេកលើសគណនា ។ ក្រៅនគរតែងគូក្រសិនសាយ អើលវែងឆ្ងាយឱបអមនគរា តែឥឡូវស្បាតជិតដោយព្រឹក្សា បិទគង្គាកើតជាត្រិបតាប់តាន់ ។ មើលខ្លោងទ្វារពណ៌នាពុំអស់ក្បួន ពេលក៏ជូនទៀបទោរព្រះសុរិយ៍ន ខំកាត់ចូលបូរីដោយបន្ទាន់ ដល់ប្រាសាទបាយ័នរាជភិរម្យ ។ ប្រាង្គណ៍បាយ័នលោកសាងជាប្រាង្គណ៍មូលមានកំពូលប្រាង្គណ៍បេញជា ៤ មុម ក្នុងកំពូលមួយៗឆ្លាក់រូបព្រហ្ម បួនៗជុំគ្រប់ប្រាង្គណ៍ប្រូងប្រាងក្រៃ ។ ឯរោងទងជុំវិញជ្រុងកែងកាត់ ទ្វារលោកបាត់កាត់មួយទ្វារ ១ នៃ ក្នុងឡប់ឡែបបែមុខទៅទីទៃ បគុរស្បស្មើផ្ទៃបីដាន់សាយ ។ ឱប្រាង្គណ៍នេះមើលទៅគំរបើមលន់ ខ្ពង់ៗគិតទៅគួរតែស្តាយ

ប្រាង្គណ៍នេះតើជាក់អ្វីពីព្រេងនាយ តាមបរិយាយគឺជាក់ភាពយោនី ។ គឺកាលដើមកាន់សាសនាព្រាហ្មណ៍ ប្រព្រឹត្តតាមដម្រាព្រះសូលី យកយោនីឧមាភោគវតី ជាសិរីសួស្តីតាំងបូជា។ គេយល់ថាមនុស្សយើងក្នុងធរណី កើតចេញពីយោនីនាងឧមា នាងជាម្តាយមានគុណទាំងលោកា ទើបនាំគ្នាសាងជាកំណើតហោង ។ បើមានការមង្គលបំរើឥឫក្ស ព្រាហ្មណ៍យកទឹកស្រោចភាពបង្ហូរត្រង់ មកប្រសិទ្ធិ៍ស្រោចអស់មហាជនផង បំបាត់ក្តីសៅហ្មងពាកឥន្ទ្រិយ៍ ។ ភាសាព្រាហ្មណ៍គេកាន់ដម្រាសែ ទើបកែខែបម្លងរូបយោនី សាងប្រាង្គណ៍នេះតាំងជាមន្ទីរទីលោកសញ្ញឹឲ្យហៅថាបាយ័ន ។ ឯសព្ទ-បា-នោះថាមួតមួយៗ តាមដំរូយសព្ទ-បា-គឺមួយខណ្ឌ យ័នសព្ទនេះពុំមែនជាលេខយន្ត កុំប្រកាន់យន្តលេខតាមភាសាគ ។ សព្ទយ័ននេះគឺជាភាសាព្រាហ្មណ៍ មានក្នុងក្បួនសព្ទនាមប្លែងសង្ស្រ្កឹត ខ្ញុំមើល ៗ បាយ័នក៏ត្រូវចិត្ត នឹកអាណិតដល់ក្សត្រពីបូរាណ ។ លោកមានបុណ្យកសាងប្រាង្គណ៍បាយ័ន ទុកក្នុងខណ្ឌនិរេស

នៃក្សត្រក្សាន្ត មានទេសកាលក៏ឡើងប្រតិស្ឋាន ស្រោចស្រប
ប្រាណដោយទឹកនាងឧមា ។ សែនរុងរឿងភ្លើងបុណ្យភ្លើង
កេរ្តិ៍ឈ្មោះ កិត្តិសព្ទឮសុះសព្វភារា បរទេសរាជកោតខ្លាច
ឡើងវិត្ថា រាស្ត្រប្រជាសឹងក្សាន្តសំរានកាយ ។ ឥឡូវព្រះនិ
រាសទៅជាព្រៃ ទាំងប្រាង្គណ៍ជ័យក៏ដល់ក្តីអន្តរាយ ឃើញ
តែស្មៅដែផ្ទៃបែបឡែបខ្វាយ ស្តាយអើយស្តាយមិនគួរមកព្នេះ
ណា ។ ទីខាងជើងមានវត្តលោកសង្ឃនៅ ព្រះនាមហៅព្រះ
ងោកលោកលេខា ឱព្រះងោកៗមែនឬយ៉ាងណា ឮគេថា
យល់ជាអស្ចារ្យក្រៃ ។ ខ្ញុំទៅមើលពុំឃើញព្រះលោកងោក
គិតប្រយោគយល់ថាព្រះម្ចាស់ថ្លៃ រូបព្រះធំលន់លើសព្រះដទៃ
ឯងរំពៃមើលងុបដួបងោកមក ។ វត្តមួយខាងបស្ចិមគ្មានលោក
សង្ឃ កុដិវិហាររួចបង់គ្មានទីជ្រក វត្តនោះឯងគេហៅវត្ត
គោកធ្លក តនោះមកវត្តប្ញូងបោលជួបគ្នា ។ វត្តនោះហៅព្រះ
ឥន្ទទេពកោសី អង្គព្រះជីក៏ធំសមរូបា កុដិវិហារបាំងព្រះគ្មាន
ឡើយណា អនិច្ចាមើលទៅសង្វេគក្រៃ ។ ឱអង្គព្រះឥន្ទទេពកោ

សីអើយ មិនគួរឡើយមកនៅកណ្ដាលព្រៃ អាប់រាសីដោយសែង
ហែងដោយថ្ងៃ ទីអាស្រ័យពុំមានក្បាន្តព្រះកាយ ។ បើព្រះអង្គ
ទៅគង់ស្រុកខ្ញុំរ៉ា ខ្ញុំនឹងសាងសាលាវិហារថ្វាយ ទាំងគ្រឿងតុ
គ្រឿងតាំងឲ្យផ្ចិតឆាយ ដូចជាព្រះទាំងឡាយស្រុកព្រះដំបង ។
គ្រាន់និមន្តធន់លើកទៅពុំបាន ព្រោះធំហួសប្រមាណធ្ងន់កន្លង
បើអង្គតូចទៅរ៉ានឹងរ៉ាប់រង ដាក់ដឹកឆ្លងមកស្រុកទុកបូជា ។
ឱលោកណាសទ្ធាសាងព្រះនេះ ម្ដេចមិនរិះគ្រេះមើលដោយ
បញ្ញា កាលស្រុកដីមិនផុតក្ដីអនិច្ចា មកគិតជានិច្ចំតាំងទៀង
ទាត់ ។ កាលប្រទេសរុងរឿងធ្វើតាមចិត្ត ដល់ប្រទេសវិបរិត
កើតវិបត្តិ ព្រះជីធំនឹងរំកិលក៏កើតខាត់ គោងបាំកាត់ចិត្តបោល
ទុកច្រេះណា ។ បើយ៉ាងព្រះតូច ៗ ល្មមយករូប តែដល់ស្រុក
ខាត់ខ្ទបដូចម្ដេចម្ដា ចង់រំលៀកក៏បានដូចចិត្តា ចុះជម្រាធំខ្ទប
តូចមិនខាត់ ។ ដូចរាស្ត្រទាសតាំងឡើងជានាហ្មឺន ប្រព្រឹត្ត
កីនហួសការរាជបញ្ញត្តិ នឹងដកចេញចាកទីក៏មិនខាត់ តែ
មហាក្សត្រវិបត្តិដកពុំបាន ។ គោងបាំនៅទៅតាមយថាកម្ម

ទុក្ខក៏ទ្រាំទោសក៏ទ្រាំទម្រាំក្សាន្ត ដូចព្រះអង្គឥន្ទទេពជាបែប មាន ក្សាន្តពុំបានព្រោះប្រាណធំលើសគេ ។ អធិប្បាសាស្តា ព្រះជិនវង្ស ពុំស្ថិតស្ថេរបេរលង់ក្នុងនគរ ដោបុណ្យបាបអ្វីពី បុព្វ បានជាប្រែប្រួលព្រៃដូច្នេះ ។ ស្រុកនេះសូន្យតើសូន្យ ពីរាជណា ពង្សាវតារជម្រាងណាអែះ នឹងបានមើលឲ្យដឹង រាជនោះនេះ ខ្ញុំនឹងត្រេះឲ្យត្រូវតាមល្បាក្សត្រ ។ ខ្ញុំគន់មើល វត្ត ៣ ស្រែបបរបេរ ទៅមើលរាជមន្ទីរបក្រវត្តិ៍ នៅខាងជើង ព្រះដោកលោកបែងបាត់ ខឿនបង្វាត់ខ្វាត់ខ្វែងវែងរវឹង ។ ប្រាង្គណ៌ប្រាសាទបែកបាក់ធ្លាក់ខ្ទេចខ្ទី នៅតែទីគ្រិះក្រោមកាត់ ទទឹង មុខប្រសាទស្ពានរាបភាពជាបឹង ជើងជណ្ដើរដើរមាន សឹង្ហឈរប្រឹងប្រែង ។ ឯផ្ទៃផ្ដែរធ្លាក់រូបរឿងក្បូនខេន ជិះ គជេន្ទ្រហៃស្ពជាជួរវែង ខាងជ្រុងៗរូបគ្រុឌឈរចំទែង ខ្លះ សអ្ដែងបាប់រាសុក្រីក្រាយ ។ មុខព្រះលានមានប្រាង្គណ៌ជា កាត់ៗ ហៅប្រសាទស្លូព្រាត់ខ្ពស់ត្រសាយ ខ្ញុំយល់ៗនឹក កោតគេអំបាយ ប្រាង្គណ៌ខ្ពស់ធ្វាយបងព្រាត់ហ៊ានស្លួរបាន ។

ទីខាងក្រោយប្រាសាទទៅបាត្លួន មើលក្បាច់ក្បូនឡប់ឡែជា ជានៗ ឱបាក្លួនខ្លួននាងក្នុងវាំងស្ពាន ពួលកំសានលេងពួន បន្លែងអង្គ ។ ទីខាងជើងខ្លោងទ្វារមានគ្រឹះគ្រែ ជាថ្នាក់ហែ សឹងរូតហ្លួតហៀនហង្ស លើមន្ទីរសាងរូបចក្រពង្ស ស្ដេចគំលង់គង់នៅប្រចាំទី ។ ខ្ញុំយល់រូបព្រះបាទសង្ខប័ក្រ គេសាកដាក់ជាឡាក់រាជជានី កើតសម្តេទវេទនាសលសែនទ្វី មិនគួរទីមកកើតវិបត្តិប្ទេះ ។ ពួជម្រាបរម្យរាពីបូរាណ ជាព្រះបមក្សត្រក្សត្តនគរនេះ ប្រហារនាគឈាមនាគផ្សប់ផ្សាយផែះ ត្រូវព្រះកាយកើតប្រែះប្រែជាឃ្លង់ ។ មើលពុំជាវេទនាពន់ប្រ-មាណ ឥសីសានមកប្រស់ប័ក្រពង្ស ស្ដេចពុំជឿតាមពាក្យឥសីសង្ឃ ទើបព្រះអង្គបង់ការអាសាររាយ ។ ឥសីទឹងផ្ដាសាភាជនិវេស ចៅប្រទេសក៏លុះក្ដីអន្តរាយ បានជាទីស្រុកនេះកើតខ្វាត់ខ្វាយ ដោយបរិយាយដៅ ៗ ពុំពិស្ដារ ។ ខ្ញុំគ្រេះ ៗ នឹកតេះស្ដេចគំលង់ ព្រះទ័យទ្រង់មានះអហង្ការ កើតហេតុអ្វីនឹងនាគទើបប្រហារ ឲ្យខូចស្រុកអាសារស្មាដៃខ្លួន ។ គួរឬ

ក្រុងនគរសេសប្រទេសធំ ប៉មកំផែងជិតជុំដ៏មាំមួន សត្រូវណានឹង
អាចចូលមកកួន តែគិតទៅចុះក្សត្រព្រះត្រៃលក្ខណ៍ ។ សព្វសង្ខារ
មិនថាទាំងស្រុកដី ទូបូរីសាយសព្វគ្រប់ដំណាក់ ទុកជាបេះ
យ៉ាងណាក៏គង់ធ្លាក់ អញ្ជើញអ្នកមើលស្ដាប់ចាប់អារម្មណ៍ ។
នគរធំបរមបូរាណរាជ មើលគួរខ្លាចសឹងព្រៃស្រោងស្រាងជុំ
មានអ្នកស្រុកតាំងនៅជាជុំៗ រកស៊ីតាមនិគមអ្នកជនបទ ។
រយៈផ្លូវទៅដល់នគរធំ ដោយនិយមវាស់ពីនគរវត្ត ប្រមាណ
បាន ៩០ សិនប្រាកដ ចូរកំណត់កត់ចុះលោករាល់គ្នា ។
ក្រែងបានទៅនឹងងាយដឹងទិសទី រាជធានីបូរាណទិសឧត្ដរា
តែផ្លូវបារាំងគេកាប់ផ្ដា ទំនងជាយូរទៅគង់សប្បាយ ។
ខ្ញុំដើរគន់ដើរកត់នគរធំ ពុំបានជុំនគរទេលោកាយ ពេលក៏
ជួនសូរិយេជ្រេព្រះឆាយ ក៏រៀបកាយវិលមកសៀមរាបវិញ ។
លោកចៅហ្វាយលោកធំលោកស័ក្ដិបី សូរេចការបក្រីក្រុងភ្នំ
ពេញ បង្គំលាវិលព្រះដំបងវិញ ខ្ញុំក៏អស់ក្ដីម្នេញការលោកីយ៍ ។
ដល់មកស្រុកសាន្ដសុខឥតទុក្ខា ដោយអំណាចប៉ក្រាគ្រប់កេ

សី ទាំងគុណកែវរតន៍ត្រៃថ្លៃទាំងបី ជួយចំរើនរាសីឥតហ្មង សៅ ។ រឿងនិរាសប្រកាសតែប៉ុណ្ណោះ សូមទុកស្នេះប្រារព្ធ បញ្ឈប់នៅ គ្រាន់នឹងតែងតអង្គព្រះបមចៅ កាលស្ដេចនៅ ពុំទាន់វិលភ្នំពេញ ។ ខ្ញុំលាហើយពុំដឹងក្រោយយ៉ាងណា រាជ កិច្ចាពុំទាន់ប្រកាសចេញ ហេតុដូច្នោះទុកឲ្យប្រាជ្ញភ្នំពេញ គេ តែងចេញតរឿងព្រះចក្រី ។ ខ្ញុំឥតន្ធាបារ្យបែងតែងពុំបាន ព្រោះ គ្មានដានលំអានយោគសេចក្ដី ហេតុនោះសូមមេត្តាប្រោសប្រ ណី ខ្ញុំបញ្ចប់សេចក្ដីតែប៉ុណ្ណោះ ។

សូមទោសលោកមេធីកវីជាតិ កុំឧបវាទពាក្យកាព្យខ្ញុំតែង នេះ សូមជម្រូវឲ្យត្រូវតាមលោកចេះ បើមិនផែះកុំបើកលើក ចូលចេញ ។ កុំប្រមាទពាក្យកាព្យប៉ាតែងងាយ យារមុខតាម និយាយដាក់បំពេញ បើមិនចេះពាក្យស្រួយខ្យល "រ" មិញ ឲ្យដេកវិញជាជាងកុំតែងឡើយ ។ មួយបើអ្នកឯណាចង់ចម្លង តាមទំនងនិរាសនេះលោកអើយ ចូលរាំងខ្យល់-រ-ល-ជាត្រើយ

តែបាត់ហើយខូចដល់ខ្ញុំអ្នកតែង ។ មួយស្រៈ. ៃ,រ៉ៃភ្លៃនឹងស្រៈ. ី,
វិសញ្ញនីខ្យល់.ស, លោកសម្តែង កុំឲ្យប្រូលយារមុខទង្គុកឯង
ឲ្យនៅតាមកន្លែងទីដោយខ្ជួន ពាក្យសំយោគការន្តវិធីសព្ទ
ប្រូលលំដាប់រ៉ាប់គ្នាទៅតាមជ្លួន យោគសេចក្តីតាំងមុខឲ្យមាំមួន
រកបុងជ្លួនមេភាព្យសភាពអឺយ ។ ៚

## បុណ្យចំរើនអាយុ គំរប់ ២០ ឆ្នាំនៃសាលាបាឡីជាន់ខ្ពស់
## គំរប់ ១០ ឆ្នាំ នៃព្រះរាជបណ្ណាល័យ
## និងគំរប់ ៥ ឆ្នាំនៃពុទ្ធសាសនបណ្ឌិត្យ
## ពីថ្ងៃសុក្រ ១៤ កើត និងថ្ងៃសៅរ៍ ១៥ កើត ខែពិសាខ
## ឆ្នាំ ច ឆស័ក ព. ស. ២៤៧៧ ត្រូវនឹងថ្ងៃ ២៧
## និង ២៨ ខែអាវ្រិល ឆ្នាំ ១៩៣៤

សាលាបាឡីជាន់ខ្ពស់, ព្រះរាជបណ្ណាល័យកម្ពុជា: និង ពុទ្ធសាសនបណ្ឌិត្យ, បានធ្វើបុណ្យគំរប់ ២០ ឆ្នាំ. ១០ ឆ្នាំ នឹង ៥ ឆ្នាំ ពីថ្ងៃ ២៧ និង ២៨ ខែអាវ្រិលឆ្នាំ ១៩៣៤ ក្រោម មហោអធិបតី នៃព្រះករុណាព្រះបាទសម្តេចព្រះស៊ីសុវត្ថិ មុនីវង្ស ព្រះចៅក្រុងកម្ពុជាធិបតី នឹងលោកឡូរេស៊ីដង់សុប៉េរីយើរ ស៊ីលវែស្ត្រ បុណ្យនេះធ្វើក្នុងទីព្រះរាជបណ្ណាល័យកម្ពុជា ។

ព្រះរាជបណ្ណាល័យកម្ពុជា បានផ្សាយដំណឹងអំពីបុណ្យ នេះដល់សាធារណជនខ្មែរក្នុងក្រុង នឹងក្នុងខែត្រក្រៅ តាំងពី

ជាង១ខែមុន ដើម្បីឲ្យបានដឹងដំណឹងបុណ្យហើយនឹងបានចូលមកទទួលអនុមោទនាយកផលានិសង្ស តាមសេចក្ដីប្រាថ្នា ។

ថ្ងៃសុក្រ ១៣ កើតខែពិសាខឆ្នាំចធស័ក ព.ស. ២៤៧៧ ត្រូវនឹងថ្ងៃ ២៧ អាវ្រិលឆ្នាំ ១៩៣៤ ជាថ្ងៃចូលបុណ្យនេះ តាំងពីពេលព្រឹកក្នុងថ្ងៃនោះ បានបាត់ការរៀបចំនៅទីព្រះរាជបណ្ណាល័យ មានដោតទង់នៅទីជុំវិញនឹងនៅក្នុងទីបន្ទប់របស់មន្ទីរនេះ ព្រមទាំងប្រដាប់រៀបរៀងដោយផើងឈើ តាំងពីមាត់ជណ្ដើរក្រោមរហូតដល់ទីខាងក្នុង ។ ទីបន្ទប់ព្រះរាជបណ្ណាល័យក៏ក្រាលពេញទៅដោយព្រំ នៅទីបន្ទប់ធំខាងលិចជាទីតាំងពិធីបុណ្យមានរៀបតុអាសនៈព្រះ ២ គឺអាសនៈព្រះ ១ ជារបស់ព្រះរាជទ្រព្យដែលក្រុមព្រះរាជបណ្ឌិត្យយកមកតាំង មានព្រះពុទ្ធរូបមាស ១ អង្គ ឬកែវ ១ អង្គ ដែលព្រះករុណាជាអំម្ចាស់ជីវិតលើត្បូង ប្រោសព្រះរាជទានឲ្យយកមកចូលធ្វើពិធីពុទ្ធាភិសេក នឹងអាសនៈព្រះរបស់ព្រះរាជបណ្ណាល័យ ១ មានព្រះពុទ្ធរូបប្រាក់នាគប្រក់ ១ អង្គដែលបានមកអំពីខែត្រក្រៅ យក

មកប្រតិស្ឋាននៅទីនោះ បម្រុងនឹងធ្វើពិធីពុទ្ធាភិសេកនៅក្នុងវេលាយប់ ។ អាសនៈព្រះទាំងពីរនេះតាំងប្រដាប់ដោយស្លឹកឈើស្រស់នឹងផ្កាស្រស់ធ្លកធ្លាសពណ៌គ្នាផ្សេង ៗ ។

នៅត្រង់មាត់ទ្វារខាងត្បូង មានផែនសំពត់ ១ ធំរបនាជារូបត្របកឈូក ហើយមានសរសេរឈ្មោះសៀវភៅផ្សេងៗដែលព្រះរាជបណ្ណាល័យបោះពុម្ពហើយគ្រប់ត្របកទាំងអស់ គឺត្របក ១ ឈ្មោះសៀវភៅ ១ គូឆ្លាស់ដោយព័ណ៌ផ្សេង ៗ មុខគួរឲ្យគយគន់ ហើយអាចធ្វើឲ្យអ្នកដែលមើលបានដឹងច្បាស់ថាព្រះរាជបណ្ណាល័យបានបោះពុម្ពសៀវភៅអ្វីខ្លះហើយ ។

វេលារសៀលក្នុងថ្ងៃនោះ ពីម៉ោង ៤ ទៅទល់នឹងម៉ោង ៥ ជាពេលសមោសរធំ គឺអ្នករាជការក្រុមព្រះរាជបណ្ណាល័យ មានអ្នកស្រីការប៉ឺឡែសជាប្រធាន នឹងព្រះសង្ឃដែលជាគ្រូក្នុងសាលាបាលី ជាក្រុមជំនុំពុទ្ធសាសនបណ្ឌិត្យនឹងព្រះសង្ឃដែលនិមន្តមកចំរើនពុទ្ធបរិត្តចំនួន ៣៥ អង្គ នឹងព្រះសង្ឃខែត្រក្រៅដែលមកជួយក្នុងបុណ្យនេះខ្លះទៀត នឹងអ្នករាជការក្រសួងព្រះ-



ព្រះករុណាព្រះបាទសម្តេចព្រះស៊ីសុវត្ថិមុនីវង្សទ្រង់ស្តេចយាង

ជាមហាអធិបតីបុណ្យក្នុងព្រះរាជបណ្ណាល័យ

បរមរាជវាំង ក្រសួងរដ្ឋបាល ក្រសួងតុលាការ ព្រមទាំងពួកឧបាសកឧបាសិកា ដែលនៅក្នុងក្រុងនឹងដែលមកពីខេត្តក្រៅខ្លះ បានជួបជុំព្រមប្រម៉ាណប្រហែល ៣០០ ពាយរូប ។

វេលាម៉ោង ៩ ព្រះករុណាជាអំម្ចាស់ជីវិតលើត្បូង ស្តេចព្រះរាជដំណើរដោយព្រះទីនាំងរថយន្តមួយអន្លើដោយព្រះបរមឱរសាធិរាជព្រះអង្គអធិបតី នឹងអស់លោកសេនាបតីទាំង ៥ ហែហ្កានព្រះរាជបណ្ណាល័យ ជួបជុំដោយអ្នករាជ្ការបារាំងសែសមានលោកប៉ូអារេត៍អបធិតីក្រសួងរដ្ឋប្រសាសនោបាយ ជាដំណាងលោកឡឺរេស៊ីដង់ត៍សុប៉េរិយើរជាប្រធាន នឹងលោកគោបេរ បាល័ដ្ឋទូលឆ្លង, លោកបឺស្តុង្ស៊ុដេលេគេអមរាជ្ការខ្មែរ, លោកបាប់ទិស្ត អ្នកគ្រូគលិស្តស៊ុរិល, លោកុស្សស្មៀនត្រាលោកឡឺរេស៊ីដង់ត៍សុប៉េរិយើរ លោកឡាំប៉ែរ្ត, លោកឡឺសែហ្វ នឹងភរិយានឹងពួកមន្ត្រីកិត្តិយសជាតិបិនយួនផ្សេង ៗ ក៏បានមកជួបជុំដើម្បីសម្ដែងសេចក្ដីត្រេកអរផងនឹងទទួលអនុមោទនាក្នុងការព្រះរាជកុសលគ្រានេះ ។ ខណៈរថយន្តព្រះទីនាំងទៅដល់

ព្រះរាជបណ្ណាល័យ ទាហានក្រុមរក្សាព្រះអង្គថ្វាយគំនាប់ និងក្រុមភ្លេងព្រះរាជទ្រព្យក៏បន្លឺស័ព្ទសរសើរព្រះបារមីថ្វាយជាព្រះកិត្តិយសតាមទំនៀម ។ លំដាប់នោះអ្នកស្រីការប៉ុទ្វែស្បេញទៅថ្វាយគំនាប់អញ្ជើញស្ដេចចូល, ព្រះករុណា ៗ ក៏យាងចូលទៅក្នុងព្រះរាជបណ្ណាល័យ គណៈសង្ឃសូត្រ "ជយន្តោ" ថ្វាយព្រះពរជ័យ ស្ដេចយាងទៅប្រថាប់រាបនៅទីរាជាសនៈទៀបអាសន៍ព្រះ ហើយទ្រង់ព្រះប្រារព្ធសន្ទនាប្រាស្រ័យ នឹងគណសង្ឃ ៣៥ រូបដែលនិមន្តមកបំរើនពុទ្ធបរិត្តតាមសមគួរហើយប្រារព្ធនឹងលោកគ្រូព្រះស្រីសម្មតិវង្ស ឯម បាងហ្វាងសាលាបាឡី អំពីទ្រង់យកព្រះពុទ្ធរូបពីរព្រះអង្គមកចូលធ្វើពុទ្ធាភិសេក នឹងយកទៅដំកល់ប្រតិស្ឋានឯទីភ្នំបូកគោ ហើយទ្រង់សូមឲ្យលោកគ្រូព្រះស្រីសម្មតិវង្សប្រាត់ការពុទ្ធាភិសេកថ្វាយផង ។ តពីនេះទ្រង់យាងមកកាន់ទីបន្ទប់កណ្ដាលដែលមានរៀបព្រះទីនាំងកៅឡៀថ្វាយជាទីប្រថាប់ ដើម្បីត្រាស់ប្រារព្ធរឿងជាទីគាប់ព្រះទ័យនឹងជាទីរំលឹកដល់គណៈសង្ឃនឹងគ្រហស្ថទាំងអស់ ដូចមានតទៅនេះ

## ព្រះបន្ទូលស្វាគមន៍

នូវវេលាដែលទ្រង់ព្រះសណ្ដាប់ធម៌ "ជយន្តោ" ដែលព្រះសង្ឃទាំង ៣៥ អង្គសូត្រថ្វាយជ័យមង្គលជាស្រេចហើយ ព្រះករុណាជាអម្ចាស់ជីវិតលើត្បូង ទ្រង់យាងមកកាន់ទីបន្ទប់កណ្ដាល ហើយទ្រង់មានព្រះបន្ទូល សុំឱ្យលោក ប៉ូអាវេត៍ បាងហ្វាងក្រសួងរដ្ឋប្រសាសនោបាយ បញ្ជូនសេចក្ដីអរគុណបំពោះដល់លោកឡឺរេស៊ីដង់ត៍ស៊ុយ៉េរីយើរ ដែលលោកមិនបានអញ្ជើញមកគួរឱ្យមានសេចក្ដីស្ដាយ ហើយដែលបានចាត់ខ្លួនលោកឱ្យមកជាបំនួស ក្នុងពិធីបុណ្យជាមង្គលប្រសើរនេះ ។ ព្រះករុណាជាអម្ចាស់ជីវិតលើត្បូងទ្រង់ថ្លែងសេចក្ដីអរគុណដល់លោក ប៉ូអាវេត៍ផង អំពីដែលលោកបានអញ្ជើញមកជាដំណាងលោកឡឺរេស៊ីដង់ត៍ស៊ុយ៉េរីយើរ មួយអន្លើដោយមន្ត្រីផ្សេងៗ ក្នុងរាជ្ការប្រូតិកតូរាត៍ ដើម្បីនឹងធ្វើនូវបុណ្យនេះឱ្យរឹងរឹតតែមានសួស្ដីជ័យមង្គលរុងរឿងប្រសើរឡើង ។

រួបពីនេះ ទ្រង់ប្រារព្ធអំពីគុណគណៈសង្ឃដែលជាអាចារ្យ សាលាបាឡី និងក្រុមជំនុំប្រែព្រះត្រៃបិដក ដែលយកចិត្តទុកដាក់ទំបង្ហាត់បង្រៀន និងផ្សាយធម៌អាថ៌ឲ្យបានបេះដឹងទូទៅក្នុងកម្ពុជរដ្ឋ ហើយប្រតិបត្តិត្រឹមត្រូវតាមពុទ្ធបញ្ញត្តិ ។

តពីនេះទ្រង់ប្រារព្ធដល់ព្រះសង្ឃគ្រប់រូបទូទៅ ហើយទ្រង់សូមឲ្យព្រះសង្ឃទាំងអស់មានសេចក្តីសន្តោសនឹងអធ្យាស្រ័យក្នុងការប្រតិបត្តិព្រះពុទ្ធសាសនា បើកាលណាមានសេចក្តីសន្តោសនឹងអធ្យាស្រ័យ ទើបហៅថាជាអ្នកប្រតិបត្តិក្នុងព្រះ-ពុទ្ធសាសនា ហើយជាអ្នកប្រាជ្ញបេះចាំស្ទាត់នូវព្រះត្រៃបិដក ។

ដែលព្រះករុណាជាអំម្ចាស់ជីវិតលើត្បូងទ្រង់ទទួបប្រារព្ធអំពីរឿងនេះ គឺដោយទ្រង់មានព្រះប្រាថ្នាយ៉ាងសំខាន់ ដើម្បីឲ្យព្រះសង្ឃគ្រប់អង្គប្រព្រឹត្តជាគំរូយ៉ាងប្រសើរ ដល់សាធារណជនក្នុងផ្លូវបដិបទានៃព្រះពុទ្ធសាសនា ហើយដែលទ្រង់ប្រារព្ធបាត់នេះ គឺមិនមែនគ្រាន់តែជាប្រយោជន៍ដល់សាធារណជនក្នុងបច្ចុប្បន្នសម័យនេះតែម្យ៉ាងទេ គឺថែមមានប្រយោជន៍ដល់ក្នុង

អនាគតកាលផង ដើម្បីឱ្យបានធម៌អាថ៌ដែលជាបរិសុទ្ធល្អឥតមន្ទិលជាប់ជាដំណរដល់បណ្ដាជនក្នុងសម័យខាងក្រោយ ។ បំណែកខាងគ្រឿងស្លៀកពាក់របស់ឃរាវាសសោតក៏ត្រូវប្រព្រឹត្តទៅតាមបែបភាពជាខ្មែរដើម្បីឱ្យមានលំនាំរំទស័ក្ដិសមជាអ្នកប្រណិបតន៍ព្រះពុទ្ធសាសនា ។

ព្រះករុណាជាអម្ចាស់ជីវិតលើត្បូងទ្រង់គាប់ព្រះរាជហឫទ័យដោយពេញទី ហើយទ្រង់ពោលសរសើរព្រមដោយព្រះមហាគរុទាំងមូល អំពីការដ៏ប្រពៃដែលកើតមានឡើង ដោយស្នាដៃសាលាបាលី ព្រះរាជបណ្ណាល័យ និងពុទ្ធសាសនបណ្ឌិត្យ ទាំង ៣ នេះ ។ ព្រះករុណាជាអម្ចាស់ជីវិតលើត្បូងទ្រង់មានព្រះបន្ទូលញាំងកំឡាំង អ្នកបួសនិងគ្រហស្ថឱ្យមានឡើង ដើម្បីនឹងប្រឹងផ្សាយនូវធម៌អាថ៌សិក្ខាវិន័យនៃព្រះបរមគ្រូតទៅទៀត ឱ្យបានគង់នៅអស់កាលជានិច្ច ។

ដើម្បីនឹងបញ្ចប់ព្រះបន្ទូល, ព្រះករុណាជាអម្ចាស់ជីវិតលើត្បូង ទ្រង់ភ្ញាក់រឭកដល់ព្រះវររាជបិតា និងលោកបាងហ្វាង

ដំបូងនៃសាលាបាឡី ដែលជាទីនាំឲ្យធ្វើបុណ្យយ៉ាងរុងរឿងក្នុងថ្ងៃនេះជាគំរប់ ២០ ឆ្នាំ នៃសាលា ហើយទ្រង់ព្រះរាជទានពរសព្ទសាធុការដល់សាធារណជនទាំងអស់ឲ្យបានអាយុវែងនឹងឲ្យបានសេចក្ដីសុខគ្រប់ប្រការ ។ ជាមុននឹងស្ដេចយាងត្រឡប់អ្នកស្រីការប៉ីទ្បេសបានអញ្ជើញឲ្យស្ដេចទតព្រះនេត្រ សម្ពត់ផ្កាឈូកដែលសរសេរឈ្មោះសៀវភៅគ្រប់យ៉ាង របស់ព្រះរាជ-បណ្ណាល័យគ្រប់ត្របកឈូកទាំងអស់ រួចពីនេះក៏អញ្ជើញស្ដេចទតព្រះនេត្រគម្ពីរដែលបានពីស្រុកភូមាមក ដែលធ្វើពីសំពត់ចីវរទិបមានលាបពណ៌ក្រហមនឹងពណ៌ខ្មៅ ។ លុះទ្រង់ទតព្រះនេត្រស្រេចហើយក៏ទ្រង់ស្ដេចព្រះរាជដំណើរ ដោយព្រះទីនាំងរថយន្តត្រឡប់ព្រះបរមរាជវាំងវិញ ។

ក្នុងថ្ងៃបុណ្យនេះតាំងពីវេលាព្រឹកបានបាត់ការចែកសៀវ-ភៅកាព្យច្រៀងរឿងពុទ្ធបរិវត្ត ដែលលោកអាចារ្យបាប-ពិនក្រុមជំនុំព្រះត្រៃបិដកបានតែង ដល់មហាជនដែលបានអញ្ជើញទៅក្នុងទីនោះទូទៅគ្រប់គ្នា ។



ព្រះសង្ឃចំរើនពុទ្ធបរិត្តក្នុងព្រះរាជបណ្ណាល័យ

ក្រោយដែលព្រះករុណាជាអំម្ចាស់ជីវិតលើត្បូងយាងទៅ ហើយក៏ផ្តើមការចំរើនពុទ្ធបរិត្ត ព្រះសង្ឃ ៣៩ រូបគឺគណៈមហានិកាយ ២០ រូប គណៈធម្មយុត្ត ១៩ រូប ដែលនិមន្តមកពីវត្តផ្សេង ៗ ក្នុងក្រុង គឺវត្តឧណ្ណាលោម, បទុមវត្តី, លង្ការាម, សារាវ័ន, វត្តភ្នំពេញ, ពុទ្ធឃោសារាម, ពិភទ្ធវង្ស៊ី, ក៏ចំរើនពុទ្ធបរិត្ត ដល់ម៉ោង ៦ កន្លះបប់ ។

ក្រោយដែលចំរើនបរិត្តរួចហើយក្នុងវាងម៉ោង ៧ ក៏ផ្តើមធ្វើពិធីពុទ្ធាភិសេក; លោកគ្រូព្រះស្រីសម្មតិវង្សបានបាត់ឲ្យភិក្ខុ ២ រូបដែលទទួលនិមន្តមកសូត្រាបាឡីពុទ្ធាភិសេក ឲ្យតាំងសូត្រអភិសេកព្រះពុទ្ធរូបទាំង ៣ ព្រះអង្គនោះ លុះដល់ម៉ោង ៧ កន្លះបប់ ។

កាលធ្វើពិធីពុទ្ធាភិសេកហើយ ក្នុងវាងម៉ោង ៨ ផ្តើមសម្តែងធម៌ទេសនា សង្កេតមើលក្នុងវេលានោះឃើញមានមហាជនទាំងបព្វជិតទាំងគ្រហស្ថប្រមាណ ៤០០ រូប នេះស្មានតែចំនួនដែលបានចូលទៅក្នុងទីសាលា នៅមានបព្វជិតនឹងគ្រ-

ហស្តទៀតជាច្រើនណាស់ ដែលបានត្រឡប់ទៅទីលំនៅវិញ ទទេ ដោយមិនមានទីអង្គុយ លោកគ្រូព្រះវិមលធម្ម ភួង វត្ត បទុមវត្តី ជាអ្នកសម្ដែងរឿងបឋមនោះ ពីរឿងពុទ្ធបរិវត្ត នោះឯង ។ ស្រង់សេចក្ដីមកដោយសង្ខេបដូច្នេះ ។

ដំបូងចាប់ប្រារព្ធរឿងដែលធ្វើបុណ្យចំរើនអាយុសាលាថា "វេលានេះព្រះករុណាជាអំម្ចាស់ជីវិត និងលោកគ្រូព្រះស្រីសម្មតិវង្សជាចាងហ្វាងសាលាបាឡី និងលោកស្រីការប៉ុឡែសជាចាងហ្វាងព្រះរាជបណ្ណាល័យ និងជាអគ្គលេខាធិការពុទ្ធសាសនបណ្ឌិត្យ បានផ្ដើមធ្វើបុណ្យ ចំរើនអាយុសាលាបាឡី ដែលមានអាយុបានគំរប់ ២០ ឆ្នាំ ព្រះរាជបណ្ណាល័យបានគំរប់ ១០ ឆ្នាំ ពុទ្ធសាសនបណ្ឌិត្យបានគំរប់ ៤ ឆ្នាំ ដោយលំដាប់ សឹងនៅក្រោមព្រះបរមរាជូបត្ថម្ភនៃព្រះករុណាជាអំម្ចាស់ជីវិត ដើម្បីឲ្យសាលាទាំង ៣ នេះមានដំណើរទៅកាន់សេចក្ដីវឌ្ឍនាការចំរើនរុងរឿងតទៅ ដែលទុកជាដូងប្រទីបដ៏ធំសម្រាប់បំភ្លឺផ្លូវនៃខេមរជាតិឲ្យដើរទៅកាន់អារ្យវិថី ។

ប៉ុណ្ណោះហើយក៏ចាប់សម្ដែងព្រះធម្មទេសនា និយាយចាប់ដើមតាំងអំពីព្រះសាក្យមុនីសម្មាសម្ពុទ្ធសោយព្រះជាតិជាសុមេធបានចេញបួសជាតាបសឫសីសម្រេចឈានលោកីយ៍ហោះហើរបាន ក្នុងពុទ្ធុប្បាទកាលនៃព្រះទីបង្ករសម្មាសម្ពុទ្ធ ។ ថ្ងៃ១ព្រះសុមេធតាបសបានទៅជួបនឹងព្រះទីបង្ករនោះ ទ្រង់ព្យាករណ៍ទុកថា អំណើសទៅអនាគតកាល ព្រះតាបសនេះនឹងបានត្រាស់ជាព្រះពុទ្ធ១អង្គទ្រង់ព្រះនាមថា "គោតម" ក៏ឯព្រះសុមេធតាបសនោះកាលធ្វើកាលកិរិយាទៅហើយ បានទៅកើតក្នុងឋានសួគ៌ជាន់តុសិត មាននាមថាតុសិតទេវបុត្រអស់រវាងពុទ្ធន្តរ ២០ ប្លាយអង្គ ទើបបានចុតិមកកើតក្នុងឧទរនៃព្រះនាងសិរិមហាមាយាជាអគ្គមហេសីនៃព្រះបាទសុទ្ធោទនព្រះចៅក្រុងកបិលពស្តុក្នុងដែនសក្កជនបទក្នុងមជ្ឈិមប្រទេស ។ កាលប្រសូតមកហើយមានព្រះនាមថា "សិទ្ធត្ថ" ព្រះរាជបិតាទ្រង់ស្ងួនរក្សាយ៉ាងបំផុតទាល់តែចំរើនព្រះជន្មវស្សាបាន ១៦ ឆ្នាំ ទើបទ្រង់ធ្វើពិធីអភិសេកសមរសនឹងនាងពិម្ពាទេវី ដ៏ជាព្រះរាជធិតា

ព្រះបាទសុបពុទ្ធព្រះបៅក្រុងទេវទហនគរ ។ ដល់មកព្រះជន្ម ២៩ ទើបមានព្រះរាជឱរស ១ អង្គទ្រង់ព្រះនាម រាហុល ក្នុងវេលានោះទ្រង់ពិចារណាឃើញសេចក្ដីចាស់ឈឺស្លាប់ដែលវិលគ្របទៅលើសត្វទាំងពួងគ្រប់រូបគ្មានអ្នកណាមួយនឹងចៀសបាន ។ ឧបាយដែលនឹងចៀសសេចក្ដីចាស់ជាដើមប្រហែលជាមាន ប្រៀបដូចជាមានងងឹតហើយតែងមានភ្លឺកែគ្នា មានក្ដៅហើយតែងមានរបស់ត្រជាក់កែគ្នា មានចាស់ឈឺស្លាប់ហើយគង់ជាមានមិនចាស់មិនឈឺមិនស្លាប់កែគ្នាដែរ តែការដែលនឹងស្វែងរកឧបាយនេះបានឃើញតែភេទបព្វជិតជាឱកាសទំនេល្មមនឹងស្វែងរកបាន កាលទ្រង់រំពឹងដូច្នេះហើយក៏សម្រេចព្រះហឫទ័យចេញទ្រង់ព្រះផ្នួស លុះទ្រង់ព្រះផ្នួសហើយបានទ្រង់ស្វែងរកធម៌នោះអស់វារៈ ៦ ឆ្នាំ ទើបបានត្រាស់អនុត្តរសម្មាសម្ពោធិញាណជាអង្គព្រះអរហំសម្មាសម្ពុទ្ធក្នុងលោក ។ តាំងអំពីនោះមកទ្រង់ធ្វើពុទ្ធកិច្ចប្រោសវេនេយ្យសត្វសម្មាយឲ្យបានសម្រេចមគ្គផលនិព្វានតាមយ៉ាងព្រះអង្គឯរាបមកដល់ព្រះជន្ម ៨០ ទើប

ស្តេចរំលត់ខន្ធចូលកាន់ព្រះបរមនិព្វាន ។ សេចក្តីដែលពណ៌-នាមកនេះហៅថា បឋមត្រាស់ សន្មតិថាចប់តែប៉ុណ្ណោះ ហើយលោកធម្មកថិកថែមសេចក្តីខាងចុងនេះបន្តិចទៀតថាការដែលព្រះករុណាជាអម្ចាស់ជីវិតព្រមដោយលោកជាចាងហ្វាងសាលាអម្បាលនេះកំណត់ធ្វើបុណ្យចំរើនអាយុសាលាជម្រើវក្នុងថ្ងៃ ១៤-១៥ កើតខែពិសាខជាថ្ងៃដែលពួកពុទ្ធសាសនិកជននិយមថាជាមហាមង្គលសម័យហេតុអាស្រ័យជាថ្ងៃដ៏ប្រហែលនឹងថ្ងៃដែលព្រះពុទ្ធអង្គប្រសូតត្រាស់ដឹងនឹងបរិនិព្វាន ជាកិរិយាសម្តែងឲ្យឃើញថាប្រទេសកម្ពុជាវេលានេះ មានព្រះពុទ្ធសាសនារុងរឿងហើយ ហាក់ដូចជាមានព្រះពុទ្ធមកត្រាស់ថ្មី ប្រការសាសនាឲ្យខ្ជះខ្ជាយទៅ ក្នុងរវាងប្រម៉ាណ ១០០ ឬ ២០០ ឆ្នាំ មុននេះព្រះពុទ្ធសាសនាក្នុងប្រទេសយើងបានអាប់អោនស្រពោនចុះជាខ្លាំង ដល់មកសម័យនេះអាស្រ័យព្រះមហាករុណាធិគុណនៃព្រះករុណាជាអម្ចាស់ជីវិតនឹងរាជការប្រតិភូរាត់បារាំងសែសទំនុកបំរុងក៏ត្រឡប់រុងរឿងឡើងវិញយ៉ាងបិញ្ចាប ដោយបង្កើត

ឲ្យមានសាលាទាំង ៣ ជាកំឡាំងប្រកាសសាសនា ដែលជារបស់ល្អឲ្យខ្មែរយើងកាន់ ។

តែប៉ុណ្ណេះហើយលោកព្រះវិមលធម្មក៏ផ្ញើនូវអភិសច្ចវាចាជា ដោយអំណាចរតនត្តយានុភាព នឹងទេវានុភាព សូមឲ្យព្រះករុណាជាអម្ចាស់ជីវិតព្រមដោយរាជបរិសទ្យក្នុងកម្ពុជរដ្ឋបាននូវសេចក្ដីសុខសម្រាន ប្រាសចាកឧបសគ្គវិបត្តិទាំងប៉ុន្មានកុំឲ្យមកទើសទាក់បំពាក់ក្នុងព្រះកមលសន្តាន សព្វទិវារាត្រីហោង ។

បប់ព្រះធម្មទេសនាតែប៉ុណ្ណេះ

ទេយ្យទានដែលប្រគេនលោកទេសន៍កណ្ដនេះ គឺ

ត្រៃទេសឯក ១ ត្រៃ, ទៀន ១ ហោ, ឈើគូស ១ ហោ, ធូប ១ សំណុំ, បារី ១ កញ្ចប់, តែ ១ កញ្ចប់, ស្ករស ១ នាឡិ នឹងប្រាក់ ៤រ៉ៀល០០ ។

ប្រគេនលោកទទួលសព្វ ៤ រូបក្នុង ១ រូប គឺ

ស្បង់ទេសឯក ១, ទៀន ១ ហោ, ឈើគូស ១ ហោ,

ធូប ១ សំណុំ, បារី ១ កញ្ចប់, តែ ១ កញ្ចប់, ស្ករស ១ នាឡិ.។ រួមជាប្រាក់ ២៨ រៀល ។

វេលាកំពុងទេសនា លោកស្រីការប៉ឺឡែសបានអុចទៀនធូបឲ្យគេយកទៅបូជាព្រះធម្មទេសនា វេលាទេសន៍ចប់ហើយ លោកស្រីការប៉ឺឡែសនឹងលោកឡឺសែហ្វ៉ព្រមទាំងម៉ាដាម បានចូលទៅស្រោចស្រង់ព្រះពុទ្ធរូបដែលអភិសេកទាំង ៣ ព្រះអង្គ ក្រោយនោះលោកគ្រូព្រះស្រីសម្មតិវង្ស នឹងអ្នកឯទៀតក៏បានចូលទៅស្រោចស្របជាក្រោយ រាប់ជាចប់កិច្ចក្នុងវេលាយប់នេះតែប៉ុណ្ណោះ ។

ព្រឹកឡើងថ្ងៃសៅរ៍ទី ២៨ ក្នុងខែដដែលនេះ វេលាម៉ោង ១០ ព្រឹក ព្រះសង្ឃ ៣៥ រូបដែលចំរើនពុទ្ធបរិត្តពីល្ងាច ថែមលោកគ្រូព្រះញាណវង្សី ចៅអធិការវត្តពុទ្ធឃោសារាម ១ រូប ទៀតជា ៣៦ រូប ក៏និមន្តមកដល់នៅទីព្រះរាជបណ្ណាល័យ ក្នុងវេលានោះមានអ្នករាជការក្នុងព្រះបរមរាជវាំង មានសម្ដេចចៅហ្វា ។ ជាដើម នឹងក្រុមព្រះរាជបណ្ណាល័យ មានលោក

ស្តាប់បានយកចិត្តទុកដាក់ប្រុងស្តាប់រាល់គ្នា ហើយមានពាក្យសរសើរថា លោកក្មេង ៗ ជាន់ក្រោយនេះប៉ុនអធិប្បាយធម៌គ្របះល្អណាស់ ។

ដល់មកម៉ោង ៧ ប៉្លាយឯយប់ទើបបញ្ចប់ធម្មទេសនា ។

ទេយ្យទានដែលប្រគេនលោកទេសន៍ ៣ រូបនេះ ក្នុង ១ រូប ត្រៃទេសឯក ១ ត្រៃ, ទៀន ១ ហោ, ឈើគូស ១ ហោ, ធូប ១ សំណុំ, ស្ករបារាំង ១ ហិប, តែ ១ កញ្ចប់, បារី ១ កញ្ចប់, និងប្រាក់ ៦៛៦៦ ។ លោកអានត្រៃ ៤ រូប ក្នុង ១ រូបចីពរទេសឯក ១ ទៀន ១ ហោ, ឈើគូស ១ ហោ, ធូប ១ សំណុំ, ស្ករស ១ នាឡិ, តែ ១ កញ្ចប់, និងប្រាក់ ២ រៀល ។ លោកបាត្តបាស ២៨ រូប ក្នុង ១ រូបស្បង់ទេសឯក ១ ទៀន ១ ហោ, ឈើគូស ១ ហោ, ធូប ១ សំណុំ, ស្ករស ១ នាឡិ, តែ ១ កញ្ចប់, និងប្រាក់ ១ រៀល ។ បូកតែថ្លៃរបស់ត្រូវជាប្រាក់ ១៩២៛៣០ សេន បូកទាំងសាប់ប្រាក់ ៦០ រៀលទៀត ២៥២ រៀល ៣០ សេន ។ នៅមានប្រាក់ដែលអ្នកស្តាប់មានសទ្ធាបូលទៀត មិនបានគិតរួមក្នុងប្រាក់នេះទេ ។



ដល់វេលាយប់ម៉ោង ៩ មានល្ខោនព្រះរាជទ្រព្យរាំរឿងពុទ្ធបរិវត្ត៍នៅព្រះទីនាំងចន្ទ្រឆាយា ក្នុងព្រះបរមរាជវាំង មានមនុស្សជាច្រើន ទាំងអ្នករាជ្ការបារាំងខ្មែរនឹងអាណាប្រជានុរាស្ត្រអញ្ជើញទៅមើលចំនួនប្រម៉ាណ ១០០០ នាក់ ។ ព្រះករុណាជាអំម្ចាស់ជីវិតលើត្បូងមិនស្តេចចេញ ព្រះអង្គម្ចាស់អធិបតីចំនួសព្រះអង្គ លោកអាំងស្ប៉ិកទ័រប៉ូអាពេត៍ចំនួសលោកឡឺរេស៊ីដង់ស៊ុប៉េរិយើរ របៀបដែលរាំនោះដូច្នេះ ។

## ឈុតទី ១

ព្រះសិទ្ធត្ថកុមារចេញទ្រង់ប្រពាតសួន គង់រាជរថបាំងក្លស់ មានសារថីបរព្រះរាជរថតាមទំនៀម វេលាចេញទៅដល់ព្រៃទ្រង់ឃើញទេវនិមិត្តទាំង ៤ គឺមនុស្សចាស, ឈឺ, ស្លាប់នឹងអ្នកបួស ។

## ឈុតទី ២

ព្រះសិទ្ធត្ថចេញទ្រង់ព្រះផ្នួស មានព្រះព្រហ្ម, ព្រះឥន្ទ្ర, ព្រះចតុលោកបាល នឹងពួកទេវបុត្រទេវធិតាជាច្រើនហែហមជូនព្រះអង្គចេញទ្រង់ព្រះផ្នួស ។

ឈុតទី ៣

ទ្រង់កាត់ព្រះកេសាទ្រង់ព្រះផ្នួស   ព្រះព្រហ្មយកត្រៃចីវរមកថ្វាយ ។

ឈុតទី ៤

កងទព្វមារាធិរាជលើកមកគំរាមដណ្តើមយករតនបល្លង្ក ។ តែត្រង់ឈុតនេះនិងឈុត ១ ទៀតខាងក្រោយ មិនធ្វើឲ្យឃើញជាអង្គព្រះពុទ្ធឡើយដោយក្រែងមានទោស ធ្វើឲ្យឃើញតែមារនិងសេនាពលប៉ុណ្ណោះ ។

ឈុតទី ៥

ត្រង់សម្តែងធម្មចក្រ   ធ្វើឲ្យឃើញជារូបកង់ចក្រយ៉ាងធំ សឹងប្រដាប់ដោយភ្លើងអគ្គិសនីឆ្លុកព័ណ៌ មានមនុស្សនិងទេវតា មកមីដេរដាស ដើម្បីស្តាប់ព្រះធម្មទេសនា ដូចសេចក្តីដំណាលក្នុងរឿងធម្មចក្កប្បវត្តនសុត្តនោះស្រាប់ ។

ក្នុងវេលាដែលបេញ ១ ឈុត ៗ នោះសុទ្ធតែបិទភ្លើងទាំងអស់ ទុកតែភ្លើងដែលសម្រាប់បញ្ចាំងឆ្លុះឲ្យឃើញរឿងប៉ុណ្ណោះ

ហើយមើលទៅឃើញព័ណ៌ស្រងាត់សុខុមល្អ ក្នុង ១ ឈុតល្អ ១ បែបៗ គ្រប់ឈុតទាំងអស់ ។

អ្នកដែលមើលទាំងអស់គ្នាលាន់មាត់សរសើរគំនិតលោកស្រីការប៉ុឡែស ចែះចាត់ចែងការរុងរឿងល្អណាស់ ហើយមាន សេចក្ដីស្ដាយគ្រប់ៗគ្នា អំពីដែលរឿងចប់ឆាប់ពេក មិនអស់ចិត្តសោះ ។

វេលាម៉ោង ១០ និង ១៨ មិនុត្រចប់រឿង ។

រាំរឿងនេះដោយបំណងសេចក្ដីថា ចក្រពោលគឺព្រះធម៌ របស់ព្រះសម្មាសម្ពុទ្ធ ជាអំម្ចាស់យើង បានវិលទូទៅក្នុងប្រ-ទេសកម្ពុជា គួរជាទីត្រេកអររបស់យើងដែលជាអ្នកម្ចាស់ស្រុក រាប់ថាជាមហាភ័ពរបស់យើងរាល់គ្នាយ៉ាងវិសេស ។ ៚

# សត្តធនសូត្រ

## ឧកញ្ញាភក្តីរាជាយុំងអាចារ្យសាលាបាឡីជាន់ខ្ពស

## រៀបរៀង

ឯវម្មេសុតំ ឯកំសមយំភគវា សាវត្ថិយំវិហរតិ ជេតវនេ អនាថបិណ្ឌិកស្សអារាមេ ។

ឯតំសុត្តំ វីសត្តធនសូត្រ គឺខ្ញុំអានន្ទបើរស្តាប់ហើយ អំពីទីចំពោះព្រះភក្ត្រនៃព្រះដ៏មានបុណ្យជាម្ចាស់, ដោយអាការតែម្តង ក៏ចងចាំទ្រទ្រង់ដោយសោតវិញ្ញាណវិថីមានមនោវិញ្ញាណជាប្រធាន ពុំមានឲ្យឃ្លៀងឃ្លាតដោយអក្ខរព្យញ្ជនឯណានិមួយឡើយ.

ក្នុងកាលសម័យថ្ងៃ ១ សម្តេចព្រះបរមគ្រូសាស្តាជាម្ចាស់ ទ្រង់សម្រេចព្រះឥរិយាបថទាំង ៤ គង់នៅក្នុងវិហារព្រះជេតពន ជាអារាមនៃអនាថបិណ្ឌិកសេដ្ឋី សាងថ្វាយទៀបក្រុងសាវត្ថី រាជធានីនិវេសស្ថាន.

គ្រាកាលនោះឯង ព្រះដ៏មានព្រះភាគជាម្ចាស់ ទ្រង់បន្ទូល

ត្រាស់ហៅនូវព្រះភិក្ខុទាំងឡាយ ថា ភិក្ខវោ ម្នាលភិក្ខុទាំងឡាយ ទើបព្រះភិក្ខុទាំងឡាយឆ្លើយទទួលព្រះពុទ្ធដីកាថា ភទ្ទន្តេ ដូច្នេះ សម្តេចព្រះជិនវង្សត្រាស់ថា សត្តិមានិ ភិក្ខវេ ធនានិ ម្នាលភិក្ខុទាំងឡាយ ទ្រព្យទាំងឡាយនេះមាន ៧ ប្រការ, កតមានិសត្ត ទ្រព្យទាំងឡាយ ៧ ប្រការតើដូចម្តេចខ្លះ, ទ្រព្យទាំងឡាយ ៧ ប្រការនេះ, សទ្ធាធនំ ទ្រព្យគឺសទ្ធា ១, សីលធនំ ទ្រព្យគឺសីល ១, ហិរិធនំ ទ្រព្យគឺហិរិ ១, ឱតប្បធនំ ទ្រព្យគឺឱតប្ប ១, សុតធនំ ទ្រព្យគឺសុត ១, ចាគធនំ ទ្រព្យគឺចាគ ១, បញ្ញាធនំ ទ្រព្យគឺបញ្ញា ១,

កតមញ្ច ភិក្ខវេ សទ្ធាធនំ ម្នាលភិក្ខុទាំងឡាយ ទ្រព្យគឺសទ្ធាតើដូចម្តេច, ឥធភិក្ខវេ អរិយសាវកោសទ្ធោហោតិ, ម្នាលភិក្ខុទាំងឡាយ ជនអរិយសាវកក្នុងសាសនានេះ មានសទ្ធាជឿនូវពោធិញាណនៃព្រះតថាគតដូច្នេះគឺ,

ឥតិបិ សោភគវា អរហំ សម្មាសម្ពុទ្ធោ វិជ្ជាចរណសម្បន្នោ សុគតោ លោកវិទូ អនុត្តរោបុរិសទម្មសារថិ សត្ថាទេវមនុស្សានំ ពុទ្ធោ ភគវាតិ,

ដូច្នេះថា ព្រះដ៏មានព្រះភាគជាម្ចាស់នោះ ជាព្រះអរហំ ដោយហេតុដូច្នេះផង, ជាព្រះសម្មាសម្ពុទ្ធ ដោយហេតុដូច្នេះផង, ដល់ព្រមដោយវិជ្ជា ៣ វិជ្ជា ៨ នឹងចរណ ១៥ ដោយហេតុដូច្នេះខ្លះ, សុគតោ មានព្រះដំណើរល្អដោយហេតុដូច្នេះខ្លះ, លោកវិទូ ជ្រាបច្បាស់នូវលោកទាំង ៣ ដោយហេតុដូច្នេះខ្លះ, អនុត្តរោ បុរិសទម្មសារថិ ជានាយសារថីទូន្មាននូវបុរសគួរដល់ទូន្មាន មានបុគ្គលដទៃក្រៃលែងពុំមាន ដោយហេតុដូច្នេះខ្លះ, សត្ថា ទេវមនុស្សានំ ជាសាស្តាប្រដៅនៃទេវតានឹងមនុស្សទាំងឡាយ ដោយហេតុដូច្នេះខ្លះ, ពុទ្ធោ ត្រាស់ដឹង (គឺថារីកពេញទី) ដោយហេតុដូច្នេះខ្លះ, ភគវា មានចំណែកគឺបារមីធម៌ ដោយហេតុដូច្នេះខ្លះ, ឥទំវុច្ចតិភិក្ខវេសទ្ធាធនំ ម្នាលភិក្ខុទាំងឡាយ ទ្រព្យនេះឯងគឺតថាគត ពោលថាទ្រព្យគឺសទ្ធា,

កតមញ្ចភិក្ខវេសីលធនំ ម្នាលភិក្ខុទាំងឡាយ ទ្រព្យគឺសីលតើដូចម្តេច,

ឥធភិក្ខវេអរិយសាវកោ បាណាតិបាតាបដិវិរតោហោតិ,

អទិន្នាទានាបដិវិរតោហោតិ កាមេសុមិច្ឆាចារាបដិវិរតោហោតិ, មុសាវាទាបដិវិរតោហោតិ សុរាមេរយមជ្ជបមាទដ្ឋានាបដិវិរតោ-ហោតិ,

ម្នាលភិក្ខុទាំងឡាយ ជនអរិយសាវកក្នុងសាសនា វៀរបំពោះចាកបាណាតិបាត ការសំឡាប់សត្វមានជីវិត, វៀរបំពោះចាកអទិន្នាទាន ការកាន់យកនូវទ្រព្យ គឺម្ចាស់ពុំបានឲ្យ ដោយកាយដោយវាចា, វៀរបំពោះចាកមុសាវាទ ការពោលកុហកបញ្ឆោត, វៀរបំពោះចាកសុរាមេរយមជ្ជបមាទដ្ឋាន, ហេតុជាទីដំកល់នូវសេចក្ដីប្រមាទគឺគ្រឿងផឹកនូវទឹកស្រវឹង គឺ-សុរា ៥ យ៉ាងនឹងមេរយ ៥ យ៉ាង, ឥទំវុច្ចតិភិក្ខវេសីលធនំ ម្នាលភិក្ខុទាំងឡាយ ទ្រព្យនេះឯងហើយគឺព្រះតថាគតពោលថាទ្រព្យគឺសីល, កតមញ្ចភិក្ខវេហិរិធនំ ម្នាលភិក្ខុទាំងឡាយ ទ្រព្យគឺហិរិតើដូចម្ដេច,

ឥធភិក្ខវេ អរិយសាវកោ ហិរិមាហោតិ ហិរិយតិកាយ-ទុច្ចរិតេន វចីទុច្ចរិតេន មនោទុច្ចរិតេនហិរិយតិ បាបកានំ អកុ-សលានំ ធម្មានំ សមាបត្តិយា,

ម្នាលភិក្ខុទាំងឡាយ ជនអរិយសាវកក្នុងសាសនានេះ មានសេចក្តីអៀនខ្មាស់អំពីកាយទុច្ចរិត ការប្រព្រឹត្តអាក្រក់ដោយកាយ ខ្មាស់អំពីវចីទុច្ចរិត, ការប្រព្រឹត្តអាក្រក់ដោយវាចា ខ្មាស់អំពីមនោទុច្ចរិត, ការប្រព្រឹត្តអាក្រក់ដោយចិត្ត, ខ្មាស់អំពីកិរិយាដល់ព្រមនៃធម៌ទាំងឡាយ ដ៏លាមកជាអកុសល, ឥទំវុច្ចតិភិក្ខវេហិរិធនំ ម្នាលភិក្ខុទាំងឡាយទ្រព្យនេះឯងហើយ គឺតថាគតពោលថាទ្រព្យគឺហិរិ, កតមញ្ចភិក្ខវេឱត្តប្បធនំ ម្នាល-ភិក្ខុទាំងឡាយទ្រព្យគឺឱត្តប្បតើដូចម្តេច,

ឥធភិក្ខវេ អរិយសាវកោ ឱត្តប្បី ហោតិ ឱត្តប្បតិ កាយ-ទុច្ចរិតេន វចីទុច្ចរិតេន មនោទុច្ចរិតេន ឱត្តប្បតិ បាបកានំ អកុសលានំ ធម្មានំ សមាបត្តិយា,

ម្នាលភិក្ខុទាំងឡាយ ជនអរិយសាវកក្នុងសាសនានេះ មានសេចក្តីក្តៅក្រហាយតក់ស្លុត អំពីកាយទុច្ចរិត អំពីវចីទុច្ចរិត, អំពីមនោទុច្ចរិត អំពីកិរិយាដល់ព្រមនៃធម៌ទាំងឡាយ ដ៏លាមកជាអកុសល, ឥទំវុច្ចតិភិក្ខវេឱត្តប្បធនំ ម្នាលភិក្ខុទាំង

ឡាយទ្រព្យនេះឯងហើយគឺតថាគតពោលថាទ្រព្យគឺឱតប្ប. កតមញ្ចភិក្ខវេសុតធនំ ម្នាលភិក្ខុទាំងឡាយទ្រព្យគឺសុតតើដូចម្តេច.

ឥធភិក្ខវេអរិយសាវកោ ពហុស្សុតោហោតិ សុតធរោ សុតសន្និចយោ យេតេធម្មា អាទិកល្យាណា មជ្ឈេកល្យាណា បរិយោសានកល្យាណា សាត្ថំសព្យញ្ជនំ កេវលំបរិបុណ្ណំ បរិសុទ្ធំ ព្រហ្មចរិយំអភិវទន្តិ តថារូបស្សធម្មាសុតាហោន្តិ ធតាវចសាបរិចិត្តា មនសានុបេក្ខិតា ទិដ្ឋិយាសុប្បដិវិទ្ធា ឥទំវុច្ចតិសុតធនំ,

ម្នាលភិក្ខុទាំងឡាយ ជនអរិយសាវកក្នុងសាសនានេះ ជាពហុស្សូត អ្នកទ្រទ្រង់នូវសូត្រ អ្នកសន្សំនូវសូត្រ ធម៌ទាំងឡាយឯណាមានពីរោះក្នុងខាងដើម មានពីរោះក្នុងកណ្តាល មានពីរោះក្នុងទីបំផុត សម្តែងនូវព្រហ្មចរិយប្រកបដោយអត្ថ ប្រកបដោយព្យញ្ជន បរិសុទ្ធបរិបូរណ៍ ពុំមានសេសសល់ ធម៌ទាំងឡាយមានសភាពដូច្នោះ គឺអរិយសាវកនោះ ស្តាប់

ហើយ ទ្រទ្រង់ហើយ ស្ទាត់ហើយដោយវាចា សំឡឹងរឿយៗ ដោយចិត្ត ចាក់ធ្លុះដោយប្រពៃដោយទិដ្ឋិ ម្នាលភិក្ខុទាំងឡាយ ទ្រព្យនេះឯងហើយគឺតថាគតពោលថាទ្រព្យគឺសុត, កតមញ្ច ភិក្ខវេចាគធនំ ម្នាលភិក្ខុទាំងឡាយ ទ្រព្យគឺចាគតើដូចម្ដេច.

ឥធភិក្ខវេ អរិយសាវកោ វិគតមលមច្ឆេរេន ចេតសា អគារំអជ្ឈាវសតិ មុត្តចាគោ បយតបាណី វោស្សគ្គរតោ យាចយោគោ ទានសំវិភាគរតោ.

ម្នាលភិក្ខុទាំងឡាយ ជនអរិយសាវក ក្នុងសាសនានេះ មានចិត្តមានមន្ទិល គឺសេចក្ដីកំណាញ់ ប្រាសចេញហើយ មានទានបរិច្ចាគរួចស្រឡះហើយ មានដៃរបស់ខ្លួនលាងស្អាត ហើយ ត្រេកអរហើយក្នុងកិរិយាលះបង់ មុខគួរដល់កិរិយាសូម ត្រេកអរហើយក្នុងទាននឹងចំណែកស្មើ នៅគ្រប់គ្រងនូវផ្ទះ, ឥទំវុច្ចតិភិក្ខវេចាគធនំ ម្នាលភិក្ខុទាំងឡាយ ទ្រព្យនេះឯង ហើយគឺតថាគតពោលថាទ្រព្យគឺចាគ, កតមញ្ចភិក្ខវេបញ្ញា-ធនំ ម្នាលភិក្ខុទាំងឡាយ ទ្រព្យគឺបញ្ញាតើដូចម្ដេច.

ឥធភិក្ខវេអរិយសាវកោ បញ្ញវាហោតិ ឧទយត្ថគាមិនិយា ឧទយញ្ច អត្ថញ្ច គន្តុំ បរិច្ឆិន្ទិតុំ បញ្ញាយសមន្នាគតោ អរិយាយនិព្វេធិកាយ សម្មាទុក្ខក្ខយគាមិយា ។ ម្នាលភិក្ខុទាំងឡាយ ជនអរិយសាវកក្នុងសាសនានេះ មានបញ្ញា ប្រកបដោយបញ្ញាដ៏ប្រសើរ ជាគ្រឿងត្រាស់ដឹងដើម្បីដល់ ដើម្បីកំណត់ នូវកិរិយាអស់ទៅ នូវកិរិយាចំរើនជាទីដល់ក្នុងហេតុទាំងពីរ ជាទីដល់នូវសេចក្តីអស់ទៅនៃទុក្ខដោយប្រពៃ,

ឥទំវុច្ចតិភិក្ខវេបញ្ញាធនំ ម្នាលភិក្ខុទាំងឡាយ ទ្រព្យនេះហើយគឺតថាគតពោលថាទ្រព្យគឺបញ្ញា, ឥមានិខោភិក្ខវេសត្តធនានិ ម្នាលភិក្ខុទាំងឡាយ ទ្រព្យទាំងឡាយនេះ ហៅថាទ្រព្យ ៧ ប្រការ ព្រះបរមសាស្តាចារ្យ ព្រះអង្គញុំាងសូត្រឲ្យចប់ហើយ ព្រះអង្គកាន់យកនូវកំពូលទេសនា ដោយបទគាថាទាំងឡាយថា,

សទ្ធាធនំសីលធនំ ហិរិឱត្តប្បិយធនំ សុតញ្ចាគោច បញ្ញាវសត្តមំ យស្សឯតាធនាសន្តិ ឥត្ថិយាបុរិសស្សវា អទ-

ឡិទ្ទោតិតំអាហុ អមោឃំតស្សជីវិតំ តស្មាសទ្ធញ្ចសីលញ្ច បសាទធម្មទស្សនំ អនុយុញ្ជេថមេធាវី សរំពុទ្ធានសាសនន្តិ,

អធិប្បាយថា ទ្រព្យទាំងឡាយនេះ ទ្រព្យគឺសទ្ធា ១, ទ្រព្យគឺសីល ១, ទ្រព្យគឺហិរិ ១, គឺឱតប្ប ១, គឺសុត ១, គឺចាគ ១, ទ្រព្យជាគំរប់ ៧ គឺបញ្ញា ១, មានដល់បុគ្គលឯណា ទោះជាស្ត្រីក្តី, បុរសក្តី, អ្នកប្រាជ្ញទាំងឡាយ ហៅនូវបុគ្គលនោះថាពុំមែនមនុស្សក្រខ្សត់ឡើយ ជីវិតរបស់អ្នកនោះពុំបានសោះសូន្យទទេ ហេតុដូច្នោះបុគ្គលជាអ្នកប្រាជ្ញ កាលនឹករលឹកនូវពាក្យប្រដៅរបស់ព្រះពុទ្ធជាម្ចាស់ទាំងឡាយហើយ ចូរប្រកបរឿយ ៗ នូវសទ្ធានឹងសីល នូវកិរិយាឃើញនូវបសាទធម៌នេះហោង ។ះ៚—

សត្តធនសុត្តំនិដ្ឋិតំ ចប់សត្តធនសូត្រតែប៉ុណ្ណោះ



ប្រាសាទព្រះគោ (ក្នុងប្រជុំអង្គរ) នេះជារូបឃើញក្រោយដែលរៀបចំជួសជុលឡើង

# រឿងសាសនប្រវត្តិ

## បរិច្ឆេទទី ៦

## សុវណ្ណភូមិ

### ព្រះមហាពិទូរក្រសេមរៀបរៀង

## បរិច្ឆេទទី ៦

## ព្រះពុទ្ធសាសនាផ្សាយទៅប្រទេសសុវណ្ណភូមិ

ប្រទេសឯណាដែលឈ្មោះថា "សុវណ្ណភូមិ" ជាទីដែលគួរពិចារណា មានអ្នកខ្លះពោលទៅហើយថា សុវណ្ណភូមិគឺប្រទេសមន, តែដោយមតិរបស់ខ្ញុំយល់ថា បណ្តាប្រទេសដ៏តាំងនៅក្នុងរវាងប្រទេសឥណ្ឌា នឹងប្រទេសចិន គឺរួមទាំងប្រទេសភូមា មន ថៃយៃ លាវ សៀម ខ្មែរ យួននេះឯងជាប្រទេសសុវណ្ណភូមិ ត្រូវនឹងពាក្យថា អាំងដូចិន (Indochine) ប្រែថាប្រទេសដ៏តាំងនៅក្នុងរវាងប្រទេសអាំងនឹងប្រទេសចិន ន័យ ១ ទៀត ប្រៀបដូចពាក្យថា មជ្ឈិមប្រទេស (ប្រទេសដ៏តាំងនៅត្រង់កណ្តាល) នេះមិនចំពោះតែនគរកបិលពស្តុ ឬនគរណាមួយឡើយ គឺជាសហរដ្ឋរួមប្រទេសទាំងអស់ ១៦ ពាក្យថា

សុវណ្ណភូមិក៏ដូច្នោះ តាមរឿងក្នុងគំរាំភូមិសាស្ត្រសៀមបុរាណ ក៏ជាប្រទេសអំបាលនេះជាប្រទេសសុវណ្ណភូមិដែរ ដែរហៅដូច្នេះ ព្រោះជាប្រទេសដ៏សម្បូណ៌ទៅដោយមាស ក្នុងសម័យនោះ មានពួកពាណិជឥណ្ឌៀនាំទំនិញមកលក់ដូរយកមាសទៅជា-រឿយ ៗ ទាល់តែល្បីនាមថា សុវណ្ណភូមិ ។

ក៏រឿងពុទ្ធសាសនាផ្សាយមកប្រទេសសុវណ្ណភូមិ មានពុទ្ធសាសនប្រវត្តិប្រាកដក្នុងទីផ្សេង ៗ គឺ សិលាចារិក របស់ព្រះចៅរាមាធិបតី (ព្រះចៅផែនដីមន) ១ គម្ពីរមហាវង្ស ១ ទាំងនេះជាដើមដែលមានសេចក្តីរួមគ្នា ហើយគួរជឿយកជាពិតបាន ។ ឯសិលាចារិកនោះ ព្រះចៅរាមាធិបតីទ្រង់អារាធនាព្រះសង្ឃ មន ដែលទៅឧបសម្បទមកអំពីលង្កាទ្វីបឲ្យធ្វើសីមាហៅថា “កល្យាណីសីមា” តាមនាមសីមាទឹកដែលព្រះសង្ឃទាំងនោះទៅឧបសម្បទ. ហើយត្រាស់ឲ្យចារិកអក្សរសំដែងពុទ្ធសាសនប្រវត្តិ នឹងករណិយកិច្ច ដែលទ្រង់បានធ្វើមកហើយជាដើម ឲ្យឈ្មោះថា “សិលាកល្យាណី” ទាំងអស់មាន ១០ផែន

ក្នុង ១ ផែនកំពស់ប្រមាណ ៤ ហត្ថ ១ ចំអាម មុខបន្ទា ២ ហត្ថ ១ ចំអាម កម្រាស់ ១៨ ធ្នាប់ ប្រតិស្ឋានទុកនៅតំបន់ស្រុកដែលហៅសព្វថ្ងៃនេះថា សោន្គយោង នៅក្រៅក្រុងហង្សាវតីទៅខាងលិច ចារិកជាភាសាមគធ ២ ផែន ជាភាសារាមញ្ញ ៨ ផែន ក្នុងកាល ព.ស. ២០១៩ ។

អំពីនេះនឹងនាំយកសេចក្ដីក្នុងសិលាកល្យាណីនោះមកសំដែងដោយសំខេបដូចមានតទៅនេះ កាលព្រះមោគ្គលីបុត្រតិស្សថេរ ធ្វើទុតិយសង្គាយនាហើយ បានបញ្ជូនព្រះថេរានុថេរទាំងឡាយឲ្យចេញទៅប្រកាសព្រះពុទ្ធសាសនាក្នុងនានាប្រទេសដូចពោលហើយខាងដើម បំណែកឯព្រះថេរ ២ អង្គ គឺព្រះសោណថេរ ១ ព្រះឧត្តរថេរ ១ ទទួលថេរបញ្ជាទៅកាន់ប្រទេសសុវណ្ណភូមិ [១] ដំរូងចាប់ប្រតិស្ឋានព្រះពុទ្ធសាសនាក្នុងរាមញ្ញប្រទេស ក្នុងរជ្ជកាលព្រះចៅសិរិមាសោករាជ ៗ ទ្រង់ទទួលរាប់អាននឹងទំនុកបំរុងព្រះថេរទាំង ២ នេះយ៉ាងល្អ គឺ ទ្រង់សាងព្រះអារាម ១ នៅលើខ្នងភ្នំឲ្យឈ្មោះថា "កៃលាសបរពតចេតិយ

(១) សេចក្ដីត្រង់នេះ ត្រូវគ្នានឹងគម្ពីរមហាវង្ស ។

វិហារ" ជាដំបូង ហើយនិមន្តព្រះថេរទាំង ២ អង្គមកគង់នៅ ព្រះថេរទាំង ២ បានសំដែងព្រហ្មជាលសូត្រជាដំបូង ញ៉ាំងឫស នៃព្រះពុទ្ធសាសនាលទ្ធិថេរវាទ ឲ្យប្រតិស្ឋានចុះក្នុងដែនប្រទេសសុវណ្ណភូមិ ក្នុងពុទ្ធសាសនកាលកន្លងទៅបាន ២៣៦ ដោយប្រការដូច្នេះ ។ អំពីនោះមកព្រះពុទ្ធសាសនាក៏សន្សំម ៗ ផ្សាយទៅក្នុងដែនសុវណ្ណភូមិដោយអន្លើ ៗ តាមប្រទេសដែលមានអ្នកជ្រះថ្លារាប់អាន ដូចយ៉ាងប្រទេសភូមា-ខ្មែរ-លាវ ។

លុះសម័យតមក ក្នុងរជ្ជកាលព្រះចៅមនោហរី (ក្សត្រិយ៍មន) ព. ស. ១៦០០ ប្រាកដថា ព្រះពុទ្ធសាសនាបានផ្សាយរហូតមកដល់ប្រទេសភូមា និងប្រទេសកម្ពុជាភាគខាងលើ គឺត្រង់ដែនសៀមសព្វថ្ងៃនេះ តែក្នុងពង្សាវតារភូមាត្រង់រជ្ជកាលព្រះចៅអនុរុទ្ធមហារាជថា ព្រះពុទ្ធសាសនាក្នុងប្រទេសមនរុងរឿងជាងគេ ដោយហេតុនេះ កាលព្រះចៅអនុរុទ្ធបានសោយរាជ្យក្នុងពុទ្ធសករាជដូចមានលើនេះ តាំងរាជធានីនៅអរិមទ្ទបុរី ជាអ្នកមានមហិទ្ធានុភាពដ៏ច្រើន ស្ដេចលើកទ័ពទៅកម្ចាប់ប្រ-

ទេសជិតខាង គឺប្រទេសថៃយែរហូតទល់តណ្ណៀ នឹងប្រទេស មន លាវ មកទល់នឹងប្រទេសកម្ពុជា បានមកក្នុងអំណាចស្រែបរាជការសង្គ្រាមហើយ ត្រាស់ឲ្យនាំយបែបលទ្ធិសាសនាក្នុងរាមញ្ញប្រទេសទៅប្រតិស្ឋានក្នុងក្រុងអរិមទ្ទបុរី ខាងលង្កាទ្វីបក៏បានមកសុំសមណវង្សទៅប្រតិស្ឋានក្នុងសម័យជាមួយគ្នានេះ ជាហេតុឲ្យព្រះចៅអនុរុទ្ធមហារាជ នឹងព្រះបាសិរិសំឃពោធិ-វិជយពាហុជាសម្ពន្ធមេត្រីនឹងគ្នា វេលាក្រោយព្រះចៅអនុរុទ្ធបញ្ជូនរាជទូតឲ្យទៅសុំចម្លងគម្ពីរព្រះត្រៃបិដកអំពីប្រទេសលង្កាមកផ្សាយក្នុងប្រទេសភូមា គ្រានោះព្រះពុទ្ធសាសនាក្នុងប្រ-ទេសភូមារាប់ថារុងរឿងជាបំផុត ។

គណសង្ឃរាមញ្ញដែលទៅឲ្យឧបសម្បទអ្នកលង្កាក្នុងសម័យនោះមានព្រះឧត្តរាជីវថេរជាប្រធាន នឹងសាមណេរ ១ អង្គឈ្មោះ ឆបដ (ឬឆបទ) ទៅជាមួយផង លុះនៅយូរបន្តិចទៅភិក្ខុអំបាលនោះក៏ត្រឡប់ព្រះនគរវិញទាំងអស់ នៅតែឆបដសាមណេរនៅរៀនព្រះត្រៃបិដកនឹងឧបសម្បទក្នុងទីនោះ លុះ

រៀនបេះបរិបូណ៌ទាំងមានវស្សា ១០ ពេញជាថេរហើយ ក៏គិតនឹងត្រឡប់ស្រុកទេសវិញ ទើបបបួលព្រះថេរឯទៀត ៤ អង្គមកផង ដូចមានប្រាកដក្នុងសិលាកល្យាណី បំពោះសេចក្តីត្រង់នេះថា :

ឯវញ្ចបន សោ ចិន្តេត្វា "តាមលិត្តិវាសីបុត្តេន សិវលិថេរេន, កម្ពោជរាជតនុជេន តាមលិន្ទត្ថេរេន, កិញ្ចិបុរវាសីតនយេន អានន្ទត្ថេរេន, លង្កាទីបវាសីកាត្រជេន រាហុលត្ថេរេន ច សទ្ធឹ សីវិជាយ នាវំ អភិរូហិត្វា បច្ចាគច្ឆន្តិ ។ តេ បញ្ចបិ មហាថេរា តិបិដកធរា ព្យត្តា បណ្ឌិតា ។ ប ។

ប្រែថា កាលព្រះឆបដថេរនោះគិតនឹងត្រឡប់ព្រះនគរដូច្នោះហើយ ក៏បបួលព្រះថេរទាំងឡាយ ៤ អង្គ (៥ ទាំងខ្លួន) គឺព្រះសិវលិថេរ ជាបុត្រអ្នកស្រុកតាមលិត្តិគ្រាម ១ ព្រះតាមលិន្ទថេរ ជារាជបុត្រព្រះចៅក្រុងកម្ពុជា ១[១] ព្រះអានន្ទថេរ ជាបុត្រអ្នកស្រុកកិញ្ចិបុរី ១ ព្រះរាហុលថេរជាបុត្រអ្នកលង្កា ១

(១) ពាក្យត្រង់នេះ ១ ៗដែលនាំឲ្យយលថា ក្នុងព.ស. ១៦០០ ឬមុននេះព្រះពុទ្ធសាសនាលទ្ធិថេរវាទបានផ្សាយមកដល់ប្រទេសកម្ពុជាហើយ ដោយមិនពោងសង្ស័យ ។

ឡើងជិះសំពៅត្រឡប់មកព្រះនគរវិញ ព្រះថេរអំបាលនេះសុទ្ធតែជាអ្នកទ្រទ្រង់នូវព្រះត្រៃបិដកឆ្លាសជ្រៀងក្នុងធម្មវិន័យ និងជាអ្នកមានកំលាំងអាចក្នុងបដិភាណវោហារ កាលមកដល់ប្រទេសរាមញ្ញហើយជ្រាបថា ព្រះឧត្តរាជីវថេរទៅនៅក្រុងអរិមទ្ទបុរីហើយ ក៏នាំគ្នាហួសទៅក្រុងអរិមទ្ទបុរី ដើម្បីនៅជាមួយគ្នានឹងព្រះឧត្តរាជីវថេរ ។ ការព្រះសាសនាក្នុងប្រទេសមនក្នុងកាលប្រមាណ ព.ស. ១៥៧០–១៦៧០ នៅបំរើនរុងរឿង បំណែកខាងប្រទេសភូមាចាប់បំរើនឡើងក្នុងរជ្ជកាលព្រះចៅអនុរុទ្ធអំពី ព.ស. ១៦០០ ជាដើមមក ។ លុះផុតរជ្ជកាលព្រះចៅអនុរុទ្ធមហារាជហើយ ក្សត្រិយ៍ដែលសោយរាជ្យតមកគ្មានព្រះតេជានុភាពយ៉ាងព្រះអង្គ ។ ពួកប្រទេសរាជទាំងពួងក៏ត្រឡប់តាំងឥស្សរភាពឡើងរៀងខ្លួន ការព្រះសាសនាក្នុងប្រទេសទាំងពីរក៏សន្សឹម ៗ អាប់ឱនចុះដោយលំដាប់ ។

លុះដល់ ព.ស.២០០៣ ព្រះមហាក្សត្រិយ៍រាមញ្ញ១អង្គទ្រង់នាម រាមាធិបតី ឬធម្មចេតីយ៍ ឬស្រីមហាបិដកធរ

សោយរាជ្យនៅសុធម្មនគរ (ហង្សាវតី) ព្រះរាជាអង្គនេះឧបតិ
ក្នុងត្រកូលដូចម្តេចមិនប្រាកដ តែមិនមែនជារាជវង្សក្នុងរឿង
រាជាធិរាជរបស់មន ចាប់និយាយពីត្រឹមឈ្មោះនេះបួសជា-
សាមណេរនៅវត្តស្រីប្រាង្គណ៍ក្នុងក្រុងហង្សាវតី កាលអាយុ-
១៤ ឆ្នាំ បានទៅសិក្សាវិជ្ជានៅក្រុងភូកាម ទាល់តែបានជា
ពហុស្សូត គឺ ចេះគម្ពីរព្រះត្រៃបិដក និងចេះតក្កសាស្ត្រ ព្យា-
ករណសាស្ត្រ អលង្ការសាស្ត្រ ជោតិសាស្ត្រ វេទ្យសាស្ត្រ
គណិកសាស្ត្រ និងភាសាតាងប្រទេស ហើយត្រឡប់មកនៅ
វត្តស្រីប្រាង្គណ៍វិញតាមដើម តែងត្រេចទៅទេសនាប្រដៅមហា
ជនជារឿយៗ មានមនុស្សស្គាល់និងរាប់អានច្រើន មានទាំង
នាងក្សត្រិយ៍ ១ អង្គជារាជធិតាព្រះចៅរាជាធិរាជជាអ្នកឧបដ្ឋាក
និងរៀបចំឲ្យឧបសម្បទជាភិក្ខុ មាននាមហៅថា មហាបិដក-
ធរ ។ នាងក្សត្រិយ៍នេះក្នុងពង្សាវតារភូមាថា មានរាជស្វាមី
និងបុត្រហើយ តែជាមេម៉ាយមកពីកាលណាមិនប្រាកដ កាល
ក្នុងរជ្ជកាលព្រះចៅធម្មរាជាដែលជាឧរសរបស់នាង សឹងបាន

សោយរាជក្នុងលំដាប់មកអំពីព្រះចៅរាជាធិរាជ នាងក្សត្រិយ៍នេះក៏ធ្លាក់ទៅជាមហេសីព្រះចៅក្រុងភូកាម ៗ អង្គនោះសោយរាជ្យមិនយូរប៉ុន្មាន មានមនុស្សលបពិឃាតបង់ នាងក៏ធ្លាក់ទៅជាភរិយាអ្នកមានបណ្ដាសក្ដិ ១ នាក់ឈ្មោះ ត្រាពញ្ញា នៅក្រុងភូកាមនោះ មានធិតា ១ តែនឹងកើតដោយព្រះចៅភូមា ឬដោយត្រាពញ្ញាមិនប្រាកដ ព្រះមហាបិដកធរទើបទៅនាំបម្រើតនាងនឹងធិតាមកក្រុងហង្សាវតីវិញ ។

ឯនគរហង្សាវតីមានព្រះមហាក្សត្រិយ៍ដំណវង្សមកអំពីព្រះចៅរាជាធិរាជ ព.ស. ១៩៦៦ មកដល់ ព.ស. ១៩៩៦ បាន ៥ ព្រះអង្គ ព្រះចៅញ្ញរូជាឧរសរបស់នាងក៏បានសោយរាជ្យ ១ អង្គដែរ តែត្រូវនឹងវេលាប្រទេសមិនសាន្តត្រាន កើតចម្បាំងកាប់សម្លាប់តែគ្នាឯង ទាល់តែរាជវង្សព្រះចៅរាជាធិរាជប្រុសៗសុគតអស់ទៅ អ្នកនគរទើបព្រមគ្នាអញ្ជើញនាងក្សត្រិយ៍មេម៉ាយនោះឲ្យឡើងសោយរាជ្យក្នុងកាល ព.ស. ១៩៩៦ ព្រះនាងក៏ឲ្យព្រះមហាបិដកធរសឹកមកអភិសេកនឹងព្រះធិតារបស់ព្រះ

នាង ហើយតាំងជាមហាឧបរាជ ព្រះនាងនៅក្នុងរាជសម្បត្តិបាន ៧ ឆ្នាំ ក៏លើករាជសម្បត្តិឲ្យមហាឧបរាជសោយរាជ្យជាដំណាងតមក–កាលក្នុងព.ស.២០០៣ទ្រង់ព្រះនាមជ្ញូបពោលហើយខាងដើម ។

កាលផែនដីមុន ៗ តាំងអំពីរជ្ជកាលព្រះចៅរាជាធិរាជក៏កើតសឹកសាមសង្គ្រាមជ័យនឹងប្រទេសភូមាមកហើយ ក្នុងរជ្ជ-កាលត ៗ មកក៏បេះតែច្បាំងគ្នាឯងពួនបុះពួនឡើង ទាល់តែផុតរាជវង្សដែលជាក្សត្រា នៅសល់តែរាជវង្សក្សត្រី លុះដល់រជ្ជកាលព្រះចៅរាមាធិបតីជាភ័ពដ៏ប្រសើរ ដោយស្រុកទេសសាន្តត្រានគ្មានអ្នកណាដណ្តើមរាជបល្ល័ង្កទៀត ជាឱកាសឲ្យទ្រង់ចាត់ការទំនុកបំរុងព្រះរាជអាណាចក្រនឹងពុទ្ធសាសនចក្រឲ្យរុងរឿងឡើងដោយផ្លូវបណ្ឌិតវិស័យ ។

ដូចយ៉ាងក្នុងសម័យមួយនោះ ទ្រង់ព្រះចិន្តាថា ការឧប-សម្បទជាភិក្ខុអាស្រ័យមកពីបព្វជា គឺបួសជាសាមណេរដោយត្រឹមត្រូវជាមុនសិន នឹងតោងអាស្រ័យប្រកបព្រមដោយសម្បត្តិ

៥ គឺសីមាសម្បត្តិ ១ បរិសសម្បត្តិ ១ វត្ថុសម្បត្តិ ១ ញត្តិសម្បត្តិ ១ អនុសាវនសម្បត្តិ ១ បើប្រកបដោយសម្បត្តិ ៥ នេះ ហើយកម្មទើបមិនវិបត្តិ គួរដល់ឧបសម្បទកម្ម តែវត្ថុសម្បត្តិ ញត្តិសម្បត្តិ អនុសាវនសម្បត្តិ ឃើញជាជារបស់គួរហើយ ព្រោះវត្ថុ គឺឧបសម្បទាបេក្ខជាបុគ្គលមានលក្ខណបរិសុទ្ធ ទាំងអាចារ្យអ្នកសូត្រក៏អាចសូត្រធ្វើអក្ខរវិធីឲ្យបរិបូណ៌បាន តែឯសីមាសម្បត្តិនឹងបរិសសម្បត្តិ ដូចម្ដេចហ្ន៎ជារបស់ដែលត្រឹមត្រូវបរិបូណ៌ ។ លំដាប់នោះទើបត្រាស់ឲ្យប្រមូលគម្ពីរវិន័យបិដក គឺពួកបាលីវិន័យ ១ ពួកអដ្ឋកថាវិន័យ ១ សារត្ថទីបនី ដីកាវិន័យ ១ វិមតិវិនោទនី ដីកាវិន័យ ១ វជិរពុទ្ធិ ដីកាវិន័យ ១ កង្ខាវិតរណីអដ្ឋកថាមាតិកា ១ ដីកាកង្ខាវិតរណី ១ វិនយវិនិច្ឆយបករណ ១ សីមាលង្ការបករណ ១ សីមាលង្ការសង្គហ ១ ទ្រង់យកមកពិនិត្យមើលដោយញាណដ៏សុខុមហើយ ឃើញជា សីមានឹងបរិសក្នុងប្រទេសរាមញ្ញវិបត្តិ ទើបត្រាស់ឲ្យប្រជុំសង្ឃដែលឆ្លាសក្នុងវិន័យ ត្រួតមើលម្ដងទៀតក៏ឃើញវិបត្តិដូចគ្នា ទ្រង់មាន

ព្រះហឫទ័យស្ងួតពន់ប្រមាណ ទើបអារាធនាព្រះថេរ ២២ មាន ព្រះមោគ្គល្លានថេរជាប្រធាន នឹងបាត់រាជទូត ២ នាក់ គឺចិត្រ-ទូតនឹងរាមទូតព្រមដោយគ្រឿងពុទ្ធបូជានឹងរាជបណ្ណាការឲ្យទៅ កាន់លង្កាទ្វីប ដើម្បីនឹងឧបសម្បទឡើងជាថ្មី ព្រោះទ្រង់បាន ជ្រាបថា កាលក្នុងរជ្ជកាលព្រះចៅបរក្កមពាហុ មហារាជ ដែល បានប្រាប្តាភិសេកក្នុងកាល ព. ស. ១៧០៨ ក្នុងឆ្នាំទី ១៨ ក្នុង រជ្ជកាលនោះ បានទ្រង់ជំរះព្រះពុទ្ធសាសនាឲ្យបរិសុទ្ធឡើងម្តង ព្រះសង្ឃក្នុងប្រទេសនោះក៏បរិសុទ្ធមានគុណគួររាប់អាន ។

សមណទូតរាមញ្ញ ទៅដល់លង្កាក្នុងរជ្ជកាលព្រះចៅភូវ-នេកពាហុ (ព. ស. ប៉ុន្មានមិនប្រាកដ) ព្រះចៅភូវនេកពាហុ ទ្រង់បដិសណ្ឋារទូតរាមញ្ញយ៉ាងល្អដោយធូរមេត្រី នឹងទ្រង់បាត់ ការឲ្យបព្វជាឧបសម្បទឡើងជាថ្មីនៅកល្យាណីសីមា បួនថ្ងៃ ទើបស្រេចការឧបសម្បទកម្ម ព្រះធម្មកិត្តិមហាថេរជាឧប-ជ្ឈាយ៍ ព្រះមង្គលថេរជាកម្មវាចាចារ្យ ។ល។ ព្រមដោយ គណសង្ឃ ២២ រូបជា ២៤ រូប ។ កាលស្រេចការឧបសម្បទ

ហើយ ព្រះចៅភូរិនេកពាហុក៏ព្រះរាជទានតាមព្រះសង្ឃរាមញ្ញ ដែលឧបសម្បទថ្មីទាំង ២២ រូបជាថ្មី ដើម្បីជាកិត្តិយសនឹងជាទីរឭកអស់កាលជ័យូរ គឺ:

| | | |
|---|---|---|
| ព្រះមោគ្គល្លានថេរ | ផ្លះនាមជា | ព្រះសិរិសង្ឃពោធិសាមិ |
| ព្រះកុមារកស្សបថេរ | » | ព្រះកិត្តិសិរិមេឃសាមិ |
| ព្រះញាណសាគរថេរ | » | ព្រះបរក្កមពាហុសាមិ |
| ព្រះពុទ្ធវង្សថេរ | » | ព្រះពុទ្ធឃោសសាមិ |
| ព្រះនន្ទថេរ | » | ព្រះសីហឡទីបវិសុទ្ធសាមិ |
| ព្រះរាហុលថេរ | » | ព្រះគុណរតនធរសាមិ |
| ព្រះសុមង្គលថេរ | » | ព្រះជិនាលង្ការសាមិ |
| ព្រះធម្មរក្ខិតថេរ | » | ព្រះរតនមាលីសាមិ |
| ព្រះបុទ្ឋសុមង្គលថេរ | » | ព្រះសទ្ធម្មតេជសាមិ |
| ព្រះកស្សបថេរ | » | ព្រះធម្មារាមសាមិ |
| ព្រះមណីសារថេរ | » | ព្រះភូរិនេកពាហុសាមិ |
| ព្រះមហាសិវលិថេរ | » | ព្រះតិលោកគុរុសាមិ |

| | | |
|---|---|---|
| ព្រះសារីបុត្តថេរ | ផ្លះនាមជា | ព្រះសិរីរតនសាមិ |
| ព្រះសុមនថេរ | » | ព្រះមង្គលថេរសាមិ |
| ព្រះបុទ្បកស្សបថេរ | » | ព្រះកល្យាណតិស្សសាមិ |
| ព្រះគុណសាគរថេរ | » | ព្រះវនវាសីតិស្សសាមិ |
| ព្រះជវនបញ្ញាថេរ | » | ព្រះរតនាលង្ការសាមិ |
| ព្រះបុទ្បសិរីលិថេរ | » | ព្រះមហាទេវថេរសាមិ |
| ព្រះធម្មរាជិកថេរ | » | ព្រះឧទុម្ពរគិរិសាមិ |
| ព្រះបន្ទនថេរ | » | ព្រះបុទ្បាភយតិស្សសាមិ |
| ព្រះបុទ្បនន្ទថេរ | » | ព្រះបន្ទគិរិសាមិ |
| ព្រះសោណុត្តរថេរ | » | ព្រះសិរិទន្តធាតុសាមិ |

ស្រេចការឧបសម្បទ នឹងព្រះរាជទាននាមព្រះថេរអំបាល នេះហើយ ទើបត្រាស់ឲ្យចាត់ចែងគ្រឿងរាជបណ្ណាការផ្សេង ៗ មានរូបព្រះសិរិទាឋ្ឋធាតុ នឹងពូជពោធិព្រឹក្សជាដើម ព្រមទាំងនាវាបញ្ជូនព្រះសង្ឃរាមញ្ញត្រឡប់មកព្រះនគរវិញ ។ កាលព្រះសង្ឃអំបាលនេះមកដល់ហើយ ព្រះចៅរាមាធិបតីក៏ទ្រង់

អាវាធនាឲ្យធ្វើកល្យាណីសីមា និងបារិកសិលាកល្យាណី ដូចពោលហើយខាងដើម ។ ក្នុងរជ្ជកាលនេះការព្រះសាសនារាប់ជា រុងរឿងម្ដង អំណឹសអំពីនោះមកព្រះពុទ្ធសាសនាក្នុងប្រ-ទេសភូមាក្ដី ក្នុងប្រទេសមនក្ដី មានតែត្រឹមគង់ទ្រង់ និងអាប់ឱនចុះដោយលំដាប់ ដោយហេតុគ្មានព្រះមហាក្សត្រនិងឧបត្ថម្ភដូចក្នុងកាលមុនៗ ទាំងវេលានេះ ប្រទេសទាំងពីរនេះធ្លាក់ទៅជាបំណុះប្រទេសដទៃផង ព្រះសាសនាស្ថិតនៅដោយអាស្រ័យកំឡាំងសទ្ធាជ្រះថ្លារបស់រាស្ត្រអ្នកស្រុកដែលធ្លាប់គោរពប្រតិបត្តិអំពីដូនតាមកហើយ ក៏នាំគ្នាបួសរៀនប្រតិបត្តិបន្តិចៗ តាមប្រវេណីដរាបដល់សព្វថ្ងៃនេះ ។៚—

# ឯកសហស្សរាត្រី

## ឬ

## មួយពាន់មួយយប់

### ក្រម្ការជុំ-ម៉ៅ ប្រែចេញពីភាសាបារាំងសែស

លុះទៅដល់មាត់ត្រពាំង អារក្ខប្រាប់ទៅតាចាស់ថា “ចូរឯងបង់ទៅ, ហើយចាប់ត្រីមក” តាចាស់មិនបារម្ភថាមិនបានត្រីឡើយ ព្រោះមើលទៅឃើញដេរដាសក្នុងទឹកត្រពាំងនោះ ប៉ុន្តែមកមានសេចក្ដីឆ្ងល់ជាទីបំផុត ដ្បិតត្រីនោះមាន ៤ ពណ៌ផ្សេងពីគ្នា គឺពណ៌ស, ក្រហម, ខៀវនឹងលឿង, តាចាស់ក៏ចាប់សំណាញ់គ្រវែងទៅ ហើយទាញមកវិញ បានត្រី ៤ គ្រប់ពណ៌ទាំងអស់, ដោយគាត់មិនដែលឃើញដូច្នេះសោះ គាត់ក៏អង្គុយសំឡឹងមើល ហើយស្មានក្នុងចិត្តថាមុខជានឹងលក់បានប្រាក់ច្រើនមិនខាន, គិតដូច្នេះហើយមានអំណរឥតឧបមា វេ-លានោះអារក្ខប្រាប់ទៅថា “ចូរឯងយកត្រីនេះទៅចុះ ហើយត្រូវឯងយកទៅថ្វាយស្ដេច ៗ នឹងព្រះរាជទានប្រាក់ឯងជាច្រើន

មិនខាន" ហើយឯងមកបង់ក្នុងទីនេះទៀតបានរាល់ថ្ងៃ ប៉ុន្តែអញហាមឯងទុក ឋាត្រូវបង់ ១ ថ្ងៃតែ ១ សំណាញ់ទេ លើសពីនេះទៅទៀតមិនបាន បើឯងមិនតាមពាក្យអញ នឹងកើតគ្រោះការមិនខាន ត្រូវឯងប្រុងប្រយ័ត្នឲ្យមែនទែន, អញហាមតែប៉ុណ្ណោះ បើឯងប្រតិបត្តិតាមនឹងបានសេចក្ដីសុខអស់កាលជាអង្វែងតរៀងទៅ" ឋាដូច្នេះហើយក៏ទន្ត្រាំដីព្រឹប ៗ ដីក៏បែកញែកឡើង លុះអារក្ខបុះផុតទៅ ដីក៏ជិតទៅវិញក្នុងខណនោះឯង ។

តាចាស់ទើបប្ដេជ្ញាចិត្តនឹងធ្វើតាមបណ្ដាំអារក្ខមិនឲ្យឆ្គងគឺមិនហ៊ានបង់ ១ សំណាញ់ថែមទៀតឡើយ រួចត្រឡប់តាមផ្លូវដដែលទៅលំនៅអាត្មាវិញ ដោយសេចក្ដីត្រេកអររីករាយជាជ-ភាប ហើយពិចារណាតាមផ្លូវ ១ពាន់ ១ម៉ឺនយ៉ាងអំពីរឿងរបស់ខ្លួននោះឯង ។ លុះបានទៅដល់ក្នុងក្រុងហើយ គាត់មិនបានចូលទៅឯផ្ទះ គាត់យួរឯត្រីនោះបង្ហួសដំរង់ទៅឯព្រះរាជវាំងវិញ ដើម្បីយកទៅថ្វាយដល់ស្ដេច ។

ឯស្ដេចនោះបានឃើញត្រីប្លែកជាទីអស្ចារ្យដូច្នោះក៏ទ្រង់ចាប់មកសង្កេតពិនិត្យ ១ ម្ដង ៗ លុះបានពិនិត្យ ១ ស្របក់ទើបទ្រង់ប្រគល់ឲ្យទៅមហាមាត្យ ដោយទ្រង់ព្រះដំរាស់ថា "ចូរមហាមាត្យឯងយកទៅឲ្យសត្រីនាយពិសេសដែលស្ដេចស្រុកក្រិកបានសម្រិងរើសផ្ញើមកអញ ដើម្បីនឹងធ្វើក្រយាស្ងោយឲ្យអញ អញសង្ឃឹមថាត្រីនេះច្បាស់ជាមានរស់ពិសារក្រៃលែងត្រឹងទៀតតាមដែលបានពិនិត្យដល់រូបរាងរបស់វា" មហាមាត្យបានទទួលត្រីនោះ ហើយយកទៅប្រគល់ដល់ដៃសត្រីនាយពិសេសដោយខ្លួនឯង ហើយប្រាប់ថា "ត្រីទាំង ៤ នេះគេទើបនឹងយកមកថ្វាយ. ស្ដេចត្រាស់បង្គាប់ឲ្យយកមកបំអិនធ្វើក្រយាស្ងោយ" ប្រគល់ឲ្យស្រេចក៏ត្រឡប់ទៅគាល់ស្ដេចវិញ ទើបស្ដេចត្រាស់បង្គាប់ឲ្យយករូបិយមាស ៤០០ រៀលប្រគល់ឲ្យទៅតានេសាទម្ចាស់ត្រី ៗ តាម្ចាស់ត្រីគ្រាដែលបានទទួលប្រាក់ហើយ ក៏នឹកមមៃតែក្នុងចិត្ត មិនដឹងជាខ្លួនបានប្រាក់មែនទែន ឬគ្រាន់តែស្រមៃយល់សព្វទេ ព្រោះមិនដែលបានកាន់ប្រាក់ច្រើនដូច្នេះ

ម្តងសោះ លុះតែបានយកប្រាក់នោះទៅបំណាយក្នុងកិច្ចការផ្សេងៗឯផ្ទះ ទើបបានប្បាស់ក្នុងចិត្តអំពីភ័ពស័ណាងរបស់ខ្លួន។

ដល់មកត្រង់កន្លែងនេះ នាងសែរាសាដក្រាបទូលទៅស៊ុលតង់សារ្យាថា "បពិត្រព្រះករុណាជាអម្ចាស់, ខ្ញុំម្ចាស់បានហ្វាយរឿងអ្នកនេសាទនេះរួចហើយ ត្រូវខ្ញុំម្ចាស់និយាយអំពីសត្រីនាយពិសេសផង ព្រោះរឿងនេះតទៅនឹងមានសេចក្តីប្លែកអស្ចារ្យណាស់, នាងនាយពិសេសនោះ កាលបានលាងសំអាតត្រីទាំង ៤ ហើយ ក៏ដាក់ចៀនក្នុងខ្ទះទៅ លុះឆ្អិន ១- បំហៀងហើយ ក៏ប្រែត្រឡប់ទៅ ១ បំហៀងទៀត ទើបតែនឹងត្រឡប់ស្រេច ស្រាប់តែជញ្ជាំងរោងពិសេសប្រែះបើកឡើងលេចឯសត្រីម្នាក់រូបឆោមល្អផើតឆាយចេញពីក្នុងនោះមកនាងនោះស្លៀកពាក់សុទ្ធព្រៃ រំលេចដោយផ្កាដេរជាសបែបស្រុកឥស៊ីប្ត, ពាក់រយ៉ាពេជ្រនឹងខ្សែករប្រដាប់ដោយកែវមុក្តាពាក់កងដាំត្បូងទទឹមនៅដៃទាំងសងខាង ហើយកាន់បង្កើសត្រាំង ១ គូដើរចូលទៅប្របខ្ទះ, រីនាងនាយពីសេសឃើញដូច្នោះ

ក៏ភាន់ភាំងស្មារតីសាំងស្ងៀមនៅពុំនាំពា សត្រីកាន់បង្កើសនោះ យកបង្កើសគោះក្បាលត្រី ១ ហើយសួរថា "នែមបា, ឯងកំ-ពុងជាប់កិច្ចរវល់ឬ?" លុះមិនឮត្រីឆ្លើយក៏សួរពាក្យដដែលម្តងទៀត ក្នុងវេលានោះត្រីទាំង ៤ ងើបក្បាលឡើង ឆ្លើយប្រាប់ទៅវិញដោយសំឡេងក្បោះក្បាយថា "បាទ,បាទ, កំពុងជាប់កិច្ច, ប៉ុន្តែបើអ្នកចេញថ្លៃ យើងចេញថ្លៃដែរ, បើអ្នកសងបំណុលគេ យើងសងបំណុលគេដែរ, បើអ្នកគេបរត់ យើងមានជ័យជំនះ ហើយយើងសប្បាយចិត្ត" ត្រីនិយាយដូច្នេះហើយ សត្រីនោះក៏ចាប់ខ្ទះជៀនផ្កាប់ទៅក្នុងភ្លើង ហើយចេញតាមកន្លែងនោះទៅវិញបាត់ទៅ ឯជញ្ជាំងដែលប្រែះរបើកក៏ជិតដូចដើមវិញ ។

ក្នុងគ្រានោះសត្រីនាយពិសេសបានដឹងស្មារតីភ្ញាក់ខ្លួនឡើងវិញ ទើបស្ទុះទៅចាប់ទាញយកត្រីពីក្នុងភ្លើងបង្ក្រានមកតែត្រីនោះខ្លោចខ្មៅទៅជាធ្យូងអស់ នឹងកែកុនរៀបក្រយាស្ងោយថ្វាយស្តេចមិនកើត ។ នាងនោះកើតទុក្ខអម្ពេញឥតឧបមាអង្គុយទ្រហោយំអស់ទំហឹងថា "ឱម្ចាស់ថ្លៃខ្ញុំអើយ, ខ្លួនខ្ញុំនេះ

មិនដឹងជាទៅជាអ្វីទេ បើទុកជាខ្ញុំយកសេចក្ដីក្រាបទូលស្ដេចៗ ក៏មិនជឿតាម ម្លោះហើយសំព្រះអង្គទ្រង់ព្រះភិរោធនឹងខ្ញុំមិនខាន"

កំពុងតែខ្សឹកខ្សួលតែម្នាក់ឯង ស្រាប់តែលេចមហាមាត្យមកសួរថាត្រីនោះឆ្អិនហើយឬនៅ, នាងក៏សារសព្វសេចក្ដីជំរាបមហាមាត្យគ្រប់ប្រការ ឯមហាមាត្យកើតសេចក្ដីជឿងឆ្ងល់ណាស់ តែមិនបានយករឿងក្រាបទូលស្ដេចតាមដំណើរ រកឯហេតុដទៃផ្សេងទូលបន្លប់ឲ្យបានស្រួលព្រះរាជហឫទ័យវិញ ។ ក្នុងវារៈនោះក៏ចាត់បំរើឲ្យទៅតាមយកខ្លួនតាបាស់មកហើយប្រាប់ថា "ម្នាលនេសាទ, ចូរឯងរកត្រីឲ្យអញ ៤ ទៀត ឲ្យបានដូចត្រីពីមុន ដ្បិតត្រីមុននោះគេធ្វេសប្រហេសធ្វើឲ្យខូចមិនបានបំអិនថ្វាយជាក្រយាស្ងោយ" តានេសាទមិនបានបរិយាយអំពីរឿងអារក្ខផ្ដាំថាឲ្យបង់តែ ១ សំណាញ់ក្នុង ១ ថ្ងៃ យកឯរឿងផ្សេងមកជំរាបកែដោះសារវិញ ថាផ្លូវនោះឆ្ងាយដាច់ស្រយាលណាស់នឹងទៅរកមកមិនទាន់ សន្យាដល់ថ្ងៃស្អែក.ទើបរកមកជូនឲ្យបាន ។

តានេសាទចេញពីផ្ទះទៅតាំងពីយប់ ឆ្ពោះទៅត្រពាំងនោះឯង ហើយបានបង់សំណាញ់ចុះលុះទាញឡើងវិញ បានត្រី ៤ ពណ៌ផ្សេងគ្នាទាំងអស់ដូចកាលជាន់មុនទៀត គាត់ក៏ត្រឡប់ទៅវិញ ហើយយកត្រីទៅប្រគល់ជូនមហាមាត្យនូវពេលដែលបានណាត់ទុក ។ មហាមាត្យយកត្រីនោះចូលទៅរោងពិសេសហើយអង្គុយចាំពិនិត្យមើលជាមួយនឹងសត្រីនាយពិសេសដាក់ត្រីលើខ្ទះជៀនដូចជាន់មុន លុះឆ្អិន ១ ចំហៀងរួចត្រឡប់ប្រែ ១ ចំហៀងទៀត ខណៈនោះជញ្ជាំងរោងពិសេសប្រែរបើកឡើង ហើយសត្រីដដែលកាន់បង្គោលចេញមកទៀត ដើរចូលទៅជិតខ្ទះជៀននិយាយពាក្យដដែលដូចពីមុន. ឯត្រីក៏ងើបក្បាលឡើងឆ្លើយតបដូចកាលពីមុននោះទៀត ។

សត្រីនោះក៏លើកខ្ទះផ្កាប់ទៅលើភ្លើង ហើយចេញទៅតាមប្រហោងជញ្ជាំងវិញដូចជាន់មុន ។ ឯមហាមាត្យលុះបានឃើញជាក់នឹងភ្នែកអាត្មាដូច្នេះហើយ ក៏និយាយនឹងនាងពិសេសថា "រឿងនេះអស្ចារ្យចំឡែកណាស់គួរឲ្យឆ្ងល់ ខ្ញុំត្រូវយក

សេចក្តីក្រាបទូលដល់ស្តេចឲ្យទ្រង់ជ្រាបអំពីរឿងនេះ" ថាតែប៉ុណ្ណោះក៏ក្រោកដើរចេញទៅ ក្រាបទូលដល់ស្តេចគ្រប់ប្រការ ។

គ្រានោះស្តេចមានសេចក្តីសន្ទិះសង្ស័យជាខ្លាំង ដើម្បីឲ្យច្បាស់ហេតុដោយព្រះអង្គឯង, ទ្រង់ក៏ត្រាស់ឲ្យទៅហៅតានេ-សាទឲ្យចូលមក, លុះតានេសាទមកដល់ស្តេចសួរថា "នែនេ-សាទ, តាឯងរកត្រី៤ពណ៌នេះឲ្យអញបានទៀតឬទេ?" តាចាស់ក្រាបទូលថា "បើព្រះករុណាជាអម្ចាស់អនុញ្ញាតឲ្យទូលព្រះបង្គំរកដល់៣ថ្ងៃ នោះទូលព្រះបង្គំជាខ្ញុំហ៊ានសន្យាថ្វាយ ថាច្បាស់ជានឹងរកថ្វាយបានមិនខានឡើយ." ស្តេចក៏ព្រមអនុញ្ញាតឲ្យ ។

លុះដល់ថ្ងៃសន្យា តាចាស់ស្ទាយសំណាញ់ទៅកន្លែងដដែល បង់បានត្រីទាំង៤ពណ៌នោះមកទៀត ហើយយកទៅថ្វាយស្តេចតាមសន្យា ស្តេចមានសេចក្តីសោមនស្ស ទើបព្រះរាជទានប្រាក់៤០០រៀលទៀតឲ្យតានេសាទ ។

លុះបានត្រីហើយ ស្តេចបង្គាប់ឲ្យយកទៅក្នុងបន្ទប់ព្រះ-អង្គ ហើយឲ្យយកគ្រឿងប្រដាប់សម្រាប់ចៀនទាំងប៉ុន្មានទៅ

ក្នុងទីនោះ, ព្រះអង្គទ្រង់គង់ចាំមើលត្រីជាមួយនឹងមហាមាត្យ ។ កាលណាមហាមាត្យជៀនឆ្អិនម្ខាងហើយ ក៏ចាប់ត្រឡប់ទៅម្ខាងទៀត. ខណៈនោះជញ្ជាំងបន្ទប់ប្រេះបើក ហើយលេចឯមនុស្សខ្មៅម្នាក់ធំសំបើម កាន់ដំបង ១ ធំនៅដៃដើរចូលមក. មិនឃើញស្ត្រីទន់ភ្លន់ដូចជាន់មុនទេ ។ មនុស្សខ្មៅនោះលុះដើរចូលមកជិតខ្ទះជៀនក៏យកដំបងគោះក្បាលត្រី ហើយបន្លឺនូវសំឡេងលាន់ខ្ទរសួរទៅត្រីថា "ម្នាលត្រី, ឯងកំពុងជាប់កិច្ចរវល់ឬ" សួរតែប៉ុណ្ណោះ ត្រីក៏ងើបក្បាលឡើងឆ្លើយថា "បាទ, យើងទាំងអស់គ្នាជាប់កិច្ចរវល់, ប៉ុន្តែបើអ្នកចេញថ្លៃ យើងក៏ចេញដែរ, បើអ្នកសងបំណុល, យើងក៏សងបំណុលដែរ, បើអ្នកគេចរត់ យើងមានជ័យជំនះ ហើយយើងសប្បាយចិត្ត"

ត្រីនិយាយស្ទើមិនទាន់ផុត មនុស្សខ្មៅក៏ចាប់ខ្ទះជៀនផ្កាប់ទៅលើភ្លើងបង្កាត់ខ្លោចទៅជាធ្យូងអស់ទៅ រូបបិយគឃ្លើនតាមប្រេកដែលចេញមក ឯជញ្ជាំងនោះក៏ជិតដូចដើមវិញ ។ ក្នុងគ្រានោះស្ដេចមានបន្ទូលទៅនឹងមហាមាត្យថា

“ម្នាលមហាមាត្យ, តាមដែលអញបានឃើញអម្បាញ់មិញនេះ អញមិនអាចនឹងដំរង់ចិត្តឲ្យស្ងៀមនៅជាសុខបានឡើយ, ត្រីទាំងប៉ុន្មាននេះប្រហែលជាមានបើអ្វីម្យ៉ាងៗ មិនលែង មួយទៀតអញចង់ដឹងឲ្យប្រាកដណាស់” រួចស្ដេចមានព្រះដម្រាស់ឲ្យហៅខ្ជតតានេសាទចូលមកគាល់ៗ លុះតាចាស់ចូលមកដល់ស្ដេចមានព្រះបន្ទូលសួរថា “នែនេសាទ, ត្រីទាំងប៉ុន្មានដែលឯងបានយកមកឲ្យអញ នាំឲ្យអញមានសេចក្ដីសន្ទ័ះសង្ការពន់ប្រមាណណាស់ តើឯងទៅចាប់ពីទីណាមក” តានេសាទក្រាបទូលថា “បពិត្រព្រះករុណាថ្លៃវិសេស សូមទ្រង់ជ្រាបក្រោមល្អងធូលីព្រះបាទ, ទូលព្រះបង្គំចាប់មកពីក្នុងត្រពាំង ១ នៅជាបន្លោះភ្នំ ៤ ដែលយើងមើលឃើញពីនេះទៅ” ស្ដេចសួរទៅមហាមាត្យថា “ឯងដែលស្គាល់ត្រពាំងនោះដែរឬទេ” មហាមាត្យក្រាបទូលថា “ទូលព្រះបង្គំបានទៅបរបាញ់សត្វលេងនាទីជិតភ្នំនោះប្រហែល ៦០ ឆ្នាំហើយ តែមិនដែលឃើញត្រពាំងនោះសោះ ហើយមិនដែលទាំងឮគេនិយាយផង” ស្ដេច

មានព្រះបន្ទូលសួរទៅនេសាទទៀតថា "ពីវាំងអញទៅត្រពាំងនោះ បើដើរដោយជើងចំនួនប៉ុន្មានម៉ោងដល់" តាចាស់ក្រាបទូលថាប្រហែល ៣ ម៉ោងប៉ុណ្ណោះឯង ។ ដូចជាវេលានោះនៅថ្ងៃនៅឡើយ ស្ដេចត្រាស់បង្គាប់ឲ្យរៀបទីនាំងអស្សុត្ដរជាប្រញាប់ យាងចេញទៅជាមួយនឹងសេនាមាត្យដ៏ច្រើន យកតានេសាទជាមគ្គនាយក់នាំផ្លូវផង ដើម្បីឲ្យបានដល់ទៅទីនោះមុនអស្ដង្គត ។

លុះស្ដេចមកដល់ភ្នំ ១ ក៏ឆ្លងកាត់ខ្នងភ្នំនោះទៅ ស្រាប់តែឃើញវាលវែង ១ ធំទូលាយគួរជាទីអស្ចារ្យ ដែលមនុស្សប្រមិនដែលឃើញសោះ ស្ដេចទៅពីនោះបន្តិចទៅ ក៏ដល់ត្រពាំងធំ ១ នៅជាចន្លោះភ្នំទាំង ៤ ដូចពាក្យតានេសាទទូលមែន. ក្នុងត្រពាំងនោះមានទឹកថ្លាស្អាត ហើយមើលឃើញត្រីទាំងអស់សុទ្ធតែដូចត្រីដែលតាចាស់បានយកទៅថ្វាយ ។ ស្ដេចបានទៅពិនិត្យត្រីលើមាត់ត្រពាំងនោះ ១ វេលា ទើបមានព្រះឱង្ការនឹងសេវកាមាត្យរាល់គ្នា ថាយើងមិនគួរជាមិនដែលស្គាល់ត្រពាំង

ដែលនៅជិតទីក្រុងនេះសោះ សេនារាល់គ្នាក៏ទូលតបថា ទាំងអស់គ្នាមិនដែលបានឮអ្នកណានិយាយម្ដងអំពីត្រពាំងនេះ ទើបស្ដេចមានព្រះឌីម្រាស់ថា "បើអ្នករាល់គ្នាមិនដែលដឹង មិនដែលឮគេនិយាយពីត្រពាំងប្ញឹនេះដូច្នោះ ខ្លួនអញក៏ឆ្ងល់ណាស់. មួយទៀតអញតាំងចិត្តថាមិនត្រឡប់ទៅនគរវិញ ជាមុនដែលបានដឹងច្បាស់នៃរឿងរ៉ាវរបស់ត្រពាំងនេះ និងត្រីទាំង ៤ ពណ៌នោះឯង." មានព្រះបន្ទូលតែប៉ុណ្ណោះ ហើយត្រាស់បង្គាប់ឲ្យបោះបារាំងជាព្រះពន្លា នៅលើមាត់ត្រពាំងក្នុងគ្រានោះ ។

លុះចូលរាត្រីមកស្ដេចយាងចូលក្នុងព្រះពន្លា ហើយទ្រង់មានព្រះបន្ទូលនឹងមហាមាត្យថា "មហាមាត្យ. អញមានសេចក្ដីបរិវិតកជាខ្លាំងអំពីត្រពាំងទើបមានក្នុងទីនេះផង អំពីមនុស្សខ្មៅចូលទៅក្នុងបន្ទប់ដែលយើងបានឮសំដីនិយាយផង រឿងទាំងនេះបណ្ដាលឲ្យអញចង់ដឹងដើមឫសពន់ពេកណាស់ អញនឹងទប់ទល់នៅស្ងៀមកន្ដើយពុំបាន អញបានគិតជាស្រេចថានឹងភៀសខ្លួនចេញទៅតែម្នាក់ឯង ត្រីវងងនៅ

រក្សាទីកន្លែង កុំប្រាប់អ្នកឯណាឲ្យដឹង ១ ជា ២ ។ លុះព្រឹកស្អែកឡើង បើសេនាយោធារាល់គ្នាចូលមកគាល់ ត្រូវឯងពោលបញ្ឆោតថាអញមានសេចក្ដីវិតកបន្តិច ចង់នៅស្ងាត់តែម្នាក់ឯង ហើយឲ្យវាត្រឡប់ទៅវិញចុះ ដល់ថ្ងៃក្រោយត្រូវឯងនិយាយដូចដែលទៀត ដរាបដល់អញត្រឡប់មកវិញ" ។

មហាមាត្យ ក្រាបទូលឃាត់ជាច្រើនដងមិនឲ្យស្ដេចចេញ ក្រែងមានអន្តរាយក្នុងទីស្ងាត់នោះ ប៉ុន្តែទូលទាស់យ៉ាងណាក៏ឥតអំពើ ព្រោះស្ដេចមិនព្រមលះបង់ព្រះដំរិះដែលទ្រង់បានគិតទុកជាមុននោះ ហើយក៏រៀបចំព្រះអង្គនឹងយាងបាទចេញទៅ យកតែព្រះសែងថ្លា ១ សៀតជាប់នឹងព្រះអង្គ ដល់ពេលស្ងាត់ទ្រង់ក៏យាងចាកព្រះពន្លាឥតមានយកអ្នកណាតាមហែជាមួយផង ។

ទ្រង់សីហនាទសំដៅទៅភ្នំ ១ ហើយយាងឡើងទៅលើភ្នំនោះ ដោយសេចក្ដីលំបាកនឿយហត់ជាខ្លាំង ទ្រង់ឆ្លងកាត់ខ្នងភ្នំនោះលេចទៅក្នុងវាល ១ ហើយដល់ពេលអរុណរះឡើង ទើបទ្រង់ប្រទះឃើញផ្ទះ១ធំ ទ្រង់មានសេចក្ដីសោមនស្សក្នុង

គ្រានោះពន់ពេកណាស់ ដោយសង្ឃឹមថានឹងបានជ្រាបហេតុភេទមិនខាន ៗ លុះយាងចូលទៅជិត ឃើញជាប្រាសាទ ១ ស្តុកស្តុំស្កឹមស្កៃស្អធើត ដ៏ប្រដាប់ដោយថ្លើមថ្មខ្មៅរលោងស្រិល ប្រកដោយដែកថែបយ៉ាងឯកភ្លឺផ្លេកដូចកញ្ចក់. ស្តេចក៏សង្កេតនូវក្បូរក្បាច់រំលេចនាជញ្ជាំងថៃវក្រៅ រួចយាងរហូតទៅដល់ទ្វារថៃវ ឃើញទ្វារនោះមានស្លាប ២ បើកម្ខាងបិទម្ខាង ៗ មុននឹងចូលទៅខាងក្នុង ស្តេចបានគោះទ្វារសិន, ដើមឡើយទ្រង់គោះយ៉ាងស្រាល តែមិនឃើញមានមនុស្សចេញមកសោះ ទើបគោះម្តងទៀតខ្លាំងបន្តិច ដោយទ្រង់ស្មានថាក្រែងគេមិនឮ លុះគ្មានឃើញមនុស្សម្នាក់ចេញមកសោះ ស្តេចក៏គោះយ៉ាងខ្លាំងម្តងទៀត ជាន់ក្រោយនេះក៏នៅតែមិនឃើញមានមនុស្សចេញមក ស្តេចមានសេចក្តីសង្ស័យក្នុងវេលានោះមុះហិមា ដោយទ្រង់ពិចារណាថាប្រាសាទធំហើយស្អាតយ៉ាងនេះ មិនសំជាគ្មានមនុស្សនៅ, ទើបទ្រង់ព្រះដំរិះថា "បើទុកជាគ្មានមនុស្សក៏អញឥតខ្លាច ហើយបើប្រសិនជាមានមនុស្សមកក៏អញមានគ្រឿងប្រដាប់នឹងការពារខ្លួនអញ"

ទ្រង់ព្រះដំរិះដូច្នេះហើយ ក៏យាងចូលទៅតាមទ្វារថែវនោះ ឯងដ៏រាបដល់ទីធ្លា ១ ទើបទ្រង់មានព្រះបន្ទូលតែ ១ ព្រះអង្គឯង ថា "នៅទីនេះគ្មានមនុស្សសំរាប់ទទួលអ្នកដំណើរដែលត្រូវការជ្រកអាស្រ័យ ១ វេលាទេឬ?" ទ្រង់មានព្រះបន្ទូលដ៏ដែលនេះ ៣-៤ ដងទៀតយ៉ាងខ្លាំងៗ តែគ្មានឮមាត់មនុស្សម្នាក់ឆ្លើយតបសោះ ។ ហេតុដែលស្ងៀមស្ងាត់សូណ្យដូច្នេះ បណ្ដាលឲ្យទ្រង់មានព្រះវិតកជាខ្លាំង ខណៈដែលទ្រង់យាងកាត់ឆ្លងទីធ្លាធំនោះ ទ្រង់ងាកឆ្វេងងាកស្ដាំរកមើលក្រែងឃើញមានមនុស្សនៅក្នុងទីនោះ លុះផុតទីធ្លាទៅទ្រង់យាងចូលទៅក្នុងមហាមណ្ឌីរ ដែលក្រាលពាសពេញដោយព្រែព្រំជាទ្រនាប់ជើង ហើយមានទាំងបង្អួចប្រដាប់សុទ្ធតែរនាំងព្រែយ៉ាងល្អអំពីស្រុកក្លឹង ផុតពីទីនោះទៅទ្រង់យាងទៅដល់បន្ទប់ "អស្ចារ្យ" នៅកណ្ដាលបន្ទប់នោះមានស្រះ ១ មារូបរាជសីហឈរគ្រប់ជ្រុងទាំង ៤ ហើយមានទឹកហូរចេញពីមាត់ ទឹកដែលហូរធ្លាក់មកកើតទៅជាត្បូងពេជ្រនឹងកែវមុក្ដា ធ្លាក់ខ្ចាយឡើងទៅលើស្មើរនឹងដល់ជម្សូល ។

ប្រាសាទនោះមានសួនឧទ្យានព័ទ្ធគ្រប់ទិសទាំង ៣ ហើយមានផ្លូវខ្វាត់ខ្វែង មានស្រះមានដំណាំនឹងផ្កាគ្រប់បែបយាងប្រ-ឡូងលំអគ្នា, ប៉ុន្តែដើម្បីញាំងទីនោះឲ្យរឹតតែសប្បាយគួរគន់ទៅទៀត នោះគឺមកពីបក្សីគ្រប់ភាសាបន្លឺនៅសម្រែកអឺងអាប់សព្ទសាំនតាមភាសាទីទៃ ៗ នៅជានិច្ចក្នុងទីនោះ ព្រោះមានរនាំងលួសព័ទ្ធព័ទ្ធជុំវិញពីក្រៅដើមឈើទាំងអស់ មិនឲ្យបក្សីទាំងនោះហើរចេញចាកទីកន្លែងសួនបាន ។

គ្រានោះស្ដេចយាងពីបន្ទប់ ១ ទៅបន្ទប់ ១ ដ៏ប្រិដាប់ប្រិដាផតមានខ្ពស់ដោយរបស់សុទ្ធសឹងមានដំឡៃ, លុះទ្រង់នឿយព្រះកាយក៏ឈប់សម្រាកព្រះអង្គត្រង់កន្លែង ១ មានបង្អួចបំហរឆ្ពោះទៅសួនឧទ្យាន ហើយរបនាប្រិដាប់ប្រិដាដូច ៗ គ្នា, យូរបន្តិចឮស្នូរសំឡេងប៉ុញប៉ូវគួរសង្វេគអនិច្ចា មកប៉ះពាល់ដល់សោតបសាទ ទ្រង់ក៏ផ្ទៀងព្រះកម្មទាំងសងស្ដាប់ ហើយបានឮជាក់ស្ដែងជាពាក្យប៉ុញប៉ូវថា "ឱភ័ពសំណាងើយ, បើឯងមិនឲ្យអញត្រអាលសប្បាយយូរទេ, ឯងធ្វើឲ្យអញរងកម្មវេទនា

ជាងមនុស្សទាំងអស់ដូច្នេះហើយ ក៏ចូរឯងកុំទុកជីវិតអញឲ្យនៅរស់យូរឯងទុក្ខវេទនាឡើយ, ចូរឯងផ្តួលផ្តាច់ជីវិតអញឲ្យដាច់ ដើម្បីឲ្យផុតអំពីទុក្ខទាំងនេះ ឱព្រះម្ចាស់ថ្លៃខ្ញុំអើយ, ចុះគួរឲ្យខ្ញុំនៅរស់ដល់ណាទៀត បើខ្ញុំសោយទុក្ខវេទនាយ៉ាងដូច្នេះ"

ដោយទ្រង់មានសេចក្តីអាសូរដល់សំដីប្តូញប្តូរនោះពេកណាស់ ក៏ទ្រង់ក្រោកឡើង ហើយយាងឆ្ពោះទៅកន្លែងដែលឮសំឡេងនោះ លុះយាងទៅដល់ទ្វារបន្ទប់ ១ ទ្រង់បើកទ្វារនោះឡើង ស្រាប់តែឃើញមនុស្សជំទង់ម្នាក់រូបស្អាតបាត ប្រដាប់កាយដោយរបស់មានដំឡៃ អង្គុយលើអាសនៈ ១ ដ៏ខ្ពស់ឡើងពីផ្ទៃដី ទំនងជាមនុស្សមានទុក្ខមែន ស្តេចក៏យាងចូលទៅជិតហើយគំនាប់ទៅមនុស្សនោះ, ឯមនុស្សជំទង់ក៏ឱនសិរសាយ៉ាងទាបគំនាប់តបមកវិញ ហើយដោយខ្លួនមិនបានក្រោកចុះពីទីអាសនៈ ក៏ពោលពាក្យថា "បពិត្រលោកម្ចាស់, សូមលោកអត់ទោសដល់ខ្ញុំ, ខ្ញុំយល់ឃើញថាគួរណាស់តែក្រោកទៅទទួលលោក ហើយគោរពដោយកិរិយាប្រពៃ, ប៉ុន្តែខ្ញុំធ្វើ

កិច្ចនោះមិនបានឡើយ ព្រោះមានហេតុជាធំហួសកំឡាំង ខាំងមិនឲ្យខ្ញុំសម្រេចបាន. សូមលោកម្ចាស់ កុំយល់ថាខ្ញុំជាមនុស្សជួអសប្បុរសឡើយ"— វេលានោះស្ដេចមានព្រះបន្ទូលតបវិញថា "ខ្ញុំមានសេចក្ដីសោមនស្សណាស់ទៅហើយ ដោយបានឃើញអ្នកមានសេចក្ដីរោះរាយដល់ខ្ញុំ រឿងដែលអ្នកសូមទោសខ្ញុំ ព្រោះមិនបានក្រោកទទួលនោះ ចូរអ្នកកុំបារម្ភ ខ្ញុំគិតប្រកាន់ថាអ្វីឡើយ ខ្ញុំបានឮសំឡេងអ្នកថ្ងូរញថ្ងូរអំពីសេចក្ដីទុក្ខវេទនា ខ្ញុំក៏មានចិត្តអាណិតអ្នកពន់ប្រមាណ ទើបខ្ញុំចូលមកដើម្បីជួយសង្គ្រោះអ្នកឲ្យរួចចាកទុក្ខ តាមកំឡាំងដែលខ្ញុំជួយបាន ហើយខ្ញុំសង្ឃឹមថាអ្នកមុខជាពណ៌នារឿងរបស់អ្នកប្រាប់ខ្ញុំមិនខាន ប៉ុន្តែមុននឹងនិយាយរឿងនោះ ខ្ញុំសូមឲ្យអ្នកប្រាប់ខ្ញុំសិនពីត្រពាំងធំនៅជិតទីនេះដែលមានត្រី ៤ ពណ៌ផ្សេងគ្នា តើមានហេតុភេទដូចម្ដេច ហើយប្រាសាទនេះជាប្រាសាទអ្វី, គេសាងពីក្នុងគ្រាណា, ហេតុអ្វីបានជាអ្នកមកនៅក្នុងប្រាសាទនេះតែម្នាក់ឯង" បុរសនោះបានឮពាក្យសួរទាំងប៉ុន្មាននេះហើយ

ក៏ខ្សឹកខ្សួលឡើងក្នុងវេលានោះ មានវាចាថា "ឱវាសនាមនុស្សយើងនេះជារបស់ប្រែប្រួលណាស់, អាចរុញមនុស្សឱ្យខ្ពស់ឡើងហើយទាញទំលាក់ឱ្យទាបចុះវិញបាន, នរណាមួយដែលអាចសោយសុខបានអស់កាលជានិច្ច" ។

ឯស្ដេចនោះបានឮវាចាដូច្នេះ ក៏កើតធម្មសង្វេគពន់ពេក ទើបទ្រង់មានព្រះបន្ទូលសួរហេតុដែលនាំឱ្យកើតទុក្ខធ្ងន់នោះ មនុស្សជើទង់ឆ្លើយតបវិញថា "ឱម្ចាស់ខ្ញុំអើយ, ចុះមិនឱ្យខ្ញុំកើតទុក្ខដូចម្ដេចបាន ទុក្ខរបស់ខ្ញុំនេះធ្ងន់ពេកណាស់ គ្មានអ្នកឯណាជួយឱ្យរួចឡើយ" ថាតែប៉ុណ្ណោះបុរសនោះក៏បើកជាយអាវឡើងបង្ហាញទៅស្ដេច ហើយថាខ្លួននេះជាមនុស្សតែពីត្រឹមក្បាលចុះមកដល់ចង្កេះប៉ុណ្ណោះទេ ចុះពីចង្កេះទៅសុទ្ធតែប្លើមថ្មទាំងអស់ ។

វេលានោះស្ដេចមានសេចក្ដីធ្ងល់ឥតឧបមា ទើបទ្រង់មានព្រះបន្ទូលទៅនឹងបុរសនោះទៀតថា "ដែលអ្នកបង្ហាញខ្ញុំអម្បាញ់មេញនេះនាំឱ្យខ្ញុំព្រឺសិរសាពន់ពេក តែសេចក្ដីព្រឺនេះ

ក៏រឹងរិតតែនាំខ្ញុំឲ្យចង់ដឹងរឿងរបស់អ្នកទៅទៀត ព្រោះជារឿងបំឡែកបន្លោះមិនដែលប្រទះឃើញ មួយទៀតខ្ញុំនឹកស្មានថាឯត្រពាំងនឹងត្រីនោះ ក៏គង់មានរឿងប្លែកអស្ចារ្យណាស់ដែរ, បើដូច្នេះខ្ញុំសូមអង្វរអ្នកដោយស្មោះសរ សូមឲ្យអ្នកអធិប្បាយប្រាប់ខ្ញុំឲ្យសព្វគ្រប់បើអ្នកនិយាយប្រាប់ខ្ញុំ ខ្ញុំនឹងព្យាយាមធ្វើឲ្យអ្នកបានសេចក្ដីសម្រាកទុក្ខខ្លះមិនខាន" វេលានោះបុរសជុំទង់ឆ្លើយតបវិញថា "ខ្ញុំនឹងពណ៌នាជូនលោកស្ដាប់មិនខាន ថ្វីបើរឿងនេះនិយាយទៅហើយនាំឲ្យខ្ញុំបានទុក្ខជាថ្មីទៀត ប៉ុន្តែសូមឲ្យលោកប្រុងត្រចៀកទាំង ២ នឹងស្មារតី ដើម្បីកត់សំគាល់នូវសេចក្ដីដែលលោកបានស្ដាប់ទាំងប៉ុន្មាន ទោះបីសេចក្ដីនោះជាការហួសធម្មតា, ហួសគំនិតដូចម្ដេចក្ដី"

## រឿងស្ដេចក្មេងនៅនគរកោះខ្មៅ

"លោកក៏ប្រហែលជាបានជ្រាប កាលដើមព្រះវររាជបិតាខ្ញុំដែលទ្រង់ព្រះនាមថាព្រះបាទម៉ាហ្មូទ គ្រងរាជសម្បត្តិនៅទីនេះគឺនគរកោះខ្មៅនេះឯង ដែលយកឈ្មោះតាមភ្នំតូចៗ ទាំង ៤

ព្រោះភ្នំទាំង ៤ នេះនៅបំជ្រុងកោះទាំង ៤ អុម ទីក្រុងរបស់ព្រះបិតាខ្ញុំបានតាំងបំកន្លែងដែលក្លាយទៅជាត្រពាំងធំជួបលោកបានឃើញនោះឯង ។

ព្រះវរបិតាខ្ញុំទ្រង់ទិវង្គតក្នុងព្រះជន្ម ៧០ ឆ្នាំ ហើយខ្ញុំបានទទួលគ្រប់គ្រងរាជសម្បត្តិនោះតមក បានយកអគ្គមហេសីក្រោយទទួលរាជាភិសេកបន្តិច ។ សត្រីដែលខ្ញុំបានរើសយកជាអគ្គមហេសីនោះគឺប្អូនជីដូន ១ របស់ខ្ញុំ នាងនោះមានចិត្តប្រតិពទ្ធស្មោះស្ម័គ្រនឹងខ្ញុំដ៏លើសលប់ ហើយចំណែកខ្ញុំវិញក៏មានសេចក្ដីស្នេហាជាទីបំផុត នៅជាមួយគ្នាជាសុខដរាបមកលុះដល់កំណត់ ៥ ឆ្នាំ, ក្នុងគ្រាក្រោយនេះឯងខ្ញុំសំគាល់ឃើញថាប្រពន្ធខ្ញុំនឿយណាយអស់ចិត្តពីខ្ញុំ ។

មានថ្ងៃ ១, វេលាដែលនាងចេញទៅស្រង់ជុំរះកាយមុនវេលាសោយល្ងាចនោះខ្ញុំងងុយជាខ្លាំង ក៏ប្រាសដេកទៅលើកម្រាលក្នុងបន្ទប់ខ្ញុំទៅ, វេលានោះមានស្រីស្នំ ២ នាក់ចូលទៅបក់ឲ្យខ្ញុំខាងលើ ១ ខាងក្រោម ១ ។ ស្រីទាំង ២ នោះស្មាន

ជាខ្ញុំដេកលក់ ក៏វានិយាយខ្សឹបគ្នាវិតិច ៗ, ឯខ្ញុំខំសំងំធ្មេច ភ្នែកធ្វើជាលក់ ចាំស្តាប់វានិយាយ ។

ស្រី ១ និយាយទៅកាន់ស្រី ១ ថា "អើ ឯងយល់ថាដូច ម្តេច? ចំណែកខាងអញ ៗ យល់ថាព្រះអគ្គមហេសីពេញជាគិត ខុសណាស់, អម្បាលដល់ម្ចាស់យើងមានរូបរាងយ៉ាងនេះ ហើយ នៅតែមិនស្រឡាញ់បាន" ស្រី ១ នោះឆ្លើយឡើងថា "មែនហើយហាង, អញក៏យល់ដូច្នោះដែរ, ប៉ុន្តែអញឆ្ងល់គិត មិនយល់សោះ ហេតុអ្វីបានជាព្រះអគ្គមហេសីលបចេញទៅតែ ឯងស្ងាត់ ៗរាល់តែយប់ ហើយទ្រង់មិនជ្រាបសោះ?" នាង ម្នាក់ឆ្លើយថា "នែ ព្រះអង្គទ្រង់ជ្រាបឯណាបាន ព្រោះព្រះនាង បានយកថ្នាំឫសឈើមកលាយនឹងទឹកឲ្យទ្រង់សោយរាល់តែ ល្ងាច, ឯថ្នាំនោះសោយទៅវេលាណា ក៏ផ្ទំលក់ឥតកំរើកដូច មនុស្សស្លាប់ បានជាព្រះនាងចេញទៅទីណាបានតាមចិត្ត ឥត មានកោតញញើតអ្វី វេលាត្រឡប់ចូលមកវិញ ទើបយកថ្នាំអ្វី ១មុខផ្សេងមកដាក់នៅព្រះនាសា ឲ្យទ្រង់ដឹងព្រះស្មារតីឡើង,"។

ត្រង់នេះសូមឲ្យលោកពិចារណាមើល តើមិនឲ្យភ្ញាក់ផ្អើលក្រែវក្រោធឯណាបាន ប៉ុន្តែបើទោះណាជាដូចម្ដេចក្ដី ក៏ខ្ញុំខំអត់ធ្មត់មិនក្រទីក្រទាទៅបាន ។ កាលនោះខ្ញុំធ្វើជាភ្ញាក់ដឹងខ្លួនឡើង ហើយធ្វើអាការហាក់ដូចជាឥតបានឮពាក្យអ្វី ១ មាត់សោះ ។

ឯព្រះអគ្គមហេសីត្រឡប់មកពីស្រង់វិញហើយ ក៏ចូលសោយក្រយាស្ងោយទាំងអស់គ្នា ។ មុននឹងចូលផ្ទុំព្រះនាងកាន់ទឹក ១ កែវយកមកឲ្យខ្ញុំនឹងដៃឯង គឺជាកែវដែលខ្ញុំតែងសោយរៀងមក ប៉ុន្តែម្ដងនេះ វេលាដែលទទួលមក ខ្ញុំមិនបានផឹកដូចមុន ៗ ខ្ញុំដើរអែបទៅរកបង្អួច ហើយក្លែងបន្ទំចាក់ទឹកចោលអស់ទៅ ទើបខ្ញុំប្រគល់កែវទៅឲ្យវិញមិនឲ្យដឹងជាបានចាក់ទឹកចោលឡើយ ។

រួចក៏នាំគ្នាចូលទៅកាន់ក្រឡាបន្ទំ លុះយូរបន្តិចទៅស្មានជាខ្ញុំដេកលក់ហើយ ព្រះនាងក៏ក្រោកឡើងភ្លាមឥតមានប្រយ័ត្នអ្វីបន្តិចសោះ ហើយនិយាយសម្លេងខ្លាំងថា “ចូរឯង

ដេកម្នាក់ឯងចុះ ហើយកុំក្រោកឲ្យសោះ" ប៉ុន្តែប៉ុណ្ណោះក៏ចាប់គ្រឿងប្រដាប់មកតែងកាយ រួចចេញពីក្រឡាបន្ទុំទៅ ។

(មានតទៅទៀត)

# រឿងព្រេងខ្មែរ

## ១– រឿងអណ្ដើកនឹងស្វា

◎ មាននិទាន ១ ថាអណ្ដើកនឹងស្វាវាទៅសុំជន្លងនឹងគ្នា តែគ្មានកូនចៅទៅចងពន្ធអ្វីទេ ពាក្យគ្រាន់តែថាសុំគ្នាធ្វើជន្លងៗ ហើយស្រឡាញ់រាប់អានគ្នា ដូចអ្នកទាំងពួងគេជន្លងនោះដែរ លុះបំណោយយូរទៅជន្លងខាងស្វានោះគេមានកូនគេត្រូវរៀបការ បំណែកជន្លងស្វាបានហៅភ្ញៀវពួកស្វាសន្មត់ថ្ងៃនឹងស៊ីការ ទើបនឹកឃើញដល់អណ្ដើកជាជន្លងថា ឥឡូវកូនយើងការនេះហៅភ្ញៀវអស់ហើយ នៅតែអណ្ដើកជាជន្លងមិនទាន់បានទៅប្រាប់ ឥឡូវថ្ងៃការវាជិតណាស់ទៅហើយ បើដូច្នេះឲ្យបម្រើទៅអញ្ជើញគាត់មកផងបំណាច់យើងរាប់គ្នាយូរឆ្នាំមកហើយ ៗ ក៏បាត់បម្រើទៅអញ្ជើញ ថ្ងៃដែលគេនឹងប្រជុំញាតិស៊ីនោះអណ្ដើកក៏ទៅដល់ដែរ តែនឹងឡើងទៅស៊ីផឹកនឹងគេឡើងទៅមិនរួច ទើបឯពួកស្វាឃើញក៏ទៅប្រាប់ជន្លងអណ្ដើកថា ដ្បិតជន្លងមកដល់ហើយនៅឯក្រោមដើមឈើ ជន្លងស្វាក៏ចុះមកឃើញអណ្ដើក

ក៏ប្រាប់ថា ជន្លងឯងឡើងមិនរួចនឹងគេមានតែជន្លងឯងខាំវល្លិ៍នេះ បុះរួបយើងនឹងស្រាវឡើងទៅ ប៉ុន្តែបើមិនទាន់ដល់ទៅកន្លែងដែលយើងឲ្យអង្គុយទេ ជន្លងឯងកុំនិយាយឲ្យសោះទោះបីឃើញអ្វីឬគេថាអ្វីក៏ដោយ តែនិយាយធ្លាក់មកស្លាប់ហើយ អណ្តើកក៏ទទួលបណ្តាំជន្លងនោះសព្វគ្រប់ហើយតាំងទទួលខាំវល្លិ៍ ពួកស្វាទាំងប៉ុន្មានក៏ស្រាវវល្លិ៍នោះឡើងនាំអណ្តើកទៅឯថ្នាក់លើ ។

លុះទៅទើបនឹងរៀបដល់កន្លែងដែលគេនឹងដាក់នោះជួនជន្លងស្រីស្វាឃើញអណ្តើក ក៏សួរដោយរាប់អានថាជន្លងសុខសប្បាយជាទេ. អណ្តើកក៏ភ្លេចឯពាក្យបណ្តាំហាមាត់ស្តីទៅនឹងជន្លង របូតមាត់ធ្លាក់ឯខ្លួននោះមកប្រេកដល់ដី, បែកឯស្នូកនោះដួបគេកាប់នឹងកាំបិតស្លាប់កាលវេលានោះទៅហោង. ខានឯស៊ីការនោះទៅ ។

បប់ដំណើរហៅថាមាត់អណ្តើក ៗ នេះអ្នកមានប្រាជ្ញាគួរគិតឃើញថាអ្នកឯណាដែលមិនចាំបណ្តាំគេដួបជាសត្វអណ្តើកនឹងខូបខ្លួន ។

## ពាក្យឃ្លោងថា.

៙ អាសូអណ្ដើក ខំភាវទើកៗ បង់ទៅស៊ីការ ឡើងដល់
ហើយហោង ជន្លងស្រីស្វា. ឃើញហើយយស្សរថា អ្នកមកហើយរី
អណ្ដើកបានស្ដាប់ ហើបហាៈមាត់ប្រាប់ ប្រាជ្ញានឹងស្ដី របូត
ប្រាណមក ធ្លាក់ប្រោកដល់ដី បែកស្នុកជាបី ជាប្អូនប្រិភាគ
ខានបរិភោគ្គា ព្រោះព្រើលអាត្មា មិនចាំពាំពាក្យ គេផ្ដាំមកមុន
ដាក់រន្ធត្រចៀក ឥឡូវភ្លេចពាក្យ ភ្លេចពាលើស្លាប់ ។៙៚—

## ២– រឿងឈ្មោះមៅចូលសាសន៍ចាមយកប្រពន្ធ

មានម្នាក់ឈ្មោះមៅ ទំលីនៅក្នុងខេត្តភ្នំពេញ នៅមាត់ទន្លេមេកុង ចៅមៅនោះបានទៅឃើញកូនក្រមុំចាមល្អមានចិត្តស្រឡាញ់ចង់បានធ្វើជាភរិយាខ្លួន ចូលមកសុំដណ្ដឹងពួកចាមៗមិនឲ្យថាព្រោះខុសសាសន៍គ្នា បើព្រមចូលសាសន៍ជាមួយទើបឲ្យបាន ចៅមៅហេតុតែស្រឡាញ់នាងនោះណាស់ក៏ព្រមទៅចូលសាសន៍ជាមួយនឹងពួកចាមនោះ ចូលសាសន៍រួចហើយចាមនោះព្រមឲ្យ បានរៀបការយកនាងនោះធ្វើជាប្រពន្ធ ឯចៅមៅចូលសាសន៍នោះក៏មិនទាន់បេះដឹងធម៌វិន័យរបស់សាសន៍ចាមជានោះដូចម្ដេចនៅឡើយទេ បានតែប្រពន្ធហើយក៏នាំទៅស្រុករបស់ខ្លួន លុះថ្ងៃក្រោយត្រូវការនឹងជូនប្រពន្ធមកសួរញាតិសន្ដានឯស្រុកប្រពន្ធ មកដល់ពេលនោះជាថ្ងៃបុណ្យពួកចាមជា គេត្រូវចូលទៅស្លូត្រធម៌នៅព្រះវិហារនោះខានមិនបាន គេចៅមៅនោះក៏ប្រាប់ទៅមៅថា ឯងមកនេះត្រូវហើយព្រោះមានបុណ្យក្នុងពេលល្ងាចនេះគេត្រូវចូលទៅព្រះវិហារទាំងអស់គ្នា មៅឯងទៅចូល

ស្លូតនឹងគេ ចៅមៅតបទៅថា ខ្ញុំសុំមិនទៅទេ ព្រោះមិនគ្នាន់ចេះ ចាំធម៌អ្វីសោះដឹងជាស្លូតយ៉ាងដូចម្ដេចខ្លះ គ្រូនោះប្រាប់ថា ទេ ធម៌ពេលនេះមិនមានធម៌ស្លូតខ្លាំងៗទេ ស្លូតតាមចិត្តរៀង ខ្លួន ហើយស្លូតតិចៗផង បើយើងមិនចេះគ្រាន់តែចូលទៅ នឹងគេក៏បាន ឲ្យមើលតែមុខ ធ្វើតែតាមគេទៅក៏បានដែរ បើ គេក្រាបៗ នឹងគេ បើគេក្រោកៗ នឹងគេ គេធ្វើអ្វីយើងធ្វើ តែតាមទៅមិនពីបាកអីទេ មៅឯងចាំមើលតែអញធ្វើដំរាប់តាម អញចុះ ចៅមៅក៏ព្រមទៅ បានខ្ចីសារុងថ្មីរបស់គេ ១ ស្លៀក ហើយជួតក្បាលទ្រមើងៗ ហាក់ដូចជាសង្ឃរាជជាធំដុំ ។

ដល់ចូលទៅព្រះវិហារពួកចាមជ្វាទាំងនោះគេធ្វើវត្តបដិបត្តិ តាមទំនៀមគេ ចៅមៅចាំមើលតែគ្រូរបស់ខ្លួន លុះពួកចាមជ្វា មកជួបជុំហើយ ពួកសង្ឃរាជធំៗ គេអង្គុយខាងមុខ ឯចៅមៅ នឹងគ្រូនៅខាងក្រោយបន្តិច តែគ្រូនោះឲ្យចៅមៅទៅអង្គុយពី ខាងមុខខ្លួនវិញ ដើម្បីស្រណុកកិះប្រាបពីក្រោយ ។

ឯរបៀបចាមជ្វាធ្វើវត្តនោះ មានឈរៗហើយអង្គុយៗរួច

បន្តិចក្រាប ក្រាបរួបជើបឡើងអង្គុយទៅទៀតធ្វើដូចជាបំពិតក្តិតគ្រហឹត ធ្វើទៅកាន់តែរហ័សញាប់ឡើង ចៅមៅក៏ប្រឹងធ្វើតាមមិនឲ្យខ្វះទេ លុះដល់វេលាក្រាប ៗ ហើយក្រោកឡើងបំពិតម្តងទៀតនោះចៅមៅគ្មានមិនធ្លាប់ស្លៀកសារុងបំពិតដូចនោះបេះតែបំពិតញឹកញាប់ណាស់ត្រូវនឹងសារុងនោះប្រិ៍ភាំងក្រញេងក្រញង់ម្លោះហើយវាលេចឯពងល្ហូចេញមកក្រៅសារុងសំពត ៗគ្រូនោះឃើញក៏លូកដៃទៅពាល់លេងឲ្យចៅមៅដឹងដើម្បីឲ្យប្រយ័ត្ន ចៅមៅកគិតឃើញថា "ឱដល់ថ្នាក់ទ្រពងហើយ" ក៏លូកដៃទៅទ្រពងល្ហូសង្ឃរាជថ្វាខាងមុខខ្លួននោះ ស្រាប់តែសង្ឃរាជនោះគេខឹង គេដាក់ ១ ជើងទៅត្រូវឯក្បាលឈ្មោះមៅយ៉ាងធ្ងន់ ។

ចៅមៅគិតឃើញថា ឱអញមិនទាន់ដាក់អីតើ រួបក៏ដាក់ទៅក្បាលគ្រូឯងនោះបណ្តោយ ១ ជើងទៅទៀតយ៉ាងខ្លាំងស្ទើរតែនឹងបាក់ក ចៅមៅក៏មិនយល់ជាគេដាក់ដោយខឹងនោះទេឯគ្រូកាលឃើញចៅមៅធ្វើដូចនោះក៏បាត់មាត់មិនបានស្តីថាអ្វីឡើយ ។

មានម្នាក់ទៀតធ្វើជាមេស្រុក កាលស្រុកពីដើមមិនទាន់ឲ្យហៅជាមេឃុំ មេស្រុកនេះធ្វើជាមេស្រុកឃុំគោករកា ខេត្តភ្នំពេញមានការទៅព្រែកព្នៅទិញប្រដាប់គ្រឿងកបិទ ដល់ទិញប្រដាប់គ្រឿងសព្វគ្រប់ហើយនៅភ្លេចស្ករស ១ មុខទៀតមិនទាន់បានទិញមេស្រុកនោះប្រាប់ចិនថាឲ្យថ្លឹងស្ករស ១ នាលថែមទៀត ចិនកូនឈ្នួលនោះក៏ទៅយកស្ករសនឹងថ្លឹងឲ្យ តែស្ករនោះវាដាក់ក្នុងថាប់គ្របនៅជិតថាប់ដែលវាដាក់អំបិលសនោះដែរ លុះចិនទៅបើកយកស្ករមកថ្លឹងឲ្យ មេស្រុកនោះតាមទៅមើលក្រែងវាថ្លឹងឲ្យមិនគ្រប់ភ្នែកជញ្ជីង លុះដើតមើលទៅឃើញអំបិលសនោះវាសល្អជាងស្ករសសាច់សហើយថៃល្អណាស់ មេស្រុកឃើញហើយប្រាប់ចិនថានែអាចឹកកុំថ្លឹងអា នុះ អញយកអាខាងនេះវិញ ចិនមិនព្រមបេះតែប្តូរស្ករនោះថ្លឹង មេស្រុកប្រាប់ថែមទៀតថាកុំឲ្យយកអាណឹង យកឯណោះវិញ កាន់តែតឹងសំឡេងណាស់ ចិនតបវិញនិយាយជាពាក្យខ្មែរ តែចិននោះជាតិចិនឆៅទើបមកពីស្រុកនិយាយខ្មែរមិនច្បាស់

ប៊ិនប្រាប់ថា «អានីប៉េតើ» មេស្រុកស្មានតឹងគុំនិតខ្ជួនថា ប៊ិនថា ប៉េនេះប្រហែលអានេះល្អថ្លៃច្រើនហើយវាមិនលក់ឲ្យ ៗ អាចោក ក៏ឆ្លើយតបទៅប៊ិនវិញថា អើយកប៉េតឹងហើយ អានោះមិនមែត ប៉េមិនយកទេ ប៊ិននោះមិនព្រមក៏ប្រាប់ទៀត «អានីប៉េស៊ីប៉ាយ យ៉ាយកមិងម៉ាងទេ «ពាក្យនេះជាពាក្យខ្មែរថាអំបិលស៊ីប្រៃយក មិនបានទេ» មេស្រុកនោះឆ្លើយថាអញយកប៉េស៊ីប៉ាយណាំង ហើយប្តឹងអានេះវិញបុះ អានោះមិនយកទេ ប៊ិននោះប្រាប់ថា ឡាក់ឯងស៊ីម្ហូកឡុងមើត្ល» មេស្រុកឮប៊ិនប្រាប់ថាឲ្យស៊ីជ្ជូហ្មោះ ក៏ត្រេកអរគិតថាស៊ីស្ករអានេះម្តងឲ្យសន្លឹកកាស រួបទៅយកទឹក មកខ្ពុលមាត់សព្វគ្រប់ហើយ ក៏លូកដៃទៅចាប់សំបកគ្រុមនៅ ក្នុងនោះបូកយ៉ាងពេញរួបអកទៅក្នុងមាត់, កាលណាបួល ហើយឯអំបឹល ១ គ្រុមនោះវាប្រៃក្រៃលែង ក៏ធន់មិនបានខ្ជាក់អំ-បិលនោះបេញមកវិញមានសេចក្តីខ្មាស់ប៊ិននោះក្រៃពេក ហើយ ប៊ិននោះវាបង្អុលមុខថែមទៀតថា ឡាក់ឯងមិងឡឹង គេប៉ាប់ ហើយថា ប៉េស៊ីប៉ាយ ៗ មិងឡឹង" នេះមកតែអំពីសេចក្តីមិន

ជាក់ហើយប្រមាននឹងចិត្តគិតខ្លួនបានជាខុសរហូត បើសិនជាបញ្ជាក់ស្ទួរសិនឲ្យដឹងច្បាស់កាលណានឹងទៅស៊ីអំបីលនោះមួយទៀតគេប្រាប់ហើយ ប៉ុន្តែស្តាប់មិនបានទៅប្រមានខុសពីសំដីវិញ ។

មានរឿងម្នាក់ទៀតឈ្មោះមិនប្រាកដនៅស្រុកបិន ពីរនាក់បងនឹងប្អូនខ្លៃនឹងគ្នា បងខ្លៃនោះជាអ្នកក្រប្អូនខ្លៃនោះគេអ្នកមានសម្បត្តិទ្រព្យ លុះ ១ ថ្ងៃអាពុកក្មេកមានកិច្ចរវល់ត្រូវប្រាប់កូនចៅបងប្អូនទៅស៊ីផឹកនៅផ្ទះគេ ប្អូនខ្លៃនោះបានមកជួបនឹងបងបបួលទៅស៊ីឯផ្ទះអាពុកក្មេក បងនោះនិយាយប្រាប់គេតាមត្រង់ថាមិនហ៊ានទៅស៊ីទេ, ព្រោះខ្លួនជាអ្នកក្រមិនធ្លាប់ទៅស៊ីម្ហូបចំណីល្អក្រែងមិនត្រូវបែបបទខ្មាស់គេ ប្អូនខ្លៃនោះជាមនុស្សចិត្តសប្បុរសនឹងបងក៏ប្រាប់ទៅវិញថាមិនអីទេទៅពីសាចុះបើមិនដឹងឲ្យមើលតែតាមខ្ញុំ ៗ ស៊ីអីស៊ីណាឯងទៅ មិនក្រអីប៉ុន្មានទេឲ្យទៅជាមួយនឹងខ្ញុំចុះ បងនោះក៏ព្រមទៅជាមួយ លុះទៅបរិភោគបាយនៅទីនោះបបួលគ្នាស៊ីបាយតាមធម្មតាទៅ លុះ

ដល់គេលើកសំឡខ្មៅមក ប្អូនក៏យកបង្គើសចាប់ ១ មកពមរូប ជញ្ជក់អស់ហើយខ្ជាក់សម្បកខ្មៅនោះដាក់នឹងកន្សែង ហើយ គេបោលសំបកនោះទៅ ។

ឯបងនោះមិនដឹងហើយមិនជាឃើញគេធ្វើដូច្នោះ ក៏ខំ ជញ្ជក់រូបខំទំពាឯសំបកខ្មៅនោះទាល់តែល្អិតក៏ខំលេបទៅ ប្អូន ឃើញដូចនោះក៏លេងស៊ីខ្មៅនោះ ទៅយកឯអំពៅដែលគេឡៅ ទុកនៅបាននោះមកស៊ីៗរូបគេយកកន្សែងខ្ជាក់ដាក់ហើយបោល ទៀតទៅ បងឃើញគេស៊ីអំពៅក៏ខំយកអំពៅនោះមកស៊ីនឹងគេ ទៀត ស៊ីអំពៅលុះតែល្អិតកាកលេបទៅទៀត ប្អូននោះលែងស៊ី អំពៅរាទៅស៊ីសម្លមីសួទៀត ទើបតែនឹងពមមកក្នុងមាត់នឹក ឃើញបងស៊ីអំពៅទាំងកាកនោះហើយក៏អស់សំណើចទប់មិន ឈ្នះក៏បេញសំឡេងមកឮតែឃឹកៗដោយអំណាចខ្យល់ទប់ឃឹក នោះ មីសួរាស្ទុះដោយអំណាចខ្យល់នោះឡើងទៅចូលឯរន្ធច្រ- មុះទាំងពីរចេញឯមីសួរនោះមកក្រៅ បងខ្លៃឃើញដូច្នោះហើយ ក៏បោលបង្គើសទៅក្នុងឋាសឋាទេលែងស៊ីហើយ ស៊ីឯទៀត

ទាំងអស់ធ្វើតាមបាន ខ្មៅនឹងអំពៅទាំងសំបក-ទាំងកាកស៊ីបានទាំងអស់ ដល់ស៊ីមីស្លឲ្យខ្ពស់នឹងប្រមុះយ៉ាងដូច្នេះធ្វើតាមមិនបានទេ ប្អូនឯងស៊ីតែឯងចុះ ។ បងលែងស៊ីហើយ ស៊ីតទៅទៀតមិនកើតទេ ។

(មានពាក្យឃ្លោងជាដូចក្រោមនេះសារុបកាព្យតែ ១)

៙ ឱលោកអ្នកកាយការលោកីយ ជនជាតិប្រុសស្រី រាល់រូបា មិនរើសមិនរេះថាអ្នកណា បើមិនស្ទាត់ការកុំទុកចិត្ត ។ គោងតែសាកសួរឲ្យច្បាស់សិន សង្កេតសង្កិនរកពាក្យពិត កុំអាលកុំអាងថាដឹងគិត នឹងភ្លោយគំនិតបង់អាសា។ នឹងខុសនឹងខូចដូចបោមៅ ម្មោៗទៅធាក់គ្រូអាត្មា ព្រោះស្តាប់បង្គាប់មិនច្បាស់ការ អាចារ្យប្រាប់ថាឲ្យតាមគ្នា ។ ដល់តាមទៅលើការប្រឡំ ប្រែជាមិនសមដូចចិត្ត មិនដឹងនឹងបោលឲ្យអ្នកណា ខុសឯអាត្មាឥតបើគិត ។ បើមិនទាន់បេះមិន

ទាន់ជាក់ គួរអ្នកគួរនឹងប្រឹងពិនិត្យ កំពុះកំពាទៅតាមចិត្ត ត្រូវគិតត្រូវគូឱ្យសព្វសិន ។ តែខំប្រឹងរឿងប្រព្រឹត្តិបួស ប្រើនហួស ប្រើនហាក់ដូចជាបិន គ្នាស្លាក់មីស្ងួរបេញត្រឡិន បៃមហិគ្នា ប៉ុន្នខ្លះប្រមុះ ។ ម្លឹងៗទៅស្មានបានកាលណា ស្មានណាំង ខូបការទៅលើខុស មិនដែលអ្នកណាស៊ីហើយខ្លះ ទៅក្នុងប្រមុះ ដូចនោះបាន ។

## បប់រឿងស្មាននឹងបិត្តខ្លួន

## ៣– រឿងសំឡាញ់ពីរនាក់នៅគ្រូជាមួយគ្នា

១ មានបុរសពីរនាក់ទៅរៀនអក្សរគ្រូជាមួយគ្នា បានសុំគ្នាធ្វើជាសំឡាញ់ហើយសណ្យាគ្នាថា បើយើងបែកទៅនៅទីទៃគ្នាទៅ បើអ្នកណាមានកិច្ចធុរៈយ៉ាងម្ដេចក្ដី ត្រូវឲ្យជួយគ្នាទៅវិញទៅមក កុំឲ្យមើលបំណាំគ្នា អ្នកទាំងពីរលុះនៅយូរទៅ សំឡាញ់ម្នាក់នោះបានបួសរៀនហើយសឹកទៅយកភរិយា នៅផ្ទះជិតផ្ទះសេដ្ឋីនៅស្រុកទៀបវត្តនោះ តែរកស៊ីក្រលំបាកណាស់ ឯសំឡាញ់ម្នាក់នៅបួសជាសង្ឃ ហើយបានឮគេនិយាយថាប្រពន្ធរបស់សំឡាញ់អាត្មានោះសាហាយនឹងកូនសេដ្ឋីនៅផ្ទះជិតនោះជាយូរមកហើយ លោកសង្ឃជាសំឡាញ់បានដឹងដើមអាទ៍ដូចនោះ គិតឃើញថាបានជាសំឡាញ់រកស៊ីក្រលំបាកនេះមកពីនាងប្រពន្ធមានចិត្តក្បត់ពីប្ដី នឹងនាំទៅប្រាប់ឃើញថាសេចក្ដីមិនគាប្បី ហើយគិតឃើញអំពីផ្លូវសន្មត់នឹងគ្នានោះផង គួរតែទៅសង្គ្រោះតាមបណ្ដាំដើម គិតឃើញដូចនោះហើយក៏លាគ្រូបាកសិក្ខាបទទៅនៅនឹងសំឡាញ់ បាន

ប្រាប់សំឡាញ់ថាបានជាសឹកមកនេះពីព្រោះអាណិតសំឡាញ់ឯងរកស៊ីមិនឃើញមាននឹងគេ ឥឡូវអញមកជួយរកស៊ីមិត្រឯង ៗ ព្រមតាមគំនិតអញគិតដែរឬទេ ព្រោះយើងបានសន្មតិប្តេជ្ញានឹងគ្នាថា បើអ្នកខាងណាទាល់ក្រឲ្យជួយគ្នាទៅវិញទៅមក សំឡាញ់មានភរិយានោះក៏ព្រមព្រៀងទទួលធ្វើតាមគំនិតសំឡាញ់របស់ខ្លួន លុះនៅយូរជាមួយដរាបទៅ តែងគន់មើលកិរិយានាងប្រពន្ធនោះដឹងហេតុពិតប្រាកដ តែមិនអាចនឹងប្រាប់សំឡាញ់នោះឡើយ ហើយនិយាយនឹងគ្នាថា សំឡាញ់អើយយើងរកស៊ីសព្វថ្ងៃខំទាំងម្លេះក៏មិនឃើញមានបានផលប្រយោជន៍អ្វីសោះ បើដូច្នោះយើងគិតទៅទិញឈើមកធ្វើជាក្ដារបាស់ទុំសំរាប់ទុកលក់ឲ្យគេ អញក៏ចេះធ្វើជាងខ្លះដែរហើយ បើយើងទិញក្ដារថ្លៃ ៥ រៀលមកធ្វើទៅយើងលក់ដល់ទៅ ១០ រៀល ឬ ១២ រៀល តាមល្អអាក្រក់នោះឃើញបំណាញជាងរកស៊ីឯទៀត សំឡាញ់មានប្រពន្ធនោះក៏ព្រមរកប្រាក់ទៅទិញក្ដារបានមក បបួលគ្នាធ្វើជាម្ឈូស ១ យ៉ាងមាំ ធ្វើហើយលើកទៅទុក

ឯដំណេកសំឡាញ់ប្ដីប្រពន្ធ ហើយនិយាយផ្ដាំថា ក្ដារនេះធ្វើទុកលក់ប៉ុន្តែត្រូវទុកនៅជិតដំណេកសំឡាញ់ឯង យើងស្ដាប់សួរនៅក្ដារនេះល្អឬអាក្រក់ បើនៅជិតខ្ញុំនោះខ្ញុំតែម្នាក់ឯងតែកាលណាដេកលក់ទៅមិនឮ ឯមិត្រឯងមានគ្នាពីរនាក់ បើ ១ដេកនៅ ១ សំឡាញ់នោះហេតុតែគិតមិនឃើញឧបាយប្រាជ្ញសំឡាញ់របស់ខ្លួន ក៏នាំគ្នាលើកម្សួសយកទៅទុកកន្លែងខ្លួននឹងភរិយា លុះយូរទៅសំឡាញ់បណ្ឌិតនោះបាននិយាយបបួលថាយើងគិតទៅរកនេសាទត្រីស៊ីបានម្ដងដ្បិតអត់អួរអាហារណាស់បើដូច្នោះឲ្យមិត្រឯងប្រាប់ប្រពន្ធឯងឲ្យរៀបអង្ករឆ្នាំងនឹងរេបបាយបម្រុងទុកស៊ីបានមួយយប់ឲ្យ បើយើងរកត្រីបានធ្វើជាប្រហុកយកមកទុកស៊ីឬធ្វើជាប្អកកុំឲ្យអត់ដូចសព្វថ្ងៃ ឯនាងភរិយាសំ-ឡាញ់នោះ កាលបានឮថាប្ដីនឹងសំឡាញ់ខ្លួនចេញទៅរកនេ-សាទដល់ពីរឬបីយប់ដូច្នោះក៏មានចិត្តរីករាយរួសរាន់រកគ្រឿងប្រដាប់ សម្រាប់ឲ្យយកទៅល្មមគ្រប់គ្រាន់បានពីរឬបីយប់កុំឲ្យខ្វះខាតក្រែងប្ដីឆាប់ត្រឡប់មក រៀបហើយប្រគល់

ឲ្យទៅ  ប្ដីនឹងសំឡាញ់នាំគ្នាវែកអង្កររឆ្នាំងបាយទៅឯបឹង ។

ឯនាងភរិយានៅផ្ទះតែម្នាក់ឯង  ក៏បានពេលល្អសប្បាយគាប់ចិត្តណាស់  បានប្រាប់កូនសេដ្ឋីជាសាហាយថាប្ដីមិននៅទេ ចេញទៅរកត្រីឯបឹងហើយ ទៅក៏យូរប្រហែលជាពីរឬបីយប់ឲ្យទៅដេកឯផ្ទះខ្លួនសាបាយតាមចិត្តយើង ដល់ពេលវេលាយប់កូនសេដ្ឋីនោះក៏ឡើងទៅដេកជាមួយនឹងនាងសាហាយនោះឥតកោតញញើតតាំងពីពន់ព្រលប់ ។

ឯបណ្ឌិតសំឡាញ់ដែលនាំគ្នាទៅដល់បឹងបងសន្ទូចនោះលុះប្រមាណពេលដឹងថា  ប្រហែលនោះកូនសេដ្ឋីមុកជាមកដេកហើយ ៗ និយាយនឹងសំឡាញ់ថា  មិត្រយើងនៅបងសន្ទូចដេកនៅនេះមិនបានទេ  មូសខាំខ្លាំងណាស់  យើងត្រឡប់ទៅដេកផ្ទះវិញ  ព្រឹកឡើងសិមយើងមកមើលត្រីសាសន្ទូចចុះ  រួចក៏នាំគ្នាដើរប្រញាប់រួសរាន់ទៅផ្ទះ   ហៀបនឹងដល់ផ្ទះប្រាប់សំឡាញ់ដែលមានប្រពន្ធថា សំឡាញ់ទៅដល់ផ្ទះកុំឲ្យនិយាយហើយសិ.

ឡាញ់ឯងទៅឡើងជណ្ដើរខាងក្រោយ ខ្ញុំឡើងជណ្ដើរខាងមុខ ឲ្យសំឡាញ់ឯងហៅប្រពន្ធឯងឲ្យបើកទ្វារធាប់ឡើង ខ្ញុំស្រែកប្រាប់ពីជណ្ដើរខាងមុខឲ្យអុចភ្លើងឡើង សំឡាញ់នោះក៏ធ្វើតាមដល់ទៅឡើងលើផ្ទះក៏ធ្វើតាមដូចនេះទាំងអស់ ។

ឯនាងប្រពន្ធនឹងកូនសេដ្ឋីនោះកំពុងតែដេកលក់ លុះឮសំដីប្ដីខ្លួននឹងសំឡាញ់ហៅនៅគ្រប់អន្លើ ខាងមុខខាងក្រោយដូច្នោះ ក៏ភិតភ័យញ័រជើងដៃ ព្រោះសាហាយនៅដេកជាមួយគ្នានឹងចុះទៅខាងណាក៏មិនបានជណ្ដើរមុខនោះមាត់បណ្ឌិត ក្រោយនោះមាត់ប្ដី ហើយចេះតែស្រែកហៅឲ្យបើកទ្វារ នឹងអុចបន្ទះធាប់ឡើង ៗ កូនសេដ្ឋីនោះទៅណាមិនរួច នាងនោះប្រាប់ឲ្យចូលទៅក្នុងក្ដារម្ឈូសសិនទៅ ទំរាំមានពេលស្រួលស្ងាត់សឹមលបចុះទៅ នាងនោះក៏បើកក្ដារម្ឈូសឲ្យសាហាយខ្លួនចូលសំងំនៅនោះហើយគ្របក្ដារពីលើទៅវិញដដែល រួចទើបអុចភ្លើងទៅបើកទ្វារឲ្យប្ដីនឹងសំឡាញ់ខ្លួនចូលមក ឯបណ្ឌិតសំឡាញ់នោះដឹងការកាលវេលានាងនោះធ្វើអាការឲ្យឃើញគួរដូច្នោះក៏ដឹង

គំនិតថាកូនសេដ្ឋីប្រាកដជាចូលក្នុងក្ដារម្សួសពិតហើយ ក៏យកដែកគោលធំយ៉ាងវែងនឹងពូថៅ១កាន់ទៅអង្រិង់មើលឮសូរមានមនុស្សនៅក្នុងនោះក៏យកដែកគោលវាយផ្ដាប់ជុំវិញយ៉ាងមាំទុកនៅនោះ ឯប្ដីសំឡាញ់នោះក៏មិនអាចដឹងសោះឡើយ លុះវេលាព្រឹកបណ្ឌិតសំឡាញ់នោះប្រាប់ទៅសំឡាញ់អាត្មាទាំងពីរនាក់ប្ដីនឹងប្រពន្ធថា សំឡាញ់អើយក្ដារយើងចង្រៃទេ ល្ងាចមិញសូរអាក្រក់ណាស់ យើងទុកមិនបានទេ បើដូច្នេះហើយយើងសែងទៅដុតចោលទៅកុំស្ដាយប្រាក់ប្រាំ-ប្រាំមួយរៀលនេះសុំយើងរកទិញទៀតឲ្យបានល្អ ថាតែប៉ុណ្ណោះក៏បង្គាប់សំឡាញ់នោះជាមិត្តឯងទៅរកស្នែងមកខ្ញុំរកខ្សែនឹងបងសែងយកទៅទាន់ពីព្រឹក ថាតែប៉ុណ្ណោះក៏នាំគ្នាភើចក្ដារម្សួសប្រមៀលទំលាក់ចុះមកដល់ដី ឯសំឡាញ់ដែលមានប្រពន្ធនោះក៏ធ្វើតាមសព្វគ្រប់មិនហ៊ានប្រកែកសោះ ។

ឯនាងសាហាយនោះបានឮបណ្ឌិតសំឡាញ់ប្ដីនិយាយគិតនឹងសែងទៅដុតដូច្នោះហើយ ក៏ភិតភ័យរត់ទៅប្រាប់ដល់សេដ្ឋីជា

អាពុកតាមហេតុដែលកូននៅក្នុងក្តារ ម្ចាស់គេនឹងសែងទៅដុត ហើយ សុំឲ្យទៅនិយាយជាដាច់ នោះសេដ្ឋីឲ្យបម្រើម្នាក់មកសួរតថ្លៃ ឯបណ្ឌិតថាក្តារនេះលក់ថ្លៃណាស់ ព្រោះវាចង្រៃធ្វើហើយ បានតែយកដុតចោលទើបបានបាត់ចង្រៃ បើអ្នកឲ្យថ្លៃច្រើនខ្ញុំប្រថុយចង្រៃម្តងទៅចុះ បម្រើសួរថាអ្នកលក់ថ្លៃប៉ុន្មាន បណ្ឌិតតបថា បើដាច់ចិត្តពីចង្រៃនេះលុះតែវាស់ប្រាក់កំពោះនឹងក្តារនេះទើបលក់ នោះទើបបាត់ចង្រៃ បំរើមកជំរាបសេដ្ឋីតាមរឿងនោះវិញ សេដ្ឋីឲ្យទៅសុំថ្លៃម្តងទៀតថាសុំតថ្លៃតែពាក់កណ្តាល បណ្ឌិតមិនព្រមថាបើចុះនៅពាក់កណ្តាលនោះចង្រៃរឹតតែច្រើនឡើងទៀត បើដូច្នេះអ្នកទៅប្តឹងលោកវិញចុះខ្ញុំមិនព្រមចុះថ្លៃទៅទៀតទេ ហើយក៏ទៅនិយាយនឹងសំឡាញ់ធ្វើហាក់ដូចជានឹងសែងយកទៅ ថាម៍សំឡាញ់យើងសែងទៅ ចាប់ស្នែងនឹងសែងទៅ បណ្ឌិតនោះថាឱភ្លេចយកពូថៅទៅកាប់ឱះ ទើបឡើងទៅយកពូថៅចុះមកវិញបំរើពីសេដ្ឋីរត់មកដល់ទៀតថាសុំឲ្យអ្នកបង្អង់សិន សុំនិយាយថ្លៃម្តងទៀតសុំឲ្យចុះពីកំពោះខ្លះនៅត្រឹម

កាប គឺភាគ ៣ ហោលឲ្យ ១ ភាគ បណ្ឌិតនោះតែមិនព្រមទៀត ហើយថាកុំនិយាយយូរខ្ញុំមិនព្រមបយបុះទេ ខ្ញុំនឹងអាលយកទៅជុត សេដ្ឋីអាណិតជ្បិតកូនតែ ១ ទ្រាំមិនបានក៏ឲ្យថ្លៃស្មើនឹងក្ដារទើបបណ្ឌិតនោះទទួលយក ។

សេដ្ឋីក៏បានយកប្រាក់មកដាក់គរគ្រប់សព្វហើយក៏ប្រគល់ប្រាក់ នឹងក្ដារឲ្យ ទាវិញ-ទៅមកហោង សេដ្ឋីក៏យកក្ដារនោះមកគាស់យកកូនពីក្នុងក្ដារនោះកូននោះស្ទើរតែនឹងស្លាប់ ចាប់ដើមអំពីថ្ងៃនោះមកកូនសេដ្ឋីក៏រាងចាលលែងហានមានសាហាយស្មន់ទៀតឡើយ ។ នេះគួរពិចារណាមើលចុះទំនិមលោកថាអួសទូកកុំឲ្យល្អាន ចាប់ត្រីបានកុំឲ្យល្អក់ទឹក ។

## ពាក្យទំនុកថា

ស្រីអើយនាងស្រី កាលអត់ពីប្ដី ផ្ដាំទៅសាបាយ នាងនៅម្នាក់ឯង មាសមិនសប្បាយ គ្មានគេថ្នមកាយ កែវដេកមិនលក់ ។ កិលេសកាម តែងទាញនាំ ទៅរកនរកសប្បាយភ្លេចខ្លួន រាជ្ជនផ្ដុំទុក្ខ ទង់ទាញទៅមុខ ព្រោះអវិជ្ជា ។

ដល់ប្រុសសាហាយ បានមកនិយាយ ក្សិទស្នាលចិន្តា ថាឪ
អ្នកថ្លៃ ថ្ងៃនេះជួបគ្នា ប្អូនប្អូកមហា រឭកពេកពន់ ។ បើ
បានអ្នកមក អ្នកប្រុសពន្លក ប្អូនមិនអាក់អន់ ទុក្ខទាំងប៉ុន្មាន
បាត់បានស្រោកស្រន់ ឲ្យប្អូនបានគន់ បានកើយរួមរិត ។
ប្រាណប្រុសល្ហាសល្ហន់ ដេកនឹងប្រពន្ធ សំឡាញ់បណ្ឌិត កំ
ពុងពេញពាល ត្រកាលគាប់ចិត្ត មិនមានគន់គិត កាលការ
មរណា ។ គេឡើងមកទាន់ ភិតភ័យរន្ធាន់ ឋប់អន្ទះសា មក
មានគំនិត គិតចូលក្នុងក្ដារ សម្ងំអាត្មា ថាគេមិនយល់ ។
បណ្ឌិតនោះសោត គេក៏មិនឆោត គេមានយោបល់ ទៅ
អង្រង់ក្ដារ ប្រាជ្ញដឹងកល់ គេបានសំគាល់ គំនិតអាត្មា ។
គេយកដែកគោល វ៉ែងធំន៏នល វាយផ្ចាប់នាគា គ្រប់ជ្រុង
ទាំងបួន មាំមួនមុះហិមា ភ្លឺឡើងគិតគ្នា សែងយកទៅជុត ។

ចប់រឿងអួសទូកកុំឲ្យល្អាន ចាប់ត្រីបានកុំឲ្យល្អក់ទឹក

(មានតទៅទៀត)

# ៤– រឿងបុរស ៤ នាក់

## ទី ១ ក្បាលទំពែក - ទី ២ សំបោរហៀរ - ទី ៣ ពព្រៀកភ្នែក ទី ៤ សំទក់ជើង

មានថ្ងៃ ១ បុរស ៤ នាក់ដើរទៅជួបគ្នានៅសាលាសំណាក់ ១ បាននិយាយសួរគ្នាទៅវិញទៅមក ថាអាទំពែកបើអាឯងដើរហាលថ្ងៃអាឯងក្តៅដែលឬទេ អាទំពែកឆ្លើយថាអញដើរហាលថ្ងៃមិនក្តៅទេ បុះអាសំបោរហៀរបើកាលណាសំបោរហៀរបេញមកពីក្នុងច្រមុះច្រើនអាឯងជូតវាបេញដែរឬមិនជូតទេ, អាសំបោរហៀរឆ្លើយប្រាប់ទៅវិញថាអញមិនជូតបេញទេ, បុះអាពព្រៀកភ្នែកបើមមង់វាមករោមភ្នែកអាឯងច្រើនអាឯងបក់បណ្តេញវាបេញដែរឬមិនបក់វាបេញទេ, អាពព្រៀកភ្នែកប្រាប់ទៅវិញថាអញមិនបក់បណ្តេញវាឲ្យហើរបេញទេពីភ្នែកអញ, បុះអាសំទក់ជើងបើអាឯងដើរទៅណាឆ្ងាយអាឯងមានបុករួយស្រពន់ជើងទេ, អាសំទក់ជើងប្រាប់ទៅវិញថាអញមិនដែលបុករួយស្រពន់ជើងអញទេ, បើអញមានបុករួយស្រពន់ជើងអញ

មិនមែនដើររួចពីផ្ទះមកជួបនឹងអាឯងទាំងអស់គ្នាទេ, អាទាំង ៤ នាក់នេះដល់និយាយអួតខ្លួនវាថាខ្លាំងពូកែដោយខ្លួនយ៉ាងនេះ ក៏វាបបួលគ្នាទាំង ៤ នាក់ធ្វើជាពួកម៉ាកមិត្រសំឡាញ់គ្នា ហើយវាចង់ដឹងរិទ្ធិខ្លាំងពូកែម្នាក់ ៗ ក៏វានាំគ្នាចុះដើរពីសាលាទៅទៀត ដល់ដើរទៅឆ្ងាយបន្តិចទៅអាទំពែកវាហាលថ្ងៃក្តៅ អាសំទក់ជើងក៏វារួយបុកស្រពន់ជើងវា អាសំបោហៀរក៏សំបោហៀរហូលមាត់ច្រើន ហើយអាពព្រៀកភ្នែកក៏មានមមង់រោមភ្នែកវាច្រើន តែអ្នកទាំង ៤ នាក់នេះមិនបានបេញវាបានិយាយដូចម្តេចពីព្រោះអួតខ្លួនសុទ្ធតែពូកែដោយខ្លួន ហើយទទួលដើរទៅប្រទះឃើញត្រពាំង ១ មានទឹកយ៉ាងតិចល្អម ក៏អាទំពែកបបួលគ្នាចុះទៅផឹកទឹកនោះដល់ចុះទៅដល់ក្នុងត្រពាំងកំពុងតែក្បង់ទឹកផឹក អាសំទក់វាមានវាចា ថាអញក្បង់ទឹកផឹកអំបាញ់មិញប្រទះឃើញត្រីរ៉ស់ ១ ប្រប៉ុនកំភួនជើងហើយវាលូកដៃវាទៅស្ទាបជើងវា អាទំពែកឮថាអាសំទក់ឃើញត្រីរ៉ស់ប្រប៉ុនកំភួនជើងក៏វាបបួលគ្នាបាចទឹកត្រពាំងនោះយកត្រី ហើយដល់បាច

ទឹកនោះខ្លាំងទៅវាខ្វាយទឹកខ្ទាតមកប៉ះក្បាលទំពែក ហើយអាសំបោហៀរទៅលើកដៃចង្អុលថា ត្រីហែលទៅខាងណោះ ហើយ ហកមកខាងណោះវិញហើយ ឯខ្នងដៃហើយនឹងប្រមុះប៉ះគ្នាហើយបានអាតព្រៀកទះដៃទៅបំមុខ ហើយនឹងទៅបៀតត្រជៀកវាថា ៗ អាណាធ្វើយ៉ាងម្តេចក៏អញស្តាប់បានដឹងទាំងអស់ ។

# ៥– រឿងបុរសកំជិលមានប្រពន្ធគ្រប់លក្ខណ៍

មានរឿងព្រេង ១ ដែលបានឮមក ថាមានបុរសកំជិល
ម្នាក់មាននាមមិនប្រាកដតែមានប្រពន្ធគ្រប់លក្ខណ៍ មានកិរិយា
ល្អគោរពប្រដិបត្តិប្តីតាំងពីចាប់ដើមបានគ្នាជាប្តីប្រពន្ធនោះបុរស
ខ្ជិលបេះតែពីដេកឃ្លានក្រោកឡើងស៊ីៗរួចដេកទៅវិញទៀតសូម្បី
ភ្ជុំដក់ក៏ឲ្យប្រពន្ធមួរឲ្យដែរ ប្រពន្ធក៏ជាមនុស្ស គោរពប្រដិបត្តិប្តី
មិនមានពាក្យអាក្រក់និយាយទៅលើប្តីសោះ លើកបាយទឹកនឹង
របស់អ្វីសំពះ ដល់នៅយូរទៅមានសេចក្តីក្រខ្វាំងណាស់ នាង
នោះក៏រកអ្វីពិញ្ចឹមពុំបានសោះហើយ ថ្ងៃ ១ នាងរៀបស្លា ៥ ម៉ាត់
បារី ៥ ចូលទៅក្រាបសំពះប្តីថាខ្ញុំសុំទោសអ្នកប្តីដ្បិតយើងសព្វ
ថ្ងៃក្រណាស់យើងមិនបានរកស៊ីគ្មានអ្វីទទួលទានទេ សុំឲ្យអ្នក
ប្តីទៅរកកាប់នង្គ័លរនាស់ធ្វើស្រែនឹងគេរដូវធ្វើស្រែហើយ ប្តីឮ
ថាឲ្យនាងដាំបាយរៀបជាសំណុំប្តីនឹងទៅរកកាប់ឈើធ្វើនង្គ័ល
រនាស់ ប្រពន្ធក្រោកពីយប់ដាំបាយរៀបជាកញ្ចប់មានជឹងពូហៀ
រៀបទុកឲ្យ បុរសកំជិលដេកទាល់ថ្ងៃរះប្រពន្ធពុំហានដាស់ចាំ

ឲ្យក្រោកខ្លួនឯង ដល់ក្រោកហើយប្រពន្ធដងទឹកទៅឲ្យលាង មុខរួចស្រេច នាងក៏ហុចស្លាបព្រាទៅឲ្យប្ដីនឹងបាយកញ្ចប់គ្រឿង ប្រដាប់ បុរសនោះក៏ចុះពីលើផ្ទះទៅចូលក្នុងព្រៃកឃើញ ឈើ ១ ដើមមែកសាខាមូលត្រជាក់ បុរសនោះក៏ដាក់បាយសំ-ណុំដឹងពួយើ ហើយដេកគងអន្ទាក់ខ្លាមើលទៅលើហើយនិ-យាយតែម្នាក់ឯងថាមែកនេះត្រូវធ្វើភ្នាងនង្គ័លមែកនេះធ្វើជាយាម មែកនេះត្រូវធ្វើដងមែកនេះត្រូវធ្វើនឹមមែកនេះត្រូវធ្វើរនាស់ គ្រាន់ តែដេកថាបណ្ដើងដល់ពេលឃ្លានបាយក្រោកឡើងស្រាយបាយ សំណុំស៊ី ៗរួចដេកថាដូចមុនទៀត ថ្ងៃរសៀលត្រឡប់មកផ្ទះវិញ ប្រពន្ធឃើញរត់ទៅទទួលយកគ្រឿងប្រដាប់នាំប្ដីឡើងលើផ្ទះយក ទឹកលាងជើងឲ្យប្ដីហើយសួរប្ដីថាអ្នកទៅបានការដូចម្ដេចខ្លះ ថា មិនទាន់បានទេនាងចាំស្អែកបានទៅទៀត ដល់ព្រឹកឡើងប្រ-ពន្ធរៀបចំដូចមុនបុរសនោះទៅទៀតដល់កន្លែងដើមឈើមុននោះ ក៏ដេកគងអន្ទាក់ខ្លាដូចមុនទៀតគ្រប់ ៣ ថ្ងៃ ដើមឈើនោះមាន អរុក្ខទេវតាអាស្រ័យនៅនោះឮបុរសកំជិលថាដូច្នោះ ក៏ភិតភ័យ

ខ្លបខ្វបទីលំនៅរកកន្លែងនៅគ្មាន ក៏គិតគ្នានឹងតាមទៅវាយសម្លាប់បុរសកំជិលនេះឲ្យស្លាប់នៅមាត់ជណ្ដើរផ្ទះកុំឲ្យវាមកកាប់ឈើនេះបាន បុរសនោះក៏ត្រឡប់មកផ្ទះវិញ អរុក្ខទេវតាតាមមកដល់មាត់របង នាងជាប្រពន្ធរត់ទៅទទួលប្ដីដល់មាត់ជណ្ដើរយកទឹកលាងជើងប្ដីទេវតាខ្លបសិរីសួស្ដីប្រពន្ធនោះចូលមិនចុះមិនហានវាយ បុរសនោះក៏រួចពីអន្តរាយឡើងលើផ្ទះទៅប្រពន្ធសួរនិយាយដូចមុនទៀតថាបានគ្រប់សព្វអស់ហើយព្រឹកនឹងទៅកាប់ វេលានោះទេវតាភិតភ័យណាស់ បុរសនោះមុខជាកាប់ហើយព្រឹកនេះក៏នាំគ្នាមកនិយាយអង្វរថាសុំកុំឲ្យកាប់ដើមឈើនោះ បុរសថាអញមិនព្រមទេ ព្រឹកនេះអញទៅកាប់ហើយ ទេវតានោះភ័យណាស់ក៏មកគិតគ្នានិយាយសូកប្រាប់ទីកន្លែងកំណប់មាសប្រាក់នោះឲ្យបុរស ៗ ថាឲ្យកំណប់អញប៉ុន្មានកន្លែង ទេវតាថាពីរកន្លែង ថាមិនព្រមទេបើ ៤ កន្លែងបានព្រមហើយឲ្យដាក់ឈើសំគាល់ឲ្យផង ទេវតាក៏ព្រមធ្វើតាមកុំឲ្យតែកាប់ដើមឈើនោះបុរសថាខ្ញុំលែងកាប់ព្រឹកនេះខ្ញុំទៅគាស់កំណប់យកហើយ ទេវ-

តាហាទៅបុះខ្ទុំដោតឈើសំគាល់ឲ្យ ដល់ព្រឹកឡើងនាំប្ដីប្រពន្ធទៅគាស់កំណប់ដែលទេវតាឲ្យ ក្នុងកំណប់មួយ ៗ ជញ្ជូនបីថ្ងៃពីរនាក់ប្ដីប្រពន្ធសុទ្ធតែមាសនឹងប្រាក់ហាក់គរពេញផ្ទះ នាងនោះក៏រៀបចំដាក់ហិបដាក់ឡាំងមិនឲ្យអ្នកណាឃើញ ហើយក៏យកជាងមកជួលឲ្យធ្វើគ្រឿងប្រដាប់លលក់ជាជុំនួញ រិតតែមានឡើង ៗ បានជាសេដ្ឋី ១ មានមនុស្សក្រុះករមូលមកនៅពឹងទ្រព្យជាច្រើនរាប់មិនអស់ ។០៚—

# បញ្ជីសៀវភៅដែលមានជាវនៅទីព្រះរាជបណ្ណាល័យ

| | | |
|---|---|---|
| ព្រះត្រៃបិដក (បាឡីនឹងប្រែជាមួយគ្នា) ១ ឈប់ ១០០ សៀវភៅ | ថ្លៃ | ២៥០'០០ |
| រឿងព្រះពុទ្ធសាសនា សៀវភៅធំហើយក្រាស | " | ១'៥០ |
| អភិធម្មត្ថសង្គហ ទើបនឹងបោះពុម្ពលើកទី ២ | " | ១'២០ |
| ដំណាលពុទ្ធចេតិយ (មានរូបថ្លុកពុម្ពច្រើន) | " | ១'៨០ |
| កច្ចាយនូបត្ថម្ភក, របៀបរៀនបាឡីយ៉ាងឆាប់ ខ្សែ ១ | " | ១'៣០ |
| ខ្សែ ២ | " | ១'៤០ |
| បញ្ញាសជាតក ខ្សែ ១ (រឿងព្រះសមុទ្ទឃោស នឹងព្រះសុធន) | " | ០'៥០ |
| គិហិបដិបត្តិ, វិធីសមាទានរក្សាសីល សំរាប់ឧបាសក-សិកា | " | ០'៤៥ |
| សាមណេរវិន័យ, សិក្ខាបទសម្រាប់សាមណេរសិក្សា | " | ០'៣០ |
| បាដិមោក្ខសង្ខេប, សិក្ខាបទសម្រាប់ភិក្ខុសិក្សា | " | ០'៣០ |
| ១០០ គាថា, គឺគាថាចំនួន ១០០ ដកយកពីគម្ពីរផ្សេងៗ មានធម្មបទជាដើម | " | ០'២០ |
| មនោបុញ្ញកថា | " | ០'១៥ |
| ទសបារមីកថា, និយាយអំពីបារមីទាំង ១០ របស់ព្រះសម្មាសម្ពុទ្ធ | " | ០'៣០ |
| សីមាវិនិច្ឆ័យ | " | ០'១០ |
| នាគោបមាទិកថា | " | ០'០៨ |
| ញាណកថា | " | ០'១២ |
| សុរាទោសកថា, សម្តែងអំពីទោសដែលកើតឡើងដោយការសេពសុរា | " | ០'០៥ |
| អនុត្តរិយសូត្រ | " | ០'០២ |
| អំពីប្រាសាទវត្តនគរ (អក្សរខ្មែរ) | " | ០'៣៥ |
| (អក្សរសៀម) | " | ១'០០ |
| ដើមកំណើតប្រាសាទអង្គរ (អក្សរបារាំង) | " | ១'៥០ |
| ពុទ្ធោវាទានុសាសនី, សេចក្តីបោទនាទ្ធើយអំពីធម៌របស់ឧបាសក-សិកា | " | ០'១៥ |
| មរណានុស្សតិកម្មដ្ឋាន, សេចក្តីរំពឹងដល់សេចក្តីស្លាប់ | " | ០'៤០ |
| អនត្តលក្ខណសូត្រ | " | ០'១០ |
| កាលាមសូត្រនឹងបរាភវសូត្រ, អំពីការមិនគួរជឿនឹងហេតុដែលនាំឲ្យវិនាស | " | ០'១៥ |
| ច្បាប់ថ្មី, ពាក្យកាព្យរបស់ក្រមង៉ុយ សម្រាប់ប្រដៅប្រុសស្រី | " | ០'១៥ |

ព្រះរាជបណ្ណាល័យកម្ពុជា

# KAMPUCHÉA SURIYA

# កម្ពុជសុរិយា

សៀវភៅទស្សនាវដ្ដីចេញរាល់ខែ ពីព្រះរាជបណ្ណាល័យ

ឆ្នាំគំរប់ ៦ VI

ខែ ១០, ១១, ១២, រួមគ្នា

កុង្ស៊ីយសេនាបតីបានអនុញ្ញាតហើយ
សម្ដេចសង្ឃនាយកទាំងពីរគណៈយល់ព្រម

ព្រះរាជបណ្ណាល័យកម្ពុជា
BIBLIOTHEQUE ROYALE DU CAMBODGE

ភ្នំពេញ
ការផ្សាយរបស់ព្រះរាជបណ្ណាល័យ
ព.ស. ២៤៧៧
គ.ស. ១៩៣៤

អ្នកទទួលខុសត្រូវ: ជុំ-ម៉ៅ

# សូមជូនដំណឹងដល់អ្នកមើលទស្សនាវដ្ដីកម្ពុជសុរិយា

---

ក្នុងឆ្នាំទី ៦ នេះ សៀវភៅទស្សនាវដ្ដីទាំង ១២ ខ្សែ រួមមកដេរផ្ចាប់គ្នាជា ៤ ក្បាលវិញ គឺក្នុង ១ ក្បាលមាន ៣ ខ្សែ ៗ ដែលយើងធ្វើដូច្នេះនេះ គឺប្រយោជន៍ដើម្បីឲ្យបានរហ័សឆាប់ផងនឹងឲ្យបានធូរសោហ៊ុយក្នុងការជួលបោះពុម្ពនោះផង ព្រោះសៀវភៅទស្សនាវដ្ដីក្នុងឆ្នាំនេះបន្ថយថ្លៃចុះមកត្រឹម <u>៤ រៀល</u> ក្នុង ១ ឆ្នាំ ហើយចំនួនទំព័រនៅដដែល ថែមមានរឿងរ៉ាវកាន់តែប្លែកពីរោះច្រើនជាងឆ្នាំមុនៗ ។

យើងមានសេចក្ដីសង្ឃឹមថាអ្នកមើលទស្សនាវដ្ដីទាំងអស់គ្នា នឹងមានសេចក្ដីសង្ឃឹមទុកចិត្តលើយើងតទៅ ហើយនឹងចុះឈ្មោះជាវជាថ្មីឡើងទៀតមិនខាន ។ល។—

ព្រះរាជបណ្ណាល័យកម្ពុជា

# បញ្ជីរឿង


ទំព័រ

១ — រឿងបឋមសម្ពោធ បទល្ខោន របស់ឧកញ៉ាសុត្តន្តប្រីជា ឥន្ទ . . . . ៥

២ — កាលលោកក្រាហ៊្វយគូវែរណើរយេណេរាល់ ប. អ. អញ្ជើញមកមើលព្រះរាជបណ្ណាល័យ . . . . . . . . . . . . . ៣៩

៣ — ឯកនិបាតជាតក - ៣. ទុមេធជាតក អាចារ្យហ៊ាមក្រុមជំនុំព្រះត្រៃបិដកប្រែចេញពីបាឡីមកជាភាខ្មែរ . . . . . . . . . . ៤៥

៤ — ពាលចិត្តប្បពោធនសូត្រ ឧកញ៉ាកក្តីភាជា យ៉ាំង អាចារ្យបង្រៀនបាលាបាឡីជាន់ខ្ពស់ ប្រែចេញពីបាឡីគម្ពីរខុទ្ទកបាឋ មកជាភាសាខ្មែរ . . . ៥៦

៥ — ពហុទូលិ - ទ្រិត បុណ្យបូជាទេវធិតារក្សាផ្លៀង ស្រង់ចេញពីសៀវភៅអ័ល្បូនៈ របស់លោករពិន្ទ្រនាថតាគោរ ក្រុម្ការ ជុំ-មៅ ប្រែចេញពីភាសាបារាំងសែស មកជាភាសាខ្មែរ . . . . . . . . . . ៨៥

៦ — កាលលោក វិណោរេបាំង គូវែរណើរយេណេរាល់ប្រទេសឥណ្ឌូសិនអញ្ជើញមកទស្សនាការពុទ្ធសាសនបណ្ឌិត្យ . . . . . . . . ៩៧

៧ — ឯកសហស្សរាត្រី ឬមួយពាន់មួយយប់ ក្រុម្ការ ជុំ-មៅ ប្រែចេញពីភាសាបារាំងសែសមកជាភាសាខ្មែរ (ត) . . . . . . . . . . ១០៤

៨ — រឿងព្រេងខ្មែរដែលមិនទាន់ចេញផ្សាយៈ

១ — រឿងជាតិសត្វខ្លាធំ . . . . . . . . . . . . ១៣៤

២ — រឿងបុរសម្នាក់មានកូន ៤ នាក់ សិក្សាជំនាញស្ទាត់នូវវេទវិជ្ជា៤បទ ១៣៨

៣ — រឿងបុរសម្នាក់ឈ្មោះចៅអាចម៍សេះ . . . . . . . . ១៤៩

៩ — អំពីមរណភាពលោកម៉េណៅទ្រិយេរជាចាងហ្វាងសាលាឱ្យជាដើម្បាត្រៃក្រុងភ្នំពេញ . . . . . . . . . . . . . . . ១៥៤


# រូបថ្តិតពុម្ព


១ — លោកក្រាហ៊្វយកំពុងមើលរថយន្តផ្ទុកសៀវភៅរបស់ពុទ្ធសាសនបណ្ឌិត្យ . . . . . . . . . . . . ៤០

២ — នៅទីក្រុមជំនុំព្រះត្រៃបិដក . . . . . . . . . . ៩៨

៣ — លោកវិណោរេបាំង គូវែរណើរយេណេរាល់ប្រទេសឥណ្ឌូស៊ីនទស្សនាការរថយន្តផ្ទុកសៀវភៅពុទ្ធសាសនបណ្ឌិត្យ . . . . ១០២

៤ — លោកម៉េណៅទ្រិយេរ. . . . . . . . . . . . . ១៥៤

# TABLE DES MATIÈRES

Pages

1° — Le grand départ du Bodhisattva, pour atteindre la Bodhi — Pièce composée par l'Okuha Suttantaprichéa Inn .............................. 5
2° — Visite de M. Graffeuil, Gouverneur Général p. i. à la Bibliothèque Royale ......................... 39
3° — Eka Tripāta Jātaka. III. Dumedha Jātaka, traduit du pāli en cambodgien par l'Achar Him, membre de la Commission du Tripitaka .......... .......... ..... 45
4° — Bālācittappabodhana Sūtra, tiré de Khudakapāṭha et traduit du pāli en cambodgien par feu Oknha Phéakdey Réachéa Yaing, Professeur à l'Ecole Supérieure de Pāli à Phnom-Penh ............... 56
5° — BAHADULI-VRATA ou culte de la déesse de la pluie, tiré de l'Alpona de Rabindranath Tagore et traduit du français en cambodgien par Kromokar Choum-Mau 85
6° — Visite de M. René Robin, Gouverneur Général de l'Indochine, à l'Institut Bouddhique.. ............ 97
7° — Eka Sahasrarātrī ou les Mille et une nuits, (contes Arabes) traduit du français en cambodgien par Kromokar Choum-Mau (suite)...... ............ 104
8° — Contes populaires cambodgiens inédits :
I — Légende sur l'origine des tigres............ 134
II — Histoire d'un homme qui a quatre enfants possédant chacun une science différente..... 138
III — Conte de Chau Ach Sès ou l'homme au crottin de cheval .............................. 149
9° — Notice nécrologique sur M. Ménétrier ........... 154

## ILLUSTRATIONS :

I — M. Graffeuil visitant l'auto-librairie de l'Institut Bouddhique............................... 40
II — Dans la Salle de la Commission du Tripitaka à l'occasion de la visite de M. René Robin Gouverneur Général...................... 98
III — M. René Robin devant l'auto-librairie de l'Institut Bouddhique lors de sa visite à cette institution le 27 Juillet 1934 ............... 102
IV — Portrait de M. Ménétrier................ 154

រឿងបឋមសម្ពោធិ

ពាក្យកាព្យ

បទស្មោនរបស់ឧកញ្ញាសុត្តន្តប្រីជា ឥន្ទ

រៀបរៀង

## បទ ៣

យើងនឹងថ្លាថ្លែងបែងដោយអាទ៍ កាលអង្គលោកនាថរាជ នាថា សោយសុខសម្បត្តិខត្តិយា ក្នុងមហានគរកបិលពស្តុ ។ ព្រមទាំងព្រះវង្សរាជពង្សា សែនមហារុងរឿងច្រើនសក្តិយស បិតុរង្គអភិរម្យសោមនស្ស ឲ្យមហាបុរសគ្រងបូរី ។ ក្រមក្សាន្ត សំរានដោយនាងស្នំ ប្រគំបំរើស្មើប្រក្រតី ស្តេចមានព្រះអគ្គ អ្គ្រេសី ទេវីទ្រង់នាមព្រះពិម្ពា ។ ជាចមលែងស្នំនារីរតន៍ ព្រះ កាយប្រាកដល្អសោភា មានព្រះឱរសរឿងឫទ្ធា នាមារាហុល រាជកុមារ ៘ ពាក្យ ។ ពន្ធសិន្ធុ ។ ច្រើនបុណ្យច្រើនគុណអនន្តឯក អនេកៈលើសលប់ទាំងភពភារ រយឯកពុះបួលជាបរិពារ នាំ សារអាករឋ្វាយក្សត្រថ្លៃ ។ ទិសទសស្ញប់ស្ញែងក្រែងអំណាច

ពុំអាចតរឹទ្ធិ៍ប្រឡងដៃ ស្តេចសោយរាជគ្រងក្នុងវៀងវៃ ព្រះ-ជន្មម្ភៃប្រាំបួនប្លាយ ៨ ។ ថ្ងៃមួយស្តេចទ្រង់ព្រះវិតុក ជាទុក្ខនឹងរាជន្វរាងកាយ កើតស្លាប់វិប័ត្តិព្រាត់ខ្វាត់ខ្វាយ អន្តរាយដោយក្តីភ័យមរណា ។ អធុរំ លំអៀងមិនទៀងទាត់ សង្ខារសព្វសត្វសឹងអនិច្ចា វិលវល់នៅក្នុងសង្សារា អវិជ្ជាបង់ជិតងងឹតជុំ ។ ព្រះទ្រង់នើយណាយកាយលោកិយ៍ បក្រីបង់សាងភិនេស្ក្រម ស្វែងមគ្គស្វ័កផល់ថ្កល់បរម និព្វានសុខុមជាសុខា ។ ទើបទ្រង់ក្រោកចាកព្រះទៃនទ៌ ពោធិចាត់បែងតែងកាយា បើកព្រះយើភ្ជូសុវណ្ណា យាត្រាចេញចាកព្រះប្រាង្គណ៍ស្ថាន ៨ ។ ពាក្យ ។ ស្មើ ។

លុះយាងដល់មកទ្វារប្រាសាទ បរល់ឆន្នអាមាត្យដេកឱបប្រាណ ទើបដាស់នាយឆន្នហើយត្រាសហ្កាន បងើយបងមានចិត្តភ័ក្តិ ។ ចូរបងដោះហ្លួងឆាប់ម្នីម្នា ទៅយកអសុពារាជពាជី បងគ្រឿងនាំមកឲ្យទាន់ទី យើងនឹងបរលើទៅសាងព្រឹល ៥ ។ ៣.ក្យ ។ គ្រាអើយគ្រានោះ នាយឆន្នអាមាត្យជាតិ

បណ្ឌិត កំពុងនិទ្រាលក់លក់ស្និទ លុះឮទ្រង់រិទ្ធិដាស់អាត្មា ។ នាយឆន្នក៏ក្រោកពីដំណេក ក្រលេកបែរយល់ព្រះបក្រា តក់ស្លុតរន្ធត់ភិតតក្រមា ក្រាបឱនសិរសាបង្គំខ្ញី ។ ទូលសួរបពិត្រខត្តិយា មានបើទៅឯណាទាំងរាត្រី ទូលបង្គំលក់ពុំដឹងស្មារតី បក្រីមកដាស់ខុសវេលា ៣ៗ ពាក្យ ។ កាលអើយអើយកាល្នោះ ព្រះបមរិទ្ធិវង្គពង្សពុទ្ធា លុះឮនាយឆន្នសួរកិច្ចាក្សត្រាក៏ថ្លែងបែងសេចក្តី ។ បងើយយប់នេះយើងត្រេកត្រង់នឹកបង់បេញសាងសម្ពោធិ បួរបងទៅនាំយកពាជី ក្នុងទីព្រះរោងឲ្យយើងវ៉ា ៤ៗ ពាក្យ ។ គ្រាអើយគ្រានោះ នាយឆន្នអាមាត្យបាទវិច្ចា ទទួលព្រះបន្ទូលព្រះបក្រា ម្នីម្នាទៅកាន់ព្រះរោងដែ ២ៗ ស្មើ ។ លុះដល់រោងសេះរាជភិរម្យ យល់សេះមួយធំសមប្រពៃ ទើបយកគ្រឿងបងរាជម្នោមៃ ស្រាយនាំបេញវិហ្កានក្សត្រា ២ៗ ពាក្យ ។ ស្មើ ។ ដល់ហើយនាយឆន្នបង្គំបាទ ទូលអង្គនរនាថរាជនាថា បពិត្រសេះនេះកបសក្តាគួរជារាជយានព្រះបក្រពង្ស ២ៗ ពាក្យ ។ កាល្នោះ ព្រះបម

វិសុទ្ធិពុទ្ធវង្ស ទទួលយកសេះព្រះយានទ្រង់ ប្រាស្រ័យកាន់
អង្គរាជពាជី ។ បងើយបងសេះកបរិទ្ធិវែង បូរជូនយើងឯង
បាកធានី បេញទៅសាងសំព្រះពោធិ ក្នុងទីរាត្រីនេះណាបង។
បើយើងបានត្រាស់ច្បាស់កាលណា នឹងសងគុណបាដែលចម្លង
ត្រាស់ស្រែបស្ដេចទ្រង់អង្អែលខ្នង ច្បាស់ច្បងឡើងគង់ដោយ
ទាន់ទី ។ នាយឆន្នអាមាត្យអគ្គស្រ័យ តោងកន្ទុយម្នោមៃរឿង
រិទ្ធី កៀវកៀកជាប់តាមរាជពាជី ដោយចិត្តភក្ដីតក្សត្រក្សាន្ត
៘ ពាក្យ ។ បទនោន ។ សេះអើយសេះទេស ប្រិបួនហ័ត្ថសេសសម
ប្រាន សខៀវរៀវវែងរិទ្ធិហាណ ទុកអានភូឆាយសាយហាង។
ស្រោបមាត់សឹងមាសសុវណ្ណ ឈ្នាន់ពាក់ផ្ទាក់ពន្លសងខាង
កែបកែមសែមសយសំអាង ពេជ្រប្រោះឆ្លោះព្រាងអម្ពរ ។
បន្ទំបែងសែងចាប់អារាមរឿង វាយផ្កាយចាប់គ្រឿងអលង្ការ
វាតផាយសាយផាត់ល្អងកេសរ ភូធរបើកបរបរចេញខ្មី ។
យានី ។ អស្សារ្យក៍ក្រើកស្ថានទេវា តត្រាជាបមក្នុងស្ងួគ៌ស្រី
បើកទិព្វបក្ខទតមកខ្មី យល់ព្រះពោធិបេញសាងព្រឹស ។

កោសីត្រេកអរពន់កាំលាំង ចាប់សង្ខផ្លុំឮទាំងឋានបិត បតុ-
លោកមហាព្រហ្មបុរោហិត ប្រសិទ្ធិពរថ្វាយព្រះបមពល ។
អស់ហ្វូងទេព្តាព្រហ្មទាំងអស់ សោមនស្សប្រជុំទាំងសាកល
នាំគ្នាហោះបុះហែទសពល ពេញទាំងមណ្ឌលផ្ទៃមេឃា ៗ ពាក្យ
ត្ថុំ ។ (ភាយ) លុះហោះមកដល់ផ្ទៃផែនដី កោសីហែមុខព្រះ
ភជា បតុលោកទ្រើងអស្សុពា ព្រហ្មាកាងឆ័ត្របាំងក្សត្រ
ក្សាន្ត ។ ទេវតាតូបធំជុំស្មោះសរ ត្រេកអរប្រគំភ្លេងសួគ៌ស្ថាន់
បន្លឺថ្វាយដែកងស័ព្ទសាន់ ហោមជុំក្សត្រក្សាន្តហែបរលី ៗ ពាក្យ ។
ដើត ។ បទធា ។ នឹងថ្លែងបែងដល់ក្រុងមារា ស្មោយសុខនៅ
នាស្ថានសួគ៌ស្រី ឈ្មោះបរៈនេមិត្តវស្សវតី អសុរីជាបមទេព
ទេវា ។ ក្រេមក្សាន្តសម្រានក្នុងស្ថានស្ថិត ស្នមស្និទសឹង
នាងទេពកញ្ញា គង់គាល់បំរើអសុរា ទេវតាកោតក្រែងស្ញែង
បារមី ។ ពន្ធសឹង្គ ។ យក្ខមានព្រះរាជធិតា ទាំងបីអង្គា ស្រស់
ប្រិមប្រិយ ឈ្មោះនាងរាគាអរតី តណ្ហាប្អូនស្រីទាំងបីអង្គ ។
សឹងមានបរិវារកញ្ញាសួគ៌ គំនាប់គាប់គួរ ៗ ភិសៈវង់ តែង

ឡើងគាល់មារជាបិតុរង្គ នៅក្នុងប្រាង្គណ៍កែវអលង្ការ ៤។ ពាក្យ
ភយ ។ ថ្ងៃដែលពោធិ៍បេញសាងផល ដំណឹងដឹងដល់មក
ក្រុងមារ អសុរីកើតចិត្តអហង្ការ គិតក្រែងភូវនាប់ផុតនិស្ស័យ ។
ឯះចៅសិទ្ធត្ថរាជកុមារ បេញបង់សង្ខារគ្រានេះនៃ ទៅបួស
ព្រួសផុតកណ្តាប់ដៃ កន្លងនិស្ស័យអញហើយណា ។ បើប្រះ
មានតែទៅហាមគាត់ ឃាត់កុំឲ្យភ្លាត់ពីលោកា គិតៈស្រុបអ-
សុរីរៀបអាត្មា ចាប់កែវក្រទាបេញបរខ្មី ៦។ ពាក្យ ។ ក្រោណៃ
ដើត ។ លុះដល់យក្ខយល់ពង្សពុទ្ធា គង់លើអសុពារៀងរង្សី
ឥន្ទព្រហ្មហោមជុំជាកោសី អសុរីក៏ស្រែកសួរទៅថ្វាត់ ។ នែ
ចៅសិទ្ធត្ថរាជកុមារ មកបង់សង្ខារការប្រតិព័ទ្ធ ទៅណាមក
ណាទាំងយប់ស្ងាត់ ខុសភេទមហាក្សត្រពីបូរាណ ៤។ ពាក្យ ។
កាល្មោះ ព្រះបមមាលីរិទ្ធិហាន លុះឮក្រុងមារសាកសួរដាន
ក្សត្រក្សាន្តក៏មានបន្ទូលខ្មី ។ រុំយចៅមារាទុច្ចរិត យើងទៅ
សាងព្រឹឍព្រហ្មចារីយ៍ ឲ្យបានជាយានលោកទាំងបី ល្ងល់
អ្វីមកសួរយើងប្រះណា ៤។ ពាក្យ ។ កាល្មោះ ក្រុងមារ

អសុរិន្ទយក្សា បានស្ដាប់ពោធីថែងឈ្មោះណា ទើបតបវាចា ប្រលោមក្សត្រ ។ ហៃចៅសិទ្ធត្ថបុត្រសុធោទន៍ កុំឆោតទៅបួសលើយសិទ្ធត្ថ ប្រាំពីលថ្ងៃទៀតមានចក្ររតន៍ សម្រាប់ចក្រពត្រកើតដល់អ្នក ។ ហេតុនុះបួលវិលទៅក្រុងវិញ កុំទៅស្រលេញពុទ្ធចក្រ គួរតែស្រលេញខាងយសស័ក្តិ មហាចក្រជាធំក្នុងលោកិយ៍ ៦ ពាក្យ ។ កាលណោះ ព្រះបមនរិន្ទរឿងរង្សី លុះឮមារាមាយាស្ដី ចក្រីក៏ត្រាស់សងវាចា ។ អើយមារមាយាកុំមកហាម យើងនេះពុំតាមពាក្យទេណា មហាចក្រនុះយើងពុំប្រាថ្នា ដូចជាទឹកមាត់ទឹកម៉ូត្រហ្មង ។ យើងមកនេះប៉ង ពោធិញាណ ជាស្ពានចម្លងនៃសត្វផង មារឯងកុំនាំយកបំណង មកបង្កយើងនេះពុំជាប់ឡើយ ។ ចូរជៀសចេញទៅណាមារា យើងបរអសុពាតឡូវហើយ តែនៅភ្លៅបាក់ពុំលែងឡើយ មារើយបើកផ្លូវយើងនឹងទៅ ៨ ពាក្យ ។ កាលណោះ ឯក្រុងមារិតចិត្តឃោរឃៅ ឮព្រះបន្ទូលក្សត្របរមចៅរឹងពុំវិលទៅរាជរដ្ឋា ។ ទាល់ចេះទាល់ចិត្តគិតយក្ខ កើត

អៀនអន់អាក់ព្រះបក្រា អសុរីពុំសមក្តីប្រាថ្នា ទើបលាពោធី កាន់ទីស្ថាន ៤ៗ ពាក្យ ។ ដើត ចូល ។ ឯអង្គព្រះនរិន្ទពិនត្រៃ ភព្វ យល់មារត្រឡប់ទៅវិមាន ព្រះទ័យភិរម្យពោធិញាណរា ទើបបរអស្សយានដោយវេហាស ២ៗ ពាក្យ ។ ដើត ។ លុះយាងមក ដល់ស្ថានផលធី អនោមានាទីហេមវា ទើបទ្រង់បញ្ឈប់អសុពា វាជាយាងចាកម្ចោមៃមេយ៍ ២ៗ ពាក្យ ។ រូ ។ ប្លែងឯអស់ហ្វូង ទេពទេវា ឥន្ទ្រាជាធំក្នុងដែនត្រៃ កាលហែជូនអង្គក្សត្រថ្លាថ្លៃ ដល់ឭនាទីអនោមា ។ ទើបគាំគ្នាលាបមក្សត្រក្សាន្ត ត្រឡប់ វិលស្ថាននៃអាត្មា កោសីក៏ទៅត្រៃត្រឹង្សា ព្រហ្មាក៏ទៅព្រហ្ម វិមាន ៤ៗ ពាក្យ ។ ដើតចូល ។ យានី ។ ឯឯណោះមែនមានទេព្វ ឧត្តម ឈ្មោះកាដាកមហាព្រហ្មរិទ្ធិប្លើងប្លាន ជ្រាបថាព្រះ ពោធីក្សត្រក្សាន្ត បេញសាងភិញ្ញាណពុទ្ធសម្ភារ ។ មហា- ព្រហ្មត្រេកអរអំណរក្រៃ ចាត់ត្រៃបាតប្រិត់គ្រឿងបរិក្ខារ សម្រាប់ អ្នកបួសហ្លួសសង្សារ ចាត់ស្រែបត្រអាលហោះបុះខ្មី ៤ៗ ពាក្យ ត្នុំ ។ លុះហោះមកដល់ក្សត្រឧត្តម មហាព្រហ្មក៏ចូលទៅវិន្ទី

លើកយកបរិក្ខារថ្វាយពោធិ ថ្លែងដោយសាមគ្គីរសវាចា ។ បពិត្រព្រះសិទ្ធត្ថខត្តិយវង្ស គ្រឿងនេះប្អូនទ្រង់បព្វជ្ជា ថ្វាយស្រេចមហាព្រហ្មបង្គំលា វិលទៅកាន់មហាវិមានព្រហ្ម ៗ ៣ក្យ ដើតចូលឆាក ភយ ។ កាលណោះ ព្រះបរមមោលីក្សត្រឧត្តម ទទួលបរិក្ខារមហាព្រហ្ម អភិរម្យប្រីយ៍ប្រែមកស្រែមអង្គ ។ ទើបទ្រង់ដោះគ្រឿងអលង្ការ មកុដកែវសង្វារអាភរណ៍ទ្រង់ កណ្ដាលចាហុវ័កព្រះទម្រង់ ស្រេចទ្រង់ត្រាស់កាន់នាយឆន្នា ។ ហៃឆន្នអមាត្យបិត្តភក្តិ បងើយកុំបីមានកង្វា ប្អូនតាំគ្រឿងនេះ នឹងអស្សពា វិលទៅភារាប្ញូរវិញ ។ បងទៅក្រាបទូលព្រះបិតុរង្គ កុំឱ្យស្ដេចទ្រង់ជាទុក្ខម្នេញ មួយទៀតបងទូលពីរឿងអញ បេញមកបំពេញពោធិញាណ ៗ ៣ក្យ ។ គ្រានុះ នាយឆន្នអមាត្យជាតិទាហាន ឮទ្រង់ត្រាសប្រើឱ្យវិលស្ថាន វិមានពុំបង់នឹងបរលី ។ ដោយក្ដីស្រឡាញ់ពោធិសត្ត ពុំចង់ឱ្យព្រាត់បេញចាកទី តែខ្លាចអំណាចព្រះភូមី ចាំបិត្តបរលីទាំងទុក្ខា ។ ខំប្រឹងឱនសីរបង្គំរាប់ ទទួលប្រដាប់គ្រឿងក្សត្រា

ក្រោកដើរដឹករាជអសុញា នេត្រាគន់មើលតែពោធិ៍ ៚ ពាក្យ ។

គ្រានុះឯសេះគន្ធព្វរាជពាជី ស្លុតត្រង់តអង្គព្រះភូមី ពុំបង់បាកទី

ពីក្សត្រក្សាន្ត ។ គ្រ័នឆន្នអាមាត្យដឹកបរលី ពាជីរន្ធត់ស្លុត

វិញ្ញាណ អន់អួលក្នុងចិត្តអាណិតប្រាណ សន្តានជាសត្វពុំបេះ

ស្ដី ។ គិតតែក្នុងចិត្តថាឱអញ កើតមកនេះពេញជាក្រក្រី កំ-

ណើតតិរច្ឆានពុំដឹងអ្វី នឹងស្ដីអង្វរនៅអាសា ៚ ពាក្យ ។ ពីណាប ។

អនិច្ចាឱអញស្រឡាញ់ម្ចាស់ ឥឡូវមកប្រាសម្ចាស់ប្នះណា

ព្រះអឺយព្រះនៅតែឯកា នឹងបាននរណាកំដរប្រាណ ។ ខ្ញុំនៅ

ទៅវានឹងបំរើ តាមដោយអំពើជាតិរច្ឆាន ឥឡូវព្រោសប្រើឱ្យ

វិលស្ថាន វិខានមិនបង់នឹងបរលី ។ សេះសោកសល់សែន

ណែនឱរា នេត្រាជោរជល់សល់សែនទ្វី ស្រយ៉ុតស្លុតស្លាំង

គាំងឥន្ទ្រីយ៍ ឱនសីរង្វូលីសៅសោកា ៚ ពាក្យ ។ អូត ។

សង្ហារសេះសត្វខំកាត់ចិត្ត អាណាចអាណិតអាណោចណា

អ័កអួលក្ដួលក្ដៅសៅភ័ក្ត្រា គិតថាឱអញពេញសោសល់ ។

អាភ័ពកំណើតកើតជាសត្វ ទាន់ព្រះហើយបាត់ផ្លូវមគ្គផល សិ

ណាងពុំបំជាបុគ្គល នឹងបួសសាងផលតាមក្សត្រា ។ នេះរូប ជាសេះបួសម្តេចបាន សន្តានអាភ័ពដូព្រេះណា អញើយស៊ូ ស្លាប់យកជីវ៉ា ផាគ្រឿងបូជាព្រះបមក្សត្រ ។ សេះ ជីរបាឌតិប គេបមើលក្រោយ កន្សែងសោកសោយឡស្រែង៉ាត់ អស្សុត្តរ ក៏បែកប្លើមប្រម៉ាត់ ដួលបុាត់អស្មាតខាតជីវី ៙ ពាក្យ ។ អូត ។ គ្រានុះ នាយឆន្នអាមាត្យជាតិមេធី ឃើញរាជម្ចាមៃយ៍ ក្សយជីវី តក់ស្លុតឥន្ទ្រីយ៍ភាំងភិតភ័យ ។ រត់ទៅរត់មកឈ្ងោក មើលសេះ បាប់ម៉ែះមើលដឹងអាការក្សយ នាយឆន្នសុបសៅ សែនអាល័យ សង្រែវិយោកឱនសោកា ។ ឱអ្នកគន្ធស្សរាជ អើយ មិនគួរលើយមកក្សយផន្ទា ហោលយើងឲ្យនៅកំព្រា វេទនាតែឯងទៅក្រុងក្រៃ ។ ស្តាយើយសែនស្តាយបងគន្ធស្ស មិនគួរមកអស់ជីវ៉ាលៃ ហោលរូបហោលរាងកណ្តាលព្រៃ ហាលផ្លៀងហាលថ្ងៃព្រះអាទិត្យ ។ កាលដើមយើងមកជា មួយគ្នា ជូនព្រះរាជាបេញសាងព្រឹឈ ឥល្ងូវអ្នកមកស្សូន្យ ជីវិត ទាល់គិតទាល់បេះរិះមិនយល់ ។ អ្នកឯងពេញ

ជាសត្វដឹងគុណ ម្ចាស់លោកមានបុណ្យបេញសាងផល
ស៊ូយកជីវិតថ្វាយទសពល សូមផលឲ្យអ្នកបានសុខា ។
តែខ្ញុំរសនៅទៀតគរ ក្តីមរណ៍ពុំដឹងជាថ្ងៃណា ទូញហើយ
នាយឆន្ទទន់កាយា ឱនជ្រប់ភ័ក្ត្រាសោកាលៃ ។ នាយឆន្ទ
កំសាន្តក្តីវិយោគ ខំក្រោកស្រាយឃកគ្រឿងម្នោមៃយ៍ បត់ដាក់
សំពាយស្ពាយជាទៃ ស្រេចហើយប្រាស្រ័យលាអសុពា ។
ហៃសាកសព់សេះគន្ធស្បអើយ ខ្ញុំលាទៅហើយណាអ្នកណា
ថាស្រេចចាប់គ្រឿងស្ពាយម្នីម្នា លីលាដម្រង់ទៅក្រុងត្រៃ ។
ថ្លែងឯព្រះនរិន្ទពិននរនាថ ក្រោយឆន្ទអាមាត្យវិលវៀងវៃ
ស្តេចនៅតែឯងកណ្តាលព្រៃ ព្រះទ័យរឹងកងត្រៃលក្ខណ៍ ។
ទ្រង់ត្រៃចីវរមហាព្រហ្ម ជាសង្ឃ្យសក្តិសមអរិយមគ្គ រំសាយ
ព្រះផ្នួងកេសាធ្លាក់ បមប័ក្របង់កាត់ព្រះកេសា ។ តែរកព្រះ
ខ័នកាត់ពុំបាន ក្សត្រក្សាន្តគង់ភ្នែនលើអាស្នា ព្រះហស្តប្រ-
ណម្យតាំងសច្ចា ប្រនិធានបុញ្ញាធិការដាក់ ។ បើអញបាន
ត្រាស់ជាព្រះពុទ្ធ វិសេសវិសុទ្ធក្នុងត្រៃចក្រ សូមឲ្យព្រះខ័ន

ជំរុសធ្លាក់ ទេព្វរក្សប្រុះផ្ទួយជាទិព្វញាណ ។ លុះទ្រង់ប្រនិ-
ធានចប់វាចា ទ័នប្ផាក៏ធ្លាក់ចាកសួគ៌ស្ថាន បំពោះព្រះភ័ក្ត្រ
នៃក្សត្រក្សាន្ត ដោយតេជពុទ្ធញាណព្រះសាស្តា ។ កាល្មោះ
ព្រះបមនវិន្ទពិនលោកា ឈ្មៀង នត្រទតយល់ព្រះទ័នប្ផា ក្សត្រា
ក៏សោមនស្សក្រៃ ។ ព្រះភ័ក្ត្រផ្ទូរផង់ដូចវង់ចន្ទ្រ ព្រះករលូក
កាន់ព្រះទ័នដៃ លើកភ្លាងទតភ្លាងតាមនិស្ស័យ ក្សត្រថ្លៃទ្រង់
កាត់ព្រះកេសា ។ ព្រះករខាងស្តាំចាប់ទ័នពេជ្រ ព្រះករឆ្វេង
ស្តេចចាប់បុទ្សា ទន់ល្មន់ហាក់ដៃអយ្យរា កាត់ព្រះកេសាបុទ្សា
បាន ។ កាត់ស្រែបសម្តេចព្រះចក្រី លើកផ្ទងកេសីអាទិស្ឋាន
តេជះឋាបើអញនឹងបាន ត្រាស់ជាពុទ្ធញាណប្រាកដណា ។
សូមឲ្យព្រះបុទ្សាកុំភាត់ភាយ រសោះរំសាយអំពីគ្នា អណ្តែត
លឿនលយដោយវេហាស៍ ដូចកល់មាលាកម្រងភ្ញី ។ មនលុះរឿ ។
សប្ហាស្ទរេបស្រែបទ្រង់បោះ ព្រះបុទ្សានុះដូចមាល៏ អណ្តែត
ត្រសែតលើមេឃី ពោធិ៍សែនៈសាមនស្សក្រៃ ។ យានី ។ ថ្លែង
ដល់សម្តេចសហស្សនេត្រ ជ្រាបហេតុព្រះនវិន្ទពិនភព្វត្រៃ

កាត់ព្រះបុទ្ធារឿងរិទ្ធិក្រៃ សហស្សនេយ្យក៏សោមនស្សា ។ ទើបទ្រង់ក្រោកចាកទែនសៃយាសន៍ យកប្រអប់មាសដ៏លេខា អប់ដោយគ្រឿងទិព្វនៃទេវតា ឥន្ទ្រាក៏ធ្យាទហោះបុះខ្មី ។ លុះដល់យល់ព្រះបុទ្ធាច្បាស់ លយលើអាកាសស្ថានមេឃី ឥន្ទ្រាអញ្ជើញផ្គងពោធី ដំកលប្រអប់ម្ទីហើយវិលក្លាន ។ លុះដល់ត្រ័យត្រឹង្សឥន្ទកោសី សាងព្រះចេតិយ៍មណីស្ថាន បញ្ចុះព្រះបុទ្ធាបមក្សត្រក្សាន្ត សម្រាប់ជាស្ថានទេព្វវន្ទី ។ ចេតិយ៍មណីសុវណ្ណា បញ្ចុះព្រះបុទ្ធានៃពោធី ថ្វាយនាមតាមហេតុផ្គងភូមី ហៅបុទ្ធាមណីទីនុះណា ។ កាល្មោះ ឯអង្គចៅចមត្រ័យត្រឹង្សា បញ្ចុះព្រះផ្គងស្រេចហើយណា នាំនាងកញ្ញាចូលប្រាង្គណ៍ស្ថាន ។ ឯងណុះមែនមានយក្ខឃោរឃៅ តាំងទីលំនៅក្នុងស្មសាន ក្រុងមារឲ្យនៅរក្សដ្ឋាន មើលស្ថានដើមពោធិព្រឹក្សា ។ ថ្ងៃមួយយក្ខយល់ព្រះពុទ្ធអង្គ ស្តេចគង់បល្លង្កដ៏លេខា ក្រោមពោធិព្រឹក្សមែកសាខា អស្សុរាឥច្ឆាពោធិញាណ ។ គិតថាស្រមណ៍នេះអហង្ការ មិនក្រែងក្រុង

មាររិទ្ធិហាន បើប្នេះមានតែអញគិតអាន ឡើងទូលក្សត្រក្រាន្ត
ក្រុងមារា ។ គិតហើយអសុរីសំដែងរិទ្ធិ ងងឹតទូទាំងផ្ទៃមេឃា
ស្មុះហោះផ្លោះឡើងកាន់វេហាស៍ ត្រង់ទៅសួគ៌ាមារធិបតី ។
លុះដល់យក្ខបួលទៅម្នីម្នា ឱនសីរវន្ទាអាសុរី ទូលថ្លែងបែង
តាមរាយសេចក្ដី បពិត្រធិបតីបមសីរសា ។ ឥឡូវមានស្រមណ៍
មួយអងអាច មិនខ្លាចអំណាចព្រះបេស្ដា មកគង់នៅក្រោម
ពោធិ៍ព្រឹក្សា ករុណាសូមទ្រង់ជ្រាបសេចក្ដី ។ កាល្មោះ
ឯក្រុងមារារឿងរង្សី បានស្ដាប់យក្ខទូលសព្វសេចក្ដី អសុរី
ក៏ទ្រង់ក្រេវក្រោធក្រៃ ។ ស្មុះក្រោកទះដៃកាងក្រទា រីយ ៗ
មនុស្សាប៉ុនមេដៃ អហង្ការកោងកាចកំណាចក្រៃ កន្លងនិ-
ស្ស័យអញហើយណា ។ បើប្នេះមានតែប្រើបុត្រី រាគាអរតី
នាងតណ្ហា ឲ្យទៅប្រលោមដោយកាមា គង់បង់បរិយាសិទ្ធត្ថ
បាន ។ វិស័យអ្នកបួសមិនហួសកាម ទៅញយគង់ញ៉ាម
តាមសន្ដាន សត្រីសត្រូវពោធិញាណ ការនេះគង់បានសម
ប្រាថ្នា ។ គិតហើយក្រុងមារក៏រីករាយ ព្រោះយល់ឧបាយ

សមបិត្តា ទើបត្រាសហើយពួកស្នំស្នេហា ទៅហៅធិតាអញវៃៗ ។ គ្រានុះ បណ្តានាងស្នំកំណាន់ណៃ ទទួលព្រះបន្ទូលហើយចេញវៃ ត្រង់ទៅប្រាង្គណ៍ជៃរាជធីតា ។ លុះដល់នាងស្នំបង្គំទូល បពិត្រឥស្សរលើសិរសា ឥឡូវសម្តេចព្រះបិតា មានការយ៉ាងណាពុំដឹងជាន ។ ឲ្យតែពួកខ្ញុំមកខ្ញាន់ខ្ញី អញ្ជើញម្ចាស់ទាំងបីទៅកុំខាន បិតុរង្គគង់ចាំនៅក្រៅស្ថាន អ.ញ្ជើញកល្យាណឆាប់ម្នីម្នា ។ កាល្នោះនាងមារធិតាបីអង្គ ឮហើយក៏រៀបតែងកាយា នាំគ្នាយាត្រាឡើងប្រាង្គណ៍ស្ថាន ។ លុះដល់ឱនសិរលើកកំបង់ បង្គំបិតុរង្គក្នុងវិមាន កណ្តាលយោធារិទ្ធហាន កល្យាណគាល់ស្តាប់សព្វកិច្ចា ។ កាល្នោះ ក្រុងមារអសុរិន្ទ្រយក្សា យល់បុត្រមកដល់គាល់អាត្មា សែនមហាសោមនស្សហើយត្រាស់ប្កាន ។ កូនើយឥឡូវឱមានការ គឺសិទ្ធត្ថកុមារសក្តាហាន ចេញសាងបន្ទុំពោធិញ្ញាណ ជាយាននៃសត្វក្នុងភពត្រៃ ។ ថាបើបណ្តោយឲ្យគាត់បាន ផ្លូវពោធិញ្ញាណគ្រានេះនៃ គាត់នឹង

ជាធំក្នុងដែនត្រៃ កន្លងនិស្ស័យអញបិតា ។ ហេតុនុះបួល
កូនទៅល្បួងលោម ប្រលោមឲ្យគាត់បង់បរិយា ដោយការ
លោកីយ៍ក្ដីកាម កុំឲ្យបានជាព្រះពុទ្ធបាន ។ កាល្មោះ កូន
មារទាំងបីរីទ្ធិហាន បានស្ដាប់បិតុរង្គឲ្យតែងប្រាណ ទៅ
លោមទ្រង់ញាណដោយវេណី ។ ទើបឱនទទួលរ៉ាប់អាសា
ដោយកលមាយាជានារី នាំគ្នាបង្គុំបុះបរលី មកកាន់ប្រាង្គណ៍
មណីទីអាត្មា ។ ដល់ហើយនាងបីសំអាងអង្គ ដោយគ្រឿងទេព
ទ្រង់ដ៏លេខា មកុដកងអារាមរឿងរ៉បនា ភូសាសមស័ក្ដិសូ-
ភ័កសាយ ។ ល្អរូបល្អរាងនាងអប្សរ ល្អកេសល្អកលំអកាយ
ល្អឆោមល្អឆើតឆវីឆាយ ល្អទ្រង់ល្អទ្រាយក្លាយកិន្នរ ។ តែង
គ្រឿងរឿងគ្រប់ទាំងបីប្រាណ នាំគ្នាហោះធ្យានដោយអម្ពរ
លឿនលន់លើសលែងព្រះទិនករ បរត្រង់មណ្ឌលព្រះសាស្ដា ។
លុះដល់មណ្ឌលព្រះជិនស្រី នាងមារទាំងបីឈប់គិតគ្នា ពី
គ្រោះហាយើងបីអង្គា ទទួលអាសាព្រះបិតុរង្គ ។ មកល្បួង
លោមលបៅសិទ្ធត្ថ ឲ្យគាត់ភ្លាត់ព្រិឍបាកក្រិត្យសង្ឃ ឥឡូវ

នឹងទៅទាំងបីអង្គ ការបង់ប្រុស ១ ស្រីបីនាក់ ។ នឹងកើតអៀនខ្មាស់តែគ្នាឯង ការល្បែងលោកីយ៍កើតឃ្នាំងឃ្នាក់ បើប្នះមានតែចូលម្នាក់ៗ ក្ដីស្នគ្គនាងណាការយើងបាន ។ កាល្មោះ នួននាងភាគាកែវកល្យាណ ទទួលចូលមុនបង់ក្សត្រក្សាន្ត ទើបមានសន្ធ-រសកាន់កនិដ្ឋា ។ នែប្អូនទាំងពីររួមជីវិត ចូរស្ថិតនៅនេះចាំបងរ៉ា បងនឹងចូលមុនមើលកិរិយា ថាហើយយាត្រាក្រាយចរលី ។ មកដល់យល់អង្គពង្សព្រុទ្ធា ភាគាមាយាដោយមេត្រី ព្រះអើយព្រះគង់ស្ងៀមធ្វើអ្វី ប្អូនស្រីដល់ហើយចូររ៉ាប៉ា ។ ម្ដេចធ្វើព្រងើយកន្តើយទាល់ ហាក់ជាពុំស្គាល់ប្អូនពុំងា ប្អូននេះឈ្មោះកែមកែវភាគា ជាគូជីវ៉ារួមជីវិត ។ គួរឬមកគេចភ្លេចក្ដីស្នេហ មិនប៉ុន្មានខែមកប្រែចិត្ត ថាហើយភាគាធ្វើហាក់ស្និទចូលជិតល្អងលោមដោយកល់ត្រីរ ។ រៀមអើយរៀមរាក់ សមភាពសមភក្ត្រហាក់កោសី មិនបង់វង្សជាតិជាចក្រី ប្អូនស្រីក៏ស្នគ្គស័ក្ដិស្មើគ្នា ។ ប្អូនមកនេះហ្មាយប៉ងសង្វាត ជាបាទបរិចាកព្រះរាជា អញ្ជើញរួមអាសន៍ទីនិទ្រា សន្ធនានឹងគ្នាសិនណាបង ។

កែវអើយកែវប្អូន កុំឲ្យសោះសូណ្យក្ដីបំណង លោមហើយ
រាគាបែផ្អៀងផ្អង មៀងម៉ងល្មបគន់ចុងនេត្រា ។ កាល្មោះ
ព្រះបមនរិន្ទពិនលោកា ទ្រង់យល់រាគាមារធីតា មកលោម
សាស្ដាការលោកិយ៍ ។ ព្រះគ្មានក្ដីត្រេកដំម្រេកត្រង់ នឹងអង្គ
រាគាកាឡកិណី ទើបត្រាស់គ្នាសដៀលពាលពុតស្រី មេអើយ
កុំបីមកប្រាជ្ញា ។ មេឯងឈ្មោះរាគតែងពាលរិត ឲ្យសត្វជំត
ដោយកាមា រោលបានតែមនុស្សនឹងទេវតា ត្រង់យើងកុំពា
មកព័ទ្ធព័ន្ធ ។ តួចៅជ្ញបលាមក់អាក្រក់នៅ ហោបទៅតែ
ជើងយើងពុំជាន់ ចូរបៀសបេញទៅឆាប់រួសរាន់ កុំមកកួន
កាន់នឹងយើងណា ។ កាល្មោះ នួននាងរាគាមារធីតា បាន
ស្ដាប់បន្ទូលព្រះសាស្ដា ស្ដេចកាត់ស្នេហាការវេណី ។ រាគា
ពុំសមក្ដីបំណង កើតទុក្ខមុខហ្មងខ្មាស់ពោធី ទាល់ចិត្តទាល់
បេះក្បួនរាគី ទើបថយបរលីមកទីភាក់ ។ កាល្មោះ នួននាង
កនិដ្ឋាទាំងពីរនាក់ បានយល់បងដល់ទីសំណាក់ ទើបសាក
សួរហេតុក្ដីលោកា ។ បងើយបងទៅប្រលោមក្សត្រ ការ

ស្ងាត់បានខ្លះឬយ៉ាងណា ឬមួយសិទ្ធត្ថពុំស្នេហា បែបបទយ៉ាងណាប្រាប់ប្អូនផង ។ កាល្មោះ នួននាងរាគាកែវស្នេហ៍ស្នង បានស្ដាប់កនិដ្ឋាសាកសួរសង ទើបថែងទំនងដោយត្រង់ស្មោះ ។ ប្អូនើយសិទ្ធត្ថគាត់មាំមួន បងក្លួនដោយកាមមិនតាមសោះ អស់បំប៉ុតអស់បេះកេះមិនបុះ ការនុះពុំស្រេចក្ដីបំណង ។ តែជាទំនងគាត់មិនស្នេហ៍ ព្រោះបងសៅកែទេប្អូនបង ប្រសិនយ៉ាងឯងក្មេងស្រយ៉ង លម្ដងទៅមើលប្អូនអរតី ។ កាល្មោះ នួននាងអរតីស្រស់ពីសី ទទួលបួលបង់ព្រះជិនស្រី ទើបស្ដីទៅកាន់នាងតណ្ហា ។ ប្អូនើយចាំមើលស្មាដែបង ទៅលល្បងមើលកិរិយា ជា ហើយក៏រៀបតែងអាត្មា យាត្រាក្រាយករបរបួលផ្គង ។ ដល់ហើយអរតីសម្ដែងខ្លួន ប្រើក្បួនបញ្ឈៀងពុំមៀងម៉ង មាយាគេបកែបំបែខ្នង ផ្អៀងផ្អងលួបគន់បុងនេត្រា។ ញញិមញញៀមគ្រហែមក្អក ស្ដីលស្ដីឡកដោយវាចា ព្រះអើយព្រះអង្គគង់អាស្នា តែឯងឯកាឥតគូគ្រង ។ មើលៗគួរតែអាលៃលន់ មកឥតប្រពន្ធនឹងស្នាលស្នង រូបនេះស្រីណា

អាបកខ្លង តែឃើញគង់បងឋាប់ចេតនា ។ ស៊ូផ្គាប់ស៊ូផ្គុន ឲ្យអស់ធន់ ដំរាបអស់ជន្មជាមួយគ្នា ឋាហើយអរតីធ្វើមាយា ចូលជិតអាស្នាលោមពោធិ ។ ព្រះអើយព្រះបង ប្អូនស្បូមផ្ទំ ផងរូមវណ៌ា ប្អូនមកនេះប៉ងផ្ញើជីវី ភូមីមេត្តាការសង្វាស ។ ប្អូន សោតពុំបានស្រីដូជាតិ មាយាតអ្នកលេងស្នែងប្រាក់មាស ប្អូន ឈ្មោះអរតីជំពេកណាស់ គួរជាសង្វាសការលោកិ ។ អញ្ជើញ ចុះមកយកប្អូនភា ជាបាទបរិចារណាចក្រី បំណាច់ប្អូនតាំងចិត្ត មេត្រី លោមហើយអរតីឈរវាំងរា ។ កាល្មោះ ព្រះបមនរិន្ទ្រពិន លោកា យល់នាងអរតីលោមសាស្ដា ស្ដេចពុំស្នេហាប៉ុនធូលី ។ ទ្រង់ត្រាស់កាត់កាមហាមអរតី វីយមេកុំបីមកជួជំ យើងនេះ សម្រេចសម្ពោធិ ស្រីញីយើងខ្ពើមឆ្អើមណាស្បា ។ ឯង ឈ្មោះអរតីក្ដីជំពេក ឲ្យសត្វត្រង់ត្រេកក្នុងកាមា ត្រេកបានតែ មនុស្សនឹងទេវតា ត្រង់យើងកុំពាមកត្រេកត្រង់ ។ ចូរញៀស បេញទៅមេលាមក កុំមកញីញក់យើងជាសង្ឃ មេអើយមេ ទៅកុំរារង់ យើងនេះកាត់បង់អស់ហើយណា ។ កាល្មោះ

ន្ធួនាងអរតីមារធីតា បានស្ដាប់ពោធិកាត់លោកា ទើបអៀនអាត្មារិលបរលើ ។ ថ្លែងឯន្ធួនាងទាំងទ្វេហា រាគាតណ្ហាផោមនារី យល់នាងអរតីមកដល់ទី នារីចៅពៅសួរទៅថា ។ អរតីព្រលឹងមាសបងអើយ ម្ដេចទៅកែរើយរឿងលោកា ប្រ-ហាក់ប្រហែលឬយ៉ាងណា ឬចុះដម្រារាគាបង ។ កាល្មោះន្ធួនាងអរតីរតន៍ស្នេហ៍ស្នង ឮនាងទាំងពីរសួរដើមទង ទើបថ្លែងទំនងដំណើរខ្លួន ។ បងើយការប្អូនដែលត្រេកត្រង់ ទៅបង់សិទ្ធដោយកាមកួន ខ្ញុំលពុំលេបគេបដោយខ្លួន ដូចក្បួនរាគាកាលមុនណា ។ តែជារូបខ្ញុំក្រមុំពិត ពុំស្ទូវិចាប់ចិត្តនៃក្សត្រា បើប្លោះគួរឲ្យប្អូនតណ្ហា គេសារិសមជាស្រឡាញ់បាន ។ កាល្មោះ ន្ធួនាងតណ្ហារតន៍កល្យាណ ទទួលអាសាបង់ទ្រង់ញាណ ទើបចាត់បែងប្រាណបរបួលថ្វាត់ ។ លុះដល់តណ្ហាដង្ហោយហៅ ព្រះអើយព្រះចៅព្រះបមក្សត្រ ប្អូនឈ្មោះតណ្ហាគួប្រតិព័ទ្ធ ស្ដេចគង់ស្ងៀមស្ងាត់ពុំតាំពា ។ ភ្លេចហើយឬនៅប្អូនមេត្រី ប្អូនស្រីបំរើព្រះបាទា ឧស្សាហ៍ស្ទួតាមសព្វវេលា លុះត្រាជួបជាក់អ្នកប្រុសថ្លៃ ។ ព្រះអើយព្រះគុណ ប្រកប

ដោយបុណ្យបុត្តនិស្ស័យ ប្អូនសែនស្រឡាញ់ពេញអាល្បៃក្សត្រថ្លៃចូររ៉ាប់កុំស្មេហា ។ អនិច្ចាមិនគួរមកប្រែភ័ក្ត្រ ធ្វើហាក់មិនស្មាគ្គស្មោះបិត្តា បុះមកទទួលប្អូនតិចរ៉ា បំណាច់តណ្ហាប្រាថ្នាបង់ ។ កោតបានភូមរមិនភិរម្យ កោសុម្ភដល់ហើយមិនត្រែកត្រង់ អនិច្ចាបុប្ផាកេសរបង់ កន្លង់ខ្ទឹលត្រីបឬបរ៉ាងណា ។ កាល្មោះ ព្រះបមនរិន្ទពិនលោកា ស្តេចទតទៅយល់នាងតណ្ហា ទើបមានបញ្ជាត្រាស់ទៅថ្វាត់ ។ រីយមេតណ្ហាប្រាថ្នាកាម កុំមេមកតាមប្រតិព័ទ្ធ គួហៅលាមកអាក្រក់ក្ដាត់យើងភ្ការកាប់កាត់ចោលបង់ហើយ ។ ចូលបៀសចេញទៅមេតណ្ហា កុំមកប្រាថ្នានឹងយើងឡើយ យើងអស់ធូរះនឹងមេហើយមេអើយកុំមេមកប្រាថ្នា ។ កាល្មោះ នួននាងនារីតន៍តណ្ហាឮពុទ្ធបន្ទូលកាត់ក្រេជា កើតអៀនអាត្មាហើយលាផ្គង ។ ដល់ហើយនាងពីរស្បូរសេចក្តី ម្តេចទៅប្អូនស្រីការបំណង ប្រហែលបានខ្លះឬមាសបង ឬបុះគន្លងមុនដូចគ្នា ។ កាល្មោះ នួននាងនារីតន៍តណ្ហា ទូលថ្លែងថែងប្រាប់បងទេ្ហា បង្ហើយដូច

គ្នានឹងបងឯង ។ កោតបិត្តសិទ្ធគាត់អត់បាន ពុំល្ហើប បាកស្ពានដោយការល្បែង អម្បាលរូបខ្ញុំរូបបងឯង បំពៀង សែងសាយដូចផ្កាយព្រឹក ។ ទោះមនុស្សទេវតាទាំងសា-កល តែយល់កាលណាគង់ភ្លាំងភ្លឹក ព្រះសិទ្ធគាត់ដូចដីរសឹក ឥតភ្លឹកនឹងភ្លើងយើងទាំងបី ។ រាគាជាអញតែងរោលសត្វ កំចាត់ឲ្យលុះក្នុងលោកីយ៍ អរតីជាអញត្រេកមេត្រី បងសត្វ លោកីយ៍ឲ្យស្រើបបាន ។ តណ្ហាជាខ្ញុំនាំភ្លើនបិត្ត ឲ្យសត្វ ងងិតទូទាំងស្ពាន តែព្រះសិទ្ធគាត់ហៅហាន ពុំបានបុះ កល់យើងឡើយណា ។ កូនមារទាំងបីទាល់គំនិត កើតបិត្ត ប្រទូស្តទ្រូស្តសាស្តា អកុសលបណ្តាលឲ្យរូប៉ា ប្រែបាស់ជរា ទាំងបីនាក់ ។ អនិច្ចាកូនមារកាយពិការ សាប់ស្វិតយុល យារបង្កាធ្លាក់ ខ្នងកោងលោងកែកបង្កេះគាត់ ធ្មេញបាក់គ្រ-ហុបហៀរទឹកមាត់ ។ ថ្គាល់ផតភ្នែកល្អក់សក់ស្កូវព្រាង ដោះ ធ្លាក់រយោងដើរគ្រវីត ជើងកោងដៃកែកកាន់ឈើច្រត់ ហា មាត់ហាត់ហាបហៀរទឹកភ្នែក ។ រាគាអរតីនាងតណ្ហា យល់រូប

អាត្មាពិការប្លែក កើតស្ដាយរូបកាយសែនសង្វេគ នាំគ្នារីរេក សោយសោកា ។ ភគាថ្ងូញថាឱរូបអញ ពីដើមពាលពេញ ឆោមឆាយា ល្អលន់លើសលែងទេព្វកញ្ញា ឥឡូវមកជា ចាស់អប្រិយ៍ ។ អរតីថាឱស្ដាយើយស្ដាយ រូបកាយកាល ដើមជាឆ្នើមស្រី ឥឡូវមកប្រែកើតរូបថ្មី ជាចាស់អប្រិយ៍រូប អនិច្ចា ។ តណ្ហាថាឱរូបអញើយ ដើមឡើយបំទង់ទ្រង់លេខា ប្រុសណាយល់ហើយគង់ស្នេហា ឥឡូវប្រែជាទុពលក្រៃ ។ នាងមារអ័កអួលក្ដួលឱរា ស្ដាយរូបអាត្មាស្មើរបង្ហៃ នាំគ្នា សង្រេងរឹងសង្រៃ ឱបដៃវិយោគសោយសោកា ។ លុះគ្រាន់ កំសាន្តក្ដីវិយោគ ខំក្រោកដោះឡើងបបួលគ្នា ថាយើងវិល ទៅកាន់សួគ៌ា ទូលព្រះបិតាឲ្យដឹងដាន ។ គួរឬស្រមណ៍នេះ កាបលើសលប់ បេះធ្មប់ធ្វើយើងឲ្យបង់ប្រាណ ថាហើយនាង មារផ្លោះបោះធ្យាន ត្រង់ទៅវិមានស្ថានសួរស្រី ។ លុះដល់ មន្ទល់ស្ថានមារា នាំគ្នាចុះចាកផ្ទៃមេឃី ក្រាយករបរបួលក្នុង ប្រាង្គណ៍អ៊ី ផ្លីបង្គំគាល់បិតុរង្គ ។ កាល្នោះ មារារឿងរិទ្ធិ

ចិត្តទ្រទន់ ទតយល់បុត្រីទាំងបីអង្គ ជរារូបទ្រង់អាក្រក់ក្រៃ ។
ក្រុងមារពុំស្គាល់ជាធីតា ស្មានថាជួនចាស់ជាតិដទៃ ទើប
ត្រាស់ពុំមានអធ្យាស្រ័យ រីយចាស់បង្រៃចោរសាមាណ ។
មកពីស្ថានណាចាស់កំណាច ពុំមានកោតខ្លាចយើងក្សត្រ
ក្សាន្ត ហ៊ានមកអង្គុយលើប្រាង្គណ៍ស្ថាន នរណារាប់អាន
ចាស់អប្រីយ៍ ។ កាល្នោះ នួននាងធិតាមារទាំងបី ឱនសិរ
បង្គំទូលតបឪ្ន បពិត្រធិបតីបិតុរា ។ យើងខ្ញុំទាំងបីមិនស្រី
ផ្តាស់ គឺបុត្រអម្ចាស់កើតកេសា ខ្ញុំឈ្មោះរាគាតណ្ហា អរតី
ធីតាណាបិតុរង្គ ។ ទ្រង់ប្រើឲ្យទៅបង់សិទ្ធ ឲ្យគាត់ភ្លាត់
ព្រឹលចាកក្រឹត្យសង្ឃ ព្រះសិទ្ធបិត្តគាត់ពុំត្រែកត្រង់ ទើបបង់
បំណែងយើងគ្រប់គ្នា ។ រូបកាយយើងខ្ញុំក្រមុមពិត ត្រូវរិទ្ធិ
វេទ្យមន្តសិទ្ធណា បានជាពិកលចាស់ជរា ទូលហើយនាំ
គ្នាសោកាលៃ ។ កាល្នោះ ក្រុងមារអសុរិន្ទ្ររឿងរិទ្ធិក្រៃ ស្តាប់
បុត្រីថ្លែងហេតុដូច្នេះនៃ តក់ស្លុតហឫទ័យនៃយក្សា ។ គិត
ស្តាយរូបកាយព្រះបុត្រី អសុរីក៏ទ្រង់ក្រេវក្រោធា ស្ទុះក្រោកទះ

ដៃកាងក្រទា ពះភាស្រមណ៍ក្មេងមិនក្រៃងរិទ្ធិ ។ គួរឬក្ងន អញរូបស្រឡៀ ឲ្យទៅប្រលោមដោយក្តីស្និទ ទោះស្មគ្គមិន ស្មគ្គក៏តាមចិត្ត នរណាជំរិតបង្ខំគាត់ ។ បានជាមកធ្វើព្រះ ធីតា ឲ្យបង់កិរិយារូបរឹប័ត្តិ កាប់ខ្ទាសទេវតាមនុស្សស្រពូសត្វ អេះអត់ឲ្យគាត់ឯណាបាន ។ មានតែលើកទ័ពទៅហោមចាប់ សម្លាប់ឲ្យក្ស័យប្រល័យប្រាណ ហោលទៅក្រោបក្រភាឡស្ថាន ទើបបានសមមុខស្រមណ៍បង្រៃ ។ ត្រាស់ហើយក្រុងមារ សង្កៀតធ្មេញ បញ្ចេញស័ព្ទកងទាំងដែនត្រៃ រឹយេពួកសេនា រិទ្ធិក្រៃ បេញទៅវៃៗកេណ្ឌយោធា ។ ឲ្យព្រមបតុរង្គរិទ្ធិរុទ្ធ ប្រិពឹលស្រមុទ្ទដោយគណនា អញនឹងលើកទៅយុទ្ធនា ឆាប់ៗម្នីម្នាកុំផ្សំរផ្សង ។ គ្រានុះ សេនារិទ្ធិសាយជានាយកង ទទួលឱង្ការមារទ្រើសឃ្នង បេញបរពល់ផងតាមបញ្ជា ។ កេណ្ឌពលរើសពួកទេវបត្រ រិទ្ធិរុទ្ធខ្លះខែងប្លែងកាយា ខ្លះ ប្លែងជាយក្ខខ្លួនជាស្វា ខ្លះខ្លួនទេវតាក្បាលជាយក្ខ ។ ខ្លះ ប្លែងជានាគជាគ្រុធរាជ សម្តែងអំណាចគ្របត្រៃច័ក្រ ខ្លះ

ប្លែងជាពស់ព្លើងពភ្លាក់ ខ្លះប្លែងជាព្យគ្ឃពាលម្រឹគា ។ ខ្លះជិះរាជសីសិង្ហៈតោ ខ្លះជិះគោណោគោត្រឧដ្ឋលា ខ្លះជិះដំរី មហិង្សា កាន់គ្រឿងសស្ត្រាភ្លឺព្រោងព្រាយ ។ ពល់មារពន្លឹក អធឹកក្រៃ លាន់កងទាំងផ្ទៃស្ទួគ៌ានាយេ បតក្ប្លនបតុរង្គពលនី កាយ តាំងរាយរៀបចាំក្រុងមារា ។ កាណោះ ឯក្រុងអសុរិន្ទ ហៅស្ទួគ៌ា លុះស្វាងអរុណខែមេឃា លីលាបូលស្រង់ព្រះជល ធី ។ ជំរះស្អុះស្អាងសំអាងអង្គ ភិរក្លិនទ្រង់កេសរភ្ញី ស្នាប់ព្លៀ ជើងងរជរមណី ភូសាតាគ៌ខ្នក់ភ្ញីរល្ងឺ ។ ជាយក្រែងជាយហ្វៀ រាយប្ញៀងព្រោះ ឆ្លងអង្គផ្កាជុះអលង្ករ តាបទិបតាបទ្រង់ប្ញៀង គ្រប់ពណ៌ សង្វារផ្កាញរស្វូកាណរាយ ។ កងករពាហុរ័កកែវ រំលេប ព្រះទម្រង្គប្ញៀងពេជ្រដ៏ពណ្ណរាយ កុមុដកែវអារាមមា-លាលាយ ស្បូងជរជាយរាយភ្នែកមាន់ ។ ព្រះហស្ត១ពាន់ អស្សុរា ចាប់ទេពសស្ត្រាស្នាធ្នូខ័ន កងប័ក្រលំពែងដាវវែង ស័ន ស្រេចឡើងកើយកាន់ដំរីផៃ ។ ដរីអើយដំរីសឹក ហោ៊ កងលាន់គឹកទាំងដែនត្រៃ ឈ្មោះគិរីមេខលាផៃ ធារធំស្តុម

ស្ដែស្មើព្វា ។ ប្រដាប់ស្ដាប់បំចង្កមភ្លុក ស្លឹកពោធិ៍ពោងមុខ មុក្ដា ឆ្នាក់កែមសែមសយតុវណ្ណា ភ្ញរយ៉ាផ្កាសំយ៉ុងសំយ៉ាក យ៉ែង ។ ក្ចបកោងកញ្ចោងកញ្ចក់ចាំង រាំងននបើកបាំងបិទ ទិព្វទែង ទង់ឆ័ត្របាំងឆាយព្រះសួរ្យសែង ភ្លឺបែងដែងដាស ពាសពសុធា ។ គ្រឿងខ្ពស់បំពោះបម្រ័តរាយ រំភាយរំភើយ ដោយវាតា ហ្មក្រាន់ខ្ញាន់ក្រោយមើលត្រួតត្រា បានឫក្សអស្វ-វាឡ្យលើកបរ ។ លុះលើកមកដល់មន្ទល់ទី យល់ព្រះពោធិ ធោមបវរ គង់លើបល្លង្កអលង្ករ ដូចកល់កេសររាជសីហា ។ ឥតមានតក់ស្លុតប្រហាមិត្រ សណ្ឋិតតែអង្គឯងឯកា ក្រោម ពោធិព្រឹក្សមែកសាខា អស្សារក៏ទ្បើនព្ធកតពល់ត្រៃ ។ វ៉ុយៗ សេនាគ្រប់នាយទ័ព ប្ញូរនាំគ្នាចាប់ស្រមណ៍ចង្រៃ បាញ់ចាក់ ប្រហារឲ្យក្សិនក្ស័យ តដៃកុំស្ដាប់ចាប់ឲ្យបាន ។ គ្រានោះ បណ្ដាសេនីពល់ទាហាន ឮមារឲ្យប្ញូលហោមទ្រង់ញាណ នាំ គ្នាហោ៊សា៊នដាកោលា ។ ខ្លះឰយលំពែងគ្រវែងដាវ ខ្លះការ សាវគោះបោះសិលា ខ្លះបាញ់ធ្នូស្នាប់ក្រវ័នឰ្លា ហោមជុំសា-

ស្តាអនេកក្រៃ ។ តេជះអំណាចទសបារមី រក្សាជិនស្រីបំ-
បាត់ភ័យ អាវុធក្រុងមារបរាជៃ កើតជាមាលៃកម្រងផ្កា ។
ខ្លះជាពីតានរំយោលភ្ញី ខ្លះជាមាលីភ្លួងរយ៉ា ខ្លះជាឯកលយលើ
វេហាស៍ ជាមហាអស្ចារ្យពុទ្ធវិស័យ ។ កាល្នោះឯក្រុងមារារិទ្ធិ
ក្រៃ យល់គ្រឿងអាវុធជាមាលៃ ក្តួលក្តៅហាទ័យនៃយក្សា ។
ទើបរុំងដំរីចូលបំភ័ក្ត្រ ក្រុងយក្សបាប់ច័ក្រដ៏សក្តា គ្រវែងហោល
បំព្រះភក្ត្រា ដោយចិត្តឥច្ឆាព្រះពោធិ ។ ច័ក្រគ្រឿនលឿនលើ
អាកាសស្ថាន ក្លាយជាពីតានកោសុម្ភ សំយ៉ុងបុប្ផាសុមាលី
ល្អងភ្ញីអប់អង្គព្រះបោមពល ។ ផ្កាក្រងកម្រងបងរំភាយ សាត់
ដោយព្រះពាយអណ្តែតដល់ ទក្សិណាបីជុំចូលពិកល់ ថ្វាយ
ព្រះទសពលបមលោកា ។ កាលអើយកាល្នោះ ឯរាជអសុរិន្ទ្រ
យក្សា យល់ច័ក្រជាពួនភ្លងមាលា អសុរាក់ក្នាញ់ក្នុង
ហឫទ័យ ។ គិតថាសិទ្ធត្ថគាត់មានបុណ្យ សត្រូវជាគុណា
យល់ប្លែកក្រៃ បើប្នេះមានតែអញកែខែ ប្រាស្រ័យហោទ្យ
យកបល្លង្ករតន៍ ។ គិតហើយក្រុងមារមានឱង្ការ ហៃរាជ

កុមារនាមសិទ្ធត្ថ អ្នកមកគង់លើបល្លង្ករតន៍ មិនគួរសមគាត់ គង់ឡើយណា ។ បល្លង្ករតន៍នេះរបស់យើង សម្រាប់ដិកើង ក្នុងលោក ហេតុអ្វីមកយកជាអាស្នា ពុំសមបុញ្ញាធិការ ហៅ ។ ចូរចុះចេញទៅចាកបល្លង្ក កុំមកតតាំងរាំងរានៅ មែនបើដំអឹងរឹងពុំទៅ តួហៅគង់ខ្ទេចដោយដៃយក្ខ ។ កាលអើយកាល្នោះ ឯព្រះពុទ្ធពង្សទម្រង់សក្តិ ឮមារមាយាស្តី ប្រតិប៉ក្ស ចោទ្យបល្លង្កលក្ខណ៍នៃសាស្តា ។ ទើបទ្រង់ញញឹម ប៉ប្រិមភក្ត្រ ប្រាស្រ័យតយក្ខឥតក្រមា រឺយមារហេតុអ្វីមក បរបា មោសាហារតន៍បល្លង្កខ្លួន ។ បល្លង្កនេះគឺកើតដោយ បុណ្យ យើងសាងពីមុនមកមាំមួន ហេតុអ្វីមារមកកៃសំនួន ខ្លួនតើមានអាងបន្ទាល់ណា ។ កាលអើយកាល្នោះ ឯក្រុង អសុរិន្ទ្រយក្សា ឮពុទ្ធបន្ទូលត្រាស់ប្នេះណា ទើបមានវាចាតប ជិនស្រី ។ រឺយហៅសិទ្ធត្ថកុំមាត់រឹង បើហៅចង់ដឹងពីសាក្សី យើងមានទីអាងនឹងសេនី យោធីនៃយើងទាំងអស់គ្នា ។ គេ តាំងដឹងឮទាំងសោឡស ជាជារបស់យើងមារា តួហៅថា

របស់នៃអាត្មា មានអាងនរណាជាសាក្សី ។ កាលអើយកាល្មោះ ព្រះបមនរិន្ទពិនមុនី ត្រាស់តបកាន់មារដោយទាន់ទី បើង មានធរណីជាភ័យក៏ន ។ កាលយើងសាងសមព្រះបារមី យក ផ្លែផែនដីជាប្រធាន ជ្រួចទឹកនឹកជាទិព្វភីញាណ ទើបបាន បល្លង្កតាំងប្ចេះណា ។ ត្រាស់ស្រែបស្ដេចហៅនាងធរណី នាដើយជាទីសត្តិយា បួរផុះឡើងឆាប់តំឡូវ៉ា បួរជាសាក្សី ពោធិញាណ ។ ថ្លែងដល់នាងហើងព្រះធរណី តាំងទីនៅ ក្រោមផែនដីដាន ឮពុទ្ធបន្ទូលប្រោសហៅប្រាណ កល្យាណ ពុំហានឈប់រារង់ ។ ទើបបើកស្រទ័បពសុធា ផុះឡើងម្ចី- ម្ចាបំពោះអង្គ សម្ដែងព្រះកាយនៃឆោមយង់ ឲ្យក្រុងមារា យល់អាត្មា ។ កាលអើយកាល្មោះ ឯក្រុងអសុរិន្ទយ័ក្សា បៃយល់នាងហើងទេព្វកញ្ញា ឈរខាងសាស្ដាអស្វារ្យព្រៃ ។ ក្រុងមារអភិប្រាយនិយាយឡូក បំអកតអង្គព្រះបមត្រៃ រឺយ ៗ ស្និទ្ធក្បសីលសៃ ហេតុប្ចៃយកស្រីជាសាក្សី ។ ដែលមាន ឬភេទអ្នកសាងព្រឹល មានស្រីនៅជិតមិត្រមេត្រី កើតហេតុ

អាងយកជាសាក្សី តាំងស្រីជាត្រីមុខប្ដេះណា ។ គ្រាអើយ គ្រានុះ នួននាងធរណីទេព្វកញ្ញា ឮមារបំអកឡកលញ្ជា ទើប តបមារាដោយឆាប់ខ្វី ។ វីយមារលោមកគម្រក់កាក ហៅមក ពោលពាក្យពុំជួក្ដី ហៅយកពលឯងជាសាក្សី ត្រូវហើយអសុរី ប្ញាប់ប្ញូណ ។ ឯយើងជាស្រីសាក្សីព្រះ ទ្រង់លះកាត់កាម តាមពុំបាន កាលទ្រង់សន្សំពោធិញាណ យើងបានដឹងឮ សព្វប្រការ ។ មួយកាលបំពេញព្រះបារមី ជ្រួចទឹកលើដី ជាឱឡារ លុះបានត្រាស់ជាសាស្ដាចារ្យ បល្លង្កបណ្ដាលកើត ជាក់ស្ដែង ។ ខ្លួនហៅពុំមានកសាងអ្វី ហានមកស្រដីថា ផងឯង ថាហើយនាងស្រាយកេសាវែង ប្ញូតផ្ជិងខ្វាត់ខ្វែង លើពលមារ ។ តេជះអំណាចនាងធរណី វារីហូរឡើងមហោ-ឡារ កើតជាសាគរដ៏ធំធារ លិចលង់ពលមារវិនាសប្រាណ ។ អនិច្ចាពលមារលិចគង្គា វេទនាលើសលន់ពន់ប្រមាណ ខ្លះ ឈ្លក់ខ្លះឆ្លាមប្ដូរកាត់ប្រាណ ខ្លះទឹកក្លួបប្រានដាត់ក្បែនក្បួយ ។ ខ្លះសោតសេះដាន់ដំរីចក្រ ជើងបែកដៃបាក់ធ្លុះធ្លាយផ្ទៃ ខ្លះ

នឿកនាគត្រីកាត់អាស្រ័យ   ឈាមដាសពាសផ្ទៃព្រះជលធី ។
ទឹកជោរហួរដល់ដល់អាកាស   ពលមារស្លាប់ដាសទាំងប្រថពី
សល់នៅតែរាជអសុរី  នឹងបាគីរីមេខលា ។ កាលអើយកាលនោះ
ឯក្រុងអសុរិន្ទរាជមារា   យល់ពលអាត្មាសូន្យជីវា   មើលយល់
វេទនាសល់សែនទ្វី ។ កើតបិត្តភិតខ្លាចព្រះជលសៃ  ជោរដល់
ប្រលៃដល់ជីវី  អសុរីទន់បិត្តបុះពោធី  អស់រិទ្ធិ៍រាវីតសាស្តា ។
ទើបឱនកំបង់ផ្ចង់ជួលី  លើខ្នងគីរីមេខលា  សូត្រសរសើរគុណ
ព្រះរតនា   អរហំសម្មាត្រាដល់ចប់ ។  ក្រុងមារអប្បរាជ័យ
បាញ់បុណ្យ  យកពុទ្ធគុណតាំងគោរព្យ  ទទួលសរណាគមណ៍
ចប់ភព្វ   ស្រេចវិលត្រឡប់ទៅវិមាន ។ះ៚—

ចប់រឿងបរមសម្ពោធិដោយសង្ខេប

# អំពីលោក ក្រាហ្វឺយ គូវែរណើរយេណេរាល់
# ស្ដីទីនៃប្រទេសឥណ្ឌូស៊ីន
# អញ្ជើញមកព្រះរាជបណ្ណាល័យកម្ពុជា

កាលនៅថ្ងៃ២ ៗ៧ ព.ស. ២៤៧៧ ត្រូវនឹងថ្ងៃ ៤ យូវាំង ឆ្នាំ ១៩៣៤ វេលាម៉ោង ១១ ព្រឹកលោក ក្រាហ្វឺយ ស្ដីទីគូវែរណើរយេណេរាល់ប្រទេសឥណ្ឌូស៊ីន អញ្ជើញមកឋានមន្ទីរព្រះរាជបណ្ណាល័យ មានអ្នករាជ្ការធំ ៗ ទាំងបារាំងទាំងខ្មែរ គឺលោកឡឺវេស៊ីដង់ត៍សុប៉េរិយើរ ស៊ិលវ៉ែស្ត្រ, លោកគោបេ សែហ្វកាប៊ីណេត៍លោកឡឺវេស៊ីដង់ត៍សុប៉េរិយើរ, លោកប៉ិស្កុង្ស ដេលេគេអមរាជ្ការខ្មែរ, លោកស្មៀនត្រាលោកគូវែរណើរយេណេរាល់ និងសម្ដេចចៅហ្វ៊ាវាំង, ក្រុមហ្លួងស៊ីសុវត្ថិសុភាណុវង្ស ទីបក្រី, លោកអ្នកឧកញ៉ាអគ្គមហាសេនា, ក្រុមឃុនវិសុទ្ធខត្តិយវង្ស សុភាម្រិត្យ, លោកអ្នកឧកញ៉ាយោមរាជ បានជូនដំណើរលោកមកផង ។

មានពួកអ្នកចាំទទួលនៅទីព្រះរាជបណ្ណាល័យ គឺអ្នករាជ្ការក្រុមព្រះរាជបណ្ណាល័យ និងក្រុមជំនុំរបស់ព្រះរាជបណ្ណាល័យ, ក្រុមពុទ្ធសាសនបណ្ឌិត្យ, ក្រុមសាលាបាឡីទាំងគ្រូទាំងសិស្ស, ពួកសិស្សលោកសង្ឃពីស្រុកកូសាំងស៊ីននឹងពីស្រុកលាវ, ពោលដោយនាមចំពោះលោកអ្នកធំគឺ សម្តេចក្រុមព្រះវរចក្ររណរិទ្ធិ៍, លោកស្រីការប៉ុឡែស, លោកទូរាំបែរអ្នកអង្គម្ចាស់វិឈ្ឈាយាវង្ស, លោករាជតេជះមៅ, លោកគ្រូព្រះស្រីសម្មត្តិវង្ស ឯម នឹងលោកគ្រូព្រះវិសុទ្ធិវង្ស គាត ។

ក្នុងវេលាដូចពោលហើយខាងលើ លោកក៏អញ្ជើញទៅដល់ សម្តេចក្រុមព្រះវរចក្ររណរិទ្ធិ៍ នឹងលោកស្រីការប៉ុឡែស ចេញទៅទទួលនៅទីកើយខាងមុខ នាំលោកចូលទៅខាងក្នុង មានអ្នករាជ្ការក្រុមផ្សេងៗ ដូចពោលមកហើយ វៀរលែងតែលោកសង្ឃ មកឈរចាំគិនាប់នៅល្វែងកណ្តាល ហើយអញ្ជើញលោកចូលទៅមើលកន្លែងក្រុមជំនុំព្រះត្រៃបិដក បានបង្ហាញសៀវភៅព្រះត្រៃបិដកដែលបោះពុម្ពហើយ ៤ ក្បាល



កាលលោកក្រាហ្វ៊ីយ គូវែរណើរយេណេរាល់ ប.អ. អញ្ជើញមកទស្សនាការព្រះរាជបណ្ណាល័យ

រូបថតនេះធ្វើឲ្យឃើញកាលលោកកំពុងមើលរថយន្តដែលផ្ទុកសៀវភៅយកទៅផ្សាយក្នុងខេត្តក្រៅក្នុងដែនកម្ពុជា

ហើយនឹងជំរាបអំពីកិច្ចការរបស់ក្រុមនេះ ដែលបានធ្វើមក ហើយដូចម្តេច ជូនជាសណ្តាប់ដល់លោក ស្រេចហើយនាំលោកទៅទស្សនាការទីលក់សៀវភៅនឹងរូបផ្សេង ៗរបស់ព្រះរាជបណ្ណាល័យ ដែលនៅទល់គ្នានឹងកន្លែងក្រុមជំនុំព្រះត្រៃបិដក សឹងមានសៀវភៅនឹងរូបទាំងអំបាលនោះតាំងជាអណ្តាប់រៀបរយ រួបហើយបាននាំលោកឡើង ៗ ចូលទៅដល់បន្ទប់ធំខាងលិច នៅទីនោះមានគណៈសង្ឃប្រមាណ៥០រូប មានលោកគ្រូព្រះសិរីសម្មតិវង្ស ឯម ជាប្រធាននៅចាំទទួល, លោកបានចាប់ដៃគំនាប់លោកគ្រូព្រះសិរិសម្មតិវង្ស នឹងលោកគ្រូព្រះវិសុទ្ធិវង្ស ៗ បានជំរាបលោកពីគណៈសង្ឃដែលមកប្រជុំក្នុងទីនេះថា នេះពួកពុទ្ធសាសនបណ្ឌិត្យ, នេះពួកគ្រូសាលាបាឡី នេះពួកកូនសិស្សប៉ែកខាងស្រុកកូសាំងស៊ីន ដែលរាជការបញ្ជូនមកឲ្យរៀន នេះពួកសិស្សពីស្រុកលាវ ដែលរាជការប្រទេសនោះបញ្ជូនមកឲ្យរៀន ។

លោកមានប្រសាសន៍ថា កាលពី ៣ ឆ្នាំមុននេះ លោក

បានជូនលោកកូវែរណើរយេណេរ៉ាល់ប៉ាស្គីយេរ មកត្រួតការក្នុងខេត្តខ្មែរនាដែនកូសាំងស៊ីន ជាក្នុងគ្រានោះលោកបានប៉ះពាល់នឹងព្រះពុទ្ធសាសនា ស្គាល់ព្រះសង្ឃដែលទ្រទ្រង់សិក្ខាវិន័យរបស់ព្រះពុទ្ធម្តងទៅហើយ ជាក្នុងគ្រានេះលោកក៏បានមកប៉ះពាល់នឹងពួកព្រះសង្ឃជាអ្នកប្រាជ្ញម្តងទៀត ជាលោកមានសេចក្តីសោមនស្សណាស់ ក្នុងការដែលលោកអ្នកប្រាជ្ញអំបាលនេះបានយកចិត្តទុកដាក់ធ្វើតាមមុខក្រសួង ក្រោមបង្គាប់បញ្ជារបស់អ្នកស្រីការប៉ុវែ្ឡស នឹងសម្តេចក្រុមព្រះវរចក្រ-រណាវិទ្ធ ឲ្យបានចំរើនរហ័សទាន់សេចក្តីត្រូវការ ហើយភាព្ញារមានសេចក្តីត្រេកអរណាស់ដែរអំពីដែលភាព្ញារបានបាត់ការជួយឧបត្ថម្ភការព្រះពុទ្ធសាសនានេះ ភាព្ញារមានសេចក្តីជឿនឹងទុកចិត្តក្នុងពួកព្រះសង្ឃអ្នកប្រាជ្ញទាំងអំបាលនេះជាគង់ជានឹងនាំកិច្ចការទាំងនេះឲ្យដំណើរទៅកាន់សេចក្តីចំរើន នឹងសម្រេចដោយឆាប់រហ័សតទៅថ្ងៃមុខទៀត ។

មានប្រសាសន៍ប៉ុណ្ណោះហើយ ព្រះរាជបណ្ណាល័យក៏បាន

យកសៀវភៅកាព្យភាសាបារាំង ១ ក្បាលជូនលោក ៗ ក៏បិយ ទៅអង្គុយកៅអីដែលរៀបបំរុងទុកក្នុងទីនោះ ព្រះសង្ឃក៏សូត្រ ជយន្តោជូនសព្ទសាធុការដល់លោក កាលព្រះសង្ឃសូត្របប់ ហើយ លោកក៏ក្រោកទៅគំនាប់លាព្រះសង្ឃនឹងត្រឡប់ទៅ វិញ ។ លោកគ្រូព្រះសិរីសម្មតិវង្សបានថ្លែងសេចក្ដីគាប់ចិត្ត នឹងលោកថា អាត្មាភាពមានសេចក្ដីត្រេកអរនឹងព្រះតេជ-គុណ លោក ដែលបានអញ្ជើញមកកាន់ទីនេះ គឺលោកនាំយកសិរី សួស្ដីមកឲ្យទីនេះ អាត្មាភាពមានសេចក្ដីសង្ឃឹមថាកិច្ចការទាំង ពួងរបស់មន្ទីរនេះ ដែលនឹងសម្រេចទៅបានក៏ដោយសិរីរបស់ លោកនេះឯង ។

លោកមានប្រសាសន៍ថា "សេចក្ដីដែលខ្ញុំប៉ុនប៉ងប្រាថ្នា ដូចម្ដេច សេចក្ដីនោះសូមឲ្យសម្រេចតាមដែលបានប្រាថ្នា" ហើយក៏អញ្ជើញចុះតាមទ្វារខាងលិច ទៅមើលរបិយន្តរបស់ ព្រះរាជបណ្ណាល័យដែលផ្ទុកសៀវភៅនឹងរូបផ្សេង ៗ សិងបតនៅ ទៀបមាត់ជណ្ដើរ ហើយមានបិតរូបលោកនឹងអ្នករាជ្ការទាំងពួង

ស្រេចហើយលោកឡើងរថយន្តជាមួយនឹងលោកឡឺរេស៊ីដង់សុប៉េរិយ៉េរចេញទៅ ។

វេលារសៀលម៉ោង ៤ ក្នុងថ្ងៃដដែលនោះ លោកបានអញ្ជើញទៅមើលកន្លែងលក់សៀវភៅរបស់ព្រះរាជបណ្ណាល័យនៅស្ថានីយ៍រថភ្លើង (បាក់ទូក) មើលសព្វគ្រប់ហើយលោកមានសេចក្តីត្រេកអរហើយកើតជ្រះថ្លាបានចូលប្រាក់ជួយក្នុងការបោះពុម្ពព្រះត្រៃបិដក ក្រុមពុទ្ធសាសនបណ្ឌិតបានទទួលប្រាក់នោះហើយ ៗ សូមអនុមោទនាកុសលដ៏ប្រសើរនេះ សូមឲ្យលោកសម្រេចឥដ្ឋវិបាកមនុញ្ញផលតាមប្រាថ្នាហោង ។៚

# ឯកនិបាតជាតក

## ៣– ទុមេធជាតក

## អាចារ្យ ហឹម ក្រុមជំនុំប្រែព្រះត្រៃបិដក
## ប្រែពីបាឡីមកជាភាសាខ្មែរ

### ទុមេធជាតក

ទុមេធានត្តិ   ឥទំ សត្ថា ជេតវនេ វិហរន្តោ
លោកត្ថចរិយំ   អារព្ភ កថេសិ

សេចក្ដីថា កាលព្រះសាស្ដាចារ្យជាបរមគ្រូ ទ្រង់គង់នៅឯវិហារឈ្មោះជេតវន ព្រះអង្គទ្រង់ប្រារព្ធបំពោះនូវលោកត្ថចរិយា ហើយទ្រង់សម្ដែងនូវព្រះធម៌ទេសនានេះថា ទុមេធានំ ដូច្នេះជាដើម ។ លោកត្ថចរិយា គឺប្រព្រឹត្តដើម្បីប្រយោជន៍ដល់សត្វលោក នឹងមានប្រាកដក្នុងមហាកណ្ហជាតក ក្នុងទ្វា-ទសនិបាតឯណោះ ព្រះអង្គទ្រង់នាំមកនូវរឿងរ៉ាវ ក្នុងអតីតកន្លងទៅហើយដូច្នេះថា ។ កាលព្រះរាជាទ្រង់ព្រះនាមព្រហ្មទត្តទ្រង់សោយរាជសម្បត្តិក្នុងព្រះនគរឈ្មោះពារាណសី (កាល

នោះ) ព្រះបរមពោធិសត្វជាម្ចាស់យើង ក៏ទ្រង់យាងចុះចាប់
បដិសន្ធិក្នុងផ្ទៃនៃព្រះអគ្គមហេសីរបស់ព្រះរាជានោះ ។ កាល
ព្រះបរមពោធិសត្វចេញចាកគភ៌ព្រះមាតា នោះបានតាមបញ្ញត្តិ
ជាព្រហ្មទត្តកុមារ ក្នុងថ្ងៃកំណត់នូវព្រះនាម ។ ព្រហ្មទត្តកុមារ
នោះប្រកបដោយឧទ្ទេសនៃឆ្នាំ ១៦ ទ្រង់យាងទៅរៀនសិល្ប-
សាស្ត្រ ក្នុងនគរឈ្មោះតក្កសីលា ដល់ហើយនូវកិរិយាកាន់
ត្រើយនៃត្រៃវេទ្យ សម្រេចវិជ្ជាទាំងឡាយ ១៨ ប្រការ ។
(កាលនោះ)ព្រះវររាជបិតាទ្រង់ព្រះរាជទានទីឧបរាជ ដល់ព្រហ្ម-
ទត្តកុមារនោះ(ដោយសេចក្តីរីករាយ) ។ ក្នុងសម័យនោះបណ្តា
ប្រជាជនក្នុងនគរពារាណសី មានប្រកតីនមស្សការទេវតា ប្រ-
កាន់ថាទេវតាជាមង្គលសួស្តីក្រៃពេក ហើយតែងប្រជាប់ប្រជា
ប្រស់ព្រឹក្សាដើមឈើធំៗ សម្មតិថាជាទីលំនៅទេវតា បើត្រូវ
ការបង់បានបុត្រប្រុសស្រី ឬទ្រព្យសម្បត្តិជាដើម ក៏តែងទៅ
បន់ស្រន់ក្នុងទីដែលសម្មតិនោះ បើបានសមប្រកបដួចសេចក្តី
ប្រាថ្នាហើយ ក៏តែងសម្លាប់សត្វជ្រូក មាន់ នឹងសត្វពពែជាដើម

យកសាច់ឈាមនឹងគ្រឿងក្រអូបនឹងផ្កាភ្ញីផ្សេង ៗ ធ្វើពលិការសែនព្រេនបូជាលាបំណន់ ជាទម្លាប់គ្រប់ៗគ្នា ។ ព្រះឧបរាជទ្រង់ជ្រាបកិច្ចអស់ទាំងនោះហើយ ព្រះអង្គទ្រង់ព្រះចិន្តាថា ឥឡូវនេះមហាជនមានចិត្តយាងចុះ ក្នុងអធម្មកម្មគឺកម្មមិនប្រកបដោយគន្លងធម៌ច្រើនណាស់ស្ទើរតែនឹងទាំងអស់ ជឿប្រកាន់ថាទេវតាជាមង្គលសួស្តីក្នុងលោក ហើយសម្លាប់សព្វសត្វសែនព្រេន (ដោយប្រាជ្ញាអាក្រក់យ៉ាងនេះ កម្មលាមកទាំងអម្បាលនេះ) ដល់អំណើសតតពីព្រះវររាជបិតាទៅហើយ បើអញបានស្ថិតនៅក្នុងរាជសម្បត្តិ ជំណាងព្រះវររាជបិតាកាលណា នោះអញនឹងដឹកនាំនូវអ្នកនគរទាំងអស់ឲ្យប្រតិបត្តិត្រឹមត្រូវ ឃាត់អធម្មកម្ម មិនមានឲ្យលំបាកដល់សត្វណាមួយក្នុងកាលនោះ ។

ក្នុងថ្ងៃ ១ ព្រះឧបរាជក៏ទ្រង់ឡើងគង់រាជរថ ទ្រង់ឲ្យបរចេញចាកព្រះនគរ ព្រះអង្គទ្រង់ទតឃើញដើមជ្រៃធំ១ដែលមហាជនសន្មត់ធ្លាប់បន់ស្រន់តាមសេចក្តីប្រាថ្នាផ្សេង ៗ ធ្លាប់ប្រាថ្នា

យ៉ាងណា ក៏នឹងបានសម្រេចយ៉ាងនោះ (ចុតធាប់រូសរាន់ទាន់ចិត្ត) ។ ព្រះឧបរាជក៏ទ្រង់ចុះចាករថ យាងចូលទៅក្រោមដើមជ្រៃនោះហើយ ព្រះអង្គទ្រង់បូជាដោយគ្រឿងក្រអូបនឹងផ្កាភ្ញីទាំងឡាយ ទ្រង់ប្រស់ព្រំដោយទឹកធ្វើនមស្សការប្រទក្សិណបីដួចជាថាទេវតាជាមង្គលសួស្ដី ហើយព្រះអង្គទ្រង់យាងឡើងរថ ឲ្យបរចូលមកកាន់ព្រះនគរវិញ ។ ចាប់ដើមតាំងអំពីថ្ងៃនោះទៅ ព្រះអង្គតែងយាងទៅកាន់ទីនោះជាលំដាប់ ៗ ធ្វើបូជាបីដួចជាទេវតាជាមង្គលសួស្ដី ។ ក្នុងកាលខាងក្រោយព្រះឧប-រាជ ព្រះអង្គបានស្ថិតនៅក្នុងរាជសម្បត្តិដោយអំណើសឥតអំពីព្រះវររាជបិតាទៅ ព្រះអង្គទ្រង់រាជហើយព្រះអង្គទ្រង់វៀរលែងអគតិធម៌ ៤ យ៉ាងដាច់ស្រឡះ ប្រកបដោយទសពិធរាជធម៌ដ៏-បរិបូណ៌ ហើយទ្រង់ព្រះចិន្តាថាអាត្មាអញបានសមប្រកបតាមដំរេិះចិត្ត ស្ថិតនៅក្នុងរាជសម្បត្តិហើយ ប្រយោជន៍ឯណាមួយដែលអាត្មាអញបានត្រេិះរិះទុកក្នុងមុន ឥឡូវនេះអាត្មាអញនឹងញាំងប្រយោជន៍នោះ ឲ្យសម្រេចតាមសេចក្ដីបំណងរបស់

អញ ។ ព្រះអង្គទ្រង់ព្រះដំរិះដូច្នោះហើយ ទើបទ្រង់ត្រាស់បង្គាប់សេវកាមាត្យព្រាហ្មណ៍និងគហបតីទាំងឡាយ ឲ្យប្រជុំព្រមហើយទ្រង់សន្ទនាការថា ម្នាលអ្នកទាំងឡាយដ៏ចម្រើន អ្នកទាំងឡាយបានដឹងដែរឬទេ រាជសម្បត្តិដែលយើងបាននេះ តើបានដោយហេតុឯណា ។ ជនទាំងឡាយយកសេចក្ដីក្រាបបង្គំទូលថា បពិត្រព្រះសម្មតិទេព យើងទាំងឡាយពុំបានដឹងឡើយ ។ ព្រះបាទព្រហ្មទត្តរាជជាព្រះចៅក្រុងពារាណសីទ្រង់មានមធុរវាចាថា នែអ្នកទាំងឡាយរាជសម្បត្តិនេះយើងបានដោយបួងសួងទេវតានៅដើមជ្រៃធំឈ្មោះឯណោះ យើងបានបូជាដោយគ្រឿងក្រអូបនឹងផ្កាភ្ញីជាដើម ដូចអ្នកទាំងឡាយធ្លាប់ឃើញយើងទៅមករឿយ ៗ ។ ជនទាំងឡាយទទូលថា ប្រពៃណាស់ព្រះអង្គ ។ ព្រះរាជាទ្រង់មានព្រះបន្ទូលថា យើងបានបួងសួងទេវតាក្នុងកាលនោះថា បើយើងបានរាជសម្បត្តិសមដូចប្រាថ្នាហើយ យើងនឹងធ្វើពលិការថ្វាយទេវតា ឥឡូវនេះយើងបានរាជសម្បត្តិ ដោយអានុភាពទេវតានោះមែនហើយ

បើដូច្នោះយើងនឹងធ្វើពលិការលាបំណន់ឲ្យរួចឆាប់ ចូរអ្នកទាំងឡាយចាត់ចែងរៀបគ្រឿងពលិការ ឲ្យឆាប់រហ័សរួសរាន់កុំបង្អែបង្អង់យូរយារឡើយ ។ ជនទាំងឡាយបានស្តាប់ហើយ ក៏យកសេចក្តីក្រាបបង្គំទូលថា បពិត្រព្រះសម្មតិទេព វត្ថុអ្វីដែលគួរនឹងកាន់យក ទៅធ្វើពលិការលាបំណន់នោះ ។ ព្រះមហាក្សត្រិយ៍ទ្រង់មានព្រះបន្ទូលថា នែអ្នកទាំងឡាយដ៏ចម្រើន យើងបួងសួងទេវតាកាលនោះថា បើយើងបានរាជសម្បត្តិដោយទេវតាជួយហើយ មនុស្សឯណាទ្រុស្តសីល៥នឹងមនុស្សប្រព្រឹត្តអកុសលកម្មបថ ១០ មានក្នុងរាជ្យ ក៏នឹងពិឃាដមនុស្សទាំងនោះជំនួន ១ ពាន់នាក់ យកពោះវៀននឹងសាច់ឈាមសែនព្រេនលាបំណន់ ហេតុនោះអ្នកទាំងឡាយចូរធ្វើប៉ាវគងទូងភេរីប្រាប់អ្នកនគរឲ្យបានដឹងគ្រប់គ្នាថា ព្រះរាជាជាម្ចាស់យើងកាលនៅជាឧបរាជនៅឡើយ នោះបានបួងសួងទេវតាថា បើព្រះអង្គបានរាជសម្បត្តិដូចសេចក្តីប្រាថ្នា មនុស្សឯណាទ្រុស្តសីលក្នុងរាជព្រះអង្គ ទ្រង់នឹងឲ្យសម្លាប់មនុស្សទាំងអស់នោះ

ធ្វើពលិការទេវតា ឥឡូវនេះព្រះអង្គដល់នូវរាជសម្បត្តិហើយ មានព្រះដម្រាស់ត្រាស់បង្គាប់ឲ្យពិឃាដ មនុស្សទ្រុស្តសីល ៥ ជំនួន ១ ពាន់នាក់ យកសាច់បេះដូងជាដើមសែនលាបំណន់ទេវតា នែអ្នកទាំងឡាយអើយប្បូរដឹងគ្រប់គ្នា ។ នែអ្នកទាំងឡាយ ចាប់ដើមតាំងពីថ្ងៃនេះទៅ មនុស្សឯណាទ្រុស្តសីល ៥ ក៏នឹងសម្លាប់មនុស្សនោះ ១ ពាន់នាក់ សែនព្រេនលាបំណន់ទេវតា (មិនបង្អង់ខាន) ហើយព្រះអង្គទ្រង់ពោលនូវគាថានេះដូច្នេះថា។

ទុម្មេធានំសហស្សេន យញ្ញោមេឧបយាចិតោ

ឥទានិខោហំយជ្ជិស្សាមិ ពហុអធម្មិកោជនោតិ ។

សេចក្ដីថា បូជាដែលអញបន់ហើយ ដោយពាន់នៃជនទាំងឡាយដ៏មានប្រាជ្ញាអាក្រក់ អញទៅកាន់ទេវតានឹងបូជាក្នុងកាលឥឡូវនេះ ជនមិនប្រកបដោយគន្លងធម៌ មានច្រើនលើសលប់ណាស់ ។

សេវកាមាត្យទាំងឡាយ បានស្ដាប់ព្រះរាជឱង្ការដូច្នោះហើយ ក៏តាំងចាត់ការឲ្យបារិគងទូងភេរី ក្នុងនគរពារាណសី

បម្ងាយ ១២ យោជន៍ ពួកជនដែលមានប្រក្រតីនៅក្នុងនគរពារាណសី បានដឹងឮដោយអំណាចស្ករដែលប្រព្រឹត្តទៅនោះហើយ (ក៏ស្ញប់ស្ញែងតក់ស្លុតរន្ធត់ញាប់ញ័រដោយមរណភ័យគ្រប់ៗ គ្នា បណ្ដាជនអស់ទាំងនោះ ទាល់គំនិតផុតពាក្យប្រកែក រក្សាសីលគ្រប់គ្នា) ។ ក្នុងនគរនោះតាំងរក្សាសីលគ្រប់គ្នា សូម្បីរកតែមនុស្ស១នាក់នៅទ្រុស្តសីលក៏មិនបានផង។

ព្រះបាទព្រហ្មទត្តរាជ ជាបរមពោធិសត្វ ព្រះអង្គទ្រង់រាជជាបណា បណ្ដាជនក្នុងនគររក្សាសីល ៥ សីល ៨ កុសល-កម្មបថ ១០ ជាបនោះ មិនឲ្យមានលំបាកដល់សត្វឯណានិមួយ ព្រះអង្គទ្រង់រាជប្រកបដោយគន្លងធម៌ប្រពៃ ជានាយកណែនាំបណ្ដាជនដែលនៅក្នុងដែនឲ្យប្រតិបត្តិប្រពៃ ព្រះអង្គទ្រង់បំពេញនូវបារមីទាំងឡាយ ជាខ្សែដឹកនាំនូវពួកបរិសទ្យរបស់ព្រះអង្គទៅកាន់ស្ថានទេវតា ក្នុងកាលជាបំផុតនៃអាយុ ។

ព្រះបរមលោកនាថសាស្ដាចារ្យ ទ្រង់មានព្រះពុទ្ធដីកាថានៃភិក្ខុទាំងឡាយ តថាគត ប្រព្រឹត្តដើម្បីប្រយោជន៍ដល់សត្វ

លោកមិនតែក្នុងកាលឥឡូវនេះទេ តថាគតប្រព្រឹត្តដើម្បីប្រយោជន៍សត្វលោកដូច្នេះតាំងពីដើមមក ហើយទ្រង់សម្ដែងនូវប្រជុំជាតកថា ។

នែភិក្ខុទាំងឡាយ បរិសទ្យទាំងឡាយក្នុងកាលនោះ បានមកជាបរិសទ្យក្នុងកាលឥឡូវនេះ ព្រះរាជា ៗ កំពូលក្រុងពារាណសី មិនគឺអ្នកឯណាដ៏ទៃឡើយ គឺអង្គអញតថាគតនេះឯងហោង ។

## ទុមេធជាតកំនិដ្ឋិតំ

## អត្ថនោមត្យាធិប្បាយ

រឿងរ៉ាវទី ៣ នេះ ខ្ញុំខំកាត់កំបាត់បង់នូវសេចក្ដីខ្ជិលច្រអូស ឆ្លៀតប្រែរៀបរៀងដោយសេចក្ដីជ្រះថ្លារីករាយ ក្នុងគុណសម្បត្តិរបស់ព្រះបរមពោធិសត្វជាម្ចាស់ ដែលព្រះអង្គខំធ្វើសេចក្ដីល្អរបស់ព្រះអង្គហើយមិនបិទបាំងទុក ព្រះអង្គលើកសំដែងបង្ហាញសព្វបណ្ដាជនដែលដេកត្រាំក្នុងផុកល្បាប់ ពោលគឺចិត្តដែលប្រឡាក់ប្រឡូស ក្នុងបញ្ចវេរកម្មនឹងទសអកុសល

កម្មបថ ព្រះអង្គធ្វើបណ្ដាជនទាំងនោះ ឲ្យទាល់គំនិតផុតពាក្យប្រកែកឲ្យរលាស់ខ្លួនឡើងពីផុកល្បាប់ មកដំកល់ខ្លួនក្នុងសីល ៥ សីល ៨ កុសលកម្មបថ ១០ វិញដោយងាយ មិនឲ្យមានសេចក្ដីលំបាកដល់ជនឯណានិមួយឡើយ មានគួរនាដូចគ្រូពេទ្យដែលឆ្លាតកាន់យកនូវបន្លាបាក់ដស់បន្លាដែលមុតសរីរផ្កុះដកចេញឲ្យរួចដោយងាយ មិនឲ្យមានស្នាមល្បួសតទៅទៀត នេះហើយមុខគួរឲ្យខ្ញុំមានចិត្តព្រឺព្រួចផ្ទូរផង់យ៉ាងខ្ពស់បំផុត ។ សេចក្ដីប្រព្រឹត្តរបស់ព្រះបរមពោធិសត្វ នោះសមនឹងសុភាសិតក្នុងគម្ពីរជីរសារត្ថ ថា ។

សំសំខត្វាបរេសំសំ សក្កាបរត្ថកាមកោ
សំសំសាធេលភេសំសំ បច្ចមេអត្តភារកេតិ ។

សេចក្ដីថា អ្នកប្រាជ្ញជាសប្បុរសមានប្រាជ្ញា ប្រយោជន៍របស់ខ្លួនផង ប្រយោជន៍របស់អ្នកដទៃផង តែងឲ្យនូវទ្រព្យដ៏ប្រពៃដល់ជនដទៃជាសប្បុរស គាប្បីបាននូវសេចក្ដីសុខដ៏

បរិបូណ៌ ហើយមានទ្រព្យសម្បត្តិប្រសើរក្នុងសង្សារវដ្ដ គាប្បី បាននូវព្រះនិព្វានក្នុងបច្ឆិមភព (មិនឃ្លៀងឃ្លាតឡើយ) ។

បណ្ដាជនដែលទាល់គំនិតផុតពាក្យប្រកែក ខំប្រតិបត្តិតាមព្រះបរមពោធិសត្វ កើតផលប្រយោជន៍ធំអំពីទោមកសេពគប់ នោះសំនឹងសុភាសិតក្នុងគម្ពីរនោះដែរថា ។

សទាសមេតិសតាសំ សមេតិអសតាអសំ

វាយសោកុណបំយាតិ កុសុមំយាតិឆប្បទោតិ ។

សេចក្ដីថា សត្វក្អែកតែងហើរទៅកាន់ទីសាកអសុភ សត្វកន្លង់តែងហើរទៅកាន់គម្ពផ្កា យ៉ាងណា សប្បុរសតែងទៅមករកពួកសប្បុរសប្រាជ្ញាល្អ អសប្បុរសតែងទៅមករកពួកអសប្បុរសប្រាជ្ញាអាក្រក់ យ៉ាងនោះឯង ៗះ០៚—

# ពាលបិត្តប្បពោធនសូត្រ

ឧកញ៉ាភក្ដីរាជា ឃុំង អាចារ្យបង្រៀន

សាលាបាឡីជាន់ខ្ពស់

ដកយកពីគម្ពីរខុទ្ទកបាឋ

ហើយប្រែចេញពីបាឡីមកជាភាសាខ្មែរ

## នមស្សការ

ពុទ្ធធម្មញ្ច សំឃញ្ច នមស្សិត្វាគុណាលយំ
បវក្ខាមិសមាសេន ពាលបិត្តប្បពោធនំ ។

ខ្ញុំនាមសុមេធបណ្ឌិតភិក្ខុ សូមនមស្សការនូវព្រះពុទ្ធជាម្ចាស់ ព្រះធម៌ជាម្ចាស់ នូវព្រះសង្ឃជាម្ចាស់ ជាទីលំនៅនៃគុណទាំងពួង ហើយនឹងសម្ដែងនូវពាលបិត្តប្បពោធនសូត្រ ដោយសេចក្ដីសង្ខេប ។

សេចក្ដីថា ពពួកសត្វទាំងឡាយបង្កើតលើផ្ទៃផែនដីសុទ្ធតែជាសត្វខ្លៅល្ងង់ លុះនូវអំណាចនៃលោភនឹងទោស សំគាល់នូវខ្លួនថាជាល្អថាសុខដោយចិត្តកំឡៀអស់កាលទាំងពួង ។

ឯរាងកាយរបស់គេយើងរាល់គ្នានេះ ជាទីអាស្រ័យនូវរោគផ្សេង ៗ បីដូចជាក្អមពេញទៅដោយឃ្នាំពិសពុល ពុំនោះសោតបីដូចជានគរបីសាច ព្រោះរាងកាយជារបស់ធ្វើនូវសេចក្ដីភ័យមានប្រមាណច្រើន រាងកាយតែងរលត់ទៅក្នុងវ័យនឹងមិនគឺវ័យ បីដូចជាពពុះទឹក គឺសេចក្ដីសោកតែងបៀតបៀនហើយបីដូចជាដំបៅដែលកួនសរវាមុត រាងកាយនេះគឺជរានឹងសោកគ្របសង្កត់ហើយ បីដូចជាផ្កាឈូកដែលបុគ្គលច្របាច់ដោយដៃ រាងកាយគឺបុគ្គលចិញ្ចឹមរក្សាហើយប្រកបដោយទុក្ខច្រើនបីដូចជាកូនកំណាចដែលមាតាបិតាចិញ្ចឹមរក្សា ។

ជនទាំងឡាយឯណាសេពគប់នូវរាងកាយក្នុងលោកនេះ ឧបមាដោយកិរិយាសេពគប់ដោយសត្វអាសិរពិសពស់ ជនទាំងឡាយឯណាដេកច្រើន សេចក្ដីទុក្ខទាំងឡាយនឹងកើតដល់បុគ្គលទាំងឡាយនោះច្រើនដែរ បីដូចជាសត្រូវគឺខ្លួនចិញ្ចឹមរក្សា ។

រាងកាយគឺជរាបៀតបៀនហើយ បីដូចជាគប់ភ្លើងឆេះ

ស្មៅដែលស្ថិតនៅក្នុងទីប្រាសខ្យល់ ជនទាំងឡាយឯណា សេពគប់វាប់អានរាងកាយហើយ ជនទាំងឡាយនោះប្រកប ដោយសេចក្ដីលំបាកពេកណាស់ បីដូចជាដុំដែកក្ដៅគឺបុគ្គល ញាំញីហើយមុខជានឹងក្ដៅរលោកមិនខាន រាងកាយមានសេចក្ដី សុខតិចណាស់ បីដូចជាដំណក់ទឹកសន្សើម មានទុក្ខច្រើន ដូចទឹកសមុទ្រតែងហូរទៅក្នុងលោកអស់កាលទាំងពួង រាង កាយមានទុក្ខពេកណាស់ ដល់សត្វមានអាយុវែងក្ដី សត្វ ដែលមានអាយុតិចក្ដី សេចក្ដីទុក្ខនឹងស្លាប់ក៏សឹងមានដូចគ្នា ជនពាលទាំងឡាយជាបុគ្គលប្រមាទ មានសភាពជាអ្នកសំ- គាល់នូវខន្ធថាជាសុខ តែងប្រាថ្នានូវរាងកាយគឺទុក្ខអំពីសេចក្ដី ស្លាប់បៀតបៀនហើយ មានប្រការផ្សេងៗយ៉ាងនេះឯង ជន ទាំងឡាយប្រកបដោយជាតិជាបណ្ឌិត ឃើញនូវរាងកាយ មានទុក្ខធ្ងន់ពេកដូច្នេះហើយ តែងរិះគិតរកនូវឧបាយដើម្បីដោះ ខន្ធឲ្យរួចផុតចាកទុក្ខពិតប្រាកដ ទុក្ខលក្ខណវគ្គជាបឋម ក្នុង ពាលចិត្តប្បពោធនកថាមានដោយប្រការដូច្នេះ ។

# អនិច្ចលក្ខណវគ្គ គំរប់ ២

សេចក្ដីថា ជនទាំងឡាយជាបុគ្គលមានប្រាជ្ញាខ្លៅ តែង សំគាល់ដឹងនូវខន្ធបញ្ចកគឺ(រូប,វេទនា,សញ្ញា,សំខារ,វិញ្ញាណ) ជារបស់មិនទៀង ព្រោះខន្ធបញ្ចកមានសភាពកើតឡើងនឹង វិនាសទៅវិញ ឋាជារបស់ល្អឋាជារបស់ទៀងក្នុងកាលទាំង ពួង ម្យ៉ាងវិញទៀតជរាតែងកំចាត់បង់នូវរូបជាទីសម្លាញ់របស់ សត្វទាំងឡាយ រោគទាំងពួងតែងកំចាត់នូវកំឡាំង ឯសេ្ដច មច្ចុតែងកំចាត់បង់នូវជីវិត ភោគសម្បត្តិទាំងឡាយក្ដី កូនប្រុស ស្រីទាំងឡាយក្ដី ប្រុសជាផៅពង្សឬជាមិត្តសំឡាញ់ទាំងឡាយ ក្ដី យានជំនិះទាំងឡាយក្ដី ស្រែចម្ការឬដំណាំទាំងឡាយក្ដី របស់អ្វីនិមួយគួរគាប្បីទៅតាមខ្លួនបាន សូម្បីស្ថិតនៅក្នុងស្ថាន កាមាវចរទាំងឡាយ តែងត្រេកអរហើយក្នុងកាមគុណដ៏ជាទិព្យ ក៏គង់តែលះបង់នូវរាងកាយជារបស់ខ្លួន ដោយកិរិយាអស់ បុណ្យនឹងអស់អាយុពុំលែងឡើយ ទោះរូបព្រហ្មទាំងឡាយក្ដី អរូបព្រហ្មទាំងឡាយក្ដី មានប្រក្រតីចំរើននូវឈាន មានឫទ្ធិ

អានុភាពច្រើន កាលញាំងទិសទាំងឡាយឲ្យភ្លឺស្វាងរុងរឿងបាន ព្រហ្មទាំងឡាយនេះក៏តែងលះបង់នូវអត្តភាពជារបស់ខ្លួនពុំខាន ទោះព្រះពុទ្ធទាំងឡាយក្តី ព្រះបច្ចេកពុទ្ធទាំងឡាយក្តី សាវិកទាំងឡាយក្តី ប្រកបដោយឫទ្ធិច្រើន ដែលជាទីលំនៅនៃគុណមានសីលគុណជាដើម មានមន្ទិលគឺកិលេសមានរាគជាដើមប្រាសចេញអំពីសន្តានចិត្តហើយ ព្រះអរិយបុគ្គលទាំងឡាយទាំងពួងមានព្រះពុទ្ធជាដើម លោកក៏ដល់នៅអំណាចនៃមច្ចុរាជពុំលែង ទោះសមុទ្រគឺបុគ្គលមិនគាប្បីប្រមាណទាំងឡាយ ជាអណ្តូងជាទីកើតនៃកែវទាំងឡាយ មានត្រើយប្រាំងគឺបុគ្គលឃើញមិនបានមានជុំវៅដ៏ជ្រាលជ្រៅ សមុទ្រទាំងឡាយអំបាលនោះក៏គង់ដល់នូវអំណាចនៃអនិច្ចធម៌ដូចគ្នា ទោះភ្នំសិនេរុនឹងផែនដីទាំងមូលព្រមទាំងសមុទ្រព្រមទាំងភ្នំដទៃក្តី សត្វទាំងឡាយដែលត្រេចទៅលើផែនដីក្តី ក៏គង់ដល់នូវសេចក្តីវិនាសសោះសូន្យទៅក្នុងកាលទីបំផុតនៃយុគ្គកាលពុំខានឡើយ ទោះទាំងភូមិភពទាំងឡាយអំពីខាងក្រោមស្ថានអភស្សរាក៏គង់

ដល់នូវភាវជាអាកាសទទេពុំបាននឹងនៅ បីដូចជាគ្រាប់ស្ពៃ ស្ថិតនូវចុងដែកស្រួច នឹងបាច់ពោលទៅថ្វីក្នុងសរីរកាយរបស់សត្វទាំងឡាយ ។

ជនទាំងឡាយឯណាជាអ្នកប្រាជ្ញ អាចដឹងហើយនូវរាងកាយ ថាជារបស់មានសភាពទៀងយ៉ាងនេះហើយ តែងប្រព្រឹត្តធ្វើបុណ្យឲ្យទានមានប្រការផ្សេង ៗ ដើម្បីឲ្យរួចបេញចាកភពទាំង ៣ ប្រការ គឺ កាមភព, រូបភព, អរូបភព, នេះហោង ។

អនិច្ចលក្ខណវគ្គគំរប់ ២ ក្នុងពាលបិត្តប្បពោធមានដោយប្រការដូច្នេះឯង ។

ក្នុងអនត្តលក្ខណវគ្គគំរប់ ៣ សេចក្ដីថា សម្ដេងពោលថារបដូច្នេះព្រោះប្រជុំ អវយវ ដោយប្រការឯណា សម្មតិដូច្នេះថាខ្លួនព្រោះប្រជុំនាមនឹងរូបដោយប្រការដូច្នោះ សម្ដេងហៅថារថដូច្នេះបើនាំយកនូវអវយវចេញហើយក៏ពុំមានយ៉ាងណាមិញសម្មតិដូច្នេះថាខ្លួនបើនាំយកនូវនាមនឹងរូបចេញហើយក៏ពុំមានយ៉ាងដូច្នោះឯង រាងកាយមិនមែនខ្លួនយ៉ាងនេះ បីដូចជាភូត

មារយា ព្រោះជារបស់បញ្ឆោតសត្វ បីដូចជាថ្ងៃបណ្តើរកូន ព្រោះជារបស់ប្រឡោមល្បួងសត្វ បុគ្គលពាលគាប្បីពោលដូច្នេះថាកូនរបស់ស្រីអារគាប្បីទ្រទ្រង់នូវប្រវេណី ដោយប្រការឯណា បុគ្គលពាលទាំងឡាយតែងពោលដូច្នេះថាខ្លួនដោយប្រការដូច្នោះហើយ ប្រាថ្នានូវខ្លួនក្នុងកាលទាំងពួង បុគ្គលពាលគាប្បីពោលថា អញផឹកនូវទឹកថ្ងៃបណ្តើរកូនដោយប្រ-ការយ៉ាងណា បុគ្គលពាលនោះតែងពោលថាដូច្នេះ អញប្រ-ដាប់ស្អិតស្អាងនូវខ្លួនដោយប្រការដូច្នោះហើយរាប់អានស្រឡាញ់នូវខ្លួន បុគ្គលឯណាគាប្បីពោលដូច្នេះថា អញធ្វើនូវធ្នូដោយស្នែងនៃសត្វទន្សាយហើយគាប្បីទ្រទ្រង់ បុគ្គលពាលពោលដូច្នេះថា ខ្លួនធ្វើនូវឫទ្ធិក្នុងកាលទាំងពួង បុគ្គលអ្នកស្វែងរកនូវខ្លឹមបេកពុំឃើញមានយ៉ាងណា បុគ្គលកាលស្វែងរកនូវខ្លួនក្នុងខន្ធទាំងឡាយក៏ពុំឃើញមានយ៉ាងនោះ បុគ្គលពាលឃើញនូវថ្ងៃបណ្តើរកូនអំពីចំងាយសំគាល់ថាជាទឹក ហើយស្ទុះពួលទៅជិតយ៉ាងណាមិញ បុគ្គលពាលសំគាល់នូវខ្លួនថាជា

សុខ ហើយស្រឡាញ់រាប់អាននូវខ្លួនយ៉ាងដូច្នោះឯង បុគ្គលជាបុថុជ្ជនរាប់អានស្រឡាញ់នូវរបស់គ្មានបាខនដូច្នេះហើយប្រ-ព្រឹត្តធ្វើនូវអំពើលាមកក្នុងលោកនេះ ហើយរមែងសោយសោកក្នុងកាលជាខាងក្រោយអស់កាលទាំងពួង បុរសជាអ្នកប្រាជ្ញដឹងច្បាស់នូវខ្លួន ថាជារបស់ប្រលោមល្បួងសត្វយ៉ាងនេះ បី-ដូចជាថ្ងៃបណ្តើរកូនអំពីបម្វាយ ហើយក៏មិនបានស្រឡាញ់រាប់អាននូវខ្លួនក្នុកាលទាំងពួង, អនត្តលក្ខណវិគ្គគីរប់ ៣ ក្នុងពាលចិត្តប្បពោធនកថា ក៏មានដោយប្រការដូច្នេះឯង ។

ក្នុងអសុភលក្ខណវិគ្គគីរប់ ៤ សេចក្តីថា រាងកាយនេះដ៏ពេញដោយរបស់មិនស្អាតមានខ្ទុះនឹងមូត្រល្អក់ជាដើម ជារបស់មិនល្អជាទីខ្ពើមរអើមផងក្នុងកាលទាំងពួងមែនពិត បីដូចជាក្អមដ៏ពេញ ដោយល្អក់ សេចក្តីពិតថា រាងកាយជាប្រទេសជាទីកើតរបស់សត្វដង្កូវទាំងឡាយ ជាផ្ទះមានផ្ទះជុំដីជាដើម ជាព្រៃស្មសាន ជាកន្លែងសំរាប់សំរាលកូន របស់សត្វដង្កូវទាំងឡាយក្នុងកាលទាំងពួង បីដូចជាក្អមដ៏ះពេញដោយសត្វដង្កូវ

រាងកាយសូម្បីគឺបុគ្គលបិញ្ចិមរក្សាដោយវត្ថុមានសំពត់និងគ្រឿងក្រអូបជាដើមសព្វថ្ងៃ ក៏នៅជារបស់មិនស្អាតដ៏ដែល បើដូចជាក្អមល្អក់គឺបុគ្គលបោលទៅក្នុងវត្ថុមានគ្រឿងក្រអូបជាដើម រាងកាយជាផ្ទះសំរាប់ពពួកគឺសកទាំងឡាយគឺរោមទាំងឡាយ ជាទីលំនៅរបស់ទឹកភ្នែក, ខ្ទាញ់ខាប់, ខ្ទាញ់រាវ, ញាំងវត្ថុមិនស្អាតមានស្លេស្មជាដើម ឲ្យហូរទៅកាន់ទ្វារទាំងឡាយ ៩ ក្នុងកាលទាំងពួង រាងកាយនេះសូម្បីគឺបុគ្គលកាន់យកនូវទឹកក្នុងសមុទ្រទាំងអស់ យកនូវគ្រឿងក្រអូបប្រមាណប៉ុនភ្នំព្រះសុមេរុមកលាងមកដូតមកអប់ជានិច្ចជាកាល ក៏នូវតែពុំល្អមានប្រការដូច្នោះឯង ។ ជនពាលទាំងឡាយពុំឃើញនូវរាងកាយជាទីលំនៅនៃរោគ ប្រកបដោយសោកប្រកបដោយភ័យដោយសេចក្តីអន្តរាយហើយ តែងរាប់អាននូវរាងកាយក្នុងកាលទាំងពួង ប្រសិនណាបើ អាការមានសាច់ជាដើមទាំងអស់ដែលដកល់នៅខាងក្នុង ហើយប្រាកដខាងក្រៅវិញ បុគ្គលគាប្បីកាន់បេកនូវដំបងព្រនង់ដុំដីហើយដេញក្អែកត្មាតទាំងឡាយពុំលែង ប្រសិន

ណាបើមាតាបិតាព្រមទាំងភរិយា ឃើញនូវរបស់ខាងក្នុងទាំងអស់ ប្រាកដខាងក្រៅវិញ មុខជាគ្មានស្តាយស្រណោះអាឡោះអាល័យហើយដើរចោលបោះបង់ហើយ ប្រាកដជាសត្វក្អែកក្អាតទាំងឡាយ ទំពាស៊ីនូវរាងកាយដែលប្រឡាក់ដោយសាច់នឹងឈាម គឺបុគ្គលចោលបង់ក្នុងព្រៃស្មសានមែនពិតណាស់ ញាតិសាលោហិតមិត្រសំឡាញ់នឹងមានអំពីទីឯណា ទ្រព្យសម្បត្តិអ្វីក៏នឹងមានអំពីទីឯណា ជនទាំងឡាយប្រកបដោយជាតិជាបណ្ឌិត ដឹងច្បាស់ហើយនូវរាងកាយដោយអសុភយ៉ាងនេះ គាប្បីធ្វើនូវព្រះធម៌ឲ្យជាទីគោរព ស៊ូលះបង់នូវអង្គលះបង់នូវជីវិត អសុភលក្ខណ៍វគ្គជាគំរប់ ៤ ក្នុងពាលបិត្តប្បពោធនកថា មានដោយប្រការដូច្នេះឯង ។

មរណានុស្សតិវគ្គគំរប់ ៥ សេចក្តីថា ដុំដីដែលបុគ្គលចោលទៅក្នុងអាកាស ហើយធ្លាក់ចុះមកលើផែនដីវិញ យ៉ាងណាមិញ សត្វដែលកើតមកហើយ តែងដល់នូវសេចក្តីស្លាប់ពិតដោយប្រការយ៉ាងនោះ វិរបៀបរលកទាំង

ឡាយ ពុំដែលប្រព្រឹត្តកន្លងឡេហួសអំពីប្រាំងក្នុងកាលទាំងពួង យ៉ាងណាមិញ បណ្តាពពួកជនក្នុងលោកនេះពុំដែលប្រព្រឹត្តកន្លងនូវសេចក្តីស្លាប់ ដោយប្រការដូច្នោះឯង ជារទឹកភ្លៀងទាំងឡាយ តែងធ្លាក់លើផែនដីក្នុងទិសទាំងឡាយ ទៀងនៅក្នុងទិសទាំងឡាយយ៉ាងណា បណ្តាពពួកសត្វទាំងឡាយក៏ទៀងតែដល់នូវអំណាចនៃមច្ចុរាជ ដូច្នោះឯង សត្វតិរច្ឆានទាំងឡាយទាំងពួងក្តី ប្រេត, គន្ធព, អារក្ខទឹក, មនុស្ស, អសូរ, យក្ខទាំងឡាយក្តី សត្វទាំងឡាយមានតិរច្ឆានជាដើមនោះ តែងដល់នូវសេចក្តីស្លាប់ទាំងអស់ដូចគ្នា សូម្បីទេវតាក្នុងស្ថានកាមាវចរទាំងឡាយក្តី រូបព្រហ្មក្តី អរូបព្រហ្ម ដែលមានអាយុវែងមានតេជះប្រើន ទេវតាទាំងឡាយទាំងពួងនោះ ក៏ដល់នូវសេចក្តីស្លាប់ពុំលែងឡើយ ភាជនដីគឺឆាយស្ងួនឆ្នាំងឆ្វើហើយ មានកិរិយាដល់ព្រមនូវសភាពបែកធ្លាយទៅ មែនមានឧបមាយ៉ាងណា ឯប្រជុំជនទាំងអស់មានកិរិយាដល់នូវសភាពបែកធ្លាយទៅ មានឧបម័យយ៉ាងដូច្នោះហោង ឯសេចក្តីមរណាជាធម៌

ទៀង សូម្បីតែ ១ ក៏អាចដើម្បីសម្លាប់នូវសត្វក្នុងភពទាំង៣បាន ឥតមានសែសសល់ លោកអ្នកប្រាជ្ញតែងធ្វើនូវកូនប្រពន្ធផង នូវជីវិតផង ឲ្យអណ្តែតនៅក្នុងទីងឹត ដោយអំណោយទានបុគ្គលពាលទាំងឡាយ ឃើញនូវសេចក្តីស្លាប់ដូច្នេះហើយ បុគ្គលពាលទាំងឡាយនោះពោលថា អញនឹងធ្វើនូវបុណ្យក្នុងថ្ងៃស្អែកៗហើយ តែនៅតែធ្វើនូវបាបពុំលែងឡើយ លោកអ្នកប្រាជ្ញទាំងឡាយគឹតនូវសេចក្តីស្លាប់ពិតណាស់ហើយ លោកអ្នកប្រាជ្ញទាំងឡាយនោះ តែងលះបង់នូវជីវិតព្រមទាំងទ្រព្យផងនូវអង្គផងនូវកូននឹងប្រពន្ធផងឲ្យទៅជាទានពុំបានយឺតយូរមែនពិត ។

មរណានុស្សតិវគ្គគំរប់ ៥ ក្នុងពាលបិត្តប្បពោធនកថា មានដោយប្រការដូចនេះឯង ។

វត្ថុកាម វគ្គ គំរប់ ៦ សេចក្តីថា បុគ្គលជាបុថុជ្ជនមិនដឹងនូវទោសធំក្នុងវត្ថុកាម រាប់អាននូវវត្ថុកាមរឿយៗ មានប្រមាណមិនតិច ពាក្យប្រៀបថាត្រីលេបនូវសន្ទូចដល់នូវសេចក្តីទុក្ខដោយប្រការឯណា មាណពទាំងឡាយរាប់អាននូវកាម

ទាំងឡាយហើយរមែងដល់នូវសេចក្ដីទុក្ខដោយប្រការដូច្នោះ បុគ្គលឯណាសេពគប់នូវកាមទាំងឡាយ រីគប់ភ្លើងដែលឆេះនូវក្នុងទីប្រាសខ្យល់យ៉ាងណាមិញ សេចក្ដីទុក្ខតែងប្រព្រឹត្តទៅដល់បុគ្គលនោះដោយប្រការដូច្នោះ ដើមឈើទាំងឡាយមានផ្លែច្រើន មានស្លឹក សម្បុក ពន្លក ហិនហោចទៅយ៉ាងណា ជនប្រកបដោយភោគសម្បត្តិទ្រព្យធន់ច្រើន សេចក្ដីទុក្ខច្រើនរាប់មិនបានមានដល់បុគ្គលនោះដោយប្រការយ៉ាងដូច្នោះ ពុំនោះសោតដូចបុគ្គលណាមួយចូលទៅកាន់នគរបីសាចជានគរត្រេកអរសប្បាយណាស់ បុគ្គលនោះមុខជានឹងវិនាសទៅមិនខានមានឧបមាយ៉ាងណាមិញ បុគ្គលឯណាមួយតែងសេពគប់នូវកាមគុណហើយ បុគ្គលនោះមុខជានឹងវិនាសក្នុងលោកពុំខានឡើយ បុគ្គលពាលទាំងឡាយស្រឡាញ់រាប់អាននូវកាមគុណនោះហើយ ក៏នឹងវិនាសទៅក្នុងកាលទាំងពួង បីដូចជាសត្វកណ្ដូបទាំងឡាយវិនាសទៅដោយអណ្ដាតភ្លើងក្នុងរាត្រីកាល សូម្បីទេវតាក្នុងកាមាវចរទេវលោកទាំងឡាយ សំរេចដោយ

កាមគុណទិព ក៏តែងតែលះបង់នូវកាមគុណទាំងនោះហើយ ឬតទៅពុំខាន សេចក្ដីត្រេកអរដូចម្ដេចក្នុងកាមគុណនោះបី-ដូចជាសេចក្ដីត្រេកអរក្នុងយល់សព សត្វទាំងឡាយគាប្បីលះបង់បោលនូវកាមទាំងឡាយ ឯកាមនោះសោតគាប្បីវៀរបង់បោលនូវសត្វនោះដូចម្ដេចមិញ ភោគសម្បត្តិគាប្បីលះបង់បោលនូវសត្វយ៉ាងដូច្នោះ បើពុំនោះសោតបីដូចជាផ្លែកបន្ទោរនៅក្នុងទីជាបន្លោះពពក បុគ្គលពាលបុថុជ្ជនពុំដឹងនូវទោសក្នុងកាម-គុណយ៉ាងនេះហើយ តែងពោលថាប្រាក់របស់អញ ថាមាសរបស់អញ ហើយស្រឡាញ់រាប់អាននូវប្រាក់នឹងមាសនោះឯងបុគ្គលជាអ្នកប្រាជ្ញប្រកបដោយបញ្ញាដឹងនូវទោសក្នុងកាមគុណយ៉ាងនេះហើយ លោកខ្ពើមនូវកាមគុណក្នុងលោកអស់កាលទាំងពួង បីដូចជាបុគ្គលខ្ពើមនូវភោជនាហារដ៏ប្រឡំទៅដោយថ្នាំពិសពុល វត្ថុកាមវត្ថុជាគំរប់ ៦ ក្នុងពាលបិត្តឬពោធនកថាក៏មានដោយប្រការប៉ុណ្ណោះឯង ។

កិលេសកាមវត្ថុគំរប់ ៧ សេចក្ដីថា តណ្ហាជាធម្មជាតិ

មានទុក្ខក្រៃលែងជាងទុក្ខទាំងពួង បុគ្គលពាលទាំងឡាយ មានកិរិយាអាងនូវទោសក្នុងកាមគុណជាប្រក្រតី តែងញ៉ាំងតណ្ហានោះឲ្យចំរើន បីដូចជាសត្រូវដែលបុគ្គលចិញ្ចឹមរក្សា បុគ្គលពាលលុះនូវអំណាចនៃតណ្ហាហើយ ទៅជាមនុស្សប្រមឹកផឹកនូវទឹកស្រវឹង ទៅជាមនុស្សភូតកុហកលួចលាក់នូវទ្រព្យរបស់អ្នកដទៃ ឬសេពគប់នូវភរិយាអ្នកដទៃក៏មាន ឯជនអាក្រក់បើឃើញអ្នកណានិមួយគេពុំបានប្រមាទក្នុងព្រះពុទ្ធ ព្រះធម៌ព្រះសង្ឃ ក្នុងកាលឯណានិមួយហើយ តែងមានចិត្តប្រាថ្នាធ្វើឲ្យដូចគេតែពុំព្រមធ្វើតាមក្នុងកាលទាំងពួង បុគ្គលឯណាដែលមានចិត្តស្អិតជាប់ចំពាក់នៅដោយតណ្ហាហើយ បុគ្គលនោះបើឃើញអ្នកណានិមួយហើយ ក៏មានចិត្តភិតភ័យរន្ធត់តក់ស្លុត បីដូចជាទឹកសមុទ្រដែលស្ងប់ ហើយមានខ្យល់ព្យុះធំបក់មកត្រូវដូច្នោះ បុគ្គលបាបដល់នូវអំណាចនៃតណ្ហាយ៉ាងនេះហើយ ជាអ្នកប្រមាទតែងប្រព្រឹត្តធ្វើនូវបាបក្នុងលោកនេះហើយ ក៏នឹងកំរើកញាប់ញ័រក្នុងបាបទាំងឡាយដោយច្រើន

ក្រៃលែង បុគ្គលនោះលុះសោយទុក្ខនៅក្នុងអបាយភូមិទាំង-ឡាយហើយ បើមកបង្កើតជាមនុស្សលើផ្ទៃផែនដីទៀតក៏ពុំបេះមានឆ្អែតឆ្អន់ដោយកាមគុណទាំងឡាយនោះ ពុំបានឃើញនូវទុក្ខនោះៗឡើយ បុគ្គលដែលប្រកបដោយតណ្ហាហើយបើប្រាថ្នានូវទ្រព្យរបស់អ្នកដទៃហើយពុំបានឃើញនូវទុក្ខនោះៗមានភ័យនឹងបង់នឹងបាត់ជាដើម បើពុំនោះសោត តែងធ្វើនូវជំលោះប្រកែកមួយអន្លើដោយមាតាបិតាឬបុត្តភរិយាទាំងឡាយជានិច្ចជាកាល ពីព្រោះតែលោភចង់បាននូវទ្រព្យសម្បត្តិនោះ ឯសត្វសាហាវទាំងឡាយមានសីហានឹងខ្លាជាដើមក្តី ស្តេចនឹងចោរទាំងឡាយ ដែលកាចអាក្រក់ក្តី ជួនកាលធ្វើនូវទុក្ខខ្លះជួនកាលមិនធ្វើខ្លះដល់បុគ្គលនោះ បំណែកបុគ្គលអ្នកប្រកបដោយតណ្ហាហើយ ជាបុគ្គលប្រកបដោយទុក្ខនោះឆ្អែតបរិបូណ៌ហើយ ឯតណ្ហាដែលដិកល់នៅខាងក្នុងសន្តានចិត្ត [illegible] តែងធ្វើនូវសេចក្តីទុក្ខដល់បុគ្គលនោះក្នុងអបាយទាំងឡាយអស់កាលអង្វែងយូរ ទុក្ខនោះឯងឈ្មោះថាជាទុក្ខក្រៃលែងជាងទុក្ខ

ទាំងអស់ កិលេសកាមគុណវគ្គ ក្នុងពាលបិត្តប្បពោធនកឋា ជាគំរប់ ៧ ក៏មានដោយប្រការដូច្នេះហោង ។

ទោសវគ្គគំរប់ ៨ សេចក្ដីថា បុគ្គលឯណាគឺសេចក្ដីលោភនឹងក្រោធគ្របសង្កត់សន្ដានចិត្តហើយពុំឃើញនូវអំពើជាប្រយោជន៍បន្តិចបន្តួចសោះបុគ្គលនោះមិនដឹងនូវហេតុគួរនឹងមិនគួរ ហើយតែងធ្វើនូវអំពើដែលអាក្រក់មែនពិតមិនខាន បុគ្គលនោះជេរវាយនូវមាតាបិតាបុត្តភរិយា ផៅពង្សនឹងមិត្រសំឡាញ់ហើយ គង់ដល់នូវសេចក្ដីសោយសោកក្នុងកាលខាងក្រោយ អស់កាលទាំងពួង មិនតែប៉ុណ្ណោះ បុគ្គលនោះជេរវាយនូវសមណនឹងព្រាហ្មណ៍ ជាអ្នកមានសីលស្វែងរកនូវប្រយោជន៍ ហើយតែងសោយនូវសេចក្ដីទុក្ខក្នុងកាលជាខាងក្រោយ បុគ្គលនោះគឺសេចក្ដីក្រោធសង្កត់ក្នុងកាលឯណាហើយជេផ្ដាសានូវព្រះពុទ្ធ, ព្រះធម៌, ព្រះសង្ឃ, ជាវត្ថុគួរដល់បូជាគោរពប្រតិបត្តិក្នុងលោកសព្វកាល ក្នុងកាលនិមួយពុំខានម្យ៉ាងវិញទៀត បុគ្គលគឺសេចក្ដីក្រោធគ្របសង្កត់ហើយក្នុង

កាលឯណា ឃើញនូវមាតាបិតាឬនូវបុគ្គលដទៃ បីដូចជាសត្វខ្លាក្រឡេកឃើញនូវសត្វម្រឹគក្នុងកាលនោះឯង រីភ្លើងកំពុងឆេះហើយតែងឆេះនូវវត្ថុទាំងពួងដែលមកដល់អស់ទៅដោយប្រការឯណា បុគ្គលដែលសេចក្ដីកំហឹងគ្របសង្កត់ហើយ តែងញ៉ាំងវត្ថុទាំងពួងឲ្យវិនាសទៅក្នុងកាលទាំងពួងដោយប្រការដូច្នោះឯង បុគ្គលអ្នកខឹងក្រោធទំពាស៊ីនូវថ្នាំពិសពុលស្លាប់ក៏មាន ចងកដោយខ្សែស្លាប់ក៏មាន សំឡាប់ខ្លួនដោយគ្រឿងអាវុធក៏មាន ខ្លះទំលាក់ខ្លួនក្នុងជ្រោះស្លាប់ក៏មាន លោតចូលភ្លើងស្លាប់បីដូចជាសត្វកណ្ដូបចូលភ្លើងក៏មាន សេចក្ដីទុក្ខដែលកើតមានដល់បុគ្គលច្រើនរាប់ពុំបានឡើយ បុគ្គលដែលសេចក្ដីក្រោធគ្របសង្កត់ហើយយ៉ាងនេះ ធ្វើនូវអំពើទុច្ចរិតមានប្រមាណច្រើន សោយសោកក្នុងលោកនេះលុះស្លាប់ទៅកាន់បរលោក រឹងរិតតែសោយសោកក្រៃលែងណាស់ លោកអ្នកប្រាជ្ញអាចមានប្រាជ្ញាដឹងច្បាស់ដូច្នេះហើយបើលោកដល់នូវអំណាចនៃសេចក្ដីក្រោធកាលឯណា តែងយកនូវខន្តីនឹងមេត្តាមកកំចាត់បង់នូវ

សេចក្ដីក្រោធឲ្យខ្វាត់ខ្វែងបេញជានិច្ចជាកាលពុំពេលខាន ទោស-វគ្គគំរប់ ៨ ក្នុងពាលបណ្ឌិតប្បពោធនកថា ក៏មានដោយប្រការដូច្នេះឯង ។

អវិជ្ជាវគ្គគំរប់ ៩ សេចក្ដីថា ធម៌ដែលជាទីញ៉ាំងអំពើឥតប្រយោជន៍ឲ្យកើតឡើង នឹងរកធម៌ឯណាក្នុងលោកនេះឲ្យស្មើដោយមោហាគ្មានឡើយ មោហាជាគ្រឿងនាំមកនូវទុក្ខទាំងពួង ព្រោះមោហាជាឫសគល់របស់សំសារទុក្ខក្នុងកាលទាំងពួង នាកាលទោសគឺមោហាបិទបាំងហើយ សត្វលោកពេញដោយអវិជ្ជា គាប្បីញ៉ាំងលោភនឹងទោសឲ្យប្រព្រឹត្តទៅ ព្រោះធម៌ទាំងឡាយគឺលោភនឹងទោសមានអវិជ្ជាជាហេតុខាងដើម ពុំបានឲ្យត្រាស់ដឹងនូវបុណ្យនឹងបាប បុគ្គលពាលមិនដឹងនូវបុណ្យនឹងបាបហើយ ប្រាថ្នាដើម្បីធ្វើនូវអំពើឯណា គាប្បីធ្វើនូវអំពើនោះៗទៅ សូម្បីតែសំពះឬបូជានូវមាតាបិតាក្ដី នូវសមណនឹងព្រាហ្មណ៍ក្ដីក៏ពុំមានឡើយ ពុំបានធ្វើនូវមាត្រាថាសេចក្ដីគោរព តែងធ្វើនូវអំពើដែលគេមិនគាប្បីធ្វើ តែងពោល

នូវពាក្យដែលគេមិនគាប្បីពោល  បុគ្គលពាលបើគេនិយាយ
ខុសត្រេកអរ  បើគេនិយាយត្រូវខឹង  បុគ្គលពាលបើឃើញនូវ
ភ័យអំពីមនុស្សទាំងឡាយមានចោរជាដើមហើយ  មានចិត្តភិត
ខ្លាចច្រើនពេកណាស់  ពុំបានឃើញនូវមហាចោរគឺមោហានោះ
ខាងក្នុងខ្លួនក៏ទេ  បុគ្គលពាលឃើញនូវរបស់មិនល្អដោយល្អ
នូវរបស់មិនទៀងដោយទៀង  ម្យ៉ាងវិញទៀតបុគ្គលពាលនោះ
មានកិរិយាឃើញខុសជាប្រក្រតី  អំពីសំណាក់នៃបុគ្គលដទៃ
ក្រៅអំពីខ្លួនឯង  បុគ្គលពាលតែងសេពគប់នូវបុគ្គលឯណាៗជា
មនុស្សលាមក  បុគ្គលជាគ្រហស្ថបើសេពគប់នូវមិត្រពាល-
ហើយ  គួរនាបីដូចជាផ្ទះទាំងឡាយដោយជុំវិញ  កាលបើផ្ទះ-
១ ភ្លើងឆេះហើយក៏នឹងឆេះដូចគ្នា  ហេតុដូច្នោះបុរសឯណាជា
អ្នកប្រាជ្ញ  បើប្រាថ្នានូវសេចក្ដីសុខដល់ខ្លួន  មិនគាប្បីសេពគប់
នូវបាបមិត្រឡើយ  បីដូចជាបុគ្គលពុំសេពនូវភោជនប្រកប
ដោយថ្នាំពិសពុល  ឯអវិជ្ជានេះតែងនាំមកនូវទុក្ខទាំងពួងក្នុង
កាលទាំងអស់យ៉ាងដូច្នេះ  បុគ្គលអ្នកមានប្រាថ្នានឹងបោលនូវ

អវិជ្ជានោះឡើងវាយ គាប្បីហួលជិតសេពគប់នូវអ្នកប្រាជ្ញចុះ អវិ-ជ្ជាវិគ្គជាគំរប់ ៩ ក្នុងពាលបិត្តប្បពោធនកថា ក៏មានដោយប្រការប៉ុណ្ណេះ ។

មិស្សកវិគ្គគំរប់ ១០ សេចក្ដីថា មនុស្សប្រែកបដោយមានះទាំងឡាយក្នុងសត្វលោកនេះ គុណរបស់មនុស្សទាំងឡាយនោះឥតអង្គីមានឡើយ គួរតាបីដូចជាធារទឹកភ្លៀងដែលធ្លាក់ចុះលើភ្នំហើយក៏ពុំដក់នៅបាន រីដើមឈើដែលខ្ពស់ជាងគេតែងកំរើកញាប់ញ័រដោយខ្យល់បក់មកអំពីទិសទាំងពួងមានឧ-បមាយ៉ាងណាមិញ សត្វលោកដែលមានមានះរឹងរូសក៏តែងដល់នូវសេចក្ដីវិនាសផ្សេង ៗ មានឧបម័យយ៉ាងនោះឯង ម្យ៉ាងវិញទៀតទេវទត្តថេរក្ដីបុគ្គលដ៏ទៃក្ដី ជាអ្នកច្រើនដោយមានះក្នុងលោកនេះ បុគ្គលទាំងឡាយអម្បាលនោះ តែងទៅកាន់នរកសោយទុក្ខវេទនា ដ៏បង្កើតជាពាក្យនិន្ទាសព្វកាល បុគ្គលប្រែកបដោយមិច្ឆាទិដ្ឋិហើយ រមែងពុំបាននូវរបស់មានខ្លឹមបន្តិចបន្តួចសោះ កាលបើមានទ្រព្យជាខ្លឹមហើយ តែងស្រ-

ឡាញ់រាប់អាននូវទ្រព្យនោះ បីដូចជាអារក្ខទឹករក្សានូវស្រះ បោក្ខរណី ពុំនោះសោតបើដូចជាបុគ្គលស្រេកទឹកហើយ ស្ទុះរត់ទៅជិតគិតផឹកនូវថ្លៃបណ្ដើរក្នុងស្មានថាជាទឹក ដល់នូវសេចក្ដីទុក្ខសោកដោយច្រើនក្រៃលែង មួយវិញទៀតបុគ្គលប្រកាន់នូវទិដ្ឋិអាក្រក់ ពុំបានស្ដាប់នូវព្រះធម៌ព្រះជិនស្រី ដែលអាចនាំមកនូវសុខក្នុងសួគ៌នឹងព្រះនិព្វាន តែងទៅកាន់អបាយទាំង ៤ សោយសោកដោយច្រើនក្នុងកាលទាំងពួង បើទុកជាមាសក្ដី សត្វលោកទាំងអស់ក្ដី ដែលជរាញាំញីនោះ វានឹងបានញាំញីដូចជាមាសឬផ្កាឈូក ដែលបុគ្គលញាំញីប្របាច់ដោយដៃដូច្នោះក៏ទេ ឯជរាដែលញាំញីប្របាច់សត្វលោកនេះ គឺវាធ្វើភ្នែកឲ្យងងឹតត្រចៀកឲ្យស្ដាប់សំឡេងពុំសូវច្បាស់ សំ-ឡេងដែលនិយាយទៅបីដូចជាសំឡេងមនុស្សគ ពុំឲ្យភ្ញាក់រលឹកនូវបញ្ញារបស់ខ្លួន ស្បែកសសៃជ្រីវជ្រួញយុរយា ទាំងសក់ក៏ស្កូវមានពណ៌សបីដូចសំឡីឬក ទាំងរាងកាយក៏ចិមចិយកំឡាំងតោងកាន់ឈើច្រត់ទើបដើរបាន ទុក្ខដែលកើត

ច្រើនរាប់មិនបានទាំងអស់មិនមកអំពីទីឯណាឡើយ គឺមកតែអំពីជរានេះឯង ពណ៌សម្បុរកំឡាំងអាយុ ដែលអាស្រ័យនូវរាងកាយតែងថយចុះទៅយ៉ាងនេះ លោភនឹងទោសទាំងឡាយរឹងរិតតែចំរើនច្រើនឡើង ហេតុអ្វីបានជាអ្នកទាំងឡាយមិនភ្ញាក់រលឹកសោះ បេះតែប្រហែសធ្វេសភ្លេចស្មារតីយ៉ាងនេះ ពុំខំធ្វើបុណ្យឲ្យទានរក្សាសីលចំរើនភាវនា មិស្សកវគ្គក្នុងពាលបិត្តប្បពោធនកថា ជាគំរប់ ១០ ក៏ចប់តែប៉ុណ្ណេះ ។

សីលវគ្គគំរប់ ១១ សេចក្ដីថាពិតណាស់ បុគ្គលដឹងច្បាស់នូវរាងកាយ ថាមានពៀរធំប្រកបដោយលោភទោសដូច្នេះហើយមានប្រាថ្នាដើម្បីលះបង់បោលចេញ គាប្បីធ្វើកុសលឲ្យច្រើនទើបលះបង់បាន ធម៌ទាំងឡាយនេះ គឺ ទាន, សីល, ហិរិ, ឱតប្ប, ម្យ៉ាងទៀតគឺករុណានឹងមេត្តា ជាធម៌សំរាប់កាត់បង់នូវបាបធម៌មានលោភជាដើម បុគ្គលធ្វើនូវកម្ម មានការធ្វើស្រែជាដើម ផលដែលកើតអំពីកម្មនោះក៏ជាផលឧត្ដមប្រសើរក្នុងលោក មានពូជទាំងឡាយតែងប្រាថ្នានូវផលនោះព្រោះតែ

ខ្លាប ១ លោភ ១ ទ្រព្យ ១ ផលដែលកើតអំពីកម្មនោះគឺសត្រូវ មានចោរជាដើមតែងប្រាថ្នាហើយ ផលបុណ្យមានទានជាដើម គឺយើងពោលមកហើយ បុគ្គលទាំងឡាយជាមនុស្សខ្លៅល្ងង់ ត្រូវតែប្រាថ្នានូវផលនោះអស់កាលទាំងពួង ទានឯណាសូម្បី មានប្រមាណតិច បុគ្គលធ្វើដោយចិត្តជ្រះថ្លាហើយទាននោះ មានផលច្រើន បីដូចជាពូជគ្រាប់ជ្រៃធំ ឯកុសលបុណ្យតែង ឲ្យនូវសម្បត្តិច្រើន ក្នុងស្ថានមនុស្សលោកនឹងទេវលោកទាំងឡាយ ជនទាំងឡាយច្រើនតែប្រាថ្នាធ្វើនូវទានក្នុងកាលទាំងពួង ឯទានមានផលគឺបុគ្គលឃើញហើយក្នុងកាលមុន ជនទាំងឡាយអ្នកប្រាថ្នានូវសុខអំពីទាននោះ ត្រូវតែឲ្យនូវទានជាប្រក្រតី បុគ្គលឯណាឲ្យនូវទានដែលគួរគាប្បី អ្នកប្រាជ្ញទាំងឡាយមានព្រះពុទ្ធជាដើម តែងពោលសរសើរនូវបុគ្គលនោះឯង បាបធម៌ទាំងឡាយទាំងពួង គឺរាគ, ទោស, មាន, តែងញ៉ាំងសត្វទាំងឡាយឲ្យដល់នូវទុក្ខ សត្វទាំងឡាយបរិសុទ្ធិ ដោយសីល ពុំបានបរិសុទ្ធិដោយទឹកក៏ទេ បុគ្គលពាលទាំង

ឡាយដែលប្រកាន់ខ្លួនថាជាអ្នកប្រាជ្ញ យើញនូវមន្ទិលសៅហ្មង នោះៗ ខាងក្រៅហើយ ពោលនូវពាក្យថាអញនឹងលាងនូវមន្ទិល តែខាងក្នុងក៏នូវតែមិនបរិសុទ្ធ បុគ្គលពាលទាំងឡាយមានមន្ទិលគឺកិលេសមានរាគជាដើមខាងក្នុងហើយ តែងទៅកាន់ទុគ្គតិក្នុងកាលទាំងពួង អ្នកប្រាជ្ញទាំងឡាយតែងលះបង់នូវមន្ទិលនោះចេញដោយសីល ហើយបានដល់នូវព្រះនិព្វានជាទីរំលត់បង់នូវទុក្ខទាំងពួង ។

សីលវគ្គជាគំរប់ ១១ ក្នុងពាលចិត្តប្បពោធនកថាក៏មានដោយប្រការដូច្នេះឯង ។

ហិរិឱត្តប្បវគ្គគំរប់១២សេចក្តីថា ហិរិ សេចក្តីអៀនខ្មាសអំពីការបាប ឱត្តប្ប សេចក្តីតក់ស្លុតក្តៅក្រហាយអំពីការបាបធម៌ទាំងពីរនេះជាគ្រឿងប្រព្រឹត្តល្អប្រពៃក្នុងលោក បើបុគ្គលឯណាលះបង់បោលនូវហិរិនឹងឱត្តប្បនោះហើយ បុគ្គលនោះប្រាថ្នាដើម្បីពោលនូវពាក្យឯណា ៗ ក៏ពោលនូវពាក្យនោះ ៗ ទៅប្រាថ្នាដើម្បីធ្វើនូវអំពើឯណាក៏ធ្វើនូវអំពើនោះ ៗ ទៅ បុគ្គល

ពាលទាំងឡាយ ជាបុគ្គលមិនគោរពគ្នានឹងគ្នា ធ្វើនូវអំពើផ្សេងៗមានលួចជាដើម ធ្វើនូវមេថុនធម្មដោយមាតាឬបងប្អូនស្រី បើដូចជាសត្វឆ្កែទាំងឡាយ បុគ្គលពាលទាំងឡាយ លុះធ្វើនូវអំពើបាបមានប្រមាណច្រើនហើយក៏រមែងទៅទុគ្គតិ សោយទុក្ខនូវក្នុងទុគ្គតិនោះនឹងសោយសោកដោយក្រៃលែងក្នុងកាលទាំងពួង ហេតុដូច្នោះបុគ្គលជាអ្នកប្រាជ្ញខ្លាចនូវបាបរឿយៗផងប្រកបដោយសេចក្ដីគោរពគ្នានឹងគ្នាផង តែងធ្វើនូវធម៌ទាំងពីរគឺហិរិនឹងឱត្តប្បឲ្យមាំមួននៅក្នុងលោកនេះ ជនអាក្រក់ទាំងឡាយលុះនៅអំណាចបចិត្ត ប្រទុស្តក្នុងមាតានឹងបិតាទាំងឡាយតែងសេពគប់នូវអំពើអាក្រក់មានសំឡាប់សត្វជាដើម មានប្រការផ្សេងៗក្នុងកាលទាំងពួង បុគ្គលពាលទាំងឡាយបើឃើញនូវមនុស្សចាស់ក្ដីមនុស្សក្រខ្សត់ក្ដី គឺសេចក្ដីទុក្ខមានស្រេកឃ្លានជាដើមបៀតបៀនហើយ ក៏ដើរទៅជិតមនុស្សទាំងឡាយនោះហើយ វាយក៏មានសំឡាប់ក៏មាន បុគ្គលពាលតែងធ្វើនូវកម្មដទៃប្រាកដដោយកម្មនោះហើយសប្បាយរីករាយដោយ

ចិត្តក្លៀវក្លា រមែងសោយសោកក្នុងលោកនេះផង រមែងសោយសោកក្នុងអបាយទាំងឡាយក្នុងកាលជាខាងក្រោយផង ហេតុដូច្នោះលោកជាអ្នកប្រាជ្ញ មានប្រក្រតីស្វែងរកនូវប្រយោជន៍គឺបរមត្ថធម៌ មានចិត្តប្រកបដោយសេចក្ដីករុណា តែងពោលនូវពាក្យជាទីសំឡាញ់គ្នានឹងគ្នាក្នុងលោកនេះ លោកអ្នកប្រាជ្ញទាំងឡាយទាំងពួង លោកញុំាងសេចក្ដីករុណាឲ្យកើតឡើងក្នុងសត្វទាំងឡាយ បីដូចជាក្នុងកូនរបស់លោកទាំងឡាយ លុះធ្វើនូវទានទាំងពួងទាំងឡាយហើយ តែងត្រេកអររីករាយដោយច្រើនក្រៃលែងក្នុងកាលទាំងពួង ហិរោត្តប្បវគ្គគិរ ប់ ១២ ក្នុងពាលចិត្តប្បពោធនកថា ក៏មានដោយប្រការតែប៉ុណ្ណោះឯង ។

សច្ចាទិវគ្គគិរប់ ១៣ សេចក្ដីថា ប្រជុំពីរនៃធម៌ គឺ-មេត្រី១ សច្ច១ ព្រះដ៏មានព្រះភាគសម្ដែងថា នឹងរកទ្រព្យអ្វីឲ្យស្មើដោយទ្រព្យគឺធម៌ទាំងពីរនោះគ្មានឡើយ ទ្រព្យគឺមាសប្រាក់ជាទីនាំមកនូវទុក្ខទាំងពួងក្នុងលោកអស់កាលទាំងពួង សេចក្ដីពិត បុគ្គលឯណារាប់អានមាសនឹងប្រាក់នោះហើយ

មិនមានសេចក្ដីគោរពកោតក្រែងគ្នានឹងគ្នា ហើយធ្វើនូវជំលោះប្រកែកវាយបងហើយ បុគ្គលនោះដល់នូវសេចក្ដីទុក្ខក្នុងកាលទាំងពួង បុគ្គលជេរវាយគ្នានឹងគ្នាហើយ តែងសោយនូវទុក្ខធ្ងន់ដោយប្រការច្រើន មានបំណាង៤ប្រការជាដើម ហេតុនោះបុគ្គលជាអ្នកប្រាជ្ញក្នុងលោកពុំស្រឡាញ់រាប់អាននូវទ្រព្យនោះឡើយ លោករាប់អានស្រឡាញ់នូវមេត្រីនិងសច្ច តែងរួបបាកទុក្ខទាំងពួង បុគ្គលអ្នកប្រកបដោយសទ្ធានឹងសមាធិមានចិត្តប្រកបដោយកំឡាំងព្យាយាម សេពគប់នូវបុណ្យឯណាហើយ តែងបាននូវផលនៃបុណ្យនោះធាប់ អ្នកប្រាជ្ញលុះដល់នូវផលនោះហើយ ជាអគ្គបុគ្គលទៀងប្រាកដបាកសេចក្ដីស្លាប់ បីដូចជាព្រះចន្ទមានវង់ពេញក្នុងអាកាស ប្រាកដក្នុងទិសទាំងឡាយ លោកអ្នកប្រាជ្ញជ្រាបនូវផលនៃសទ្ធានឹងសមាធិទាំងឡាយដូច្នេះហើយ លោកពុំបានប្រមាទឡើយ តែងចូលទៅជិតសេពនូវប្រជុំពីរគឺសទ្ធានឹងសមាធិនោះរឿយ ៗ ពុំដែលដាច់ កម្មដែលដិតល់នៅក្នុងរាងកាយ ទោះកម្មល្អក្ដីមិន

ល្អក្តី គឺខ្ញុំជាអ្នកស្វែងរកនូវប្រយោជន៍ គឺសេចក្តីរំងាប់នឹងទុក្ខ ជាប្រក្រតី។ពាលហើយ ពាក្យប្រកបអ្នកដ៏ប្រសើរដូច្នេះ សព្វា-ទិវគ្គជាគំរប់ ១៣ ក្នុងពាលចិត្តប្បពោធនកថា ក៏មានដោយ-ប្រការប៉ុណ្ណោះឯង ។

ពាលចិត្តប្បពោធនសូត្រ ជាទីញុំាងចិត្តនៃសប្បុរស ទាំងអស់ឲ្យជ្រះថ្លា ដ៏ប្រដាប់បំពោះដោយរយនៃគាថាជាទីសំ-រេចដោយពាក្យដូច្នេះថា គឺភិក្ខុឈ្មោះសុមេធបណ្ឌិត ជ្រើស រើសយកអំពីគម្ពីរដែលគាប់ចិត្ត ក៏ចប់សព្វគ្រប់ដោយន័យគឺ យើងពោលមកហើយដោយប្រការដូច្នេះហោង ។៚

# ពហទូលិវ្រិត

## បុណ្យបូជាទេវតារក្សាភ្លៀង

ស្រង់ចេញពីសៀវភៅ អ័ល្បុន របស់លោករពិន្ទ្រនាថ តាគោរ
ក្រម្ការជុំ-មៅ ប្រែពីភាសាបារាំងសែសមកជាភាសាខ្មែរ

ពហទូលិវ្រិត   បុណ្យបូជាទេវតារក្សាភ្លៀង
បុណ្យបូជានេះ គេធ្វើជារបៀបល្ខោនរាំ ដូចខាងក្រោមនេះ

### ឈុតទី ១

បុណ្យនេះចាប់ធ្វើនៅខែសុយេត៍; ស្ទឹងទាំងឡាយមានទឹកពេញប្រៀប ស្រីក្មេងជម្ទង់ម្នាក់នឹងស្រីដែលមានប្ដីម្នាក់ទទួមុខ មានស្រីៗដើរតាម ៤-៥ នាក់ ដើរឆ្ពោះទៅកាន់ស្ទឹង ស្រីៗទាំងនេះកណ្ដៀតក្អមហើយដើរតាមបង្វាក់ក្បាច់ស្រែកច្រៀងជាដូច្នេះ.

ម្នាលស្ទឹងទាំងឡាយ ម្នាលស្ទឹងទាំងឡាយ
អ្នកប្រទះនរណានៅក្នុងទីនេះ
គឺនាងទេព្យកញ្ញាមេភ្លៀង

ដែលកំចាត់បង់នូវទុក្ខភ័យ

ម្នាលស្ទឹងទាំងឡាយ ម្នាលស្ទឹងទាំងឡាយ

អ្នកប្រទះនរណានៅក្នុងទីនេះ

គឺនាងទេព្វកញ្ញាមេឃ្លៀង

ដែលនាំនូវសេចក្ដីសុខ

មកឲ្យដល់ត្រកូលទាំងបីរួមគ្នា (១)

រួចពីនេះក៏ពួកត្រី ៗ ទាំងនេះយកផ្កាបាចបូជាស្ទឹងម្នាក់ម្ដង ៗ ហើយម្នាក់ស្រែកច្រៀងឡើងថា៖

ម្នាលស្ទឹង, អ្នកទៅកាន់ទីឋានណា, ម្នាលស្ទឹង

ចូរអ្នកឲ្យដំណឹងខ្ញុំ អំពីអាពុកខ្ញុំ

ចូរអ្នកឲ្យដំណឹងខ្ញុំ អំពីបងខ្ញុំ

ទើបនាងស្រីដែលមានប្ដីស្រែកច្រៀងទៀតថា៖

ម្នាលស្ទឹង, អ្នកទៅកាន់ឋានណា, ម្នាលស្ទឹង

ចូរអ្នកឲ្យដំណឹងខ្ញុំ អំពីអាពុកក្មេកខ្ញុំ

---

(១) គឺត្រកូលអាពុក, ត្រកូលម្ដាយ, និងត្រកូលប្ដី,

បូរអ្នកឡុងដំណាំង អំពីស្វាមីខ្ញុំ

រូបទាំងអស់គ្នា ក៏តាំងបាចសាចផ្កាទៅជុំវិញគ្រប់ទិស ហើយច្រៀងៈ

ម្នាលទឹកស្ទឹង

ម្នាលទឹកផ្លៀង.

បូរឡុងដំណាំងយើង

អំពីអាពុកយើងនឹងបងរបស់យើង

ក្នុងវេលានោះស្រី ៗ ទាំងនោះ ធ្វើហាក់ដូចជាបានឮសួរ សន្ធឹកសត្វត្រចៀកកាំជាច្រើនហើរពីលើក្បាល ហើយធ្វើហាក់ ជាបានឮសំឡេងក្អែកបួលលើដើមពកុល(១)ដែលមានផ្កាសះហើយ ក្រអូប ហើយធ្វើឱ្យឃើញជាមេឃកាន់តែភ្លឺស្រឡះបន្តិច ៗ ឡើង ទើបស្រីម្នាក់តាំងៈច្រៀងឡើងថាៈ

អ្នកឯងមកពីរកស៊ីឬអ្វី ម្នាលក្អែក ម្នាលត្រចៀកកាំ?

អាពុកខ្ញុំ នឹងបងខ្ញុំ ព្រមទាំងទំនិញ.

(១) គឺដើមផ្កុល.

បានបេញទៅទីឆ្ងាយ ម្នាលត្រចៀកកាំ ម្នាលក្អែក

ប្រហែលជាអ្នកទាំងឡាយបានប្រទះ-សំពៅរបស់

គាត់មិនខាន?

ក្នុងវេលានោះមានផាពន្លឺថ្ងៃ បាំងចុះទៅលើកោះខ្សាច់តូប ១ ដែលលេចឡើងលើទឹក ដូចជាឆ្ងាយដែលឆ្លុះពន្លឺ ហើយ ទើបនាងស្រីច្រៀងឡើងថាៈ

ម្នាលកោះខ្សាច់ អ្នកចូរស្ដាប់ខ្ញុំ

អ្នកចូរងាកមើលជុំវិញខ្លួនអ្នក.

បើអ្នកឃើញអាពុកខ្ញុំនឹងបង ៗ ខ្ញុំ.

ចូរអ្នកញញឹមរកគាំងខ្លួនខ្ញុំផង.

រួចពីនេះឃើញមានទូកតូប ១ ឥតបង្កួតអណ្ដែតសាត់តាម ខ្សែទឹកស្ទឹងហូរចុះមក ទើបនាងស្រីស្រែកច្រៀងឡើងថាៈ

ម្នាលទូក, ម្នាលទូក, ឯងនៅជិតសមុទ្រ

ឯងចាំអាពុកអញបានឬទេ

ឯងចាំបង ៗ អញបានឬទេ

ត្រង់នេះយើងដល់មក ត្រង់កណ្ដាលពិធីបុណ្យហើយ ហើយតាំងផ្ដើមឈុត ១ តទៅទៀត ។

## ឈុតទី ២

យប់ងងិត,ភាពភ្ញូមិហាក់មានភ្នំជុំវិញ ហើយមានព្រៃស្បាត សុទ្ធតែបន្លា មានឮរលកសមុទ្រនឹងសម្រែកសត្វសាហាវ ។

នាងស្រី ភិតភ័យតក់ស្លុត, តាំងបែបត់អង្វរថា:

ឱខ្លាដែលនៅក្នុងព្រៃ

ឱក្របីដែលនៅក្នុងព្រៃ

ប្ដូរអ្នកកុំប្រទះនឹងអាពុកនឹងបង ៗ ខ្ញុំ

ប្ដូរអ្នកភ្លេចនូវបាបកម្មដែលគាត់បានធ្វើ

ហើយស្រី ៗ ទាំងអស់គ្នាឃុំហើយច្រៀងព្រមគ្នាថា:

ឱស្រុកឆ្ងាយឯណា

ដែលអាពុកខ្ញុំនឹងបង ៗ ខ្ញុំបានទៅ

ឱស្រុកឆ្ងាយឯណា

ដែលអាពុកក្មេកនឹងប្ដីខ្ញុំបានទៅ

ក្នុងវេលានោះ នាងទេព្ធធិតារក្សាព្រៃឆ្លើយបញ្ជាក់មកថាៈ

គាត់បានបេញទៅតាមផ្លូវនេះ

គាត់ត្រឡប់មកវិញតាមផ្លូវនុ៎ះ

ពេលនោះព្រះអាទិត្យរះឡើងហើយស្រី ៗ ប្ដូជាផ្កាហើយច្រៀងៈ

ម្ចាលភ្នំពណ៌មាស នៅជិតទីវៃ្ងរះ

អ្នកជាទេព្ធធិតាដែលមានឫក្សល្អ ខ្ញុំសូមគោរពអ្នក

ប្ដូរអ្នកធ្វើដើម្បីឲ្យអាពុកយើងនឹងបង ៗ យើង

ត្រឡប់វិលមកផ្ទះវិញជាយ៉ាងឆាប់

ហើយបែមកឯទេព្ធធិតារក្សាព្រៃវិញ ពោលថាៈ

យើងខ្ញុំសូមបួងសួងឲ្យលោកបានបល្ល័ង្កមាស

នាងទេព្ធធិតាមេផ្លៀងបេញមកពាក់ម្កុដពីរជាន់; ឈរលើ ទឹកសមុទ្រជើង ១ ជាន់លើថ្ងៃ ជើង ១ ជាន់លើយប់. ជើងទី ៣ ជាន់លើរជ្ជូវភ្លៀង ហើយជើង ១ ទៀតជាន់លើរជ្ជូវលំហើយ.

ទើបសមុទ្រស្រែកច្រៀងថាៈ

ខ្យល់ជំនោរពីសមុទ្រទាំង ៧

ធ្វើរលករបស់អញខ្យេគគ្រាំគគ្រេង
ទេវធិតារក្សាព្រៃឆ្លើយឡើង.
សមុទ្រ, ម្នាលសមុទ្រ ខ្ញុំគំនាប់អ្នក
នាងស្រីនិយាយទៅនឹងសមុទ្រថាៈ
ចូរអ្នកស្ងប់ទៅ!
ទើបស្រី ៗ ទាំងអស់គ្នាច្រៀងព្រម ៗ ឡើងថាៈ
អាពុកខ្ញុំនឹងបង ៗ ខ្ញុំបានបេញទៅកាន់ទីឆ្ងាយ
ប្ដីរបស់ខ្ញុំក៏បានទៅជាមួយផងដែរ
ក្នុងវេលានោះមានសំឡេង ១ បេញពីមេឃមកថាៈ
អ្នកទាំងនោះនឹងវិលមកទាំងអស់គ្នា ក្នុងថ្ងៃនេះ
អ្នកទាំងនោះនឹងវិលមកទាំងអស់គ្នា ក្នុងថ្ងៃនេះ

ហើយទាំងអស់គ្នាក៏តាំងលុតជង្គង់ប្រណម្យបំពោះមុខទេវធិតាមេឆ្លៀងដែលជាអ្នកទំនុកបំរុងការពារអ្នកដំណើរ, ទេវធិតានេះជើងម្ខាងជាន់សំពៅ ១ ជើងម្ខាងជាន់សំពៅ ១ ហើយមានក្លោះមាសពីរបើកបាំងពីលើ ។

# ឈុតទី ៣

ក្នុងភូមិ ១- រដូវជិតដាច់ខែសិបតម - រដូវវស្សាតាំងផ្ដើមឡើងហើយ ៗ តែពាំងនៅក្រោយផ្ទះក៏មានទឹកពេញព្រៀប, ឃើញមានរស្មីព្រះអាទិត្យបាំងផ្លុះលើទឹក, មានបក្សីពីរទំលើដើមត្នោត ២ ដើមហើយច្រៀងៈ

នាងស្រីតូច, ម្ចាលនាងស្រីតូច,
ប្ដូរនាងក្រោកឡើង
ដោយគុណបុណ្យ នាងទេវធិតាពហុទូលិ
ទើបសំពៅទាំងប្រាំពិល

បានចូលមកបតនៅកំពង់ក្នុងថ្ងៃនេះ

ក្នុងវេលានោះឃើញទ្វារ ១ បើកឡើង ហើយឃើញស្រីៗ នឹងនាងដែលមានប្ដី ចេញមកកាន់ជើងពាន ១ ម្នាក់ៗក្ដល់គ្រឿងបូជា ហើយក៏ដើរចេញពីផ្ទះទៅ; ទើបមានយាយចាស់ម្នាក់នៅផ្ទះជិតខាងស្រែកច្រៀងឡើងថាៈ

នែនាងស្រីៗ នែនាងស្រីតូចៗ

ការប្រព្រឹត្ត ទៅនៃមនុស្សយើងយូរអង្វែងណាស់
ភ្នែកពីរសំឡឹងឆ្ពោះដើមត្នោត..........
ឥរណាធ្ងីត្រែ
នៅទីមាត់ស្ទឹង?

ពួកស្រី ៗ ឆ្លើយតបវិញថាៈ

គឺជាអាពុកនឹងបងប្អូនយើង
គឺជាពួកអ្នកស្រុករបស់យើង

ឯត្រែបេះតែឮសំឡេងខ្ទរមកពីឆ្ងាយ មានសត្វ ១ ហ្វូង ហើរខាងលើអាកាស, ហើយពួកស្រី ៗ ទាំងនោះស្រែកថាៈ

ឱបក្សីតូច ឱបក្សីតូច
ចូរឯងទៅជាមួយនឹងយើងឯមាត់កំពង់
ដើម្បីឡើងពរដល់សំពៅ
ចូរទៅជាមួយនឹងយើង, នៃបក្សីតូច ៗ

## ឈុតទី ៤ បប់បុណ្យ

ពេលព្រឹកនៅមាត់ទន្លេគង្គា ។ គេក្រឡេកឃើញក្អួង

សំពៅស ៗ ច្រើនពីចម្ងាយ, សំពៅនេះកាន់តែជិត ៗ មកត ៗ គ្នា ហើយចូលចតនៅកំពង់, អ្នកដំណើរដើរទៅមក ហើយឮសូរសំឡេងនិយាយអឺងអាប់លាយឡំគ្នា, ពួកអ្នកសំពៅលីទំនិញចុះពីសំពៅៈ

ពួកស្រី ៗ ច្រៀងៈ

យើងសូមបូជាម្សៅក្រស្នា
ដល់ក្តារទាំងប៉ុន្មានរបស់សំពៅ
អាពុកយើងត្រឡប់មកវិញហើយ
បង ៗ យើងត្រឡប់មកវិញហើយ
យើងសូមបូជានូវជាតិហិង្គុល(១)
ដល់ក្តារទាំងប៉ុន្មានរបស់សំពៅ
យើងបានឃើញមុខអាពុកយើងហើយ
យើងបានឃើញមុខបង ៗ យើងទៀតហើយ

---

(១) ជាតិហិង្គុលនេះ តាមធម្មតា គេបូជាតែទេវតាទេ ។

នាងស្រីតែងខ្លួនជាអ្នកមានប្ដី ក៏បាចផ្កាទៅក្នុងស្ទឹង ព្រម ទាំងជាងបេក ១ ជាងតូចផង ហើយស្រែកច្រៀងឡើងថា:

យើងថ្វាយឯងទៅទន្លេគង្គា
យើងទៅរៀបចំអិនអាហារ

ទើបពួកអ្នកដំណើរនឹងអ្នកសំពៅ តាំងច្រៀងឡើងថា:

លុះបានឆ្លងកាត់សមុទ្រផ្សេង ៗ ហើយ
យើងក៏ចូលមកដល់ស្រុកកំណើតវិញ
មានសំពៅ ១ បានជាប់នៅទីឡាប់ ១
យើងក៏បានបោះបង់ទៅ
យើងមកដល់ពីទីស្រុកឆ្ងាយ
ជាមួយនឹងសំពៅយើងឯទៀតទាំងប៉ុន្មាន

ពួកស្រី ៗ ច្រៀងឡើង:

យើងទាំងអស់គ្នានៅជាកណ្ដាលពួកព្រាហ្មណ៍
អស់ទាំងទេវតាបានឧបត្ថម្ភបង ៗ យើង
ដែលបានចេញទៅទីស្រុកឆ្ងាយ

ពួកព្រាហ្មណ៍មានគ្រឿងបូជានៅដៃ ដើរចូលជិតមក ហើយពោលថាៈ

យើងសូមនមស្សការ នាងទេព្វធិតាមេផ្លៀង
ដែលជាអ្នកឧបត្ថម្ភស្រុកទេស របស់អ្នកគោរពបូជា

បប់

# ពិធីទទួលលោកគូវែរណើរយេណេរាល់
## ( រីណេ - រ៉ាប៉ាំង )

ពិធីទទួលលោកគូវែរណើរយេណេរាល់ ពោលចំពោះក្នុងព្រះរាជបណ្ណាល័យ នៅថ្ងៃសុក្រ ១ រោជខែទុតិយាសាធ ឆ្នាំចធស័ក ព. ស. ២៤៧៧ ត្រូវនឹងថ្ងៃ ២៧ ខែស្វយេត ឆ្នាំ ១៩៣៤ មានការរៀបទទួលលោក គឺនៅតាមមាត់ទ្វារប្រដាប់ដោយទង់សម្រាប់ជាតិបារាំងសែស សម្រាប់ជាតិខ្មែរ នៅមន្ទីរពុទ្ធសាសនបណ្ឌិត្យ បានយកកិច្ចការដែលក្រុមជំនុំបានធ្វើរួចហើយនឹងកំពុងធ្វើ គឺសៀវភៅព្រះត្រៃបិដកដែលបោះពុម្ពរួចហើយ ៥ ក្បាល នឹងរឿងដែលតែងដែលចំឡងសព្វថ្ងៃ នឹងពុម្ពព្រាងដែលបោះព្រាងឲ្យក្រុមជំនុំពិនិត្យ នឹងគម្ពីរស្លឹករិតសៀវភៅព្រះត្រៃបិដកសៀម - ភូមា រៀបទុកជូនលោកទស្សនា-ការ ។ នៅបន្ទប់ធំខាងលិចបានរៀបគ្រែវែងនៅក្បែរខាងត្បូង នឹងខាងលិច សម្រាប់ឲ្យព្រះសង្ឃអង្គុយបំរើនជយន្តោជូនលោក បាននិមន្តព្រះសង្ឃទាំងគណៈមហានិកាយ ទាំងគណៈ

ធម្មយុត្តិចំនួន ៤០០រូប រៀបកៅអី៩នៅជើងអាសន៍ សម្រាប់លោកសង្ឃនាយកទាំងពីរគណៈ និងលោកអធិបតីធំ អធិបតីរងប្រែព្រះត្រៃបិដក និងគ្រូបង្រៀនសាលាបាឡីខ្លះទៀត បន្ទាប់តទៅលោករាជាគណៈនឹងឋានានុក្រម មានផ្លូវសម្រាប់យសរៀងខ្លួន លំដាប់តទៅលោកកូនសិស្សសាលាបាឡី-កូនសិស្សស្រុកលាវ-កូនសិស្សស្រុកក្រសាំងស៊ុន តអំពីនោះលោកដែលនិមន្តមកអំពីវត្តផ្សេង ៗ ក្នុងក្រុង ។

ក្បែរខាងជើងរៀបកៅអីព្រះរាជទ្រព្យនឹងកៅអីរបស់ព្រះរាជបណ្ណាល័យ រៀបទទួលលោកគូវែរណើរយេណេរាល់ នឹងព្រះរាជវង្សានុវង្ស ព្រមទាំងអ្នករាជការបារាំងខ្មែរផងទាំងពួង ។

នៅវេលារសៀលម៉ោង ៤ . លោកគូវែរណើរយេណេ-រាល់ អញ្ជើញដោយរថយន្តជាមួយនឹងលោកឡូរេស៊ីដង់សុបេរ៉ិយើរ (ស៊ិលវ៉ែស្ត្រ) ទៅកាន់ព្រះរាជបណ្ណាល័យ ខណៈទៅដល់ មានទាហានក្រុមរក្សាព្រះអង្គគំនាប់តាមទំនៀម លំ-ដាប់នោះសម្ដេចក្រុមព្រះវរចក្រវណឫទ្ធិ នឹកអ្នកស្រីការប៉ុវ៉ែឡែស



បន្ទប់ក្រុមជំនុំព្រះត្រៃបិដក នៅពុទ្ធសាសនបណ្ឌិត្យ ព្រះសិរីសម្មតិវង្ស ឯប អធិបតីក្រុមជំនុំ និងក្រុមជំនុំខ្លះ

ចុះទៅទទួលអញ្ជើញលោកឡើងកាន់សាលា មានអ្នករាជការធំតូចទៅជូនដំណើរលោកជាច្រើន ប៉ែកខាងអ្នករាជការបារាំងគឺលោកវិស្យូម អធិបតីក្រសួងរដ្ឋប្រសាសន៍បាយ, លោកទ្រុប ឡៀរេចទ័រដេប៉ុរ្ទ, លោកដឺសីគូរ រេសីដង់ត៍មែរ, លោកគោបេ សេហ្រេតាប៊ីណេ, លោកឡឺប្រេវ៉ូស្ត៍, លោកម៉ារទី, លោកឌិកុឡាយ, លោកកូឡូណែលស៊ុរ, លោកល្បឺតឺណង់គេតង់, លោកឡាំបែរ, លោកហ្វារូ ដេលេគេ, លោកបាប់ទិស្ត កុងត្រុ-លើរ និងពួករេស៊ីដង់តរូមខែត្រទៀតជាច្រើនអ្នក ។

បំណែកឯអ្នករាជការខ្មែរ គឺសម្តេចក្រុមព្រះវរចក្រីណាឫទ្ធិ, សម្តេចចៅហ្វាវាំង ។ ក្រុមហ្លួងស៊ីសុវត្ថិសុភាណុវង្សទីបក្រី ។ លោកអ្នកឧកញ្ញាអគ្គមហាសេនា ។ ក្រុមយុទ្ធវិសុទ្ធិខត្តិយវង្សទីក្រឡាហោម ។ លោកអ្នកឧកញ្ញាៈយោមរាជ ។ ព្រះអង្គម្ចាស់អធិបតីក្រុមព្រះរាជយុត្តក ។ ល ។ និងអ្នករាជការឯទៀតជាច្រើន ។

វេលាលោកគូវែរណើរយេណេរាល់ អញ្ជើញចូលទៅក្នុង

សាលាហើយ បានអញ្ជើញចូលទៅមើលមន្ទីរពុទ្ធសាសនបណ្ឌិត្យជាដំបូង ដែលពួកក្រុមជំនុំគ្រប់អង្គមានលោកគ្រូព្រះសិរីសម្មត្តិវង្ស ឯម ជាអធិបតីជួបជុំនៅទីនោះ ។ លោកគូវែរណើរយេណោវាល់ លោកពោលសរសើរដល់ការដែលក្រុមជំនុំបានធ្វើនូវវេលាដែលបានពិនិត្យឃើញកិច្ចការគ្រប់បំពួកជាច្រើនជាន់ច្រើនស្រទាប់សម្រាប់ឲ្យកើតជាសៀវភៅ ១ ក្បាល ៗ ដែលបោះពុម្ពឡើង ព្រមទាំងសរសើរដល់សតិបញ្ញានឹងសេចក្ដីវាងវៃក្នុងការរៀបចំរៀបនូវពាក្យបាឡី នឹងការប្រែមកជាភាសាខ្មែរជាភស្តុតាងនៃសេចក្ដីដែលពេញចិត្តដោយការគ្រប់បំពួកដែលលោកបានពិនិត្យឃើញ លោកគូវែរណើរយេណោវាល់បានធ្វើអំណោយប្រាក់ផ្ទាល់ខ្លួនលោកចំនួន ៥០៛ ដល់ការបោះពុម្ពព្រះត្រៃបិដក ស្រេចហើយទើបលោកឡឺគូវែរណើរយេណោវាល់ចេញអំពីនោះចូលទៅកាន់បន្ទប់ធំដែលរៀបចំបម្រុងទុកសម្រាប់ទទួល ។

អ្នកស្រីការបីខ្សែសក់ដំរាបបង្ហាញលោកគណៈសង្ឃថា

នេះជាពួកនេះ ៗ ហើយលោកក៏អង្គុយនៅកៅអី ខណៈនោះលោកព្រះវិសុទ្ធិវង្ស តាត ថ្លែងសេចក្តីជូនពរសព្ទសាធុការលោកគូវែរណើរយេណោវាល់ជាជំណាងព្រះសង្ឃទាំងអស់ថា៖

លោកគូវែរណើរយេណោវាល់

គណៈសង្ឃទាំងអស់ក្នុងកម្ពុជប្រទេស មានសេចក្តីសោមនស្សជាទីបំផុតដែលបានរៀបចំទទួលលោកជាអធិបតីជាកិត្តិយស នៃពុទ្ធសាសនបណ្ឌិត្យ សូមលោកទទួលនូវពរសព្ទសាធុការដែលពួកគណៈសង្ឃឧទ្ទិសជូនលោក និងជូនដល់លោកទាំងពួងដែលអញ្ជើញមកជាមួយ ។

យើងទាំងអស់គ្នាបានដឹងជាប្រាកដថា ដែលលោកបានអញ្ជើញមកក្នុងប្រទេសឥណ្ឌូចិនជាដំបូងបំផុត នោះគឺលោកបានអញ្ជើញមកធ្វើរាជការក្នុងស្រុកកម្ពុជាជាមុន; ឃើញថាស្រុកយើងនេះមិនមែនជាដីដែលលោកមិនដែលស្គាល់ ហើយបំណែកអ្នកស្រុកទៀតក៏មិនមែនជាជាតិដែលលោកមិនធ្លាប់ឃើញ ។ យើងបានដឹងទៀតអំពីគំនិតយោបល់ដែលលោក

ធ្វើការ ព្រោះលោកពោលបំពោះពីខ្លួនលោកដោយវាចាថាដូច្នេះ "ត្រូវធ្វើ,ត្រូវធ្វើឲ្យបានផល,ត្រូវធ្វើឲ្យសម្រេចប្រយោជន៍, ត្រូវសម្រួលឲ្យបានល្អឡើងដល់ផ្លូវដែលជាវិញ្ញាណនឹងជារូបកាយរបស់ជាតិតូចទាបដែលទុកចិត្តលើយើង ដោយធ្វើអំពើយ៉ាងមធ្យ័តមួនមាំហើយយ៉ាងជិតដល់" យើងទាំងអស់គ្នាជឿជាក់ក្នុងចិត្តថានឹងបានទទួលនូវសេចក្ដីឧបត្ថម្ភដ៏មានប្រយោជន៍អំពីសំណាក់លោកជាអធិបតីយើងក្នុងការដែលពុទ្ធសាសនបណ្ឌិត្យធ្វើ ដើម្បីជួយលើកដំឡើងសតិបញ្ញារបស់ជាតិ ហើយការដែលធ្វើនេះ អ្នកខេមរជាតិទាំងមូលក្នុងក្រុងកម្ពុជា នឹងអ្នកខេមរជាតិក្នុងទិសនិរតីស្រុកកូសាំងស៊ីនបេះតែពេញចិត្តឡើងៗរាល់ៗថ្ងៃ ។

ចប់ហើយលោកគូវែរណើរយេណេរាល់ក្រោកឈរឡើងមានប្រសាសន៍ថាដូច្នេះ "ខ្ញុំមានសេចក្ដីសោមនស្សណាស់ដែលបានឃើញព្រះពុទ្ធសាសនាតាំងជារុងរឿងដ៏រាប ក្នុងស្រុកខ្មែរនឹងដែលបានឃើញពុទ្ធសាសនបណ្ឌិត្យនឹងព្រះរាជបណ្ណា-



លោកគូវែរណើរយេណេរ៉ាល់ រ៉ឺណេរ៉ូបាំង

ទស្សនាការរថយន្តដឹកសៀវភៅពុទ្ធសាសនបណ្ឌិត្យមួយអន្លើដោយមន្ត្រីបារាំង - ខ្មែរ ក្នុងទីស្នួលព្រះរាជបណ្ណាល័យ

ល័យបានធ្វើការជាប្រយោជន៍យ៉ាងធំដល់ព្រះនគរ ។ ក្នុងវេលាដែលខ្ញុំបានមកកាន់មន្ទីរនេះម្ដងកាលគ្រាមុន ខ្ញុំមិននឹកស្មានថាមន្ទីរនេះអាចនឹងធ្វើការបានយ៉ាងប្រសើរជាទីត្រូវចិត្តសាធារណៈជនទូទៅ ដូចដែលខ្ញុំបានឃើញច្បាស់នឹងភ្នែកដូច្នេះឡើយ ។ សេចក្ដីចំរើននេះបណ្ដាលមកពីព្រះសង្ឃគ្រប់អង្គខំព្យាយាមយកព្រះទ័យទុកដាក់ឥតធុញទ្រាន់, ខ្ញុំសូមអរគុណនឹងព្រះសង្ឃទាំងអស់នេះ" ។

ចប់ប្រសាសន៍នេះហើយ ព្រះសង្ឃគ្រប់អង្គតាំងសូត្រជយន្តោ, រួចពីនេះជាមុននឹងអញ្ជើញត្រឡប់ទៅវិញ លោកគូវ៉េណើរយេណេរាល់អញ្ជើញចុះទៅឯទីស្ទួនព្រះរាជបណ្ណាល័យ ដើម្បីទស្សនាការទូរបិយន្តដែលផ្ទុកសៀវភៅរបស់ពុទ្ធសាសនបណ្ឌិត្យ-ព្រះរាជបណ្ណាល័យ. នឹងសាលាបាឡីជាន់ខ្ពស់តាំយកទៅផ្សាយទូទៅក្នុងព្រះនគរ. លោកគូវ៉េរណើរយេណេរាល់ បានសរសើរអំពីបែបដែលរៀបចំធ្វើរបិយន្តនេះស្រេចហើយក៏អញ្ជើញត្រឡប់ទៅវិញ ។៚

# ឯកសហស្សរាត្រី

# ឬ

# មួយពាន់មួយយប់

## ក្រម្ការជុំ-ម៉ៅ ប្រែចេញពីភាសាបារាំងមកជាភាសាខ្មែរ

## (ត)

គ្រាដែលព្រះនាងចេញផុតទៅ ខ្ញុំក៏ស្ទុះក្រោកឡើងស្លៀកពាក់យ៉ាងប្រញាប់ ហើយចេញតាមទៅ ១ រំពេច ខ្ញុំបានលៃជំហានខ្ញុំឲ្យស្មើនឹងជំហានជើងព្រះនាង ដាក់ស្មើគ្នាលើកស្មើគ្នា ឥតធ្វើឲ្យដឹងខ្លួនឡើយ ។ លុះទៅដល់ទ្វារនិមួយ ៗ ទ្វារនោះរបើកឯង មិនបាច់បើកទេ ព្រោះព្រះនាងបានសូត្រមន្តអ្វីខ្សិប ៗ ទៅផុតទ្វារជាច្រើនសង្កាត់ បានដល់ទៅសួនច្បារទើបយាត្រាចូលក្នុងឧទ្យានទៅ ។ វេលានោះខ្ញុំឈប់បង្អង់នៅមាត់ទ្វារ ដើម្បីកុំឲ្យនាងឃើញផង ហើយដើម្បីឲ្យនាងដើរផុតទៅសិនផង ប៉ុន្តែភ្នែកខ្ញុំចេះតែរំពៃគយគន់តាមក្រោយទៅ ឃើញដើរចូលក្នុងព្រៃដែលមានផ្លូវកាត់ខ្វាតខ្វែង ហើយនៅបិញ្ជើមផ្លូវ

នោះ មានដាំដើមឈើធ្វើជារបងយ៉ាងក្រាស ។ ខ្ញុំបានស្ពាត់តាមផ្លូវផ្សេងពីខាងមុខ ហើយពួននៅក្នុងរបងឈើនោះ យូរបន្តិចលេចព្រះនាងបណ្តើរប្រុសម្នាក់មក ។

វេលានោះខ្ញុំបានផ្ទៀងត្រចៀកទាំង ២ ចាំស្តាប់សំដីនិយាយគ្នា ហើយខ្ញុំស្តាប់បានជាក់សំដីដែលព្រះនាងនិយាយនឹងប្រុសសាហាយជាដូច្នេះ "មិនគួរជាអ្នកមកប ន្ទាសខ្ញុំថាយឺតសោះ ព្រោះអ្នកដឹងជាប្រាកដអំពីការដែលតាំឲ្យទទើសទទែងមកមិនបាន បើសេចក្តីស្នេហាដោយស្មោះរបស់ខ្ញុំតាំងពីដើមមកដល់សព្វថ្ងៃនេះ នៅមិនទាន់ធួននឹងអ្នកទេ សូមឲ្យអ្នកប្រាប់មកចុះ ខ្ញុំនឹងធ្វើឲ្យឃើញប្រើនលើសដើមទៀត តើអ្នកមានប្រាថ្នាយ៉ាងណា, អ្នកដឹងហើយតើឫទ្ធានុភាពរបស់ខ្ញុំ ប្រសិនបើអ្នកឲ្យខ្ញុំធ្វើ ខ្ញុំនឹងធ្វើឲ្យទីក្រុងនឹងប្រាសាទល្អនេះ ទៅជាប្រាសាទបាក់បែកគ្រាំគ្រាហើយឲ្យមានសុទ្ធតែសត្វបបក, ទីទុយនឹងក្អែកនៅពាសពេញមុនអរុណរះឡើង. ខ្ញុំនឹងជញ្ជូនថ្មកំផែងបន្ទាយទាំងប៉ុន្មាននេះ ទៅចោលខាងនាយភ្នំកូកាស(១)

១ ភ្នំកូកាស់ជាភ្នំខ័នទ្វីបអឺរ៉ុបនឹងទ្វីបអាស៊ី

ឬបោលឲ្យផុតត្រៃដីដែលឥតមនុស្សនៅក៏បាន បើអ្នកចង់ដឹង ចូរប្រាប់តែ ១ មាត់មកចុះ ខ្ញុំជានានឹងធ្វើឲ្យប្រែប្រួលទៅបាន ឥឡូវនេះ" ។

និយាយផុតមាត់ ជើងដើរទៅដល់ផ្លូវបែក ១ ក្នុងទីនោះ ហើយងាករីលខ្លួនទៅតាមផ្លូវថ្មី ដើកាត់មុខខ្ញុំ, ខ្ញុំក៏ហូតដាវ ឡើងភ្លាម ។ ដោយអាប្រុសដើរខាងកន្លែងដែលខ្ញុំពួននៅ ខ្ញុំ បានលើកដាវឡើងកាប់សំដៅករវា ហើយដួលដេក ១ រំពេច ទើបខ្ញុំស្ទុះរត់ទៅភ្លាម ដើម្បីកុំឲ្យព្រះនាងស្គាល់បាន ឯខ្លួនព្រះ-នាងខ្ញុំអិនបានធ្វើបាបទេ ព្រោះជាប់ជាសាច់លោហិតរបស់ខ្ញុំ.

រីទំហឹងដាវដែលខ្ញុំប្រហារប្រុសសាហាយនោះ បណ្ដាល ឲ្យវាដល់នូវមរណ តែដោយអំណាចអានុភាពមន្តរបស់ព្រះ-នាង មនុស្សប្រុសក៏គង់ជីវិតនៅបាន ប៉ុន្តែគង់នៅតែជីវិត ប៉ុណ្ណោះ នឹងនិយាយស្ដីឬលើកដៃជើងមិនបាន ហៅថាជា មនុស្សមិនស្លាប់មិនរស់ ។ វេលាដែលខ្ញុំគេចរត់តាមក្នុងសួន ចូលទៅក្នុងដំណាក់នោះ ខ្ញុំឮព្រះនាងស្រែកយំប្លែងទុក្ខសព្វ

គ្រប់ ហើយខ្ញុំក៏គិតឃើញថា ដែលបានទុកជីវិតឲ្យព្រះនាង នោះជាការល្អប្រពៃណាស់ ។

លុះទៅដល់ក្នុងដំណាក់វិញ ខ្ញុំក៏ចូលដេកដូចដែល ដោយមានសេចក្ដីអំណរជាពន្លឹក ព្រោះបានធ្វើទណ្ឌកម្មដល់ អាក្សប៊ី សមតាមកិរិយាដែលវាបានធ្វើឲ្យខ្ញុំឈឺចិត្ត ហើយក៏ ដេកលក់ទៅ ។ លុះព្រឹកឡើង វេលាខ្ញុំក្រោកឃើញព្រះនាង ដេកនៅខាង ប៉ុន្តែមិនដឹងជាលក់ឬមិនលក់ ខ្ញុំក៏ប៉ុះបោកទី សេយ្យាសន៍ថ្មីៗមិនឲ្យព្រួស្វរ ហើយចូលទៅក្នុងបន្ទប់ស្រង់ ទៅ ស្លបហើយទើបខ្ញុំតែងខ្លួនចេញទៅជំរះការផែនដីតាម ធម្មតា ។ លុះត្រឡប់មកវិញបានឃើញព្រះនាងស្លៀកពាក់ខ្មៅ ប្រដាប់ជាមរណសញ្ញាទាំងអស់ ទំលាក់សក់ស្កូញស្កាញស្រ-កេកស្រកាក ដើរឆ្ពោះទៅខ្ញុំ ហើយនិយាយថា "ខ្ញុំម្ចាស់សូម ទោសព្រះបង, សូមកុំឲ្យទ្រង់យល់ទាស់អំពីសំលៀកបំពាក់ យ៉ាងដូច្នេះ, ព្រោះខ្ញុំម្ចាស់ទើបនឹងបានដំណឹង ៣ ជាអាក្រក់ មកដល់ក្នុងពេលជាមួយគ្នា ដំណឹងនោះនាំឲ្យខ្ញុំម្ចាស់មានទុក្ខ

ទោមនស្សជាយ៉ាងធ្ងន់ រកអ្វីមកប្រៀបមិនបាន" ខ្ញុំក៏សួរទៅវិញថា "ព្រះនាងមានទុក្ខដោយហេតុអ្វីខ្លះ ប្អូនប្រាប់បងឲ្យដឹងផង" ព្រះនាងឆ្លើយតបថា "ព្រះមាតាខ្ញុំម្ចាស់សោយព្រះទិវង្គត, ព្រះបិតាខ្ញុំម្ចាស់ទ្រង់ទិវង្គតកណ្ដាលចម្បាំង ហើយព្រះជេដ្ឋាខ្ញុំម្ចាស់ធ្លាក់ស្លាប់ក្នុងជ្រោះរអាងភ្នំ នេះហើយជាមេទុក្ខរបស់ខ្ញុំម្ចាស់ សូមទ្រង់ជ្រាប" ។

វេលានោះខ្ញុំគ្មានចង់អ្វីនឹងពាក្យដោះស្រាយដោយឧបាយមុសាវាទរបស់ព្រះនាងទេ ខ្ញុំគិតថាព្រះនាងច្បាស់ជាគ្មានសង្ស័យអ្វីលើរូបខ្ញុំ អំពីសំម្លាប់ប្រុសសាហាយនោះទេ ទើបខ្ញុំនិយាយទៅកាន់ព្រះនាងថា "ម្នាលប្អូនស្រី, ទុក្ខសង្រេងសង្រៃនេះបងមិនយល់ទាស់ទេ ចូរឲ្យនាងប្រាកដថាបងក៏ទទួលបំណែកទុក្ខនេះជាមួយនឹងនាងដែរ រីសេចក្ដីព្រាត់ប្រាសយ៉ាងនេះ គួរឲ្យមានទុក្ខណាស់ហើយ បើដូច្នេះចូរនាងកុំញញើត ក្នុងកិច្ចការអ្វីដែលនាងសព្វព្រះទ័យ"

សន្ធានាតែប៉ុណ្ណោះ. ព្រះនាងក៏យាងចូលទៅក្នុងបន្ទប់

អង្គុយទន្ទឹះឡើកខ្សួលតែឯងឯកា ហើយនៅស ព្រិងសព្រៃដ៏រាប ដល់ទៅ ១ ឆ្នាំគត់. ទើបមកសុំអនុញ្ញាតពីខ្ញុំ ដើម្បីសាងម៉ុង ១ ក្នុងកំផែងវាំង ជាខ្លួនព្រះនាងឯងនេះត្រូវការចូលទៅក្នុងទីនោះ រាល់វេលាដ៏រាប់លុះអស់ជីវិត ។ ខ្ញុំក៏បានអនុញ្ញាតឱ្យសាងតាម សេចក្ដីប្រាថ្នា ។ ព្រះនាងបាត់សាងម៉ុងនោះ បែបជាប្រាសាទ ១ ដ៏ស្កុកស្គម្ភ ប្រកបដោយកំពូលត្រដុងត្រដួបស្កិមស្ដែ ដែល មើលពីទីនេះទៅឃើញច្បាស់ រួបឱ្យឈ្មោះហៅថា "ប្រាសាទ ទឹកភ្នែក" ។

សាងស្រេចវេលាណា ព្រះនាងលបយកប្រុសសាហាយ ដែលត្រូវរបួស ទៅដាក់ដឹកលក់ក្នុងប្រាសាទនោះឯង ។ នាងបែ រក្សាឱ្យមានជីវិតគង់ដ៏រាបមក ដោយអំណាចមន្តនឹងបន្តក់ទឹក ថ្នាំឱ្យផឹករាល់ ៗ ថ្ងៃ ហើយទៅត្រាទ្រដោយដៃឯងសព្វទិនទេ ភាគរទៅ ។

វីមន្តនឹងទឹកថ្នាំនោះក៏មិនអាចនឹងញាំងអាប្រុសឱ្យជាបាន ហើយមិនត្រឹមតែដើរមិនរួច ថែមទាំងនិយាយមិនបានទៀត

តែសំគាល់បានជាមានជីវិត ដោយអាការប៉ប្រិចភ្នែកប៉ុណ្ណោះឯង ៗ ប៉ុន្តែបើទោះណាជាដូចម្តេចក្តី ព្រះនាងក៏នៅតែទៅថ្លែងទុក្ខបំពោះមុខអាប្រុសនោះ ១ ថ្ងៃ ២ ដងមិនដែលខាន ខ្ញុំដឹងទាំងអស់ តែខ្ញុំធ្វើពុតជាមិនបានដឹងវិញ ។

មានថ្ងៃ ១ ខ្ញុំចង់ឃើញឲ្យច្បាស់នឹងភ្នែកឯង ខ្ញុំក៏ដើរទៅកាន់ប្រាសាទទឹកភ្នែកនោះ ដើម្បីលបមើលតើព្រះនាងធ្វើអ្វីខ្លះទៅដល់ហើយខ្ញុំពួននៅទីស្ងាត់ ១ មិនឲ្យព្រះនាងឃើញខ្លួន វេលានោះខ្ញុំបានឮព្រះនាងនិយាយទៅនឹងសាហាយថា "ខ្ញុំមានទុក្ខធ្ងន់ណាស់ ដែលឃើញអ្នកនៅរងទុក្ខវេទនាដូច្នេះ, អ្នកមានសេចក្តីឈឺចាប់រងទុក្ខដូចម្តេច ខ្ញុំក៏ឈឺចាប់ដូច្នោះដែរ នែអ្នកប្រុសសំឡាញ់ ខ្ញុំនិយាយរកអ្នកប៉ោច ៗ រាល់ថ្ងៃអ្នកក៏មិនឆ្លើយតបមកខ្ញុំ ១ មាត់ តើអ្នកនៅស្ងៀមតមមាត់នឹងខ្ញុំដល់ណាទៅ សូមអ្នកនិយាយតែ ១ មាត់មករកខ្ញុំចុះ ឲ្យខ្ញុំបានធូទ្រូងបន្តិច ពេលដែលខ្ញុំបានស្ហែទុក្ខបន្តិចនោះ មានតែពេលដែលខ្ញុំបានមកនៅជិតអ្នក ក្រៅពីនេះខ្ញុំមានតែទុក្ខធ្ងន់រកអ្វីប្រៀបមិនបាន

ដោយអំណាចសេចក្ដីស្នេហាដ៏លើសលប់ ខ្ញុំមិនអាចឃ្លាតឆ្ងាយពីអ្នកបានឡើយ ប្រសិនបើអ្នកស្លាប់ ខ្ញុំក៏សុខចិត្តស្លាប់តាម សុំឲ្យយើងទៅកើតជួបគ្នាក្នុងជាតិឯមុខទៀត ។

លុះបានឮព្រះនាងពណ៌នាជាប់កំបុត ៗ ដោយអំណាចខ្សឹកខ្សួលនោះ ខ្ញុំទ្រាំអត់ធន់នៅស្ងៀមមិនបាន ទើបខ្ញុំបង្ហាញខ្លួនឲ្យឃើញដើរទៅជិតព្រះនាង ហើយពោលនូវពាក្យថា "នែព្រះនាង, សេចក្ដីយំសោករបស់ព្រះនាងក៏ធូនល្មមប៉ុណ្ណោះហើយ, ក្នុងពេលនេះត្រូវព្រះនាងបន្ទោបង់នូវសំណោក ដែលជាគ្រឿងអប្បយសចង្រៃដល់រូបយើងទាំង ២ នាក់បេញ ព្រោះធ្វើដូច្នេះ ឃើញថាព្រះនាងភ្លេចគិតសេចក្ដីគោរពដល់បងពន់ពេកណាស់." វេលានោះព្រះនាងឆ្លើយតបថា "បើទ្រង់នូវរាប់អានខ្ញុំម្ចាស់ ឬនូវអាណិតអាសូដល់ខ្ញុំម្ចាស់ជាសត្រី សូមទ្រង់មេត្តាកុំកំហែងខ្ញុំម្ចាស់ឡើយ សូមទ្រង់បណ្ដោយឲ្យខ្ញុំម្ចាស់កាន់យកនូវទុក្ខនេះតាមទំនើងចិត្តរបស់ខ្ញុំ ព្រោះពេលដែលកន្លងមកទាំងប៉ុន្មាន មិនទាន់បានរំលាយនូវទុក្ខរបស់ខ្ញុំម្ចាស់នូវឡើយ" ។

លុះឃើញថាពាក្យដែលខ្ញុំនិយាយគ្មានផលអ្វី នាំឲ្យព្រះនាងរេគិតទៅជាមានរឿងខឹងវិញ ខ្ញុំក៏លែងនិយាយតបទៅទៀត ហើយថយទៅដំណាក់វិញទៅ ។ ព្រះនាងក៏ចេះតែទៅឯម៉ុងនោះរាល់ថ្ងៃដ៏រ៉ាបដល់គ្រប់ ២ ឆ្នាំគត់ ហើយមិនលះបង់នូវទង្គិះខ្សឹកខ្សួលសង្រេងសង្រៃសោះ ។

គ្រាក្រោយមក ខ្ញុំបានទៅឯប្រាសាទទឹកភ្នែកម្តងទៀត ក្នុងពេលដែលព្រះនាងនៅខាងក្នុង, ខ្ញុំបានលាក់ខ្លួនមិនឲ្យឃើញ ហើយឮសូរសំឡេងព្រះនាងនិយាយទៅរកអាប្រុសថា "៣ ឆ្នាំហើយ អ្នកមិនដែលបេញវាចាមកកាន់ខ្ញុំ ១ មាត់សោះ អ្នកគ្មានត្រអាលមេត្រីតរតបមកខ្ញុំវិញសោះ តើអ្នកលែងស្រឡាញ់ខ្ញុំ, អ្នកស្អប់ខ្ពើមខ្ញុំហើយឬ’ ឱម៉ុងអើយឯងគិតផ្តាច់នូវសេចក្តីស្នេហា ដែលអ្នកប្រុសធ្លាប់មេត្រីដល់អញតាំងពីដើមរៀងមកឬ? តើឯងបិទភ្នែកដែលតែងធ្វើឲ្យអញបេតីជាពន្លឹក នឹងតែងធ្វើសេចក្តីត្រេកត្រអាលឲ្យកើតឡើងតាំងពីដើមរៀងមកឬ? ឆ្លើយបុះ, ប្ដូរម៉ុងឯងឆ្លើយប្រាប់មកអញថាដោយហេតុ

ស្ងាត់យ៉ាងណា បានជាឯងទៅជាកន្លែងសំរាប់ដឹកលំនៅ
ម្សាត្តិដ៏ត្រកាលនេះ"

សូមជំរាបលោកដោយត្រង់ក្នុងវេលានោះ ខ្ញុំកើតក្តៅក្រ
ាយក្នុងចិត្តឥតគណនា ព្រោះរូបអាប្រុសជាទីគាប់ចិត្ត ដែល
ះនាងផ្ទេរជីវិតស៊ូរស្លាប់ជាមួយនោះ មិនមែនជាមនុស្សមាន
ថោម ដូចជាពេលលោកមានបើស្មានក្នុងចិត្តនោះទេ អានោះ
ងជាក្លិនខ្មៅគិរិលគួរឲ្យស្មើបដល់ភ្នែកអ្នកទាំងពួង, វេលានោះ
ាហាកើតឡើង នាំឲ្យខ្ញុំប្រឡោតទប់មិនឈ្នះ ក៏ស្ទុះទៅបង្ហាញ
នឲ្យឃើញ ហើយស្រែកទៅរកម៉ុងនោះផងថា "នែម៉ុងើយ
ហតុដូចម្តេចក៏ព្រះស្តេងមិនស្រួបយកឧត្តបាតដែលធ្វើឲ្យបង្រៃ
ផនដីនេះបាត់ទៅ ហើយម្យ៉ាងវិញទៀតដូចម្តេចក៏ព្រះស្តេងមិន
ផ្លាញសាហាយទាំងប្រុសស្រីនេះឲ្យអន្តរធានទៅ" ។

ខ្ញុំទើបតែនឹងនិយាយស្មើមិនទាន់ផុតមាត់ ស្រាបតែព្រះ
ាងដែលអង្គុយនៅក្នុងទីនោះ ស្ទុះក្រោកដោយកំហឹង ស្រែក
ឡើងថា "អា! អាកំណាច! ឧនមឹងនេះធ្វើឲ្យអញបានសេចក្តី

ឈើចាប់ទាំងអម្បាលនេះ, ប្ដូរមឹងកុំស្មានថាអញមិនដឹងជាឯង បង្ករហេតុ ប៉ុន្តែអញមិនអើពើមកជាយូរហើយ. មិនតែប៉ុណ្ណោះ ថែមព្រះស្តែងមកប្រមាទមើលងាយដល់រូបអញទៀត" វេលានោះខ្ញុំឆ្លើយតាត់ឡើងដោយកំកើងថា "អើពិតជាខ្លួនអញនេះហើយ ដែលបានបណ្ដាសាដល់ឧត្ដបាតនេះ ឲ្យសមនឹងអំពើល្មើសរបស់វា. ហើយគួរតែអញបណ្ដាសាមេហាងឯងផងឲ្យជួបគ្នា អញនឹកស្ដាយណាស់ដែលមិនបានធ្វើទៅវិញ. តាំងពីយូរណាស់មកហើយ ហាងឯងប្រព្រឹត្តតែកិរិយាអាក្រក់អាស្រូវភាសឲ្យអញខ្មាសគេ" ថាតែប៉ុណ្ណោះខ្ញុំក៏ហួតដាវឡើង ដើម្បីនឹងសំឡាប់ប្រពន្ធខ្ញុំ តែព្រះនាងសំឡឹងមើលមកខ្ញុំវិញធ្វើព្រងើយ ឥតមានវន្ធត់ញញើតខ្ញុំបន្តិចសោះ ហើយថែមញញឹមស្រែកឡើងថា "កុំអាលប្រឡាត" ថាហើយក៏តាំងសូត្រអ្វីខ្សិបៗ ខ្ញុំស្ដាប់មិនបាន រួចស្រាប់តែពោលឡើងថា "ដោយអំណាចឫទ្ធិនៃមន្តនេះ សូមឲ្យខ្លួនព្រះស្តែងក្លាយទៅជាមនុស្ស ១ កំណាត់ ជាថ្ម ១ កំណាត់" ថាតែប៉ុណ្ណោះខ្លួនខ្ញុំក៏ក្លាយ ១ រំពេច ដូចជាលោកឃើញ

ស្រាប់នេះឯង គឺជារូបស្លាប់ក្នុងចំណោមមនុស្សរស់ ហើយជារូបរស់ក្នុងពួកមនុស្សស្លាប់ ។

ក្រោយដែលមេអប្រិយ៍អគ្គទេពី ធ្វើខ្លួនខ្ញុំឲ្យប្រែក្លាយដូច្នេះ ហើយវាធ្វើឲ្យខ្ញុំរសាត់មកជាប់ក្នុងទីនេះ ដោយអានុភាពមន្តដ៏ទៃទៀត ហើយវាបំផ្លាញនគរខ្ញុំ ដែលកាលពីដើមសម្បូរឥតខ្វះអ្វី ព្រមទាំងមានមនុស្សប្រុសស្រីគ្រប់ភាសា វារំលើងអស់ផ្ទះសម្បែងផ្សារផ្សោនឹងផ្លូវថ្នល់ទាំងអស់ ហើយធ្វើឲ្យក្លាយទៅជាត្រពាំងធំនឹងទីវាលស្ងាត់ ដូចជាលោកបានឃើញនោះឯង ។ ឯត្រី ៤ ពណ៌ដែលមានក្នុងត្រពាំងធំនោះ គឺជាមនុស្ស ៤ ពួកដែលកាន់សាសនាផ្សេងៗគ្នា, ត្រីសរជាពួកកាន់សាសនាមហាម៉ុត, ត្រីក្រហមពួកប៉ែរ្សដែលកាន់សាសនាព្រះអគ្គី (គោរពភ្លើង), ត្រីខៀវពួកកាន់សាសន៍យេស៊ូ ឬ គ្រិស្តាំង; ឯត្រីលឿងជាពួកហេប្រឺ ឬ យីហ្វ ។ រីភ្នំទាំង ៤ ជាកោះទាំង ៤ ដែលនគរយកឈ្មោះតាមនោះឯង ។ ខ្ញុំបានដឹងរឿងដូច្នេះ ដោយមេកំណាចវាថាក្នុងវារៈនៃសេចក្ដីកំហឹងរបស់វា តែនៅមិនទាន់អស់

សេចក្ដីនៅឡើយ គឺថាដែលវាបានបំផ្លាញទាំងអម្បាលនេះ នៅមិនទាន់ស្កប់សេចក្ដីក្រោធវាទេ វានៅមកដោះអាវខ្ញុំហើយ វាយស្មាខ្ញុំ ដោយរំពាត់លិង្គគោ ក្នុង១ថ្ងៃ១០០ខ្វាប់ត្រាតែចេញឈាមរន្ធាលប្រាលផ្អៅ លុះវាយគ្រប់១០០ហើយ វាយកសំពត់រោមពពែយ៉ាងគគ្រាតមកគ្របរុំឲ្យខ្ញុំ ហើយយកអាវសារបាប់មកបំពាក់ឲ្យពីលើ ដូចលោកឃើញស្រាប់ វាធ្វើដូច្នេះមិនមែនជាការគោរពឲ្យដល់ខ្ញុំទេ គឺធ្វើដោយលរឡកបញ្ឈឺចិត្តខ្ញុំ ។

លុះសារស័ព្ទសេចក្ដីមកដល់ត្រង់នេះ បុរសជំទង់កោះខ្មៅ ជោរជល់ទឹកនេត្រក្នុងខណៈនោះ ។ ឯស្ដេចដែលបានស្ដាប់ក៏កើតនូវសេចក្ដីតានតឹងឧរា មិនអាចពោលថាអ្វីបាន ។ បន្តិចមកបុរសជំទង់លើកដៃទាំង២ឡើង ធ្វើអញ្ជលីកម្មទៅខាងលើ ដោយបញ្ចេញវាចាថា "ឱព្រះម្ចាស់ថ្លៃថ្ងៃទ្រង់ឫទ្ធិឥតថ្វីមបាន វេលានេះខ្ញុំសូមផ្ទេរខ្លួនលើសេចក្ដីយុត្តិធម៌របស់ព្រះអង្គ ខ្ញុំសុខទ្រាំឈឺចាប់រងកម្មលំបាកតាមព្រះហឫទ័យ ប៉ុន្តែខ្ញុំសង្ឃឹមថា

ព្រះមហាករុណារបស់ព្រះអង្គ ទឹងព្រះរាជទានរង្វាន់ដល់ខ្លួនខ្ញុំវិញមិនខាន" ។

ឯស្ដេចដែលមានព្រះហឫទ័យខ្លោចផ្សា ដោយរឿងអស្ចារ្យទាំងនេះ ក៏តាំងព្រះហឫទ័យនឹងសង្កឹកជួយស្ដេចជំទង់នោះ ទើបមានបន្ទូលថា "ចូរស្ដេចប្រាប់ខ្ញុំ តើមេកាឡកិណីនោះវានៅក្នុងទីណា ហើយអាប្រុសនោះវានៅក្នុងទីណា?" ស្ដេចជំទង់តបវិញថា "អាប្រុសឧត្តបាទវានៅក្នុងប្រាសាទទឹកភ្នែកដីដែលនោះឯង គឺប្រាសាទដែលមានកំពូលមូលស្រួច ហើយមានទ្វារជាប់គ្នានឹងប្រាសាទនេះ ឯបំពែរកមេកាឡកិណី ខ្ញុំមិនអាចនឹងកំណត់ឲ្យច្បាស់ជានៅក្នុងទីណា ៗ ឡើយ, ប៉ុន្តែរាល់ថ្ងៃ វេលាព្រះអាទិត្យរះឡើង វាចូលមកវាយខ្ញុំ ១០០ រំពាត់ ហើយវាចូលទៅមើលសាហាយវា. វាវាយខ្ញុំ ១ ថ្ងៃ ១ តាមចិត្ត ព្រោះខ្ញុំគ្មានគ្រឿងអ្វីនឹងការពារខ្លួន ។ អាប្រុសនោះនៅរស់ជីវិតដល់សព្វថ្ងៃ ដោយមេកាឡកិណីវាមានថ្នាំអ្វីម្យ៉ាងលាយនឹងទឹក យកទៅបន្តក់ឲ្យផឹកការពារនូវជីវិតិន្ទ្រីយ៍មិនឲ្យរលត់

ទៅបាន ហើយវាបេះតែខ្ញុំយំខ្សឹកខ្សួលក្បែរសាហាយវារាល់តែថ្ងៃ តាំងពីយប់ដែលត្រូវរបួសមក" ។

ស្ដេចឮហើយ មានព្រះបន្ទូលថា "ឱស្ដេច, ក្នុងលោកនេះគ្មានអ្នកឯណាមានកម្មលំបាកដូចស្ដេចឡើយ, ម្យ៉ាងទៀតនឹងមានអ្នកឯណាអាណិតអាសូរអ្នកដទៃ ដូចខ្លួនខ្ញុំអាណិតស្ដេចនេះឥតអង្គឹមាន ព្រោះរឿងយ៉ាងនេះមិនដែលមានដល់រូបបុរសណាសោះ ក្រុមព្រះរាជាវិតារនិពន្ធក្នុងនគរនេះអាចនឹងអួតបាន ថារឿងនេះបំឡែកជាងរឿងទាំងឡាយដែលគេបានដឹងឮពីដើមមក ឥតមានរឿងណាប្រៀបផ្ទឹមបានឡើយ ។ ប៉ុន្តែរឿងនេះនៅខ្វះស្ពាន ១ ទៀតទើបផ្លូនបរិបូណ៌ គឺខ្វះសេចក្ដីសងសឹកតែថាត្រង់នេះខ្ញុំធានានឹងធ្វើឲ្យសម្រេចបាន ប្ដូរស្ដេចចាំទុកចុះ" ។

លុះសន្ទនាគ្នាស្រេចហើយ ទ្រង់ក៏សម្ដែងឲ្យស្ដេចជំទង់បានដឹង ថាទ្រង់ជាស្ដេចធំគ្រងរាជសម្បត្តិក្នុងនគរ ១ ជិតគ្នាហើយអធិប្បាយអំពីហេតុដែលនាំឲ្យទ្រង់យាងមកដល់ទីនេះ

ទើបទ្រង់គិតរកឧបាយកល់នឹងធ្វើសង្សឹក លុះឃើញហើយក៏ប្រាប់ឧបាយដល់ស្ដេចជំទង់ ហើយកំណត់ពេលនឹងធ្វើដល់ទៅថ្ងៃស្អែក ។ ក្នុងរាត្រីនោះស្ដេចជ័យទៅសំពកាក់ក្នុងទីដទៃសិន ។ ឯស្ដេចជំទង់ក៏គង់ពត្លឹសតាមធម្មតា គឺតាំងពីថ្ងៃដែលត្រូវអំពើមន្តមក មិនដែលបានផ្ទំ១វេលាសោះ ប៉ុន្តែក្នុងសម័យនោះ មានសង្ឃឹមថានឹងបានស្បើយទុក្ខមិនខាន ។

លុះបែកបច្ចុសភ្លឺឡើង ស្ដេចតើនពីព្រលិម ដោះឆ្លងព្រះអង្គវែងខាងក្រៅលាក់ក្នុងទី១ដ៏ស្ងាត់ ទើបយាងបាទន្ដោះទៅឯប្រាសាទទឹកភ្នែក យាងទៅដល់ក៏សំគាល់បានដោយប្រទីបជ្វាលាភ្លឺព្រោងព្រាតពាសពេញនៅទីនោះ សុទ្ធតែទៀនធ្វើដោយក្រមួនសរ ហើយមានខ្លឹនក្រអូបផ្សប់ផ្សាយ ដោយអំណាចគ្រឿងក្រអូបបំពក់ក្នុងឆ្នាំងមាស់ដ៏មានក្បាច់របនា រៀបរៀងជាជួរក្បែរគ្រែទទេដែលអាប្រុសដេក ។ វេលាដែលយាងទៅដល់គ្រែ ស្ដេចហូតដាវឡើងប្រហារមនុស្សខ្មៅដល់នូវមរណកាលក្នុងគ្រានោះ ហើយអូសសពទៅបោលក្នុងអណ្ដូង១ទៀប

ប្រាសាទស្រេចហើយកាលណា ទ្រង់យាងចូលទៅផ្ទុំសន្ទឹង លើគ្រែទេនរបស់មនុស្សខ្មៅដាក់ព្រះសែងហ្វាជិតព្រះអង្គ ទាញភួយគ្របព្រះកាយសំងំចាំសម្រេចតាមគំនិតដែលទ្រង់បានប្រារព្ធទុកជាមុន ។

កាលនោះនាងដែលបេះវេទ្យមន្តក៏ចូលទៅដល់ប្រាសាទ ឯកិច្ចជាបឋមរបស់នាង គឺដើរតំរៅទៅបន្ទប់ដែលស្តេចស្វាមីនៅ ទៅដល់ហើយដោះអាវរូបបកសំពត់ដែលរុំបេញ ទើបចាប់វាយដោយរំពាត់អស់ទំហឹង ។ រីស្តេចអាភ័ពក៏ស្រែកទ្រហោយំអង្វរដោយមធុរវាចា គួរឲ្យអាណិតពន់ពេកណាស់ តែនាងនោះមិនព្រមទទួលអង្វរសោះ វាយគ្រប់១០០រំពាត់ហើយទើបឈប់ ថែមពោលឡើងថា “វេលាដែលព្រះស្តេងឯងធ្វើសាហាយអញ ហេតុអ្វីក៏មិនគិតអាណិតផង ដល់វេលាដែលអញធ្វើព្រះស្តេងឯងវិញ អញក៏មិនអាណិតដូចគ្នា, ចូរកំសង្ឃឹមថាអញយកសេចក្តីអង្វរព្រះស្តេងឯងឡើយ” ថាដូច្នេះហើយក៏យកសំពត់គគ្រាគរុំទៅវិញ បំពាក់នូវអាវសារបាប់ឲ្យដូចដើម

រួបយាត្រាទៅកាន់ប្រាសាទទឹកភ្នែក វេលាដែលដើរចូលទៅ ក៏កើតទុក្ខខ្លាំងខ្សឹកខ្សួលអួលអាក់ ដើរថ្មម ៗ ជើងឆ្ពោះទៅឯគ្រែ ដោយស្មានថាជាប្រុសសាហាយដេកសន្ធឹងក្នុងទីនោះ ទើបពោលឡើងថា "ចុះភិសាហាវិយង់ឃ្នងអ៊ីម្លេះ មកធ្វើឲ្យអញរងទុក្ខវេទនាយ៉ាងនេះ, វេលាដែលអញទៅវិញភ្ញា ៗ គេះដៀលអញ ថាអញមានសន្ដានចិត្តជាតិរច្ឆាន, ឱអាកំណាចអើយ, អញប្ដូរអ្នកអំពើសាហាវរបស់ឯងនេះ មិនជួននឹងកំហុសដែលឯងប្រព្រឹត្តល្មើសឡើយ, នែអាក្បត់, ឯងបៀតបៀនដល់ជីវិតប្រុសអញ ដែលកំពុងតែស្រឡាញ់ពេញចិត្តដូច្នេះ មិនគឺឯងធ្វើឲ្យអន្តរាយដល់ជីវិតអញដែរឬតិ?" ទើបបែទៅនិយាយនឹងស្ដេចដែលផ្ទុំលើគ្រែ ដោយស្មានថាជាប្រុសសាហាយខ្លួនថា "ឱជីវិតប្អូនអើយ, ហេតុម្ដេចក៏អ្នកសំងំស្ងៀមជានិច្ចដូច្នេះ? អ្នកតាំងចិត្តស៊ូរបណ្ដោយឲ្យប្អូនក្ស័យប្រាណឬ? បានជាគ្មានមេត្រីមករកប្អូន ហើយប្រាប់ប្អូន ១ ម៉ាត់ឲ្យដឹងជាអ្នកនៅស្រឡាញ់ប្អូនឡើយ, នែព្រលឹងមាសប្អូន ប្ដូរឆ្លើយតប ១ ម៉ាត់មកឲ្យឆាប់ កុំផ្ទុំរង្វៀងឡើយ." ។

គ្រានោះស្ដេចផ្អើលហាក់ដូចជាទើបនឹងដឹងព្រះអង្គពីផ្ទុំលក់ ហើយទ្រង់ត្រាប់សំឡេងពួកក្លឹងខ្មៅ ឆ្លើយតបទៅដោយសំដីធ្ងន់ថា "ឯកំឡាំងនឹងឫទ្ធិ មានតែព្រះជាម្ចាស់ប៉ុណ្ណោះដែលលោកខ្លាំងពូកែ" វេលាដែលបានឮសំដីដូច្នេះ នាងមិនបានជាប្រុងចាំស្ដាប់ ក៏បន្លឺនូវសម្រែកអំណរខ្លាំងឡើងថា "ឱម្ចាស់ខ្ញុំអើយ ខ្ញុំមិនមែនជាភាន់ច្រឡំទេឬអី?" ស្ដេចជេរទៅថា "មេអកុសល, តាមមារយាទហាងឯងនេះ មិនគួរអញឆ្លើយតបសោះ" នាងសួរ "ចុះហេតុអ្វីបានជាអ្នកជេរខ្ញុំដូច្នេះ?" ស្ដេចតប "អើ, បានជាអញជេរ ព្រោះសម្រែកឃោបំនឹងសំឡេងថ្ងូររបស់ប្ដីហាងដែលហាងឯងទៅវាយរាល់ថ្ងៃ ដោយអំពើពាលនោះ ធ្វើឲ្យអញប្លង់សំងំដេកមិនបាន បើកុំតែដូច្នេះប្រហែលអញបានជាសះស្បើយនិយាយបានតាំងពីយូរមកណាស់ហើយ ហេតុនេះហើយដែលនាំឲ្យអញគមមិននិយាយតបនឹងពាក្យថ្លែងទុក្ខរបស់ហាងឯង" នាងឆ្លើយថា "បើដូច្នោះខ្ញុំនឹងទៅស្រាយមន្តចេញ ដើម្បីឲ្យអ្នកបានស្បើយឥឡូវនេះ, អ្នកឲ្យខ្ញុំទៅធ្វើវាឲ្យមានស-

ភាពដូចដើមវិញ ឬយ៉ាងណា?" ស្ដេចឆ្លើយៈ "អើ, ចូរឯងទៅឲ្យឆាប់ ហើយធ្វើវាឲ្យរួចបេញគឺឡូវ កុំឲ្យអញឮសំឡេងវាទៀត" ។

នាងចេញពីប្រាសាទទឹកភ្នែកដោយរួសរាន់ យកទឹក ១ ពែងមកស្លូត្រផ្ដុំពីលើ ទឹកនោះក៏ពុសខ្ទោលហុយផ្សែងឡើងហាក់ដូចជាដាំលើចង្ក្រានភ្លើង រួចដើរឆ្ពោះទៅក្នុងបន្ទប់ស្ដេចជាស្វាមី ហើយស្រោចទឹកនោះពីលើ ដោយបញ្ចេញវាចាថា "បើព្រះជាម្ចាស់បង្កើតឯងមកភាពសណ្ឋានដូច្នេះ ឬព្រះជាម្ចាស់ទ្រង់ខ្ញាល់នឹងឯង សូមឲ្យឯងនៅគង់ភាពសណ្ឋានដូច្នេះចុះ; ប៉ុន្តែបើឯងក្លាយមកជាភាពសណ្ឋានដូច្នេះ ដោយអំណាចមន្តរបស់អញទេ សូមឲ្យឯងវិលក្លាយទៅតាមភាពចាស់ដូចដើមរបស់ឯងវិញទៅ" គ្រាន់តែថាប៉ុណ្ណោះស្ទើរមិនទាន់ផុតពីមាត់ស្ដេចជិទង់ក៏ក្លាយទៅតាមភាពចាស់វិញ គឺតប្រែប្រួលឡើយក្រោកឈរឡើងភ្លាម ដោយសេចក្ដីត្រេកអរគឺតឧបមា ហើយពោលអរគុណដល់ព្រះជាម្ចាស់ ។ បានឃើញដូច្នេះ នាងក៏

និយាយប្រាប់ទៅថា "ត្រូវឯងបំបែរចេញឲ្យឆ្ងាយពីប្រាសាទនេះ កុំត្រឡប់មកវិញឲ្យសោះ បើមិនធ្វើតាម អញនឹងដាក់អាជ្ញាឲ្យដល់ជីវិត" ។

ស្តេចជំទង់ទទួលតាម ហើយបំបែរចេញពីនាងនោះ ឥតពោលថាអ្វី យាងទៅគង់ចាំសេចក្តីសម្រេចរបស់រាជមិត្រ នាទី ១ ដ៏សមគួរឆ្ងាយពីកន្លែងនោះ ។

នាងក៏វិលត្រឡប់ទៅឯប្រាសាទទឹកភ្លោកវិញ លុះចូលទៅដល់ទើបនិយាយទៅកាន់ព្រះរាជា ដោយស្មានជាសាហាយរបស់ខ្លួនថា: "នែអ្នកប្រុសសំឡាញ់, ឥឡូវនេះខ្ញុំបានធ្វើតាមបង្គាប់អ្នកជាស្រេចហើយ សូមឲ្យអ្នកក្រោកឡើងមកកាន់ខ្ញុំ ដើម្បីឲ្យខ្ញុំបានក្រេបនូវដំណេក ដែលខ្ញុំអាក់ខានជាយូរណាស់មកហើយ" ។

ស្តេចត្រាប់សំឡេងក្លែងខ្មៅឆ្លើយមកកាន់ទៀតថា "ការដែលឯងទើបនឹងធ្វើហើយនោះ នៅមិនទាន់ធួនឲ្យអញជាស្រឡះទេ គឺឯងគ្រាន់តែបានសម្រាលនូវសេចក្តីឈឺចាប់អញតែ

១ ភាគប៉ុណ្ណោះ តទៅទៀតគួរតែឯងរំលើងឲ្យអស់ឫសចេញ”៖ នាងសួរទៅវិញៈ “អ្នកថាឲ្យខ្ញុំរំលើងឫសនោះតើ ឲ្យខ្ញុំធ្វើដូចម្ដេចទៀត” ស្ដេចតបៈ “ឱកម្ម្រកាស! ឯងមិនទាន់យល់ទេឬ គឺអញចង់និយាយពីនគរនឹងអាណាប្រជានុរាស្ត្រព្រមទាំងកោះ ៤ ដែលឯងបានបំផ្លាញដោយវេទមន្តនោះ, រាល់តែថ្ងៃនៅវេលាពាក់កណ្ដាលអាធ្រាត្រ ត្រីទាំងឡាយដែលនៅក្នុងត្រពាំងងើបក្បាលឡើងផុតពីទឹកបន្លឺនូវសម្រែកព្រម ៗ គ្នាថាសងសឹក ៗ បំពោះខ្លួនអញនឹងខ្លួនឯង នេះហើយជាឫសកែវយ៉ាងធំ ដែលបំទាស់មិនឲ្យអញបានសះស្បើយដោយរួសរាន់ត្រូវឯងទៅធ្វើរបស់ទាំងនេះឲ្យមានកំណើតភាពសណ្ឋានដូចដើមវិញ សឹមត្រឡប់មកកាន់ទីនេះ អញនឹងហុចដៃឲ្យឯងដើម្បីជួយលើកអញឲ្យក្រោកអង្គុយឡើង” ។

ស្រីកំណាចបានឮពាក្យដូច្នេះហើយ កើតមានសេចក្ដីប្រីតាប្រមោទ្យសប្បាយរីករាយក្នុងដួងហឫទ័យឥតគណនាទើបពោលឡើងថាៈ “នែព្រលឹងប្អូន, បើដូច្នោះអ្នកនឹងបាន

សេចក្ដីសុខស្រួលក្នុងគ្រាឥឡូវនេះមិនខាន, ខ្ញុំនឹងទៅធ្វើតាមបង្គាប់អ្នកដោយរួសរាន់" ហាភ្លាមក៏ដើរចេញពីប្រាសាទ ឆ្ពោះទៅកាន់ត្រពាំងនោះឯង ដល់ហើយលូកក្បង់ទឹកឡើង ស្ងូត្រសេពវេទ្យមន្តផ្លុំទឹកនោះបាចទៅក្នុងត្រពាំងវិញ ស្ងូត្រស្ទើរតែមិនទាន់ផុត ទីក្រុងធំក៏កើតឡើងដូចដើមឮដ៏កាលនោះ ។ ត្រីទាំង ៤ ពណ៌ក៏ក្លាយទៅជាមនុស្សប្រុសស្រីក្មេងចាស់ទាំងអស់; ពួកដែលកាន់សាសនាមហាម៉ត ក៏ទៅជាពួកមហាម៉ត, ពួកកត្តូលិក ក៏ទៅជាកត្តូលិក, ពួកពៃរ្យ៍ ក៏ទៅជាពៃរ្យ៍, ពួកហេប្រើ ក៏ទៅជាហេប្រើ; នរណាកាលពីដើមជាមនុស្សអ្នកជា ក៏ទៅជាអ្នកជាវិញ ដែលធ្លាប់ជាបរិវារគេ ក៏ទៅជាបរិវារតាមថ្នាក់នឹងភារធម្មតារបស់ខ្លួនពីដើមរៀងមកឥតមានប្រែប្រួលអ្វី មានផ្ទះសម្បែង, ហាងលក់ទំនិញ មានមនុស្សនៅពេញ ទំនិញចុកហាង មានផ្លូវខ្វាត់ខ្វែងពាសពេញក្នុងនគរដូចគ្រាមុន ។

ឯពួកពលមហាក្សត្រដែលបោះបារាំសំបតក្នុងទីវាល ក៏

កើតសេចក្ដីភ្ញាក់ផ្អើលជាខ្លាំង កាលដែលបានឃើញទីវាលក្លាយទៅជាទីក្រុងធំ ១ រំពេចដូច្នោះ ។

រីនាងកាឡកិណី លុះបានធ្វើស្រេចហើយ ក៏ត្រឡប់ទៅកាន់ប្រាសាទទឹកភ្នែកវិញ ដើម្បីត្រេកត្រអាលនឹងសាហាយខ្លួនទៅដល់ហើយនិយាយថាៈ "នែអ្នកប្រុសសំឡាញ់ម្ចាស់ប្អូន, ប្អូនបានធ្វើជាស្រេចតាមបង្គាប់អ្នកហើយ, ឥឡូវនេះប្អូនចូលមកសប្បាយជាមួយនឹងអ្នក ព្រោះអ្នកបានសះស្បើយសព្វសារពាង្គកាយ គ្មានឈឺចាប់អ្វីទៀតទេ សូមអ្នកប្រុសងើបក្រោកឡើងចាកគ្រែទេន ហើយហុចដៃមកប្អូន" ស្ដេចឆ្លើយឡើងៈ "ចូរអូនខិតឲ្យជិតមកបង" នាងក៏ខិតចូលទៅ ស្ដេចប្រាប់ទៀតថាៈ "នៅមិនទាន់ល្មមទេ, ខិតចូលមកបន្តិចទៀត" នាងក៏ខិតចូលជិតទៅ ។ វេលានោះស្ដេចចាប់បានដៃហើយទ្រង់ស្ទុះក្រោកឡើងភ្លាម មិនឲ្យនាងមើលមុខច្បាស់ទាន់ ហើយទ្រង់ចាប់ដាវពុះបំកណ្ដាលក្បាលរយះចេញជា ២ ផ្នែកទៅខាងក្រោមដល់នូវមរណភាពក្នុងទីនោះ ១ រំពេច, ស្រេចហើយទ្រង់ហោះ

បង់ខ្មោចនៅកន្លែងដែលស្លាប់ ទើបយាងចេញទៅរកស្តេចក្មេងដែលនៅរង់ចាំនៅទីដទៃ ដល់ហើយទ្រង់ស្ទុះទៅឱបហើយមានបន្ទូលថាៈ "ប្អូរស្តេចត្រអាលសប្បាយទៅ កុំមានបារម្ភអ្វីទៀត សត្រូវរបស់ស្តេចរលាយអស់ហើយ" ។

គ្រានោះស្តេចជំទង់ ថ្លែងសេចក្តីអំណរអរគុណដល់មហាក្សត្រាធិរាជ ដោយមធុរវាចាផ្សេង ៗ នឹងគណនាត្រារាប់ពុំបាន ។ ស្តេចក៏ថ្វាយសព្ទសាធុការពរទៅវិញ ឲ្យប្រកបដោយអាយុ, វណ្ណ, សុខ, ពល. នឹងសេចក្តីចំរើនគ្រប់ប្រការជានិរន្តរ៍តទៅ រួចមានព្រះបន្ទូលតបទៅថាៈ "សូមឲ្យស្តេចគង់នៅជាសុខក្នុងនគរនេះចុះ ឬមួយបើចង់ទៅក្រសាលឯនគរខ្ញុំដែលនៅជិតទីនេះក៏បានឥតមានទាស់អ្វី ខ្ញុំនឹងផ្គត់ផ្គង់ឲ្យបានសេចក្តីសុខសម្រាន ដូចជាគង់ក្នុងនគរនេះដែរ" ស្តេចជំទង់ទូលតបទៅវិញថាៈ "បពិត្រមហាក្សត្រដ៏ប្រកបដោយបុញ្ញរិទ្ធិ ដែលមានព្រះគុណលើខ្ញុំជាអនេក, តើព្រះអង្គទ្រង់ស្មានថាទីនេះនៅជិតនគរព្រះអង្គឬអ្វី ?" ស្តេចឆ្លើយៈ "ខ្ញុំ

ស្ថានឋានៅជិតទីនេះមែន ព្រោះកាលដែលខ្ញុំមកចំងាយផ្លូវមិន លើសពី ៤-៥ ម៉ោង" ស្តេចជំទង់ទូលថាៈ មិនមែនដូះហ្នោះ ទេព្រះអង្គ, ចំងាយផ្លូវពីទីនេះទៅនគរព្រះអង្គ បើកំណត់ដោយ ឆ្នាំ ១ ឆ្នាំគត់ទើបដល់ ព្រះអង្គមានព្រះបន្ទូលថាជិតនោះក៏ពិត មែនហើយ តែថាកាលដែលទ្រង់យាងមកនោះ នគរទូលបង្គំ នៅក្នុងរវាងអំពើវេទ្យមន្ត ផែនដីក៏រួញទៅ តែឥឡូវនេះ ដោយ បានរដោះបេញពីអំណាចមន្តហើយ ដីដែលរួញក៏យឺតយារ ទៅតាមភាពសណ្ឋានដើមវិញ, ប៉ុន្តែបើទោះណាជាឆ្ងាយដល់ ផុតផែនដីក្តី ក៏ទូលបង្គំគួរតាមហែព្រះអង្គទៅជាដរាប ។ ព្រះអង្គមានគុណូបការដ៏ធ្ងន់លើទូលបង្គំ ត្រូវទូលបង្គំចាក រាជសម្បត្តិតាមហែព្រះអង្គទៅ ដើម្បីឲ្យឃើញជាបន្ទាល់ជាក់ ស្តែងនៃសេចក្តីតបព្រះតេជ-គុណរបស់ទូលបង្គំជាខ្ញុំ" ។

គ្រានោះស្តេចហោភ្ញាក់ព្រះអង្គឡើង ដោយទ្រង់បាន ជ្រាបសេចក្តីថា ព្រះរាជធានីរបស់ព្រះអង្គនៅឆ្ងាយពីនគរស្តេច ជំទង់ពេកណាស់ ហើយទ្រង់យោបល់មិនយល់ហេតុដែលប្រែ

ប្រែលនេះសោះ ស្ដេចជំទង់ក៏អធិប្បាយពន្យល់ការដែលផ្លាស់ប្ដូរត្រាតែអស់វិមុតិសង្ស័យ រួចពីនោះស្ដេចមានព្រះបន្ទូលថា "សេចក្ដីនឿយព្រួយដោយផ្លូវឆ្ងាយ ក្នុងការដែលវិលត្រឡប់ទៅកាន់នគរវិញនោះមិនជាអ្វីទេ ព្រោះថាខ្ញុំបានបំពេញកិច្ចដ៏ឧត្ដមរួចហើយ គឺខ្ញុំបានដោះទុក្ខស្ដេចឲ្យរួចពីកម្មលំបាកនេះឯង កុសលនេះនាំឲ្យខ្ញុំបានខ្នួនស្ដេចធ្វើជាកូន ព្រោះបានប្ដេជ្ញាថានឹងជូនខ្ញុំទៅនគរវិញ រីខ្លួនខ្ញុំនេះគ្មានកូនមួយសោះ បើដូច្នេះខ្ញុំយកស្ដេចធ្វើជាកូន ហើយខ្ញុំនឹងបង្វែរាជសម្បត្តិឲ្យទាំងអស់"

លុះប្រាស្រ័យដោយសេចក្ដីមេត្រីហើយ ស្ដេចទាំង២អង្គក៏ប្រកៀកប្រឱបគ្នាយ៉ាងស្និទ្ធ ហាក់បីដូចជាបិតានឹងបុត្របង្កើតដូច្នោះ រួចស្ដេចជំទង់ក៏ចាត់ការរៀបព្រះរាជដំណើរដោយរួសរាន់ ។ ការចាត់ចែងនេះកំណត់ ៣ សប្ដាហ៍ គឺ ៣ អាទិត្យទើបហើយស្រេច ។ អស់មុខមន្ត្រីសេនាបតីរាល់គ្នាដែលទទួលនៅថែរក្សាព្រះនគរ ក៏អាលោះអាល័យពន់ប្រមាណ ។

ស្រេចហើយទើបក្សត្រទាំង ២ អង្គយាងចេញចាករាជបុរីទៅ មានសត្វឧដ្ឋ១០០ផ្ទុកទ្រព្យផ្សេងៗ ដ៏មានដំឡៃ ដែលរើចេញពីព្រះឃ្លាំងមក ហើយមានពួកសេនាសេះ ៥០ នាក់ហែហមព្រះអង្គតាមមាគាទៅ ព្រះរាជដំណើរនេះប្រកបដោយសេចក្ដីសុខស្រួល ឥតមានមោះមន្ទិលអ្វីដល់តិចឡើយ ។ លុះយាងជិតដល់ព្រះនគរ ទ្រង់ឃាត់រាជទូតឲ្យនាំរាជសារទៅឲ្យដំណឹងដល់សេរីកាមាត្យ ដែលនៅចាំរក្សាព្រះរាជវាំង ព្រមទាំងសារសព្ទប្រាប់ហេតុភេទផ្សេងៗដែលនាំឲ្យយឺតយូរដំណើរនេះផង ។

សេនាបតីទាំងឡាយដែលនៅរក្សាព្រះរាជនិវេស លុះបានដំណឹងដូច្នេះហើយ ក៏រួសរាន់ចេញទៅទទួលស្ដេចដល់ទីដែលទ្រង់ប្រថាប់សំចតនៅ បានយកសេចក្ដីក្រាបទូលអំពីការសុខសប្បាយក្នុងព្រះរាជធានី ឥតមានហេតុភេទអ្វីបណ្ដាលឲ្យចលាចលឡើយ ។ រីបណ្ដារាស្ត្រក៏លើកគ្នាជាពួកជាកងចេញទៅថ្វាយបង្គំគាល់ទាំងពីរព្រះអង្គដោយសេចក្ដីរលឹក ហើយម្នី-

ម្ចាស់ឯបាត់បែងធ្វើបុណ្យទទួលអំណរនៅទីនោះជាច្រើនថ្ងៃ ។

ក្រោយដែលទ្រង់យាងចូលក្នុងព្រះរាជវាំង ១ ថ្ងៃ ទ្រង់បានប្រកាសដល់សេនាបតីនឹងនាម៉ឺនសព្វមុខមន្ត្រីដែលគាល់ត្រៀបត្រាក្នុងទីនោះ ពីហេតុភេទផ្សេងៗដែលនាំឱ្យយឺតយូរមិនបានយាងត្រឡប់មកវិញដោយរួសរាន់ ហើយនាំឱ្យបានស្ដេចជំទង់នៃនគរកោះខ្មៅធ្វើជារាជបុត្រ នឹងអំពីស្ដេចនេះបានបោះបង់រាជសម្បត្តិ តាមហែទ្រង់មក ដើម្បីនៅគង់ជាមួយក្នុងរាជបុរីនេះ ។ ស្រេចហើយទើបទ្រង់ព្រះរាជទានរង្វាន់ដល់សព្វមុខមន្ត្រីទាំងអស់ដែលបានបំរើរក្សានគរ ដោយសុចរិតស្លូតត្រង់ ឥតមានគិតក្បត់ប្រទុស្ដរាយដល់ផែនដី ព្រមទាំងឱ្យឡើងយសសក្តិតែរៀងខ្លួន គ្រប់ក្រុំ គ្រប់ដំណែង មុខក្រសួងទាំងអស់ក្នុងគ្រានោះ ។

ឯចំណែកតាចាស់នេសាទ ដោយគាត់ជាដើមហេតុនៃការដែលនាំឱ្យបានរដោះទុកស្ដេចជំទង់ ស្ដេចព្រះរាជទានគួររង្វាន់

ជាអនេកឥតគណនា ហើយបិញ្ចឹមរក្សាឲ្យបានសេចក្ដីសុខមួយអន្លើដោយគ្រួសា ដរាបដល់អស់ជីវិតតែរៀងខ្លួន ។ ៚ ——

រឿងដែលនឹងមានតទៅទៀត ក្នុងខ្សែទី ៨ ពីរោះអស្ចារ្យ មានរឿងអ្នកបួស ៣ នាក់ភ្នែកខ្វាក់ម្ខាងម្នាក់ទាំងអស់គ្នា កាលណាមើលត ៗ ទៅ សេចក្ដីដែលប្លែកកាន់តែមានឡើងជានិច្ច សូមអញ្ជើញមើលតទៅខ្សែក្រោយ ៗ ទៀតកុំខាន ។

# រឿងព្រេងខ្មែរ

## រឿងជាតិសត្វខ្លាធំ

ដើមឡើយ មានព្រះមហាក្សត្រសោយរាជសម្បត្តិនៅនគរ១មានព្រះអគ្គម្ហេសីជាបមសត្រី មានមន្ត្រីចតុស្តម្ភប្អូន មានហោរ៉ា ១ ជាដំណាងព្រះនេត្រទិព្វរបស់ព្រះអង្គ មានមន្ត្រីនឹងស្រីស្នំជារណ្តាប់ ពេញកេតិយសជាម្ចាស់ផែនដី តាមលំអានរបស់ព្រះអង្គ ពីបុរាណរាជរៀងមក ប៉ុន្តែព្រះមហាក្សត្រនឹងចតុស្តម្ភទាំងបួន ពុំបានរៀនមន្តត្រ័យវេទ ខាងពីការដៃយសង្គ្រាម, រាល់វេលាមុនៗ មកព្រះអង្គតែងព្រួយព្រះទៃបារម្ភនឹងព្រះមហានគរជាអានែក ដោយអានុភាពរបស់ព្រះអង្គទន់ទាបបុះ រំពឹងថា បើប្រសិនណាជាមានសឹកសត្រូវចូលមកលុកលុយដណ្តើមមុខ ជាព្រះនគរនឹងបានទៅជាកណ្តាប់ដៃនៃបច្ចាមិត្រដោយងាយ ។

មានថ្ងៃ១វេលាម៉ោង៨ព្រឹក ព្រះអង្គចេញបុងព្រះបរមរាជ-វាំង ព្រមទាំងព្រះអគ្គម្ហេសីគង់នែបអែបជិតព្រះអង្គ មានហោរា នឹងចតុស្តម្ភទាំងប្អូននៅមន្ត្រីឯទៀតក្រាបបង្គំគាល់តាមធម្មតា

ពេលនោះទ្រង់ក៏ភ្ញាក់ព្រះទ័យនឹករឭកចង់ទៅរៀនសិល្បសាស្ត្រ ឯអាចារ្យទិសាបាមោក្ខឯនគរតក្កសិលា ទ្រង់ក៏មានវាចាជំនុំព្រម នឹងព្រះអគ្គមហេសីហើយនឹងហោរានៅចតុស្តម្ភទាំងបួន ព្រះអគ្គមហេសីក៏សុំតាមទៅផង ឯហោរានឹងចតុស្តម្ភទាំងបួនក៏សុំតាម ហែព្រះអង្គទៅ ដើម្បីនឹងរៀនមន្តវិជ្ជាឲ្យបំណាន់ក្នុងព្រះនគរ ទ្រង់ក៏អនុញ្ញាតព្រម ជំនុំស្រេចហើយមានថ្ងៃ១ព្រះអង្គនឹងអគ្គមហេសី ព្រះទាំងហោរាចតុស្តម្ភទាំងបួនចេញចាកពីព្រះនគរ គិតរប់ ៧ ថ្ងៃ ដល់នគរតក្កសិលាបានជួបនឹងអាចារ្យទិសាបាមោក្ខថ្វាយខ្លួន ជាសិស្សសុំរៀនសិល្បវេទ, អាចារ្យទិសាបាមោក្ខក៏ទទួលភារ បង្រៀនព្រះអង្គនឹងព្រះអគ្គមហេសីព្រមទាំងហោរាចតុស្តម្ភបាន រៀនចេះចប់សព្វគ្រប់ ទោះបីនឹងថ្លែងខ្លួនជាសត្វតេរិច្ឆានឬជាយក្ខ គន្ធព្វសុបណ្ណាក៏សឹងបានដោយងាយ រៀនចេះចប់ស្រេចស្តេច ក៏សុំលាអាចារ្យវិលត្រឡប់មកនគរវិញ អាចារ្យក៏អនុញ្ញាតព្រម ព្រះអង្គនឹងព្រះអគ្គមហេសីនឹងហោរានៅចតុស្តម្ភទាំងបួនក៏ដំណើរ ចេញពីក្រុងតក្កសិលាមកបាន៣ថ្ងៃហេតុតែជាផលកម៌វេងផ្លូវ

យាងត្រេចកាត់ក្នុងព្រៃ អត់ស្បៀងអាហារនឹងត្រារាប់ពេលពុំអស់ សោយតែដើមឈើនឹងផ្លែឈើជាអាហារ ព្រះអង្គក៏មានសង្វេគអនិច្ចាស្ដាយជីវិតទ្រង់ក៏ជំនុំគិតនឹងហោរាចតុស្ដម្ភទាំងបួន ព្រមទាំងព្រះអគ្គមហេសីថាតទៅនេះយើងនឹងដល់នៅអាយុសង្ខារគ្រប់គ្នាព្រោះគ្មានអាហារនឹងចិញ្ចឹមជីវិត តើអស់លោកនឹងយល់ឃើញជាម្ដេចទើបហោរាទូលថា ទូលបង្គំជាខ្ញុំយល់ឃើញថាមន្តវិជ្ជាដែលបានរៀនមកសឹងបេះបប់សព្វគ្រប់ដូចគ្នា ហេតុនេះបើនឹងប្លែងខ្លួនជាសត្វខ្លាធំ ហើយនឹងចាប់សត្វដទៃទៀតធ្វើជាអាហារទំរាំតែទៅដល់ព្រះមហានគរនឹងប្លែងខ្លួនជាមនុស្សវិញក៏សឹងបាន ព្រះអង្គនឹងព្រះអគ្គមហេសីនូវចតុស្ដម្ភក៏យល់ព្រមតាម ទ្រង់ក៏មានព្រះបន្ទូលសួរថាតទៅរូបខ្លាទាំងមូលនេះលោកណានឹងត្រូវការប្លែងខ្លួនធ្វើជាអ្វី ទើបចតុស្ដម្ភសុំប្លែងធ្វើជាជើងខ្លាទាំង៤ ហោរាសុំប្លែងធ្វើជាកន្ទុយ សម្ដេចអគ្គមហេសីសុំប្លែងធ្វើជាខ្លួនខ្លា រូបខ្លាទាំងមូលនេះឃើញនៅសល់តែក្បាលគឺត្រូវអង្គព្រះមហាក្សត្រ គិតជំនុំរួចស្រេចក៏សូត្រមន្តវិជ្ជាប្លែងខ្លួន

កើតជាព្យគ្ឃរាជបានដូចសេចក្ដីប្រាថ្នា ស្ទុះបោលដេញចាប់សត្វប្រើសក្ដាន់ជាអាហារ លុះអំឡុងទៅក៏កើតជាសេចក្ដីសប្បាយភ្លេចរាជសម្បត្តិនឹងព្រះមហានគរពុំមាននឹកស្ដាយសោះ ។

ហេតុនេះបានជាសត្វខ្លាមានកំឡាំងខ្លាំងជាងសត្វដទៃឯទៀត ហើយសត្វខ្លានេះនឹងចាប់សត្វជាអាហារ គឺដឹងពីកន្ទុយជាមុនព្រោះហោរា ដងខ្លួនដែលទន់ភ្លន់គឺសម្ដេចអគ្គមហេសីជាសត្រី ឯក្បាលដែលមើលឃើញសំបើមអស្ចារ្យ គឺតួអង្គព្រះមហាក្សត្រដែលមានមហិទ្ធិរិទ្ធិជាងអ្នកទាំងអស់ ជើងទាំងបួនដែលមានកំឡាំងខ្លាំង ហើយមានក្រចកមុះមុតគឺចតុស្ដម្ភទាំងបួន ។

នេះបានគតិដល់បុគ្គលដែលស្វែងរករៀនសិល្បសាស្ត្រដ៏វិសេសដើម្បីការពារខ្លួន ដល់បានសម្រេចដូចសេចក្ដីប្រាថ្នាហើយ ត្រឡប់ជា ធ្វេសប្រហែសឡង់សតិដ៏ងិតទៅដោយវត្ថុកាមផ្សេង ៗ លះបង់ការប្រយោជន៍ប្រសើរបោល បាទក្ដីវេទនាដូចស្ដេច, អគ្គមហេសី, ចតុស្ដម្ភនឹងហោរាដែលតំរែងខាងលើលោកអ្នកដែលមានសតិបញ្ញាគាប្បីពិចារណាចុះ ៕៚

# រឿងបុរសម្នាក់មានកូន ៤ នាក់
# សិក្សាជំនាញស្ទាត់នៅវេទវិជ្ជា ៤ បទ

មានបុរសម្នាក់មានកូនប្រុស ៤ នាក់សិក្សាជំនាញស្ទាត់ក្នុងវេទជារៀងខ្លួន ម្នាក់ចេះស៊ី, ម្នាក់ចេះដេក, ម្នាក់ចេះកាត់ក្តី នឹងម្នាក់ទៀតចេះបង់ស្រី ឪពុកក៏យកកូនទាំង ៤ នាក់ទៅថ្វាយស្តេច ទូលពីវិជ្ជាកូននីមួយៗក្នុងខណៈដែលថ្វាយនោះ ស្តេចក៏ទទួលរក្សាទុក មាន ១ ថ្ងៃស្តេចពីសោធ្យម្នាក់ដែលចេះស៊ីជាមុន ឲ្យរៀបភោជនាហារជាច្រើនមុខ មានសម្ល ១ ចានស្តេចដួសទឹកនៅ ១ ក្របកដាក់ទៅក្នុងនោះហើយស្តេចប្រាប់ទៅបុរសនោះថាឲ្យស៊ីភោជនាហារឲ្យគ្រប់មុខទាំងអស់ បុរសនោះក៏បរិភោគតាមព្រះរាជឱង្ការ ដល់ទៅសម្ល ១ មុខដែលស្តេចយកទឹកនៅ ១ ក្របកដាក់ទៅក្នុងនោះបុរសនោះមិនបរិភោគ ស្តេចសួរទៅបុរសនោះថា ហេតុម្តេចចៅឯងមិនបរិភោគសំម្លនេះ បុរសនោះទូលទៅស្តេចវិញ ថាសំម្លនេះមានទឹកនៅ ១ ក្របកនៅក្នុងនោះបានជាទូលព្រះបង្គំជាខ្ញុំមិនទទួលព្រះរាជទាន ស្តេច

ក៏នឹកក្នុងព្រះទ័យថាបុរសនេះបេះដូងខាងស៊ីស្ងាត់មែន អំពីនោះទៅស្ដេចពិសោធបុរសបេះពេកទៀត ស្ដេចឲ្យរៀបទីកន្លែងយ៉ាងស្អាតហើយមានពូកនឹងកំរាលពីលើ ស្ដេចយកសក់១-សសៃទៅដាក់ក្រោមកម្រាលលើពូកនោះ ដល់ពេលយប់ហៅបុរសនោះឲ្យទៅទទួលទានដំណេក បុរសនោះប្រែះដេកទៅក្រោកឡើងវិញ ស្ដេចក៏សួរថាហេតុម្ដេចឲ្យដេកហើយក្រោកវិញ បុរសនោះក៏ទូលទៅស្ដេចថាមានសក់ ១ សសៃនៅក្នុងដំ-ណេកនោះបានជាទូលបង្គំជាខ្ញុំក្រោក ស្ដេចក៏នឹកសរសើរក្នុងព្រះទ័យថាបុរសនេះស្ងាត់ខាងវិជ្ជាដេកជាប្រាកដមែន មាន ១ ថ្ងៃមានបុរសម្នាក់ស្លាប់នៅកណ្ដាលវាលគ្មានភិនភាគស្លាកអ្វីនៅរូបកាយនោះសោះ ស្ដេចជ្រាបបង្គាប់ឲ្យតុលាការមុខក្រ-សួងសើបសួរទៅរកហេតុនោះក៏ពុំឃើញ ស្ដេចមានសេចក្ដីវិតកក្នុងព្រះរាជហឫទ័យ ស្ដេចនឹកឃើញបុរសដែលនៅបម្រើក្រោមបុណ្យដែលបេះវិជ្ជាខាងផ្លូវតុលាការនោះ ក៏មានព្រះរាជឧង្ការឲ្យហៅចូលមក ហើយមានព្រះរាជដំរះ

បាត់ប្រើឲ្យទៅស៊ើបរកពិរុធរឿងនោះ  បុរសនោះសូមព្រះរាជ
អនុញ្ញាតអំណាចក្នុងវេលាដែលស៊ើបសួរយកការនោះ ស្ដេច
ក៏ព្រះរាជទានពរឲ្យតាមសុំ  បុរសនោះចេញ ទៅដល់ទីកន្លែង
ដែលខ្មោចនោះស្លាប់  តាំងបាត់ការហៅអ្នកស្រុកទាំងអស់
មកប្រជុំមិនឲ្យសល់ដល់ម្នាក់  បុរសនោះហាមប្រាមថាក្នុង
វេលាថ្ងៃស្អែកមិនឲ្យទៅណាមកណាក្រៅពីទីភូមិខ្លួន  ឲ្យចូល
ទៅទាំងអស់គ្នាមើលគេធ្វើបុណ្យបូជាសពបុរសអនាថាដែល
ស្លាប់នៅកណ្ដាលវាលស្រែ  លើកតែមនុស្សខ្វាក់នឹងខ្វិនមិនត្រូវ
ឲ្យទៅមើល  ក្រៅពីនោះទាំងប្រុស-ស្រី ចាស់ក្មេងឲ្យចូលទៅ
មើលទាំងអស់នៅខណៈដែលរៀបចំបូជាសពនោះ  បុរសដែល
ជានាក់ស៊ើបសួរបានបាត់មនុស្សជាច្រើននាក់ដែលបានពន្យល់
ពីកិច្ចហេតុដែលរកការណ៍ពីក្នុងរឿងនោះ  បើឃើញមានរឿង
អ្វីប្រកបនឹងកិច្ចដែលបានពន្យល់នោះ  ឲ្យយកឈ្មោះនោះមក
ប្រគល់ឲ្យបុរសជានាយក្នុង ១ រំពេច  ដល់យូរទៅបូជាទៅភ្លើង
ពេញកំឡោះមានសត្រីម្នាក់ក្រមុំស្រក់ទឹកភ្នែក  ក៏បុរសជានាយ

គយគន់មើលហេតុនាំយកខ្លួននាងនោះទៅប្រគល់ឲ្យនាយខ្លួន បុរសជានាយ ក៏យកខ្លួននាងក្រមុំទៅសើបរកហេតុជម្ងឺរដែល នាងឃុំនោះដោយហេតុយោបលដ៍ល្អិត នាងក្រមុំរកផ្លូវគេចកែ ដោះសាទៅពុំបានក៏ទទួលព្រាបបុរសនោះដោយត្រង់ ថាខ្លួន នាងក្រមុំនោះបានសាហាយនឹងបុរសដែលស្លាប់ ទើបបាន គ្នាក្នុងយប់ដែលស្លាប់នោះ ជាបណ្ដាលឲ្យស្លាប់នោះគ្មានអ្នកឯ-ណាវាយដំធ្វើបាបអ្វីទេ វេលាដែលចូលដំណេកបុរសនោះប្រើ នាងឲ្យទៅរកទឹកឲ្យផឹក នាងក្រមុំមិនហានចេញទៅដងទឹកឯ-ក្រៅខ្លាចឪពុកដឹង ក៏យកផ្ដិលត្រងទឹកភ្លៀងដែលហូរធ្លាក់តាម ស្បូវប្រក់ផ្ទះនោះឲ្យផឹក ដល់ផឹកហើយក៏បណ្ដាលឲ្យដល់នៅ សេចក្ដីមរណៈភាពក្នុងខណៈនោះទៅ បុរសដែលជាអ្នកសើប សួរក៏យល់ច្បាស់ក្នុងចិត្ត ថានាងក្រមុំនេះមិនមានសន្ដានចិត្តជា ទុច្ចរិតនឹងបុរសដែលស្លាប់នោះទេ ព្រោះទើបស្រឡាញ់បាន ជួបគ្នាក្នុង ១ ខណៈនេះ គឺមានសត្វអសិរពិសអ្វីនៅលើដំបូល ផ្ទះនោះ បានជាបណ្ដាលឲ្យមានពិសពស់ដល់បុរសនោះស្លាប់

បុរសជានាយទើបចាត់ឲ្យទៅមើលលើដំបូលផ្ទះនោះ ត្រង់ល្វែងដែលនាងក្រមុំនោះទទួលទានដំណេក ឃើញពស់នាគរាជ ១ នៅលើដំបូលផ្ទះ បុរសនោះក៏ឲ្យវាយយកពស់នោះមកថ្វាយស្ដេច ឯនាងក្រមុំនោះក៏លែងទៅ ហើយទូលស្ដេចតាមដំណើរដែលសើបសួរឃើញការណ៍នោះ អសិរពិសដែលបន្ដាលឲ្យបុរសនោះស្លាប់មកពីនាគរាជនេះ ដែលពិសហូតាមទឹកផ្លៀង នាងក្រមុំត្រងយកមកឲ្យបុរសនោះផឹក ស្ដេចក៏មានសេចក្ដីសសើរថាបុរសនេះមានវិជ្ជាស្ទាត់ក្នុងការសើបសួរខាងផ្សិតុលាការមែន ។

មាន ១ ថ្ងៃសេដ្ឋី ១ នាក់ស្លាប់មានប្រពន្ធនោះល្អហើយនៅក្មេង នាងនោះប្ដេជ្ញាថាមិនយកប្ដីទៀតក៏ដំណឹងនោះជ្រាបដល់ស្ដេច ៗ ក៏ឲ្យនាហ្មឺនសព្វមុខមន្ត្រីនោះបង់នាងមេម៉ាយជាប្រពន្ធខ្មោចសេដ្ឋី នោះនាម៉ឺនទាំងអស់ទៅបង់មិនបានស្ដេចគិតថានាងនេះប្រហែលជាមិនយកប្ដីដូចដំណឹងដែលបានជ្រាបនោះមែន តែស្ដេចគិតក្នុងព្រះរាជហឫទ័យថាបើនាម៉ឺនសព្វមុខមន្ត្រីទាំងនោះប្រហែលមិនពេញសេចក្ដីប្រាថ្នានាងមេម៉ាយ

នេះបើអង្គស្ដេចប្រហែលជានាងនេះព្រម ស្ដេចយាងទៅកាន់ផ្ទះនាងមេម៉ាយនោះហើយមានព្រះរាជឱង្ការថា ល្ងាចនេះស្ដេចមកផ្ទំនឹងនាងឲ្យនាងរៀបទីកន្លែងចាំទទួល នាងមេម៉ាយក៏ទទួលតាមព្រះរាជឱង្ការមិនប្រកែក ដល់ពេលល្ងាចក៏រៀបក្រឡាបន្ទំហើយតែងនាងស្រីបម្រើម្នាក់ នាងនោះមានកើតស្រែងនៅខ្លួនផង រេបណានៅគ្រឿងប្រដាប់ដែលសម្រាប់តាក់តែងរូបកាយសត្រី ដោយគ្រឿងមាសពេជ្រនឹងគ្រឿងក្រអូបគ្រប់ប្រដាប់ហើយ ឲ្យនាងនោះចូលទៅក្នុងទីក្រឡាបន្ទំដែលរៀបចំទទួលស្ដេចតាមព្រះរាជឱង្ការ ដល់ស្ដេចយាងមកក៏មិនបានគិតពិនិត្យឲ្យសព្វគ្រប់ យល់ថាទីនេះហើយជាទីសម្រាប់នាងមេម៉ាយមែន មនុស្សទាំងឡាយមិនហានមកនៅទីនេះមែនក៏ដាក់អង្គផ្ទំឯបសំគាល់ថានាងមេម៉ាយនោះប្រព្រឹត្តទៅតាមសេចក្ដីប្រាថ្នារបស់ស្ដេចគ្រប់ប្រការ វេលាដែលស្ដេចអស់សេចក្ដីដំរេកនឹងនាងនោះហើយក៏ទ្រង់ព្រះចិន្ដាគិតថា ស្ដេចមកបង់នាងនេះបានហើយគាប្បីធ្វើឲ្យឃើញសេចក្ដីសំគាល់ដល់ភ្នែកអ្នកទាំងពួង

ផង ស្តេចក៏ចាំថ្ពាល់នាងនោះជាលាក់ឋានសេចក្តីសំគាល់ រួបក៏យាងត្រឡប់មកព្រះបរមរាជវាំងវិញ មានព្រះរាជឱង្ការផ្តាំថា ព្រឹកស្អែកនេះឲ្យនាងចូលទៅគាល់ស្តេចកុំឲ្យខាន ខណៈស្តេចយាងមកដល់ព្រះបរមរាជវាំង ស្តេចក៏មានព្រះរាជឱង្ការប្រាប់អស់នាម៉ឺនសព្វមុខមន្ត្រីថា ព្រះអង្គស្តេចទៅបង់នាងនោះបានមានទាំងសំគាល់ស្នាមព្រះទន្តនៅថ្ពាល់នាងនោះផងហើយបានប្រាប់ឲ្យចូលមកគាល់ក្នុងពេលថ្ងៃនេះ ឲ្យនាម៉ឺនសព្វមុខមន្ត្រីទាំងអស់ចាំមើល ដល់នាងមេម៉ាយចូលមកគាល់យកទាំងនាងស្រីបម្រើដែលរៀបតាក់តែងកាយទទួលស្តេចពីយប់នោះមកជាមួយផង លុះចូលមកគាល់ក៏អង្គុយតាមមុនក្រោយ នាងមេម៉ាយអង្គុយមុខ នាងស្រីបម្រើអង្គុយក្រោយ ស្តេចឲ្យនាហ្មឺនទៅពិនិត្យមើលនៅកន្លែងសំគាល់ដែលស្តេចបានប្រាប់ ហើយនោះដល់ភ្នាក់ងារដែលទទួលព្រះរាជឱង្ការទៅពិនិត្យ ត្រឡប់មកវិញទូលស្តេចថានាងអង្គុយក្រោយនោះមានស្នាមជាសំគាល់នៅថ្ពាល់ជាសំគាល់ដោយធ្មេញ ឯនាងមេម៉ាយគ្មានស្នាម

រាជឱង្ការ បានទៅដល់លើសាលាដែលនាងមេម៉ាយធ្វើបុណ្យ ខ្មោចប្ដីជាសម្រេចនៅវេលាព្រឹកស្អែកនេះ ហើយតាំងសេចក្ដី សោយសោកនឹកដល់ខ្មោចប្រពន្ធដែលស្លាប់ មានធាតុស្ពាយ ជាប់នឹងខ្លួននេះជាសំគាល់ដោយសេចក្ដីទុក្ខយ៉ាងខ្លាំង ក៏បណ្ដា អ្នកដែលជាពួកក្រុមបរិសទ្យនាងមេម៉ាយដែលនៅលើសាលា នោះទាំងប៉ុន្មានមានសេចក្ដីធ្ងល់ភាន់ភាំងគ្រប់គ្នា ហើយសួរ ទៅបុរសនោះថា "ហេតុអ្វីក៏អ្នកមកយំសោកអីនៅទីនេះជាខ្លាំង ម្លេះ" បុរសនោះប្រាប់ទៅនាក់រក្សាសាលាទាំងអស់ថា "ខ្ញុំឃើញ គេធ្វើបុណ្យខ្មោចលោកសេដ្ឋីនោះខ្ញុំនឹកដល់ខ្មោចប្រពន្ធខ្ញុំដែល ស្លាប់ដោយសេចក្ដីសង្វេគទុក្ខវេទនា នឹងព្រាត់ប្រាសជាប្ដី ១ ជាន់ទៀត ខ្លួនខ្ញុំតាំងពីប្រពន្ធស្លាប់ទៅជាយូរហើយលះបង់ ការងារចោលអស់ ស្ពាយតែធាតុប្រពន្ធដើរដោយសេចក្ដីអាលោះអាល័យ" ហើយបុរសនោះក៏សុំអ្នកចាំសាលាស្នាក់ ១ យប់ បុរសដែលចាំសាលាមិនហ៊ានសំរេចដោយខ្លួនឯងក៏យកសេចក្ដីនោះទៅជំរាបនាងមេម៉ាយជាចៅហ្វាយតាមដំណើរ ដែលបុរស

នោះអធិប្បាយពីសេចក្តីកំសត់របស់ខ្លួន ហើយនឹងសុំសាលាស្នាក់ នាងមេម៉ាយក៏មានចិត្តអាណិតដល់បុរសកំសត់ដែលមានទុក្ខព្រាត់ប្រាសប្រពន្ធនោះក៏យល់ព្រមឲ្យស្នាក់ ហើយបង្គាប់ទៅមនុស្សបម្រើ ឲ្យរៀបអាហារឲ្យទានបុរសនោះផង លុះដល់យប់នាងមេម៉ាយក៏ទៅស្តាប់ទេសនា ឆ្លងបុណ្យខ្មោចប្តីនៅលើសាលាដែលដំកល់ធាតុទុកនៅនោះ ឯបុរសចង់ស្រីក៏សំងំធ្វើជាដេកលក់ទៅ នាងស្តាប់ធម៌ទេសនាចប់ក៏ត្រឡប់មកផ្ទះវិញ ឯបុរសជាអ្នកចង់ស្រីឃើញឱកាសស្ងាត់ល្អក៏លួចយកធាតុខ្មោចប្រពន្ធខ្លួន ទៅដាក់ប្របធាតុសេដ្ឋីជាប្តីនាងមេ-ម៉ាយ លុះដល់ព្រឹកឡើងនាងមេម៉ាយចូលមកដល់សាលា បុរសនោះតាំងស្រែកយំជាខ្លាំងថាអ្នកណាលួចធាតុប្រពន្ធខ្លួនទៅបាត់ នាងមេម៉ាយឆ្ងល់ក៏សួរទៅបុរសនោះថា "ហេតុអ្វីក៏អ្នកឯងយំជាខ្លាំងម្ល៉េះ" បុរសនោះក៏ប្រាប់ទៅនាងមេម៉ាយវិញថាអ្នកណាលួចប្រពន្ធទៅបាត់ ហើយតាំងចោទប្រកាន់ទៅលើនាងមេម៉ាយថាខ្មោចប្តីនាងមេម៉ាយលួចយកធាតុប្រពន្ធខ្លួន

ទៅ នាងមេម៉ាយក៏មានសេចក្ដីអន់ចិត្តនឹងបុរសនោះប្រកា
ដល់ខ្មោចប្ដីខ្លួនថាល្ងួចប្រពន្ធ ក៏នាំបុរសនោះឡើងទៅមើ
ឃើញនៅជិតគ្នាមែន បុរសនោះតាំងសេចក្ដីហេតុប្រកាន់ដ
ខ្លួននាងមេម៉ាយថាប្ដីនាងយកខ្មោចប្រពន្ធគេទៅធ្វើប្រពន្ធហើ
លុះតែនាងព្រមមកធ្វើជាប្រពន្ធវិញទើបសុខចិត្ត ឯសេចក្
ហេតុដល់ខ្លួននាងមេម៉ាយនោះជាដំណាំច្រើនណាស់ដោយខ
បាយយ៉ាងល្អិត នាងមេម៉ាយក៏រកផ្លូវដោះសារគ្មាន ហើយទ
ទូលនឹងបាញ់កល់នោះជាទម្ងន់មានសេចក្ដីអន់ចិត្តដល់ខ្មោចប្
ខ្លួនដែលស្លាប់នោះ ថាជាមនុស្សគ្មានសប្បុរសដល់ប្រពន្ធកំពុ
កើតទុក្ខនឹងខ្លួន ហ៊ានទៅលួចប្រពន្ធគេយកមកបញ្ជើរនៅមុ
ក៏ទទួលព្រមយកបុរសនោះធ្វើប្ដី ជាសេចក្ដីតបទៅនឹងខ្មោចប្
ខ្លួនដែលទៅលួចប្រពន្ធបុរសនោះវិញ បំណែកបុរសនោះដល់
បាននាងមេម៉ាយជាប្រពន្ធនៅ៣-៤ថ្ងៃក៏បបួលទៅគាល់ស្ដេចៈ
នឹងនាម៉ឺនសព្វមុខមន្ត្រីបានឃើញ ក៏មានសេចក្ដីសរសើរដល់
បុរសនោះថាជាអ្នកមានវិជ្ជាបេះចង់ស្រីប្រាកដមែន ។ៈ៚

# រឿងបុរសម្នាក់ឈ្មោះចៅអាចម៍សេះ

មានបុរសម្នាក់ឈ្មោះមិនប្រាកដ តែគេហៅថាចៅអាចម៍សេះ ព្រោះនៅជាខ្ញុំសេដ្ឋីគេឲ្យឃ្វាលសេះប្រហែលជា ៥០ សេះ ឲ្យទៅសង់ខ្ទមនៅបៀតមាត់ទន្លេ ប៉ុន្តែបុរសនោះជាប់រំឭកគុណព្រះពុទ្ធ បើឃ្វាលសេះក្ដីឬធ្វើការអ្វីក្ដីជាប់ទន្ទេញថា សម្មាសម្ពុទ្ធោអញទៅដេញសេះ សម្មាសម្ពុទ្ធោអញទៅលើកអាចម៍សេះ ធ្វើការអ្វីនិមួយក៏ទន្ទេញជាប់ដរាបទៅ ឯអាចម៍សេះនោះទៀតមិនលើកបោលទេ ប្រកការុងទុកជាច្រើន មានថ្ងៃ ១ សំពៅ ៥០០ បើកមកពីស្រុកចិននាំទំនិញមកលក់ បុរសនោះក៏ស្រែកហៅថាឲ្យចូលមកនេះសិនសំពៅក៏ចូលមក ក៏សួរថាអ្នករាល់គ្នាបើកសំពៅមកពីណា នាយសំពៅក៏ថាមកពីស្រុកចិន បុរសនោះក៏ថាអ្នកឯងស្គាល់ស្ដេចក្រុងចិនទេ នាយសំពៅឆ្លើយថាស្គាល់ព្រោះខ្ញុំនៅជិតព្រះរាជវាំង បុរសនោះថាស្ដេចក្រុងចិននោះក្លើអញហើយជាមិត្រសំឡាញ់ពីថ្ងៃមុនរៀងមក បើអ្នកឯងត្រឡប់ទៅស្រុកចិនវិញចូលមកអញផ្ញើរបស់ទៅក្លើអញ

ផង នាយសំពៅទាំងអស់ឆ្លើយថាបាទ នាំគ្នាចេញសំពៅទៅលក់ដូរប្រហែល ១៤ ថ្ងៃនាយសំ ពៅត្រឡប់មកវិញចូលទៅរកបុរសនោះហើយសួរថាអ្នកឯងបានអីផ្ញើទៅ យកមកខ្ញុំទៅឥឡូវហើយ បុរសនោះថាខ្ទះអីរបស់ខ្ញុំរៀបដាក់ក្នុងការុងបម្រុងផ្ញើទៅនាយសំពៅក៏ប្រើជើងឈ្នួលឲ្យជញ្ជូនដាក់សំពៅប្រហែល៤០០ការុងសុទ្ធតែការុងអាចម៍សេះហើយក៏លាបុរសនោះចេញសំពៅទៅស្រុកចិន ដល់ទៅដំណាក់ផែស្តេចស្រុកចិនហើយក៏បោះយឹតថ្កាឡើងទៅទូលស្តេចស្រុកចិន ថាមានក្លើស្តេចផ្ញើរបស់ពីស្រុកខ្មែរមកថ្វាយដាក់នឹងការុងច្រើនណាស់ ស្តេចស្រុកចិនក៏ទូលថាអញមិនដែលទៅស្រុកខ្មែរទេ អញមានក្លើឯណានៅស្រុកខ្មែរនោះ ក៏មានបន្ទូលឲ្យទៅជញ្ជូនការុងអាចម៍សេះនោះដាក់គរមុខព្រះលាន ស្តេចចាត់ឲ្យស្រាយមាត់ការុងចាក់មើលរបស់អ្វីខ្លះ ដល់ស្រាយចាក់ទៅឃើញសុទ្ធតែដុំមាសគ្រប់ការុងស្តេចក៏មានព្រះទ័យត្រេកអរណាស់រកទីបំផុតគ្មាន ក៏ទ្រង់គិតក្នុងព្រះចិន្តាថានឹងបានអ្វីផ្ញើទៅគេវិញ មានតែព្រះរាជបុត្រី ១

ព្រះជន្ម ១៨ ឆ្នាំ ព្រះរូបព្រះឆោមល្អឯកលើសស្រីទាំងអស់គិត ថ្វីទៅឲ្យគេ គិតហើយក៏ចាត់ឲ្យជាងធ្វើស្គរ ១ យ៉ាងធំពាស ស្បែកសត្វទាំងសងខាង តែមានកន្លែងបើកចេញចូលពីខាង ហើយក៏ដាក់ព្រះរាជបុត្រីនោះទៅក្នុងស្គរ ហើយមានទាំងកន្សែង បក់បោយ ១ ផង ហើយចាត់បម្រើបើកសំពៅនាំទៅឲ្យបោ អាចម៍សេះដល់ទីកន្លែងបុរសនោះហើយក៏ស្រែកហៅថា ស្ដេច ក្រុងចិនក្លើផ្ញើស្គរមកឲ្យអ្នកឯង ១ ឲ្យវាយលេង បុរសនោះឮ ហើយក៏អរណាស់ នាក់បម្រើក៏យកស្គរទៅចងក្នុងរោងសេះនោះ បុរសនោះក៏ចេះតែវាយលេងថាក្លើអញស្រឡាញ់អញផ្ញើឲ្យអញ វាយលេង ដល់ថ្ងៃ ១ បុរសនោះវាយស្គរហើយទៅឃ្វាលសេះ នាងដែលនៅក្នុងស្គរនោះចេញមករៀបបាយទឹកទុកបម្រុងឲ្យ បុរសនោះហើយចូលទៅក្នុងស្គរវិញ បុរសនោះត្រឡប់មកឃើញ បាយថានរណាយកបាយមករៀបឲ្យអញៗ ឃ្លានបាយអញស៊ី ហើយ ធ្វើយ៉ាងនេះជាច្រើនថ្ងៃបុរសនោះគិតសង្ស័យថាអ្នកណា យកបាយមកឲ្យអញស៊ីរាល់ថ្ងៃម្លេះអញចាំលបមើល ក៏ឃើញ

នាងនោះចេញពីក្នុងស្គរមករូបក៏ល្អឯកហើយបក់បោយអាហារកើតឡើង ១ រំពេចបុរសនោះក៏ភ័យស្រែកថាសម្មាសម្តុខ្មោចមកពីណាល្អម្លេះអញរត់ហើយ ក៏រត់ទៅនាងនោះក៏រត់ដេញតាមបុរសនោះក៏ស្រែកសម្មាសម្តុខ្មោចកុំចាប់អញអាណិតអញលែងអញទៅ នាងថាខ្ញុំមិនលែងទេអ្នកឯងជាប្ដីខ្ញុំហើយ អាពុកខ្ញុំឲ្យមកធ្វើជាប្រពន្ធអ្នកឯងព្រោះអ្នកឯងផ្ញើមាសប្រាក់ទៅអាពុកខ្ញុំច្រើនណាស់ ប្រកែកថាទេខ្ញុំមិនយកទេ ក៏នាងនោះនិយាយលួងលោមច្រើនដងក៏ស្ងៀមនាងក៏ដឹកដៃបុរសនោះមករោងសេះវិញក្នុងវេលាយប់នោះនាងអធិស្ឋានកន្សែងបក់បោយហើយបក់ទៅកើតជាប្រាសាទរាំងរឿ មានមនុស្សគឹកកងរំពងក្នុងព្រះរាជ-វាំងបុរសចៅអាចម៍សេះហើយនឹងនាងនោះក៏នៅលើប្រាសាទមានមនុស្សបម្រើផ្ទេងស្គាំ អ្នកស្រុកទាំងពួងឃើញហើយភ្ញាក់ផ្អើលគ្រប់គ្នា ក៏រត់ទៅប្រាប់សេដ្ឋីជាចៅហ្វាយបុរសនោះថាមានកើត ប្រាសាទ រាំងរឿត្រង់ខ្ទមចៅអាចម៍សេះនោះច្រើនណាស់សេដ្ឋីសង្ស័យរត់ទៅមើលឃើញហើយ ក៏ភិតភ័យរត់ទៅទូលស្ដេចក្នុងនគរនោះតាមរឿង ។

ស្តេចជ្រាបហើយក៏ចាត់បម្រើឲ្យទៅពិនិត្យមើលឃើញពិតដូច្នោះមែន ស្តេចក៏មានព្រះទ័យទោមនស្សជាខ្លាំងថាឈ្មោះណាហ៊ានមកសាងប្រាសាទវាំងវឿក្នុងនគរអញ មានតែអញហើយជាស្តេចក្នុងនគរនេះ ក៏ចាត់ឲ្យនាម៉ឺនសព្វមុខមន្ត្រីមកគាល់ក៏មានព្រះបន្ទូលចាត់ឲ្យរៀបពលរលើកទៅចាប់អាចោរកំណាចវាមកពីណា ស្តេចក៏យាងទៅជាមួយផង វេលានោះមានបម្រើទៅប្រាប់ចៅអាចម៍សេះ ហើយនឹងនាងជាប្រពន្ធ ឯចៅអាចម៍សេះបានឮហើយក៏មានសេចក្តីភិតភ័យណាស់ ឯនាងបានប្រាប់ប្តីថាកុំឲ្យភ័យទុកឲ្យខ្ញុំប្រឹងនឹងស្តេចនេះ នាងក៏រៀបខ្លួនចេញទៅហើយអធិស្ឋានកន្សែងបក់បោយបក់ស្តេចនេះឲ្យខ្ទាត់ចេញពីនគរនេះចេញទាំងពលទាំងអស់ នាងក៏បក់ទៅស្តេចក៏ខ្ទាត់អណ្តែតត្រសែតចេញបាត់ទៅ ហើយចៅអាចម៍សេះនឹងនាងនោះបានសោយរាជធ្វើជាស្តេចដោយអំណាចវិញគុណព្រះពុទ្ធ ។ះ០៚—

# អំពីសេចក្ដីស្ដាយលោកម៉េណោទ្រីយ៉េរ

*ដែលធ្វើមរណកាលនៅចុងខែសុយេតឆ្នាំ ១៩៣៤ នេះ*

លោកម៉េណោទ្រិយេរ

លោកបានមកធ្វើការក្នុងក្រសួងសិក្សាធិការ ក្នុងក្រុងកម្ពុជានេះជាយូរឆ្នាំហើយ យើងទាំងអស់គ្នាសឹងបានស្គាល់ដោយជាក់លាក់ ៗ លោកម៉េណោទ្រីយេរនេះ លោកស្រឡាញ់រាប់អានអស់បណ្ដាជនជាតិខ្មែរដោយច្រើន លោកយកចិត្តទុកដាក់បង្ហាត់បង្រៀនបំណេះវិជ្ជាបារាំងសែសដោយមាំមួនណាស់ ធ្វើជនជាតិខ្មែរឲ្យបានចេះដឹងដោយសារលោកជាច្រើន លោកបានមកធ្វើជាគ្រូបង្ហាត់បង្រៀនបំណេះភាសាបារាំងសែស ដល់ព្រះសង្ឃជាសិស្សក្នុងសាលាបាឡីជាន់ខ្ពស់ ឲ្យបានចេះដឹងដោយសារលោកជាច្រើន លោកបានធ្វើជាមេប្រយោគប្រឡងសិស្សក្នុងសាលាបាឡីជាន់ខ្ពស់ ជាមួយនឹងអស់យើងជាច្រើនឆ្នាំ លោកសំដែងសេចក្ដីគួរសមនឹងសេចក្ដីរាប់អានដោយស្មោះបំពោះមកអស់យើងរាល់គ្នា គួររាប់លោកម៉េណោទ្រីយេរដែល



លោកម៉ណេទ្រីយេ

ជាជាតិបារាំងសេស ១ នាក់នេះ ថាជាមិត្តដ៏ប្រសើរ ១ របស់យើង ៗ បំណែកខ្លួនលោកម៉េណេទ្រីបេរនេះ ដែលយើងសង្កេតមើលទៅ ឃើញថាមិនចេះឆ្អែតដោយបំណេះវិជ្ជាឡើយ ក្នុងវេលាដែលលោកមានអាយុចំរើនហើយ ល្មមរាប់បញ្ចូលក្នុងពួកមនុស្សចាស់ លោកនៅខំឈ្លៀតរៀនបំណេះអក្សរនឹងភាសាខ្មែរបានចេះសរសេរដោយត្រឹមត្រូវនឹងនិយាយដោយត្រឹមត្រូវបាន មិនតែប៉ុណ្ណោះ ក្នុងវេលាដែលលោកឈប់សម្រាកត្រឡប់ពីក្រុងកម្ពុជាទៅសម្រាកឯស្រុកបារាំងម្តង ៗ លោកខំឈ្លៀតរៀនភាសាសង្ស្ក្រឹតនឹងបាឡី ទាល់តែបានចេះដឹងល្មមប្រើការបាន លុះលោកត្រឡប់មកដល់ក្រុងកម្ពុជាវិញ លោកខំប្រឹងរិះរកភាសាខ្មែរឃើញកំណើតពាក្យ ជាសង្ស្ក្រឹតឬបាឡីជាក់លាក់ ក្នុងពេលដែលលោកកំពុងរិះរកគោលរបស់ភាសាខ្មែរនេះយើងបានដឹងដោយជាក់លាក់ ព្រោះលោកតែងជួនមកប្រឹក្សាជាមួយនឹងយើងជារឿយ ៗ អំពីភាសាខ្មែរ ។ លោកខំព្យាយាមរិះរកដរាបទាល់តែបានធ្វើជាសៀវភៅ ១ ឲ្យឈ្មោះថា

ឱ្យបានផ្សាយដល់អ្នកឯទៀត ដូចលោកម៉េណេទ្រីយេរនេះ ក៏កម្រនឹងរកបានដោយងាយ បើទុកជារកបានក៏មិនមានច្រើនគ្នា។

យើងសូមឧទ្ទិស្សកុសលបែកផ្សាយជូនទៅលោកម៉េណេ-ទ្រីយេរ ឱ្យបានសេចក្ដីសុខ-ចំរើនក្នុងបរលោក ទាំងគ្រួសាររបស់លោកដែលរស់នៅក្នុងបច្ចុប្បន្ននេះ ក៏សូមឱ្យបានសេចក្ដីសុខ-ចំរើនអស់ជាអង្វែងតទៅ ។៚

# បញ្ជីសៀវភៅដែលមានជាវនៅទីព្រះរាជបណ្ណាល័យ

| | | |
|---|---|---|
| ព្រះត្រៃបិដក (បាឡីនិងប្រែជាមួយគ្នា) ១ ចប់ ១០០ សៀវភៅ | ថ្លៃ | ២៥០,០០ |
| រឿងព្រះពុទ្ធសាសនា សៀវភៅធំហើយក្រាស | " | ១,៥០ |
| អភិធម្មត្ថសង្គហ ទើបនឹងបោះពុម្ពលើកទី ២ | " | ១,២០ |
| ជំណាលពុទ្ធចេតិយ (មានរូបថតពុម្ពច្រើន) | | ១,៨០ |
| កច្ចាយនូបត្ថម្ភក, របៀបរៀនបាឡីយ៉ាងឆាប់ ខ្សែ ១ | " | ១,៣០ |
| " " ខ្សែ ២ | " | ១,៤០ |
| បញ្ញាសជាតក ខ្សែ ១ (រឿងព្រះសមុទ្ទឃោស និងព្រះ | " | ០,៥០ |
| គិហិបដិបត្តិ, វិធីសមាទានរក្សាសីល សំរាប់ឧបាសក | " | ០,៤៥ |
| សាមណេរវិន័យ, សិក្ខាបទសម្រាប់សាមណេរសិក្ស | " | ០,៣០ |
| បាដិមោក្ខសង្ខេប, សិក្ខាបទសម្រាប់ភិក្ខុសិក្សា | " | ០,៣០ |
| ១០០ គាថា, គឺគាថាចំនួន ១០០ ដកយកពីគម្ពីរផ្សេងៗ មានធម្មបទជាដើម | " | ០,២០ |
| មនោបុញ្ញកថា | " | ០,១៥ |
| ទសបារមីកថា, និយាយអំពីបារមីទាំង ១០ របស់ព្រះសម្មាសម្ពុទ្ធ | " | ០,៣០ |
| សីមាវិនិច្ឆ័យ | " | ០,១០ |
| នាគោបមាទិកថា | " | ០,០៨ |
| ញាណកថា | " | ០,១២ |
| សុរាទោសកថា, សម្ដែងអំពីទោសដែលកើតឡើងដោយការសេពសុរា | " | ០,០៥ |
| អនុត្តរិយសុត្ត | " | ០,០២ |
| អំពីប្រាសាទខ្វះនៅអង្គរ (អក្សរខ្មែរ) | " | ០,៣៥ |
| " (អក្សរសៀម) | " | ១,០០ |
| ដើមកំណើតប្រាសាទអង្គរ (អក្សរបារាំង) | " | ១,៥០ |
| ពុទ្ធោវាទានុសាសនី, សេចក្ដីចោទន៍ឆ្លើយអំពីធម៌របស់ឧបាសក-សិកា | " | ០,១៥ |
| មរណានុស្សតិកម្មដ្ឋាន, សេចក្ដីរំពឹងដល់សេចក្ដីស្លាប់ | " | ០,៤០ |
| អនត្តលក្ខណសុត្ត | " | ០,១០ |
| កាលាមសុត្តនិងបរាភវសុត្ត, អំពីការមិនគួរជឿនិងហេតុដែលនាំឲ្យវិនាស | " | ០,១៥ |
| ច្បាប់ថ្មី, ពាក្យកាព្យរបស់ក្រមង៉ុយ សម្រាប់ប្រដៅប្រុសស្រី | " | ០,១៥ |

សេចក្ដីរំឭកដាស់តឿន, ពាក្យកាព្យក្រមង៉ុយ រំឭកអ្នកកាន់ព្រះពុទ្ធសាសនា ; កុំឲ្យទាស់ទែងគ្នារឿងធម៌ថ្មី-ចាស់ . . . . . . . . . . . . . . . . . . ថ្លៃ ០ᐟ០៦
បែបពាក្យសក្រាវមាន ៣ សៀវភៅប៉ែកគ្នា ក្នុង ១ សៀវភៅថ្លៃ . . . . . . " ០ᐟ១៨
សំវេគនីយធម៌, អំពីការសង្វេគនិងសេចក្ដីស្លាប់ . . . . . . . . . . . " ០ᐟ១២
ឯកសហស្សរាត្រីឬ១០០១យប់ ជារឿងអារ៉ាប់, ប្រែចេញពីភាសាបារាំងសែស. ខ្សែ១ " ០ᐟ០៤
សិង្គាលោវាទសូត្រ . . . . . . . . . . . . . . . . . . . . . . . " ០ᐟ៣០
មិលិន្ទបញ្ហា សូមឧទ្ទិសកុសល . . . . . . . . . . . . . . . . . . " ១ᐟ២០
. . . . . . . . . . . . . . . . . . . . " ០ᐟ៧០
ជាយាសិកដញ្ញ នសេចក្ដីសុខ . . . . . . . . . . . . . . . . . . " ០ᐟ០៤
បុណ្ណោវាទសូត្រ រសនៅក្នុង . . . . . . . . . . . . . . . . . . " ០ᐟ០២
សតិបដ្ឋានសូត្រ . . . . . . . . . . . . . . . . . . . . . " ០ᐟ៥០

ដល់ទៅ

## ការូបប្ដិតពណ៌

ព្រះរូបសម្ដេចព្រះវរាជជំននី ១ សន្លឹក . . . . . . . . . . . ថ្លៃ ០ᐟ០២
ព្រះរូបព្រះបាទសម្ដេចព្រះស៊ីសុវត្ថិមុនីវង្សទ្រង់គ្រឿងពាក់កណ្ដាលយស . . . " ០ᐟ៥០
" " ពេញយស . . . " ០ᐟ០៦
" ព្រះស៊ីសុវត្ថិ . . . . . . . . . . . . . . " ០ᐟ២៥
ព្រះចៅក្រុងកម្ពុជា ៤ ព្រះអង្គ . . . . . . . . . . . " ០ᐟ២៥
ព្រះពុទ្ធរូបមានព្រះឥន្ទ្រនឹងព្រះព្រហ្មឈរអម . . . . . . . . . . " ០ᐟ០៥
" មានអគ្គសាវកអម (របនាណារ) . . . . . . . . . . " ០ᐟ០៥
" និព្វាន " . . . . . . . . . . . . " ០ᐟ០៥
" ៣ ព្រះអង្គ " . . . . . . . . . . . . " ០ᐟ០៥
" ១ ព្រះអង្គ " . . . . . . . . . . . . " ០ᐟ០៥
រូបវេស្សន្តរជាតក ១ ចប់ ១៣ សន្លឹក ក្នុង ១ សន្លឹកថ្លៃ . . . . . . " ០ᐟ០៦
ព្រះពុទ្ធបាទ . . . . . . . . . . . . . . . . . . . . . " ០ᐟ០៣
សំពត់មាសមានរឿងពុទ្ធបរិវត្ត . . . . . . . . . . . . . . " ០ᐟ០៣
ព្រះរូបសម្ដេចព្រះមហាសង្ឃរាជា (ទៀង) . . . . . . . . . . " ០ᐟ០៣

IMPRIMERIE NOUVELLE
A. PORTAIL-PNOM-PENH